# ផែនការគ្រប់គ្រង
# តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ ២០១៦-២០២០






រដ្ឋបាលព្រៃឈើ

ខែមិនា ឆ្នាំ ២០១៦

# ផែនការគ្រប់គ្រង
# តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច
# រុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ
# ២០១៦-២០២០


រដ្ឋបាលព្រៃឈើ
អគារលេខ ៤០ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ កម្ពុជា
គេហទំព័រ http://www.forestry.gov.kh

**International Tropical Timber Organization (ITTO)**
International Organization Center, 5th Floor
Pacifico-Yokohama, 1-1-1, Ninato-Mirai, Nishi-Ku
Yokohama, 220-1012
Japan
Tel: (81-45) 223-1110,
Fax: (81-45) 223-1111
Web Page: http://www.itto.or.jp



ឧបត្ថម្ភថវិកាដោយ: រដ្ឋាភិបាលនៃប្រទេសជប៉ុន តាមរយៈអង្គការ ITTO

ដើម្បីជាឯកសារយោង: Forestry Administration (FA, 2016). The Management Plan of Preah Vihear Protected Forest for Biodiversity Conservation 2016-2020. Phnom Penh, Cambodia: Forestry Administration.

**Photos, data and maps credits:** FA, ITTO, CAT, CWRP, WCS.



© មិនា ២០១៦ រដ្ឋបាលព្រៃឈើ

# អារម្ភកថា

គោលបំណងក្នុងការរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ ដែលបានធ្វើបច្ចុប្បន្នភាពនេះ គឺដើម្បីពង្រឹងការគាំទ្រផ្នែកបច្ចេកទេសជាមូលដ្ឋានសំរាប់ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ-ព្រៃឈើ-សត្វព្រៃ ប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានទាំងនេះសម្រាប់លើកកំពស់កម្រិតជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានព្រមទាំងរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិផងដែរ។ ផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារនេះ ត្រូវបានរៀបចំក្រោមប្រធានបទ "ព្រៃឈើសម្រាប់ប្រជាជន និងការអភិវឌ្ឍដោយចីរភាព" ដែលផ្តោតការយកចិត្តទុកដាក់ទៅលើប្រជាសហគមន៍ សង្គម និងការថែរក្សា ព្រមទាំងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិក្នុងតំបន់ព្រៃការពារព្រះវិហារ។

ការរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារនេះ មានកម្មវិធីការងារសំខាន់ៗចំនួន ៦ ដែលរួមមាន ១) កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ២) កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ ៣) កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម ៤) ការគ្រប់គ្រងតំបន់ការពារ និងព្រៃការពារតាមបណ្តោយព្រំដែនដោយមានកិច្ចសហការ ៥) កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន និង ៦) កម្មវិធីត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ។ ការរៀបចំចងក្រងផែនការគ្រប់គ្រងនេះមានការចូលរួមជាបន្តបន្ទាប់ តាមរយៈការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃការពារព្រះវិហារ និងមានការចូលរួមផ្តល់យោបល់ និងផ្តល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងវិស័យព្រៃឈើ និងសត្វព្រៃក្នុងព្រះរាជាណាចក្រកម្ពុជា ពីបណ្តានាយកដ្ឋាន ការិយាល័យ និងអង្គភាពចំណុះរដ្ឋបាលព្រៃឈើ។

ផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារនេះ ជាផែនការគ្រប់គ្រង ៥ឆ្នាំ លើកទី២ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ ត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពការងារ ដោយឈរលើមូលដ្ឋានលទ្ធផលនៃការស្រាវជ្រាវ និងបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្តផែនការគ្រប់គ្រងរយៈពេល ៥ឆ្នាំ លើកទី១។

រដ្ឋបាលព្រៃឈើមានសេចក្តីសោមនស្ស និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការ **ITTO** តាមរយៈ **FA-ITTO PD577/10 Rev.1 (F)** "គម្រោងអភិរក្សជីវចម្រុះតាមបណ្តោយព្រំដែនតំបន់ត្រីកោណមរកត កម្ពុជា-ថៃឡង់ដ៏-ឡាវ ជំហ៊ានព៣" ដែលបានជួយឧបត្ថម្ភទាំងថវិកា និងបច្ចេកទេសដល់មន្ត្រីជំនាញរបស់កម្ពុជា ក្នុងការរៀបចំចងក្រងសៀវភៅផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារនេះ។

កិច្ចខិតខំដែលមានសហការដ៏យូរអង្វែងរបស់រដ្ឋបាលព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការ **ITTO** បានគាំទ្រដល់សកម្មភាពការងារសិក្សាស្រាវជ្រាវ ជម្រុញការងារគ្រប់គ្រងធនធានព្រៃឈើ ពង្រឹងសមត្ថភាពជំនាញ និងពង្រីកការចែករំលែកឯកសារ ព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេស។

ជាការពិតណាស់ ផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ អាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព លុះត្រាតែមានការចូលរួមសហការយ៉ាងសកម្ម និងជិតស្និទ្ធពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់អន្តរជាតិ បណ្តាគ្រឹះស្ថានសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងដៃគូអភិវឌ្ឍនានា។

**ឆេង គឹមស៊ុន**

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងារអនុវត្តគម្រោងសូមថ្លែងអំណរគុណចំពោះ លោក-លោកស្រីដែលបានបង្កលក្ខណៈងាយស្រួល និងផ្តល់ទិន្នន័យសំរាប់រៀបចំផែនការគ្រប់គ្រងព្រៃការពារព្រះវិហារ ២០១៦-២០២០ ព្រមទាំងជួយពិនិត្យកែសម្រួលឯកសារនេះ។ ការងាររៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារ អាចទទួលបានជោគជ័យ ដោយសារមានការគាំទ្រ និងលើកទឹកចិត្តជាពិសេស ឯកឧត្តមបណ្ឌិត ឆេង គឹមស៊ុន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ ឯកឧត្តម អ៊ុង សំអាត អនុប្រធានរដ្ឋបាលព្រៃឈើ និងបណ្ឌិត កែវ អូម៉ាលីស ប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ។

យើងខ្ញុំក៏សូមអរគុណចំពោះ ឯកឧត្តម **អ៊ុំ ម៉ារ៉ា** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតដែល ជួយគាំទ្រ និងផ្តល់កិច្ចសហការនានា។ យើងខ្ញុំក៏សូមអរគុណផងដែរ ចំពោះអាជ្ញាធរខេត្ត ស្រុក ឃុំ និងសហគមន៍មូលដ្ឋានដែលបានជួយគាំទ្រ និងសហការក្នុងការងារគ្រងគ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ រាជរដ្ឋាភិបាលនៃប្រទេសជប៉ុន ដែលបានឧបត្ថម្ភថវិកាតាមរយៈអង្គការ International Tropical Timber Organization (**ITTO**) សម្រាប់ការអនុវត្តគម្រោងគ្រប់គ្រងព្រៃការពារតំបន់ត្រីកោណមរកតដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការ អភិរក្សជីវចម្រុះតាមបណ្តោយព្រំដែនរវាងប្រទេសថៃឡង់ដ៏-កម្ពុជា-ឡាវ ជំហានទី៣។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការរួមចំណែក និងការគាំទ្ររបស់លោក Takeshi Goto ជំនួយការនាយកផ្នែកគ្រប់គ្រងព្រៃឈើ និងបណ្ឌិត **Hwan Ok Ma** អ្នកគ្រប់គ្រងគម្រោងនៃអង្គការ **ITTO** ក្នុងការរៀបចំផែនការគ្រប់គ្រងនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការគាំទ្រ និងការណែនាំ ក្នុងអំឡុងការអនុវត្តគម្រោងដំណាក់កាលទី៣ ពីលោក Hiroshi Nakata ទីប្រឹក្សាបច្ចេកទេសនៃរដ្ឋបាលព្រៃឈើ និងលោកស្រី Naomi Matsue ដែលជាមន្ត្រីរដ្ឋបាល និងសម្របសម្រួលគម្រោង JICA ដែលផ្តល់មូលនិធិដោយគម្រោង CAM-REDD ព្រមទាំងកញ្ញា Ches Sopheap ជាមន្ត្រីគ្រប់គ្រងការិយាល័យ។

យើងខ្ញុំក៏សូមកោតសរសើរ និងថ្លែងអំណរគុណចំពោះការចូលរួមយ៉ាងសកម្មពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រី ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ ផ្នែករដ្ឋបាលព្រៃឈើឆែប និងជាំក្សាន្ត ជាពិសេសលោក យឹម ប៉ាន់ លោក អ៊ិត ភូមារ៉ា លោក ម៉ក់ បញ្ញា លោក តាន់ សេដ្ឋា ក៏ដូចជាគំនិតយោបល់ ព្រមទាំងវិភាគទានចំពោះការរៀបចំផែនការគ្រប់គ្រងនេះ ដែលផ្តល់ដោយលោក Alistair Mould ទីប្រឹក្សាបច្ចេកទេសនៃគម្រោង នៅតំបន់ភាគខាងជើងរបស់អង្គការសមាគមន៍អភិរក្សសត្វព្រៃ។

យើងខ្ញុំសូមអរគុណជាពិសេស ចំពោះសមាជិកក្រុមការងារអនុវត្តគម្រោង ITTO PD 577/10 Rev.1 (F) ដែលបានចូលរួម យ៉ាងសកម្មក្នុងការរៀបចំផែនការគ្រប់គ្រងដូចជា លោក ឈាង ដានី បណ្ឌិត J. Dennis Cengel លោក ញ៉ាន ប៊ុនថន លោកស្រី លឹម សុភាព លោក គឹម សុបុណ្យ លោក ប៉ាង ផានិត លោក ផេង សុក្រ័ក លោក សាយ ស៊ិនលី លោក យី ណារ៉ុម លោក យូ គឹមឡេង និងលោក សឹម ស៊ីនួន និងសូមអរគុណដល់អ្នកឯកទេសនានាដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយណែនាំ ពិនិត្យ និងផ្តល់អនុសាសន៍ល្អៗក្នុងការរៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងព្រៃការពារព្រះវិហារនេះ។

# សមាជិកក្រុមការងារអនុវត្តគម្រោង និង អ្នកចូលរួមរៀបចំ ផែនការគ្រប់គ្រងតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ

ផែនការគ្រប់គ្រងតំបន់ព្រៃការពារសំរាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ បាន រៀបចំដោយក្រុមការងារអនុវត្តគម្រោងអភិរក្សជីវៈចម្រុះតាមបណ្តោយព្រំដែនតំបន់ត្រីកោណមរកតកម្ពុជា-ថៃ ឡង់ដឺ-ឡាវ FA-ITTO PD577/10 Rev.1 (F) "Management of the Emerald Triangle Protected Forests Complex to Promote Cooperation for Trans-boundary Biodiversity Conservation between Thailand, Cambodia and Laos" -Cambodia Component, និងអ្នករួមចំណែកផ្សេងៗទៀត មានរាយនាមដូចខាងក្រោម៖

## ក្រុមការងារអនុវត្តគំរោង

| | | |
|---|---|---|
| ឯកឧត្តមបណ្ឌិត | ឆេង គឹមស៊ុន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ |
| លោក | ឈាង ដានី | ប្រធានគម្រោង |
| លោកបណ្ឌិត | Dennis J. Cengel | ទីប្រឹក្សាបច្ចេកទេស |
| លោក | គឹម សុបុណ្យ | អ្នកឯកទេសរៀបចំផែនការប្រើប្រាស់ដីព្រៃ និងអ្នកគ្រប់គ្រងទីវាល |
| លោក | ញ៉ាន ប៊ុនថន | អ្នកឯកទេសផែនទី |
| លោកស្រី | លឹម សុភាព | គ្រប់គ្រងរដ្ឋបាល-គណនេយ្យ |
| លោក | ប៉ាង ផានិត | មន្ត្រីទទួលបន្ទុកការអភិរក្សជីវចម្រុះ និងព្រៃឈើ |
| លោក | អ៊ិត ភូមារ៉ា | នាយខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ |
| លោក | ផេង សុភ័ក្រ | មន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍន៍សហគមន៍ |
| លោក | សាយ ស៊ិនលី | ជំនួយការទីវាលផ្នែករៀបចំផែនការប្រើប្រាស់ដីព្រៃ |
| លោក | ស៊ឹម ស៊ីនួន | ជំនួយការទីវាលផ្នែកអភិវឌ្ឍន៍សហគមន៍ |
| លោក | យី ណារ៉ុម | ជំនួយការទីវាលផ្នែកអភិវឌ្ឍន៍សហគមន៍ |
| លោក | យូ គឹមឡេង | ជំនួយការទីវាលផ្នែកជីវចម្រុះ និងព្រៃឈើ |

# មាតិកា


ទំព័រ

អារម្ភកថា ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
ក្រុមការងាររៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងព្រៃការពារព្រះវិហារ ........ iv
មាតិកា ........ v
បញ្ជីពាក្យសរសេរអក្សរកាត់ ........ ix
សេចក្តីផ្តើម ........ xi

## ជំពូកទី ១
## ស្ថានភាពទូទៅ

១.១ ទីតាំងដែនសមត្ថកិច្ច ........ ១
១.១.១ ទីតាំងភូមិសាស្ត្រ ........ ១
១.១.២ ទីតាំងរដ្ឋបាល ........ ១
១.២ ប្រភេទដី ........ ១
១.៣ ឋានលេខា ........ ២
១.៤ អាកាសធាតុ ........ ៣
១.៤.១ របបទឹកភ្លៀង ........ ៣
១.៤.២ សីតុណ្ហភាព ........ ៣
១.៤.៣ សំណើម ........ ៤
១.៥ តំបន់អេកូឡូស៊ីនៃហ្សែនព្រៃឈើ ........ ៤
១.៦ ប្រភេទព្រៃឈើ និងសត្វព្រៃ ........ ៤
១.៦.១ ប្រភេទព្រៃឈើ ........ ៤
១.៦.២ ព្រៃឈើ និងសារព័ន្ធរុក្ខជាតិ ........ ៧
១.៦.៣ សត្វព្រៃ ........ ៨
១.៧ បណ្តាញគមនាគមន៍ និងបណ្តាញផ្លូវទឹក ........ ១២
១.៨ ធនធានសំខាន់ៗរបស់ព្រៃការពារព្រះវិហារ ........ ១៣

## ជំពូកទី ២
## ស្ថានភាពសង្គម និងបរិស្ថាន

២.១ ស្ថានភាពប្រជាពលរដ្ឋ ........ ១៥
២.១.១ ប្រជារាស្ត្រ ........ ១៥
២.១.២ ការសិក្សាអប់រំ និងសេវាបណ្តុះបណ្តាល ........ ១៦
២.១.៣ ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លី ........ ១៧
២.១.៤ មុខរបរ និងប្រាក់ចំណូល ........ ១៩
២.១.៥ សុខុមាលភាព ........ ២០
២.១.៦ ជំនឿសាសនា ........ ២១
២.២ ស្ថានភាពទូទៅនៃបរិស្ថានក្នុងតំបន់ ........ ២២
២.២.១ ធនធានទឹក ........ ២២

២.២.២ ការប្រើប្រាស់ដី.......................................................................................២២
២.២.៣ កសិកម្ម .................................................................................................២៣
២.២.៤ សិប្បកម្ម និងឧស្សាហកម្ម.............................................................................២៤
២.២.៥ បញ្ហាសង្គម និងបរិស្ថាន..............................................................................២៤


## ជំពូកទី ៣
## ការកំណត់តំបន់ និងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍
## តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិកព្រៃឈើ និងសត្វព្រៃ ព្រះវិហារ


៣.១ ការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍.......................................................................... ៣៣
៣.២ ព្រៃការពារ ................................................................................................................៣៤
៣.២.១ តំបន់ប្រើប្រាស់របស់សហគមន៍ ព្រៃជំនឿសាសនា និងមរតកវប្បធម៌ (CUCR) ............៣៦
៣.២.២ ព្រៃបម្រុងទុកសម្រាប់លំហែរកំសាន្ត (FR) ......................................................៣៦
៣.២.៣ ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស (RFSE) ........................................ ៣៧
៣.២.៤ ព្រៃបម្រុងទុកការពារទីជម្រាល (WP) .................................................................. ៣៧
៣.២.៥ តំបន់ស្តារព្រៃឈើ (FRS)...........................................................................៣៨


## ជំពូកទី ៤
## យុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ
## តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិកព្រៃឈើ និងសត្វព្រៃព្រះវិហារ


៤.១ យុទ្ធសាស្ត្រគ្រប់គ្រង..............................................................................................៣៩
៤.២ កម្មវិធីគ្រប់គ្រង ......................................................................................................... ៤០
៤.២.១ កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ....................................................... ៤០
៤.២.១.១ កាត់បន្ថយបទល្មើសព្រៃឈើ និងសត្វព្រៃ ......................................................... ៤០
៤.២.១.២ ពង្រឹងការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃឲ្យមាននិរន្តរភាព ....... ៤០
៤.២.១.៣ ថែរក្សាបូរណភាពតំបន់ព្រៃឈើទាំងនៅក្នុង និងជុំវិញ តំបន់ព្រៃការពារព្រះវិហារ និង ស្តារគុណភាពតំបន់ជម្រកសត្វព្រៃ.................................................................... ៤០
៤.២.២ កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ............. ៤១
៤.២.២.១ ជម្រុញប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានទេសចរណ៍ធម្មជាតិ និងសកម្មភាពទេសចរណ៍.......................................................................................៤១
៤.២.២.២ ពង្រីកទីផ្សារទេសចរណ៍ធម្មជាតិ ...................................................................... ៤១
៤.២.២.៣ ពង្រឹងសេវាកម្ម និងកម្មវិធីមគ្គុទេសក៍ទេសចរណ៍ .................................................៤២
៤.២.៣ កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម ...................................៤២
៤.២.៣.១ កាត់បន្ថយការពឹងផ្អែកទៅលើធនធានធម្មជាតិ...................................................៤២
៤.២.៣.២ បង្កើនការចូលរួមរបស់សហគមន៍មូលដ្ឋាននៅក្នុងការគ្រប់គ្រង..............................៤៣
៤.២.៣.៣ លើកកំពស់ការយល់ដឹង..............................................................................៤៣
៤.២.៤ កម្មវិធីពង្រឹងកិច្ចសហការគ្រប់គ្រងតំបន់ការពារតាមបណ្តោយព្រំដែន.........................៤៣
៤.២.៤.១ ការពង្រឹងកិច្ចសហការគ្រប់គ្រងតាមបណ្តោយព្រំដែន..............................................៤៣
៤.២.៤.២ បង្កើនការផ្លាស់ប្តូរព័ត៌មាន ការឆ្លងកាត់ព្រំដែននៅក្នុងការគាំទ្រការអភិរក្សធនធានធម្មជាតិ និងបរិស្ថាន ..................................................................................... ៤៤
៤.២.៥ កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន ........................................ ៤៤

៤.២.៥.១ ការពង្រឹងសមត្ថភាពស្ថាប័ន ........................................................................................ ៤៤
៤.២.៥.២ ការអភិវឌ្ឍធនធានមនុស្ស ......................................................................................... ៤៤
៤.២.៥.៣ បង្កើនកិច្ចសហប្រតិបត្តិការការងារផ្ទៃក្នុង........................................................................ ៤៥
៤.២.៦ កម្មវិធីតាមដាន ត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ............................................................ ៤៥
៤.២.៦.១ វាយតម្លៃការអនុវត្តការងារគ្រប់គ្រងពីការសិក្សាស្រាវជ្រាវកន្លងមក................................. ៤៥
៤.២.៦.២ ពង្រីកការសិក្សាស្រាវជ្រាវស្តីពីសហគមន៍រុក្ខជាតិ និងសត្វព្រៃដែលមាននៅតំបន់ភូមិសាស្ត្រសំខាន់ៗ ........................................................................................ ៤៥
៤.២.៦.៣ បង្កើនការសិក្សាអំពីធនធានដី និងធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារព្រះវិហារ .... ៤៦
៤.២.៦.៤ បង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន.................................................................. ៤៦

## ជំពូកទី ៥
## ផែនការសកម្មភាព និង គំរោងថវិកាចំណាយ

ផែនការសកម្មភាពតាមកម្មវិធីនីមួយៗសម្រាប់ប្រតិបត្តិប្រចាំឆ្នាំ ២០១៦-២០២០ ............................ ៤៧

## ជំពូកទី ៦
## សន្និដ្ឋាន

សន្និដ្ឋាន ........................................................................................................................ ៦៣
ឯកសារយោង ...................................................................................................................... ៦៥
វាក្យស័ព្ទ ........................................................................................................................... ៦៧

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១.១ ៖ របបទឹកភ្លៀងប្រចាំខែ ពីឆ្នាំ ២០០២-២០១៥ ............................................ ៧៤
ឧបសម្ព័ន្ធ ១.២ ៖ សីតុណ្ហភាពសរុបប្រចាំខែ ពីឆ្នាំ ១៩៩៤-២០១២ ........................................ ៧៥
ឧបសម្ព័ន្ធ ១.៣ក ៖ ប្រភេទឈើសំខាន់ៗក្នុងតំបន់ព្រៃការពារព្រះវិហារ ..................................... ៧៧
ឧបសម្ព័ន្ធ ១.៣ខ ៖ បញ្ជីឈ្មោះផល អនុផលព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ................. ៨៣
ឧបសម្ព័ន្ធ ១.៤ក ៖ ប្រភេទថនិកសត្វសំខាន់ៗនៅតំបន់ព្រៃការពារព្រះវិហារ .............................. ៨៩
ឧបសម្ព័ន្ធ ១.៤ខ៖ បញ្ជីឈ្មោះថនិកសត្វដែលមានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ............... ១០៣
ឧបសម្ព័ន្ធ ១.៥.ក៖ ប្រភេទសត្វស្លាបសំខាន់ៗនៅតំបន់ព្រៃការពារព្រះវិហារ ................................ ១០៦
ឧបសម្ព័ន្ធ ១.៥.ខ ៖បញ្ជីឈ្មោះពពួកបក្សីដែលមានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ ............... ១១១
ឧបសម្ព័ន្ធ ១.៦.ក ៖ ប្រភេទឧរង្គសត្វសំខាន់ៗនៅតំបន់ព្រៃការពារព្រះវិហារ ................................ ១២០
ឧបសម្ព័ន្ធ ១.៦.ខ ៖បញ្ជីឈ្មោះពពួកល្មូនដែលមានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ ............... ១២១
ឧបសម្ព័ន្ធ ២.១ ៖ ទិន្នន័យសេដ្ឋកិច្ច សង្គមនៅក្នុងស្រុកឆែប និងជាំក្សាន្ត ខេត្តព្រះវិហារ ................. ១២៤
ឧបសម្ព័ន្ធ ៣.១៖ ដំណើរការធ្វើផែនទី ដីកសិកម្ម និងដីលំនៅដ្ឋាន ក្នុងតំបន់ព្រៃការពារព្រះវិហារ...... ១២៦

## តារាង

តារាង ១.១ ៖ ការផ្លាស់ប្តូរគម្របព្រៃឈើក្នុងតំបន់ព្រៃការពារព្រះវិហារ ឆ្នាំ ២០០២ និងឆ្នាំ ២០១៤ ........ ៦
តារាង ១.២ ៖ ចំនួនប្រភេទសត្វព្រៃនៅទូទាំងប្រទេស និងនៅក្នុងតំបន់ព្រៃការពារព្រះវិហារ.................... ៨
តារាង ២.១ ៖ ស្ថិតិប្រជាពលរដ្ឋរស់នៅជុំវិញ និងក្នុងតំបន់ព្រៃការពារព្រះវិហារ............................... ១៦

តារាង ២.២ ៖ ស្ថិតិចំនួនបន្ទប់រៀននៅតាមស្រុកក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ ....................១៧
តារាង ២.៣ ៖ វត្តអារាមនៅតាមបណ្តាស្រុកទាំង ២ ស្ថិតក្នុងតំបន់ព្រៃការពារព្រះវិហារ.....................២២
តារាង ២.៤ ៖ ការប្រើប្រាស់ដីនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ..............................................២៣
តារាង ៣.១ ៖ ចំនួន ទំហំ និងប្រភេទតំបន់នៃព្រៃការពារព្រះវិហារ ..........................................៣៤
តារាង ៥.១ ៖ កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ......................................................៤៧
តារាង ៥.២ ៖ កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ............. ៥០
តារាង ៥.៣ ៖ កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម ....................................៥៣
តារាង ៥.៤ ៖ កម្មវិធីពង្រឹងកិច្ចសហការគ្រប់គ្រងតំបន់ការពារតាមបណ្តោយព្រំដែន......................... ៥៥
តារាង ៥.៥ ៖ កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងស្ថាប័ន .................................................៥៧
តារាង ៥.៦ ៖ កម្មវិធីតាមដាន ត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ ............................................. ៥៩

## ផែនទី

ផែនទី ១.១ ៖ ទីតាំងភូមិសាស្ត្ររដ្ឋបាល និងទីតាំងតំបន់ព្រៃការពារព្រះវិហារ..................................១
ផែនទី ១.២ ៖ ប្រភេទដីក្នុងតំបន់ព្រៃការពារព្រះវិហារ............................................................ ២
ផែនទី ១.៣ ៖ ទីជម្រាលនៃតំបន់ព្រៃការពារព្រះវិហារ............................................................. ៣
ផែនទី ១.៤ ៖ គម្របព្រៃឈើ នៃតំបន់ព្រៃការពារព្រះវិហារ ឆ្នាំ២០១៤..........................................៥
ផែនទី ១.៥ ៖ បម្រែបម្រួលគម្របព្រៃឈើឆ្នាំ ២០១០ និង ២០១៤ នៃតំបន់ព្រៃការពារព្រះវិហារ.........៥
ផែនទី ១.៦ ៖ បណ្តាញគមនាគមន៍ ( ផ្លូវគោក) នៃតំបន់ព្រៃការពារព្រះវិហារ...............................១៣
ផែនទី ២.១ ៖ ស្ថានភាពប្រជាពលរដ្ឋស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រនៃតំបន់ព្រៃការពារព្រះវិហារ.......២០
ផែនទី ២.២ ៖ ការប្រើប្រាស់ដីនៃតំបន់ព្រៃការពារព្រះវិហារ.......................................................២២
ផែនទី ៣.១ ៖ ផែនទីប្រភេទតំបន់នៃតំបន់ព្រៃការពារព្រះវិហារ.................................................៣៥
ផែនទី ១.៤.១ ៖ របាយសត្វដំរីព្រៃអាស៊ីនៅតំបន់ព្រៃការពារព្រះវិហារ ........................................ ៩០
ផែនទី ១.៤.២ ៖ របាយសត្វខ្ទីងនៅតំបន់ព្រៃការពារព្រះវិហារ ................................................. ៩១
ផែនទី ១.៤.៣ ៖ របាយសត្វទន្សោងនៅតំបន់ព្រៃការពារព្រះវិហារ.............................................. ៩២
ផែនទី ១.៤.៤ ៖ របាយសត្វរមាំងនៅតំបន់ព្រៃការពារព្រះវិហារ ................................................. ៩៣
ផែនទី ១.៤.៥ ៖ របាយសត្វឈ្លូសនៅតំបន់ព្រៃការពារព្រះវិហារ.................................................. ៩៤
ផែនទី ១.៤.៦ ៖ របាយសត្វខ្លាខិននៅតំបន់ព្រៃការពារព្រះវិហារ................................................. ៩៥
ផែនទី ១.៤.៧ ៖ របាយសត្វឆ្កែព្រៃនៅតំបន់ព្រៃការពារព្រះវិហារ ............................................... ៩៨
ផែនទី ១.៤.៨ ៖ របាយសត្វទោចម្កុដនៅតំបន់ព្រៃការពារព្រះវិហារ ..........................................១០០
ផែនទី ១.៥.១ ៖ របាយសត្វក្រៀលនៅតំបន់ព្រៃការពារព្រះវិហារ ...........................................១០៦
ផែនទី ១.៥.២ ៖ របាយសត្វត្រដក់តូចនៅតំបន់ព្រៃការពារព្រះវិហារ ......................................... ១០៧
ផែនទី ១.៥.៣ ៖ របាយសត្វត្រដក់ធំនៅតំបន់ព្រៃការពារព្រះវិហារ............................................ ១០៧
ផែនទី ១.៥.៤ ៖ របាយសត្វទាព្រៃស្លាបសនៅតំបន់ព្រៃការពារព្រះវិហារ.....................................១០៨
ផែនទី ១.៥.៥ ៖ របាយសត្វក្ងោកនៅតំបន់ព្រៃការពារព្រះវិហារ.................................................១០៩
ផែនទី ១.៥.៦ ៖ របាយសត្វកូយក្សនៅតំបន់ព្រៃការពារព្រះវិហារ...............................................១១០

## ដ្យាក្រាម

ដ្យាក្រាម ២.១៖ ប្រភពប្រាក់ចំណូល.........................................................................................២០
ដ្យាក្រាម ២.២៖ បញ្ហាសង្គម និងបរិស្ថាន ....................................................................................២៥
ដ្យាក្រាម ៣.១៖ បែងចែកតំបន់ព្រៃឈើ........................................................................................ ៣៣

# សេចក្តីផ្តើម

តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារ (ឬ តំបន់ព្រៃការពារព្រះវិហារ) គឺជាផ្នែកមួយនៃតំបន់ជីវចម្រុះដ៏សំខាន់របស់ Indo-Burma Biodiversity Hotspot ហើយជាតំបន់មួយក្នុងចំណោមតំបន់ Global Hotspots ទាំង ៣៥ នៃពិភពលោកយើងនេះ។ តំបន់ព្រៃការពារព្រះវិហារ គឺជាទីជម្រកសំខាន់មួយសម្រាប់ប្រភេទថនិកសត្វភាគច្រើននៅក្នុងប្រទេសកម្ពុជា និងជាដែនជម្រក សត្វស្លាបប្រហែល ២៥៥ប្រភេទ ថនិកសត្វចំនួន ៥៧ប្រភេទ ឧរង្គសត្វ ៥៨ប្រភេទ និងព្រមទាំងថលជលិក សត្វជាច្រើនប្រភេទទៀត។ តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារគឺជាផ្នែកមួយនៃសម្ព័ន្ធព្រៃល្បោះ នៅក្នុងតំបន់ឥណ្ឌូចិន។

ភាពសំបូរបែបនៃសារព័ន្ធរុក្ខជាតិនៅក្នុងតំបន់ព្រៃការពារព្រះវិហារ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសំណើមបរិយាកាស (៧៤%) របបទឹកភ្លៀង (ភ្លៀងធ្លាក់ ៩៧ថ្ងៃ/ឆ្នាំ ដែលមានកំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ ១៣០១-២០៣៥មម) សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ (៣៣អង្សាសេ) សណ្ឋានដី និងសមាសធាតុដី។ ដោយសារភាពសំបូរបែបនៃសារព័ន្ធរុក្ខជាតិ តំបន់ព្រៃការពារព្រះវិហារ គឺជាប្រព័ន្ធមជ្ឈដ្ឋានសម្ព័ន្ធព្រៃល្បោះ ដែលជាដែនជម្រកសត្វព្រៃសំខាន់ៗ។ ជាមួយគ្នានេះដែរធនាគារអភិវឌ្ឍអាស៊ីបានចាត់ថ្នាក់តំបន់ តំបន់ព្រៃការពារព្រះវិហារជាផ្នែកមួយនៃច្រករបៀងសម្រាប់អភិរក្សជីវចម្រុះដែលមានអាទិភាពខ្ពស់ទាំង ៩ សម្រាប់មហាអនុតំបន់មេគង្គ (High Priority Biodiversity Conservation Corridor of the Greater Mekong Sub-region)។

នៅដើមឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានលុបចោលកិច្ចព្រមព្រៀងព្រៃសម្បទានចំនួន ១២ ការកាប់ឈើខុសច្បាប់ត្រូវបានកាត់បន្ថយជាអតិបរមា សម្ភារៈបរិក្ខា និងឈើមូលខុសច្បាប់ និងសត្វព្រៃត្រូវ បានរឹបអូសជាច្រើនករណីលុបបំបាត់ និងបិទរោងម៉ាស៊ីនអារឈើល្មើសច្បាប់រាប់រយគ្រឿង ព្រមទាំងគោលនយោបាយ និងបទដ្ឋានច្បាប់ត្រូវបានរៀបចំ។

នៅខែធ្នូ ឆ្នាំ២០០១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីប្រកាសស្តីពីការផ្អាកសកម្មភាពព្រៃគុបក្នុងព្រៃសម្បទានទាំងអស់ ហើយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើអនុក្រឹត្យស្តីពី ការបង្កើតតំបន់ព្រៃការពារចំនួន ០៣ ដែលក្នុងនោះមានតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ ស្ថិតក្នុងអនុក្រឹត្យនោះផងដែរ។

កិច្ចខិតខំប្រឹងប្រែងនេះគឺ ជាភស្តុតាងនៃការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិរក្សធនធានជីវចម្រុះការពារគម្របព្រៃឈើ និងអនុវត្តតាមកិច្ចព្រមព្រៀងជាអន្តរជាតិទាក់ទងនឹងកម្មវិធីកំណែទម្រង់វិស័យព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា។ វិធានការជាក់លាក់ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានគាំទ្រយ៉ាងពេញលេញ និងវាយតម្លៃខ្ពស់ពីបណ្តាសហគមន៍អន្តរជាតិ ។

ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាលើវិស័យមួយចំនួនដូចជា ការអភិវឌ្ឍវិស័យកសិកម្ម នេសាទ ទេសចរណ៍ ថាមពល ហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្ម និងការលើកកំពស់ជីវភាពប្រជាពលរដ្ឋពឹងផ្អែកទាំងស្រុងលើការថែរក្សាតុល្យភាពប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ។ ការបាត់បង់ព្រៃឈើ ធនធានព្រៃឈើ និងជីវចម្រុះនៅក្នុងតំបន់កំពុងបន្តនៅក្នុងអត្រាមួយគួរឱ្យបារម្ភ ស្របពេលដែលតម្រូវការធនធានព្រៃឈើ និងធនធាន ធម្មជាតិសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ កំពុងកើនឡើងជាលំដាប់។

ការអភិវឌ្ឍទាំងនេះបានផ្តល់ជាកំលាំងចលករ សម្រាប់រៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ ២០១៦-២០២០។ ការរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ មានគោលដៅផ្តល់ផែនទីចង្អុលផ្លូវ យុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រង ដើម្បីធានាការអភិវឌ្ឍធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារព្រះវិហារដោយចីរភាព។

ការរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ សម្រាប់រយៈពេល ៥ឆ្នាំ (២០១៦-២០២០) នេះផ្តល់នូវក្របខ័ណ្ឌទូទៅសម្រាប់គោលបំណងអភិរក្ស និងអភិវឌ្ឍដោយចិរភាពដែលរួមមានកម្មវិធីការងារសំខាន់ៗចំនួន ៦ដូចខាងក្រោម៖

- កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ
- កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ
- កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម
- ការគ្រប់គ្រងតំបន់ការពារ និងព្រៃការពារតាមបណ្តោយព្រំដែន ដោយមានកិច្ចសហការ
- កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន។

***កម្មវិធីត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ***

ផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ គឺជាឯកសារអាចកែសម្រួលសមស្របតាមស្ថានភាពសេដ្ឋកិច្ច-សង្គម និងបរិស្ថាន ដោយអនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការគ្រប់គ្រងនេះ មានចែងលំអិតអំពីគោលបំណងចំណាត់ថ្នាក់តំបន់ និងកម្មវិធីការងារជាអាទិភាពសំខាន់ៗ ដើម្បីគ្រប់គ្រងធនធានព្រៃឈើ និងថែរក្សាធនធានជីវចម្រុះទៅតាមមុខងារនៃតំបន់ និងអនុតំបន់នៃតំបន់ព្រៃការពារព្រះវិហារ។

## គោលបំណង

សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ពីគោលបំណងព្រៃការពារដូចខាងក្រោម៖

- ធ្វើការអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើ និងពង្រឹងដំណើរការគ្រប់គ្រងធនធានព្រៃឈើដោយ ចីរភាព ដើម្បីរួមចំណែកផ្តល់វិភាគទានជាអតិបរមាចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅក្នុងតំបន់
- លើកកំពស់ការចូលរួមពីសំណាក់វិស័យឯកជន និងសហគមន៍មូលដ្ឋានក្នុងការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងនេះ
- ធានាការសម្របសម្រួលជាមួយស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ឱ្យបានទូលំទូលាយ ដើម្បីកាត់បន្ថយជម្លោះ និងលើកកំពស់កិច្ចសហប្រតិបត្តិការ
- បន្តជំរុញដំណើរការដាំដើមឈើ និងស្តារព្រៃឈើឡើងវិញ ដើម្បីបង្កើនធនធាន និងផលិតភាពព្រៃឈើ។

មាត្រា ១ នៃអនុក្រឹត្យ លេខ ៧៦ អនក្រ.បក ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី ការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារ ចែងថាតំបន់ព្រៃការពារ ព្រះវិហារ ត្រូវបានបង្កើតឡើងស្របតាមគោលបំណងដូចខាងក្រោមៈ

- ការពារ និងអភិរក្សរុក្ខជាតិ និងសត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និងប្រភេទជិតផុតពូជ
- រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជម្រក និងការបន្តពូជរបស់ប្រភេទសត្វព្រៃ
- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍ និងអភិរក្សធនធានសេនេទិច និងសត្វព្រៃ
- ការពារ និងថែរក្សាប្រភពទឹក
- ជំរុញការអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍសហគមន៍
- លើកកំពស់ និងរៀបចំវិស័យទេសចរណ៍ធម្មជាតិ
- ថែរក្សានូវកេរ្តិ៍ដំណែលវប្បធម៌ប្រវត្តិសាស្ត្រដែលមាននៅក្នុងតំបន់។

# ជំពូកទី ១
# ស្ថានភាពទូទៅ

## ១.១-ទីតាំងដែនសមត្ថកិច្ច

### ១.១.១-ទីតាំងភូមិសាស្ត្រ

តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ ស្ថិតនៅចន្លោះខ្សែស្រប 13⁰51′19″ និង 14⁰25′01″ នៃរយៈទទឹងខាងជើង និងចន្លោះខ្សែស្រប 104⁰51′42″ និង 105⁰47′04″ នៃរយៈបណ្តោយខាងកើត។ តំបន់ព្រៃការពារនេះមានចម្ងាយប្រមាណ ៣០០គ.ម ពីរាជធានីភ្នំពេញ និងមានចម្ងាយប្រហែល ៦៤គ.ម ពីក្រុងត្បែងមានជ័យ ខេត្តព្រះវិហារ។

### ១.១.២-ទីតាំងរដ្ឋបាល

តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារគ្របដណ្តប់លើស្រុកចំនួន ២ គឺស្រុកជាំក្សាន្ត និង ស្រុកឆែប ដែលមានព្រំប្រទល់ដូចខាងក្រោម ៖

- ខាងជើងជាប់នឹងព្រំប្រទល់កម្ពុជា-ថៃ និង កម្ពុជា-ឡាវ
- ខាងកើតជាប់នឹងឃុំកំពង់ស្រឡៅ ១ និងឃុំឆែប ២ នៃស្រុកឆែប
- ខាងត្បូងជាប់នឹងក្រុមហ៊ុនព្រៃសម្បទានចិន្តាប្លាយវូត
- ខាងលិចជាប់នឹងឃុំជាំក្សាន្ត និងឃុំទឹកក្រហម នៃស្រុកជាំក្សាន្ត

ផែនទី ១.១ ៖ ទីតាំងភូមិសាស្ត្ររដ្ឋបាល និងទីតាំងនៃតំបន់ព្រៃការពារព្រះវិហារ




## ១.២-ប្រភេទដី

ដី ជាកត្តាមួយដែលជះឥទ្ធិពលទៅលើកំណើននៃការលូតលាស់របស់រុក្ខជាតិគ្រប់ប្រភេទ និងមានសារសំខាន់ សម្រាប់សេដ្ឋកិច្ចជាតិ។ ដីតែងតែមានការវិវត្តន៍ក្រោមការផ្លាស់ប្តូរសម្ពាធបរិយាកាស សំណើមនៃតំបន់ត្រូពិកក្តៅ ហើយសើមដែលជាការពុកផុយរបស់អាស៊ីត និងថ្ម។ ប្រភេទដីនៅក្នុងតំបន់ព្រៃការពារ ព្រះវិហារ តាមចំណាត់ថ្នាក់ C.D. Crocker ឆ្នាំ១៩៦២ រួមមាន Acid Lithosols, Alluvial Lithosols, Grey hydromorphics, Plinthite podzols និង Red-yellow podzols។ ប្រភេទដី និងទំហំផ្ទៃដី មានរាយលម្អិតនៅក្នុងតារាង ១.២។

ផែនទី ១.២៖ ប្រភេទដីក្នុងតំបន់ព្រៃការពារព្រះវិហារ




## ១.៣-ថានលេខា

ជាទូទៅ តំបន់ព្រៃការពារព្រះវិហារ ជាតំបន់ទំនាប ប៉ុន្តែសណ្ឋានដីនៅចុងភាគខាងជើងជាតំបន់ជួរភ្នំដងរែក ដែលមានចំណោតខ្លាំងនៅតាមព្រំប្រទល់កម្ពុជា-ថៃ ជាពិសេសនៅចំណុចមុំបី ស្ថិតនៅភាគខាងជើងនៃតំបន់ព្រៃការពារព្រះវិហារ។ ជួរភ្នំដងរែក គឺជាខ្ពង់រាបនគររាជ ឬ កូរ៉ាត ដែលមានចំណោតខ្លាំងមានវិសាលភាពលាតសន្ធឹងតាម បណ្តោយព្រំប្រទល់កម្ពុជា-ថៃ។ ចំណុចដែលមានរយៈកំពស់អតិបរមា ៧៦៦មធៀបនឹងនីវ៉ូទឹកសមុទ្រនៅត្រង់ ចំណុចមុំបីនៃ ជួរភ្នំដងរែក ជាប់ព្រំប្រទល់ប្រទេសកម្ពុជា-ថៃ-ឡាវ និងចំណុចដែលមានរយៈកំពស់អប្បរមា ៦៦ម ធៀបនឹងនីវ៉ូទឹកសមុទ្រ ស្ថិតនៅក្នុងស្រុកជាំក្សាន្ត។

តាមលក្ខណៈសណ្ឋានដី តំបន់ព្រៃការពារព្រះវិហារ គឺជាផ្នែកមួយនៃតំបន់ទំនាបពីបុរាណដែលមានថ្មចំណាស់រាប់រយឆ្នាំ និងដីល្បាយខ្សាច់នៅដើមសម័យកាល Cretaceous and Triassic periods។ សណ្ឋានដីមានលក្ខណៈទំនាប និងមានចំណោទខ្លាំងនៅភាគខាងជើងជាប់ព្រំប្រទល់កម្ពុជា- ថៃ។

លក្ខណៈពិសេសនៃតំបន់ខ្ពង់រាប គឺជាភ្នំផ្សំឡើងដោយដីល្បាយខ្សាច់។ ប៉ុន្តែ ដីនៅតំបន់ខ្ពង់រាបមួយចំនួនគឺជា ថ្មដែលគ្មានចំណាត់ថ្នាក់។ តំបន់ដែលមានរយៈកំពស់បង្គួរមិនទទួលរងការហូរចាក់បំពេញ ដោយដីល្បាប់ ស្របពេលតំបន់ផ្សេងទៀតគឺជាដីក្រហមដែលជាភស្តុតាងនៃថ្មបាយក្រៀម។ នៅរដូវវស្សា តំបន់ទីទួលដែលមានរយៈកំពស់ប្រមាណ ៣០ម មានលក្ខណៈផ្ទុយគ្នានឹងវាលស្មៅលិចទឹក។ វាលស្មៅ និងតំបន់ទទួលរងឥទ្ធិពលរបស់មនុស្សដូចជា ត្រពាំង ព្រៃល្បោះ បានផ្តល់អំណោយផលសម្រាប់សត្វស្លាបទឹកធំៗ និងពពួកគោសាទិស។

ផែនទី ១.៣៖ ទីជម្រាលនៃតំបន់ព្រៃការពារព្រះវិហារ




ប្រភព ៖ ផែនទីតំបន់អេកូឡូស៊ីហ្សែនព្រៃឈើកម្ពុជា ឆ្នាំ២០០៣

## ១.៤-អាកាសធាតុ

ខេត្តព្រះវិហារ និងតំបន់ព្រៃការពារព្រះវិហារ មានព្រំប្រទល់ជាប់ខេត្តសៀមរាប ស្ទឹងត្រែង និងកំពង់ធំ ដែលមានអាកាសធាតុស្រដៀងទៅនឹងខេត្តទាំងអស់ ហើយទទួលឥទ្ធិពលខ្យល់មូសុងតំបន់ត្រូពិក។

### ១.៤.១-របបទឹកភ្លៀង

របបទឹកភ្លៀងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរបបខ្យល់មូសុង។ ក្នុងរយៈពេលប្រហែល ៦ខែ ក្រោមរបបខ្យល់មូសុងវស្សាចាប់ពីខែ មេសា ដល់ខែ តុលា ជារដូវសម្បូរទៅដោយភ្លៀងជោគជាំស្មើរ គ្រប់ទីកន្លែង។ យោងតាមទិន្នន័យស្ថានីយ៍ឧតុនិយមខេត្តព្រះវិហារ (ស្ថានីយ៍ឧត្តុនិយមគូលែន ខេត្តសៀមរាប ឆ្នាំ ១៩៩៨-២០១៥) បង្ហាញថា នៅតំបន់ព្រៃការពារព្រះវិហារ និងខេត្តព្រះវិហារ មាន៖

- កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ (P) = ១.៥៩៤ មម
- កំពស់ទឹកភ្លៀងអតិបរមាប្រចាំឆ្នាំ = ២.០៣៥ មម
- កំពស់ទឹកភ្លៀងអប្បបរមាប្រចាំឆ្នាំ = ១.៣០១មម
- ចំនួនមធ្យមនៃថ្ងៃភ្លៀងប្រចាំឆ្នាំ = ៩៧ថ្ងៃ

### ១.៤.២-សីតុណ្ហភាព

យោងតាមទិន្នន័យដែលទទួលបានពីស្ថានីយ៍ឧតុនិយមខេត្តព្រះវិហារ បង្ហាញថា នៅតំបន់ព្រៃការពារព្រះវិហារ និង ខេត្តព្រះវិហារ មាន៖

- សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ T = ៣២,៩៤ °C
- សីតុណ្ហភាពមធ្យមអតិបរមាប្រចាំឆ្នាំ = ៣៥,២៤ °C
- សីតុណ្ហភាពមធ្យមអប្បបរមាប្រចាំឆ្នាំ = ២៥,៩៩ °C

### ១.៤.៣-សំណើម

សំណើមបរិយាកាស គឺជាផ្នែកមួយនៃអាកាសធាតុ ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរបបទឹកភ្លៀង។ ទិន្នន័យផ្តល់ដោយស្ថានីយ៍ឧតុនិយមខេត្តព្រះវិហារ បង្ហាញថានៅតំបន់ព្រៃការពារព្រះវិហារ និងខេត្តព្រះវិហារ មាន៖

- សំណើមបរិយាកាសមធ្យមប្រចាំឆ្នាំគឺ (Ah) = ៧៣,៥៥%
- សំណើមបរិយាកាសអតិបរមាក្នុងខែកញ្ញា = ៩៩,៣៥%
- សំណើមបរិយាកាសអប្បរមាក្នុងខែមេសា = ៥៤,៥0%

## ១.៥-តំបន់អេកូឡូស៊ីនៃហ្វេនព្រៃឈើ

តំបន់ព្រៃការពារព្រះវិហារ ស្ថិតក្នុងតំបន់អេកូឡូស៊ីប្រភេទ A **"តំបន់ទំនាបភាគកណ្តាល" (តំបន់អេកូឡូស៊ីនៃហ្វេនព្រៃឈើកម្ពុជា ២០០៣)**។

ព្រៃឈើមួយភាគធំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ គឺជាព្រៃល្បោះដែលទទួលរងឥទ្ធិពលមកពីជួរភ្នំដងរែក មានរយៈកំពស់ចាប់ពី ៦៦ម រហូតដល់ ៧៦៦ម ធៀបនឹងនីវ៉ូទឹកសមុទ្រ។ ដោយសារកត្តាផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នានៅក្នុងតំបន់ដូចជាតំបន់ អេកូហ្វេន អាកាសធាតុ សណ្ឋានដី ភូគុម្ពសាស្ត្រ និងប្រភេទដី គ្រាប់ពូជ រុក្ខជាតិ អាចនាំយកមកពីខេត្ត ជិតខាងរបស់ប្រទេសកម្ពុជា ដូចជា ខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ ស្ទឹងត្រែង ខេត្តរតនគីរី និងខេត្តមណ្ឌលគីរី និងអាចនាំមកពីខេត្តនានានៃតំបន់ Dry Eco-region of Indo-Burma សំរាប់ដាំដុះនៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។

## ១.៦-ប្រភេទព្រៃឈើ និងសត្វព្រៃ

### ១.៦.១-ប្រភេទព្រៃឈើ

តំបន់ព្រៃការពារព្រះវិហារ ស្ថិតនៅភាគខាងជើងប្រទេសកម្ពុជា ដែលមានផ្ទៃដីសរុប ១៩០០២៧ ហត។ ព្រៃឈើមួយភាគធំនៅតំបន់នេះជាសារព័ន្ធព្រៃចម្រុះ ដែលភាគច្រើនគ្របដណ្តប់ដោយព្រៃល្បោះ។ តំបន់ព្រៃការពារព្រះវិហារ គ្របដណ្តប់ដោយប្រភេទព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃគុម្ពោតបៃតង ព្រៃគុម្ពោតស្ងួត ព្រៃផ្សេងៗ និងដីមិនមែនព្រៃ។ ល្បោះជាប្រភេទព្រៃឈើដែលមានលក្ខណៈលុបស្មើនឹង ៥៩% (គម្របព្រៃឈើឆ្នាំ២០១៤) នៃផ្ទៃដីសរុបតំបន់ព្រៃការពារព្រះវិហារ។ គម្របព្រៃថយចុះខ្លះក្នុងរវាងឆ្នាំ២០០២ និង២០១៤ ជាពិសេសថយចុះខ្លាំងក្នុងចន្លោះឆ្នាំ២០១០ និង២០១៤ ប៉ុន្តែគម្របព្រៃនៅសល់ប្រហែល ៩១,១១% នៃផ្ទៃដីសរុប (តារាងទី១.១)។

ផែនទី ១.៤៖ គម្របព្រៃឈើនៃតំបន់ព្រៃការពារព្រះវិហារ ឆ្នាំ២០១៤




ប្រភព៖ រដ្ឋបាលព្រៃឈើឆ្នាំ២០១៥

ផែនទី ១.៥៖ បម្រែបម្រួលគម្របព្រៃឈើឆ្នាំ២០១០ និង២០១៤ នៃតំបន់ព្រៃការពារព្រះវិហារ




ប្រភព៖ រដ្ឋបាលព្រៃឈើឆ្នាំ២០១៥

តារាងទី ១.១៖ ការផ្លាស់ប្តូរគម្របព្រៃឈើក្នុង តំបន់ព្រៃការពារព្រះវិហារ ឆ្នាំ២០០២ និងឆ្នាំ២០១៤

| ប្រភេទព្រៃ | ២០០២ | | ២០០៦ | | ២០១០ | | ២០១៤ | | ការប្រែប្រួល | | អត្រាបាត់បង់ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|
| | ហ.ត. | % | ហ.ត. | % | ហ.ត. | % | ហ.ត. | % | ហ.ត. | % | |
| ព្រៃស្រោង | ៣៣.៥៨៦ | ១៧,៦៨ | ៣៥.៧០៩ | ១៨,៧៩ | ៣៥.៦៧៤ | ១៨,៧៨ | ៣៣.៨៣៦ | ១៧,៨១ | ២៥០ | ០,១៣ | ០,០១១ |
| ព្រៃពាក់កណ្តាលស្រោង | ១៨.៥១២ | ៩,៧៤ | ១៨.២៣១ | ៩,៥៩ | ១៨.១៨៩ | ៩,៥៧ | ១៦.៣៨៨ | ៨,៦២ | -២.១២៤ | -១,១២ | -០,០៩៣ |
| ព្រៃល្បោះ | ១៣០.៩៤៩ | ៦៨,៩១ | ១២៧.១៩៦ | ៦៦,៩៤ | ១២៥.០០៤ | ៦៥,៧៨ | ១១២.៤៨០ | ៥៩,១៩ | -១៨.៤៦៩ | -៩,៧២ | -០,៨១០ |
| ព្រៃផ្សេងៗ | ២.៤៥៦ | ១,២៩ | ២.២៥៧ | ១,១៩ | ២.២៨៤ | ១,២ | ១០.៤២៩ | ៥,៤៩ | ៧.៩៧៤ | ៤,២០ | ០,៣៥០ |
| **ព្រៃឈើសរុប** | **១៨៥.៥០៣** | **៩៧,៦២** | **១៨៣.៣៩៣** | **៩៦,៥១** | **១៨១.១៥១** | **៩៥,៣៣** | **១៧៣.១៣៤** | **៩១,១១** | **-១២.៣៦៩** | **-៦,៥១** | **-០,៥៤៣** |
| ដីមិនមែនព្រៃ | ៤.៥២៤ | ២,៣៨ | ៦.៦៣៤ | ៣,៤៩ | ៨.៨៧៦ | ៤,៦៧ | ១៦.៨៩៣ | ៨,៨៩ | ១២.៣៦៩ | ៦,៥១ | ០,៥៤៣ |
| **សរុបរួម** | ***១៩០.០២៧*** | ***១០០*** | ***១៩០.០២៧*** | ***១០០*** | ***១៩០.០២៧*** | ***១០០*** | ***១៩០.០២៧*** | ***១០០*** | | | |

ប្រភពៈ រដ្ឋបាលព្រៃឈើឆ្នាំ២០១៦

### ១.៦.២-ព្រៃឈើ និងសារព័ន្ធរុក្ខជាតិ

តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ គឺជាផ្នែកមួយនៃតំបន់ជីវចម្រុះរបស់ Indo-Burma Biodiversity Hotspot ហើយជាតំបន់មួយក្នុងចំណោមតំបន់ Global Hotspots ទាំង៣៥នៃពិភពលោកយើងនេះ។ ជាមួយគ្នានេះដែរតំបន់ព្រៃការពារព្រះវិហារ គឺជាផ្នែកមួយនៃតំបន់ព្រៃល្បោះឥណ្ឌូចិន ដែលមានគម្របព្រៃល្បោះដ៏ធំជាងគេនៅលើដែនដីគោកនៃតំបន់អាស៊ី។

ផ្អែកតាមការវាយតំលៃគម្របព្រៃឆ្នាំ២០១៤ បង្ហាញថា តំបន់ព្រៃការពារព្រះវិហារគ្របដណ្តប់ដោយព្រៃឈើប្រមាណ ៩១,១១%នៃផ្ទៃដីសរុបរបស់តំបន់ព្រៃការពារព្រះវិហារ។ គម្របព្រៃឈើបានថយចុះ ពី ៩៧,៦២% ក្នុងឆ្នាំ២០០២ ចាប់តាំងពីការបង្កើតតំបន់ព្រៃការពារព្រះវិហារ ប៉ុន្តែគម្របព្រៃនេះច្រើនជាងកម្រិតថ្នាក់ជាតិ ដែលមានត្រឹម ៤៨,៤៩% នៃគម្របព្រៃទូទាំងប្រទេស។

តំបន់ព្រៃការពារព្រះវិហារ ជាតំបន់វាលទំនាប និងតំបន់ភ្នំ ហើយសំបូរសារព័ន្ធរុក្ខជាតិចំរុះប្រភេទ។ ដោយសារតំបន់ព្រៃការពារព្រះវិហារ សម្បូរធនធានព្រៃឈើ និងពុំមានផ្លូវចូល ហេតុនេះមានសកម្មភាព ខុសច្បាប់ខ្លះៗកើតឡើង ដូចជាការកាប់រានយកដីព្រៃឈើ ការកាប់ឈើ និងបរបាញ់សត្វព្រៃខុសច្បាប់ នៅក្នុងព្រៃការពារនេះ។ ក្រៅពីនេះមាន ភ្លើងឆេះព្រៃកើតឡើងជារៀងរាល់ឆ្នាំនៅរដូវប្រាំង ជាពិសេសនៅតំបន់ សម្បូរព្រៃល្បោះ និងព្រៃឫស្សី។ ភាគច្រើន ភ្លើងឆេះព្រៃបណ្តាលមកពីសកម្មភាពមនុស្សដូចជា ដុតព្រៃដើម្បី ធ្វើស្រែចំការ ចាប់សត្វព្រៃ និងករណីខ្លះទៀតបណ្តាល មកពីកន្ទុយបារី។

ភាពសំបូរបែបនៃសារព័ន្ធរុក្ខជាតិនៅតំបន់ព្រៃការពារព្រះវិហារ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសំណើមអាកាស (៧៤%) និងដង់ស៊ីតេទឹកភ្លៀង (ភ្លៀងធ្លាក់មធ្យមប្រចាំឆ្នាំ ១២៤ថ្ងៃ ដែលមានកំពស់ទឹកភ្លៀងប្រចាំឆ្នាំពី ១.៥៩៤-២០៣៥មម) សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ (៣៣ អង្សាសេ) សណ្ឋានដី និងសមាសធាតុរបស់ដី។ល។ តំបន់ព្រៃការពារព្រះវិហារស្ថិតនៅតំបន់ទំនាប ដែលមានរយៈកំពស់ខ្ពស់ដោយដុំ ជាពិសេសនៅតាមតំបន់ជួរភ្នំដងរែក។ សមាសធាតុរបស់សារព័ន្ធរុក្ខជាតិមានលក្ខណៈស្រដៀងគ្នានឹង *Indochinese floristic province, Indo-Malayan region*។

វិសាលភាពតំបន់ព្រៃការពារព្រះវិហារ គ្របដណ្តប់ដោយព្រៃស្រោងតំបន់ភ្នំ ព្រៃស្រោងតំបន់ទំនាប ព្រៃល្បោះ វាលស្មៅ និងដីសើម។ បណ្តាញផ្លូវទឹកដែលមានស្ទឹង និងអូរហូរឆ្លងកាត់តំបន់ព្រៃការពារព្រះវិហារ ចាក់ចូលទៅក្នុង ទន្លេមេគង្គ និងបឹងទន្លេសាប។ ដោយសារ មានសារព័ន្ធរុក្ខជាតិសំបូរបែបតំបន់ព្រៃការពារ ព្រះវិហារ គឺជាប្រព័ន្ធមជ្ឈដ្ឋាន ព្រៃល្បោះដែលផ្តល់លក្ខណៈអំណោយផលសម្រាប់ការរស់នៅរបស់សត្វព្រៃ គ្រប់ប្រភេទ។ ក្រៅពីតម្លៃសោភ័ណភាពចំរុះនៃរុក្ខជាតិនៅភាគខាងជើងតំបន់ព្រៃការពារព្រះវិហារ មានតួ នាទីយ៉ាងសំខាន់ផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និង បច្ចេកវិទ្យា។




*ព្រៃពាក់កណ្ដាលស្រោង និងព្រៃល្បោះ នារដូវវស្សា នៅតំបន់ព្រៃការពារព្រះវិហារ*

### ១.៦.៣-សត្វព្រៃ

តំបន់ព្រៃការពារព្រះវិហារ គឺជាតំបន់ដែនជម្រកប្រភេទសត្វព្រៃដែលកំពុងទទួលរងការគំរាមកំហែងជាសកល ហើយប្រហែលជាតំបន់មានសារសំខាន់បំផុតជាសកលសម្រាប់ប្រភេទរងគ្រោះជិតផុតពូជបំផុតដូចជា ត្រយ៉ងយក្ស និង ជាតំបន់មានសារសំខាន់បំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍សម្រាប់សត្វត្មាតបីប្រភេទដែលកំពុងរងគ្រោះជិតផុតពូជបំផុត។ តំបន់ព្រៃការពារព្រះវិហារ ជាទីជម្រកដ៏មានសារសំខាន់សម្រាប់សត្វដំរីព្រៃអាស៊ី ទន្សោង រមាំង ខ្លាត្រី ឆ្កែព្រៃ និង ទាព្រៃស្លាបស ដែលប្រភេទសត្វទាំងនេះកំពុងរងគ្រោះជិតផុតពូជ។ ប្រភេទគំរាមកំហែងផ្សេងៗទៀតរួមមាន សត្វខ្ទីង រញ្ជើផេះ ស្វា ត្រោស ខ្លាឃ្មុំតូច ក្ងោក សត្វក្រៀល និងត្រយ៉ងយក្ស។

ចាប់ពីឆ្នាំ ១៩៩៨ រហូតឆ្នាំ២០០៥ រដ្ឋបាលព្រៃឈើ (អតីតនាយកដ្ឋានរុក្ខា-ប្រមាញ់) សហការជាមួយអង្គការអន្តរជាតិ CAT និងចាប់ពីឆ្នាំ ១៩៩៩ ជាមួយអង្គការ WCS និងនៅក្នុងដំណាក់កាលទី២ (២០០៨-២០១០) និងទី៣ (២០១២-២០១៦) នៃការអនុវត្តគម្រោងអភិរក្សព្រៃការពារតំបន់ ត្រីកោណមរកត បានធ្វើការសិក្សាស្រាវជ្រាវពីស្ថានភាពជីវចម្រុះនៅក្នុងខេត្តព្រះវិហារ។ លទ្ធផលនៃការស្រាវជ្រាវនេះ បានរកឃើញប្រភេទសត្វសំខាន់ដែល ប្រហែលជាមានលក្ខណៈពិសេសនៅក្នុងតំបន់អាស៊ី អាគ្នេយ៍តាមតំបន់ព្រៃល្បោះ និងដែនជម្រកផ្សេងៗទៀត ដែលសត្វព្រៃមួយចំនួនកំពុងថយចុះយ៉ាងឆាប់ រហ័សនៅកន្លែងផ្សេងទៀត។ ប្រភេទសត្វទាំងនោះរួមមាន ថនិកសត្វចំនួន ៥៧ប្រភេទ បក្សីចំនួន ២៥៥ប្រភេទ និងល្មូនចំនួន ៥៨ប្រភេទ។

តារាងទី ១.២៖ ចំនួនប្រភេទសត្វព្រៃនៅទូទាំងប្រទេស និងនៅក្នុងតំបន់ព្រៃការពារព្រះវិហារ

| ល.រ | សត្វព្រៃ | ចំនួនប្រភេទសត្វ (ឆ្នាំ២០១៤) | |
|---|---|---|---|
| | | ទូទាំងប្រទេស | តំបន់ព្រៃការពារព្រះវិហារ |
| ១ | ថនិកសត្វ | ១២៥-១៣៥ | ច្រើនជាង ៥៧ |
| ២ | បក្សី | ៥៤០-៦៣៥ | ច្រើនជាង ២៥៥ |
| ៣ | ល្មូន | ៧៣-៩៥ | ៥៨ |
| ៤ | ថលជលិកសត្វ | ៦២-៦៥ | ពុំទាន់មានការសិក្សាជាផ្លូវការ |
| ៥ | សត្វល្អិតនិងមេអំបៅ | ច្រើនជាង ៤០០ | ពុំទាន់មានការសិក្សាជាផ្លូវការ |

- **ថនិកសត្វ**

យោងតាមការស្រាវជ្រាវកន្លងមកបានបង្ហាញថា នៅក្នុងតំបន់ព្រៃការពារព្រះវិហារ មានថនិកសត្វចំនួន ៥៧ប្រភេទ (ឧបសម្ព័ន្ធ ១.៤ក និង ១.៤ខ)។ ការស្រាវជ្រាវផ្តោតជាសំខាន់ទៅលើពពួកថនិកសត្វធំៗ និងមួយផ្នែកលើពពួកប្រចៀវ។ យោងតាមការសម្ភាសន៍ជាមួយអ្នកភូមិបង្ហាញថា ប្រភេទផ្សេងៗទៀតទំនងជាមានវត្តមាននៅទីនោះ ប៉ុន្តែព័ត៌មានទាំងនោះនៅតែដូចនៅក្នុងការកត់ត្រានៃឧបសម្ព័ន្ធ។ ក្រៅពីនេះ ថនិកសត្វមួយចំនួនដែលធ្លាប់មានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារទំនងជាផុតពូជ។ ថនិកសត្វទាំងនេះរួមមាន រមាសកុយពីរ និង រមាសកុយមួយ (រមាស ដែលគេបានឃើញចុងក្រោយបំផុតក្នុងប្រទេសកម្ពុជាក្នុងទសវត្ស ១៩៣០) គោព្រៃ និង ក្របីព្រៃ (ដែលគេសង្កេត ឃើញចុងក្រោយបំផុតនៅក្នុងខេត្ត ព្រះវិហារក្នុងឆ្នាំ ១៩៦៤ Wharton 1964)។



**ដំរីអាស៊ី Asian Elephant** *(Elephas maximus)*



**ខ្ទីង Gaur** *(Bos gaurus)*



**ទន្សោង Banteng** *(Bos javanicus)*



**រមាំង ld's Deer** *(Rucervus eldii)*



**កែះ Northern Serow** *(Naemorhedus sumatraensis)*



**ខ្លារខិន Leopard** *Panthera pardus*

- **បក្សី**

តាមការស្រាវជ្រាវកន្លងមកបានបញ្ជាក់ថា បច្ចុប្បន្នមានបក្សីចំនួនប្រមាណ ២៥៥ ប្រភេទ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ មានបក្សី ៥ប្រភេទ ជាប្រភេទកម្របំផុតនៅក្នុងពិភពលោករួមមាន ត្រយ៉ងយក្ស ត្រយ៉ងចង្កំកស ត្មាតផេះ ត្មាតត្នោត និងត្មាតភ្លើងដែលប្រភេទទាំងអស់នេះកំពុងជិតផុតពូជ។ ក្រៅពីនេះ នៅមាន ប្រភេទបក្សីដែលមានដោយកម្រ និងកំពុងទទួលរងការគំរាមកំហែងដែលមានសក្តានុពលសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍ និងអ្នកស្រាវជ្រាវ។ ប្រភេទបក្សីជាច្រើនទៀតទំនងជាត្រូវបានកំណត់អត្តសញ្ញាណចេញពីតំបន់ព្រៃការពារព្រះវិហារ នៅពេលការស្រាវជ្រាវត្រូវបានធ្វើឡើងនាពេលអនាគត។ គម្រោងការពារសំបុកបក្សីកំពុងដំណើរការ នៅភាគខាងជើងរបស់ប្រទេសកម្ពុជា ដោយមានកិច្ចសហការរវាង រដ្ឋបាលព្រៃឈើ និងអង្គការសមាគមន៍អភិរក្សសត្វព្រៃ (WCS) ហើយសហគមន៍មូលដ្ឋានកំពុងចូលរួមយ៉ាងសកម្មក្នុងការអង្កេត និងការពារប្រភេទកំពុងទទួលរងការគំរាមកំហែងនេះដូចជា ពពួកត្រយ៉ង ក្រៀល និងត្មាត។ល។ ចំនួនប្រភេទសត្វដែលកម្របំផុតកំពុងកើនឡើង ដែលនេះជា សកម្មភាពសំខាន់សម្រាប់ការ គ្រប់គ្រងប្រភេទបក្សីដែលកំពុងទទួលរងការគំរាមកំហែងនៅតំបន់ព្រៃការពារព្រះវិហារ ដោយប្រសិទ្ធភាព។ ការយាមសំបុកបក្សី គឺជាយុទ្ធសាស្ត្រមួយដែលអនុញ្ញាតឱ្យសហគមន៍មូលដ្ឋានអាចរកប្រាក់ ចំណូលបាន។ សត្វបក្សីជាច្រើនប្រភេទត្រូវបានបញ្ចូលក្នុងចំណាត់ថ្នាក់ប្រភេទសត្វ ដែលត្រូវការពារក្នុងប្រទេសកម្ពុជា (ឧបសម្ព័ន្ធ ១.៥ក និង១.៥ខ)។





**ត្រយ៉ងយក្ស Giant Ibis** *(**Thaumatibis** gigantea)* **ក្រៀល Sarus Crane** *(**Antigone** antigone)*





**ក្ងោក Green Peafowl** *(Pavo muticus)* **អាហារដ្ឋានត្មាត Monthly vulture restaurant**

- **ឧរង្គសត្វ**

ឧរង្គសត្វសំខាន់ៗនៅក្នុងតំបន់ព្រៃការពារព្រះវិហារ មានចំនួន ៥៨ប្រភេទ។ ប្រភេទឧរង្គសត្វសំខាន់ៗនៅក្នុងតំបន់ព្រៃការពារព្រះវិហារមាន ក្រពើភ្នំ ត្រកួត កន្ធាយអាស៊ី។ ឧរង្គសត្វភាគច្រើនមានសារសំខាន់ ចំពោះវិស័យសេដ្ឋកិច្ច វប្បធម៌ វេជ្ជសាស្ត្រ និងបរិស្ថាន ដោយសារតែតម្រូវការរបស់វានៅលើទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ (ឧបសម្ព័ន្ធ ១.៦ក និង១.៦ខ)។



**ត្រកួត Bengal Monitor** *(Varanus bengalensis)*



**អណ្តើកព្រិច** *(Indotestudo elongata)*



**ពស់ថ្លាន់តូច Burmese Python** ***(Python*** *bivittatus)*

- **ថលជលិកសត្វ**

រហូតមកដល់ពេលនេះ ពពួកថលជលិកសត្វមានការចាប់អារម្មណ៍តិចតួចពីអ្នកអភិរក្សនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ ពពួកថលជលិកសត្វជាកត្តាចង្អុលបង្ហាញសំខាន់មួយពីភាពប្លែកៗគ្នានៃមជ្ឈដ្ឋាន ទីជម្រក និងមានផលប៉ះពាល់ដល់បរិស្ថាន (ហេតុនេះ ប្រសិនបើធ្វើការស្រាវជ្រាវ និងអង្កេតពពួកថលជលិកសត្វ គេអាចវាយតម្លៃ និងតាមដានសុខុមាលភាពប្រព័ន្ធមជ្ឈដ្ឋានខុសៗគ្នា)។ ពពួកថលជលិកសត្វដើរតួនាទីសំខាន់ក្នុងការថែរក្សាសុខុមាលភាព ប្រព័ន្ធអេកូឡូស៊ី ក្នុងនោះមានថលជលិកសត្វមួយចំនួនជាប្រភេទស៊ី សត្វល្អិតផ្សេងទៀតទាំងនៅក្នុងទឹក និងនៅលើគោក។

- **សត្វល្អិត**

សត្វល្អិតភាគច្រើនដើរតួនាទីសំខាន់ក្នុងការធ្វើឱ្យឈើពុកផុយ និងសត្វងាប់រលួយ។ មានសត្វល្អិតដែលមាន ប្រយោជន៍ និងសត្វល្អិតចង្រៃ ហើយសត្វល្អិតខ្លះជាចំណីប្រចៀវ ឧរង្គសត្វ និងពីងពាង និងសត្វល្អិតខ្លះដើរតួនាទីក្នុងការពង្រាយគ្រាប់រុក្ខជាតិ។ សត្វល្អិតខ្លះជាប្រភពវត្ថុធាតុដើម សូត្រ ទឹកឃ្មុំ ក្រមួន អាហារមនុស្ស និងសារធាតុឱសថ។ ឱម៉ាល់មានតួនាទីថែរក្សាប្រព័ន្ធអេកូឡូស៊ី និងបំផ្លាញបរិស្ថាន។ សត្វល្អិតខ្លះទៀតជាប្រភេទបំផ្លាញដំណាំ ចម្លងជម្ងឺគ្រុនចាញ់ ជម្ងឺគ្រុនឈាម និងកណ្តៀរជាប្រភេទសត្វល្អិតបំផ្លាញសំណង់។ មកដល់ពេលបច្ចុប្បន្ននេះយើង មិនទាន់មានការសិក្សាពីក្រុមប្រភេទសត្វល្អិតនៅក្នុងតំបន់ព្រៃការពារព្រះវិហារ នៅឡើយ។

- **មច្ឆា**

ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថា ជាប្រទេសមួយដែលមានទិន្នផលត្រីខ្ពស់នៅក្នុងតំបន់។ ត្រី គឺជាប្រភពប្រូតេអ៊ីនសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ ប្រជាជនកម្ពុជាទទួលទានត្រីប្រមាណ ៣០-៤០គក្រ/ឆ្នាំ/ម្នាក់ (Chheang D.et al. 2002)។ តំបន់ព្រៃការពារព្រះវិហារសំបូរអូរ និងបឹង ជាពិសេសនៅរដូវវស្សា។ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ នៅរដូវវស្សា បឹង និងត្រពាំងមួយចំនួនមិនរីងស្ងួតទេ ហើយគេឃើញមានទឹកដោយកន្លែងនៅតាមអូរធំៗ ដែលអាចផ្តល់ទឹកសម្រាប់មនុស្ស សត្វ និងរុក្ខជាតិ។ ហេតុនេះ ប្រជាពលរដ្ឋប្រើប្រាស់ប្រភពទឹកទាំងនេះសម្រាប់គ្រួសាររបស់ ពួកគេ និងនេសាទ។ កំរិតទឹកក្នុងបឹង អូរ និងទ្រង់ទ្រាយរបស់វាបានប្រែប្រួល ហើយដោយសារក្នុងបឹង និងអូរសំបូរ ត្រី និងពពួកថលជលិកសត្វ ទើបធ្វើឱ្យតំបន់ព្រៃការពារ ព្រះវិហារ សំបូរពពួកសត្វស្លាបទឹកធំៗ។

## ១.៧ បណ្តាញគមនាគមន៍ និងបណ្តាញផ្លូវទឹក

ផ្លូវជាតិលេខ ៦ ផ្លូវជាតិលេខ ៦ តភ្ជាប់ពីភ្នំពេញរហូតដល់ចំណុចផ្លូវបំបែកទៅកាន់ខេត្តសៀមរាប (តាមផ្លូវជាតិលេខ៦) និងខេត្តព្រះវិហារ (តាមផ្លូវលេខ ៦៤) កាត់តាមស្រុកកំពង់ស្វាយ ក្នុងខេត្តកំពង់ធំ។

ផ្លូវជាតិលេខ ៦៤ តភ្ជាប់ទៅកាន់ផ្លូវជាតិលេខ ៦ ត្រង់ចំណុចផ្លូវបំបែកស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បន្តទៅកាន់ស្រុកត្បែងមានជ័យ ដែលជាទីប្រជុំជនខេត្តព្រះវិហារ កាត់តាមឃុំសាលាវិស័យ ស្រុកប្រាសាទ បាល័ង្ក ខេត្តកំពង់ធំ។ ដោយសារតែផ្លូវមានស្ថានភាពទ្រុឌទ្រោម រាជរដ្ឋាភិបាលកំពុងជួសជុលផ្លូវនេះដែល មានចំងាយ ១២៦គម។ ទោះជាយ៉ាងណា ផ្លូវនេះអាចធ្វើដំណើរបានគ្រប់រដូវ ទាំងរដូវប្រាំង និងរដូវវស្សា។

បណ្តាញផ្លូវផ្សេងទៀតចេញពីស្រុកត្បែងមានជ័យទៅកាន់តំបន់ព្រៃការពារព្រះវិហារ

- ផ្លូវលេខ ៦២ ចេញពីស្រុកត្បែងមានជ័យ ទៅកាន់ទីរួមស្រុកជាំក្សាន្ត ដែលមានចំងាយ ៩២គម បន្តរហូតដល់ច្រកចូលតំបន់ព្រៃការពារព្រះវិហារ ត្រង់ចំណុចអូរអាបាន ស្ថិតក្នុងភូមិអូរក្សាន្ត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ដែលមានប្រវែង ៧គម។
- ផ្លូវលេខ ២១១ ចេញពីស្រុកជាំក្សាន្ត ទៅកាន់ស្រុកឆែប កាត់តាមឃុំម្លូព្រៃមួយ ស្ថិតនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ដែលមានចំងាយ ៨២គម។
- ផ្លូវផ្សេងទៀតៈ ចេញពីស្រុកត្បែងមានជ័យ ទៅកាន់ទីរួមស្រុកឆែប កាត់តាមឃុំម្លូព្រៃមួយ ដែលមានចំងាយ ៤៧គម កាត់តាមស្ទឹងសែន និងអូរចំនួនប្រាំទៀតដែលមានស្ពានទើបសាងសង់ថ្មីៗ។

ផែនទី ១.៦៖ បណ្តាញគមនាគមន៍ ( ផ្លូវគោក) នៃតំបន់ព្រៃការពារព្រះវិហារ




ប្រភព ៖ រដ្ឋបាលព្រៃឈើឆ្នាំ ២០១៥

បណ្តាញផ្លូវទឹកភាគច្រើន (ស្ទឹង និងអូរ) ជាដៃស្ទឹងសែនដែលមានប្រភពទឹកមកពីជួរភ្នំដងរែក។ គេអាចធ្វើដំណើរតាមទូក កាណូតតូចៗ តាមស្ទឹងសែន ទៅកាន់ស្រុកត្បែងមានជ័យ និងក្រុងត្បែងមានជ័យ បានតែនៅក្នុងរដូវវស្សាប៉ុណ្ណោះ។ បណ្តាញផ្លូវទឹកមួយទៀត គឺជាទន្លេល្ពៅ ដែលស្ថិតនៅតាមបណ្តោយ ព្រំប្រទល់ប្រទេសកម្ពុជា និងប្រទេសឡាវ ដែលជាដៃទន្លេមេគង្គ ទន្លេនេះហូរចាក់ទៅល្បាក់ខោននៃទន្លេមេគង្គ ដែលស្ថិតនៅក្នុងខេត្តស្ទឹងត្រែង។

## ១.៨- ធនធានសំខាន់ៗរបស់ព្រៃការពារព្រះវិហារ

តំបន់ព្រៃការពារព្រះវិហារ ជាដែនបម្រុងយុទ្ធសាស្ត្រដែលមានធនធានសំខាន់ៗដូចជា ព្រៃឈើ សត្វព្រៃ និង ជីវចម្រុះ ប្រភពទឹកសាប មូលដ្ឋានផលិតកម្មកសិកម្ម ប្រភពស្បៀងអាហារ រ៉ែធម្មជាតិ ធនធនវប្បធម៌-ប្រវត្តិសាស្ត្រ (ប្រាសាទបុរាណ) ប្រភពកាបូនស្តុក និងជីវម៉ាសកាបូន មូលដ្ឋានសំរាប់រៀបចំទេសចរណ៍ធម្មជាតិវប្បធម៌ មូលដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ និងការអប់រំ និងជាប្រភពផ្តល់ខ្យល់បរិសុទ្ធ សម្រាប់ការរស់រានរបស់មនុស្ស និងសត្វនៅក្នុងតំបន់។

# ជំពូកទី ២
# ស្ថានភាពសង្គម និង បរិស្ថាន

## ២.១-ស្ថានភាពប្រជាពលរដ្ឋ

### ២.១.១-ប្រជាសាស្ត្រ

តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ គ្របដណ្តប់លើស្រុកចំនួន ០២ (ស្រុកជាំក្សាន្ត និងស្រុកឆែប ក្នុងខេត្តព្រះវិហារ) និងមានឃុំចំនួន ៥ និងភូមិចំនួន ២១ក្នុងស្រុកទាំង២ ស្ថិតនៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។

ស្ថិតិប្រជាជននៅក្នុងឆ្នាំ២០១៤ នៅជុំវិញ និងក្នុងតំបន់ព្រៃការពារព្រះវិហារ មានប្រជាពលរដ្ឋចំនួន ៦.៤៧៨គ្រួសារត្រូវជា ២៨.៤៣៦នាក់ (ក្នុងនោះស្រុកជាំក្សាន្តមានប្រជាពលរដ្ឋចំនួន ៤.៨៣០គ្រួសារ និងស្រុកឆែប មានប្រជាពលរដ្ឋចំនួន ១.៦៤៨គ្រួសារ)។ ស្ថិតិប្រជាពលរដ្ឋនៅក្នុងស្រុក និងឃុំជាប់តំបន់ ព្រៃការពារព្រះវិហារ មានបង្ហាញនៅក្នុងតារាង ២.១។ ប្រជាពលរដ្ឋប្រមាណ ៩៧% គឺជាជនជាតិខ្មែរ និង ៣% ទៀតជាជនជាតិភាគតិច។ អាយុដែលអាចរស់នៅបានជាមធ្យម ៥៨ឆ្នាំ សម្រាប់បុរស និង ៥៤ឆ្នាំ សម្រាប់ស្ត្រី (វិទ្យាស្ថានជាតិស្ថិតិ, ២០១៣)។

កំណើនប្រជាជន ១៣,៤២%/ឆ្នាំ (ចន្លោះពីឆ្នាំ២០០៧-២០១៣) នៃចំនួនប្រជាជសរុបនៃនៅក្នុង ឃុំទាំង ០៦ ដែលរស់នៅជុំវិញ និងក្នុងតំបន់ព្រៃ ការពារព្រះវិហារ ។

ដង់ស៊ីតេប្រជាពលរដ្ឋកើនពី៨នាក់/គម.$^{2}$ ក្នុងឆ្នាំ២០០៦ ដល់១៥នាក់/គ.ម$^{2}$ ក្នុងឆ្នាំ២០១៣ នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ ដោយសារការផ្តល់ឲ្យនូវសម្បទានដីសង្គមកិច្ច និងចំណូលស្រុក ដែល ជាលទ្ធផលមកពីការអភិវឌ្ឍសេដ្ឋកិច្ច និងការកើនឡើងនូវតម្លៃដី។ ការវិវត្តន៍ទាំងនោះកើតមានឡើងដោយ ពុំរងឥទ្ធិពលពីបញ្ហាកង្វះខាតទឹកនូវរដូវប្រាំង កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ខ្វះខាតដីសមស្របសម្រាប់ធ្វើ កសិកម្ម បើទោះបីជាតំបន់កសិកម្មមានប្រភពទឹកត្រូវបានលិចទឹកនៅរដូវវស្សា។ ការវិវត្តន៍ទាំងនោះកើតមានឡើងដោយពុំរងឥទ្ធិពលពីបញ្ហាកង្វះខាតទឹកនូវរដូវប្រាំង កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ខ្វះខាតដីសមស្របសម្រាប់ធ្វើកសិកម្ម បើទោះបីជាតំបន់កសិកម្មមានប្រភពទឹកត្រូវបានលិចទឹកនៅរដូវវស្សា។ ទោះបីយ៉ាងណា កំណើននៃការអភិវឌ្ឍមានដំណើរការយឺត និងបង្កើតឱកាសការងារតិចតួច។

ប្រជាពលរដ្ឋនៅជុំវិញតំបន់ព្រៃការពារព្រះវិហារ ពឹងផ្អែកមួយផ្នែកធំទៅលើធនធានធម្មជាតិ និងប្រជាជន ក្នុងតំបន់ជាពិសេសយុវជនគ្មានការងារធ្វើ ហេតុនេះសម្ពាធរបស់មនុស្សទៅលើធនធានធម្មជាតិ នៅតែកើតមានស្របពេលដែលគ្រួសារថ្មីបានកាប់រានដីព្រៃសម្រាប់ធ្វើកសិកម្ម និងប្រមូលផល-អនុផល ព្រៃឈើ។ ការកើន ឡើងនូវកំណើនប្រជាពលរដ្ឋយ៉ាងឆាប់រហ័សនៅក្នុងតំបន់នេះបណ្តាលឱ្យមានការទន្ទ្រាន ដីព្រៃសម្រាប់ធ្វើកសិកម្ម និង ការតាំងទីលំនៅថ្មីបន្ថែមទៀតដែលធ្វើឱ្យមានការថយចុះនូវធនធានព្រៃឈើ-សត្វព្រៃ ជីវចម្រុះ និងប្រភពទឹក។

តារាងទី ២.១ ៖ ស្ថិតិប្រជាពលរដ្ឋរស់នៅជុំវិញ និងក្នុងតំបន់ព្រៃការពារព្រះវិហារ

| ទីតាំង | ចំនួនប្រជាពលរដ្ឋ | | | | អាយុ ១៨ ឆ្នាំឡើង | | | ដង់ស៊ីតេ |
|---|---|---|---|---|---|---|---|---|
| | គ្រួសារ | ស្រី | ប្រុស | សរុប | សរុប | ស្រី | | |
| | | | | | | ចំនួន | % | |
| **ខេត្តព្រះវិហារ** | **៥២.៤៩២** | **១១៣.៤៧១** | **១១៤.៦១៩** | **២២៨.០៩០** | **១១៥.១៥២** | **៥៨.៦៩៥** | **៥០,៩៧** | **១២,៦៨** |
| **ស្រុកឆែប** | **១.៦៤៨** | **៤.១២៦** | **៤.១៧១** | **៨.២៩៧** | **៩.៩០៤** | **៥.០៨៧** | **៥១,៣៦** | |
| ឃុំឆែបពីរ | ៦៣០ | ១.៦៩៨ | ១.៥៣៤ | ៣.២៣២ | ១.៥១១ | ៧៦១ | ៥០,៣៦ | |
| ឃុំសង្កែមួយ | ៣៣២ | ៧៨៨ | ៨២៩ | ១.៦១៧ | ៧២៤ | ៣៥៣ | ៤៨,៧៦ | |
| ឃុំកំពង់ស្រឡៅ១ | ៦៨៦ | ១.៦៤០ | ១.៨០៨ | ៣.៤៤៨ | ១.៥៥៧ | ៨០៧ | ៥១,៨៣ | |
| **ស្រុកជាំក្សាន្ត** | **៤.៨៣០** | **១០.១២៦** | **១០.០១៣** | **២០.១៣៩** | **២៦.៥២៧** | **១៣.៦៤៤** | **៥១,៤៣** | |
| ឃុំជាំក្សាន្ត | ២.១៥៣ | ៤.៧១៩ | ៤.៤០៦ | ៩.១២៥ | ៤.៣០៥ | ២.១៦៩ | ៥០,៣៨ | |
| ឃុំទឹកក្រហម | ១.៤៩៨ | ៣.០០៥ | ៣.៣៤៩ | ៦.៣៥៤ | ៣.៣២៩ | ១.៦៥៩ | ៤៩,៨៣ | |
| ឃុំមរកត | ១.១៧៩ | ២.៤០១ | ២.២៥៩ | ៤.៦៦០ | ២.០៥៦ | ១.០៦៨ | ៥១,៩៥ | |
| សរុបរួម*** | **៦.៤៧៨** | **១៤.២៥២** | **១៤.១៨៤** | **២៨.៤៣៦** | **៧.០៥៨** | **៣.៦៧៩** | **៥២,១៣** | **១៥** |

ប្រភព ៖ ក្រសួងផែនការ ឆ្នាំ២០១៤

## ២.១.២-ការសិក្សាអប់រំ និងសេវាបណ្តុះបណ្តាល

យោងតាមទិន្នន័យក្រសួងផែនការ ឆ្នាំ២០១៣ ប្រជាពលរដ្ឋសរុប (មានអាយុរវាង ៦-១៧ឆ្នាំ) ដែលទទួលបានការអប់រំមានចំនួន ៦៤% នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ នៅក្នុងស្រុកឆែប និង ស្រុកជាំក្សាន្ត។ ចំនួនអនក្ខរជនសម្រាប់ស្ត្រីនៅតែមានកម្រិតខ្ពស់ ដូចជានៅចន្លោះអាយុ ១៥-៣៥ឆ្នាំ មាន ចំនួន ៦.៦៧០នាក់ នៃចំនួនសរុប ៣៦.៨១៣នាក់ (១៨%)។ សរុបរួមចំនួនតួរលេខអនក្ខរជនចំពោះ ស្ត្រី និងបុរស មានចំនួន ៩.៤៨៣នាក់នៃចំនួនមនុស្សសរុប ៧៤.០៤៨នាក់ (១២%) ដូចមានលំអិតនៅ ក្នុង ឧបសម្ព័ន្ធ ២.១។

អនក្ខរភាពនេះបណ្តាលមកពីកក្តាជាច្រើនដែលរួមមាន កត្តាសង្គម វប្បធម៌ និងសេដ្ឋកិច្ច។ បើទោះ ជាស្ត្រីចូលរៀន នៅអាយុប្រហាក់ប្រហែលនឹងបុរស អត្រាបោះបង់ចោលការសិក្សារបស់ស្ត្រីចាប់ផ្តើមនៅ ពេលវ័យគ្រប់ការនៅពេល ស្ត្រីត្រូវជួយធ្វើការងារផ្ទះ និងឪពុកម្តាយ។ ម្យ៉ាងទៀត ឪពុកម្តាយមិនចង់ចំណាយ ប្រាក់ច្រើនទៅលើការសិក្សារបស់កូនស្រីទេ។ ក្រៅពីនេះមានភូមិតិចតួចណាស់នៅតំបន់ជនបទក្នុងតំបន់ព្រៃ ការពារព្រះវិហារមានសាលាមធ្យមសិក្សា ហេតុនេះសិស្សសាលាត្រូវធ្វើដំណើរតាមផ្លូវឆ្ងាយទៅសាលា ឬ ស្នា ក់នៅឆ្ងាយពីផ្ទះ។ តាមប្រពៃណីកូនស្រីមិនអាចស្នាក់នៅ ឆ្ងាយពីផ្ទះបានទេ។

បញ្ហាកង្វះខាត គ្រូបង្រៀននៅតាមតំបន់ជនបទ។ បច្ចុប្បន្ននេះ គ្រូបង្រៀនដែលទើបបញ្ចប់ ការសិក្សា ត្រូវទៅបង្រៀននៅតាម តំបន់ដាច់ស្រយាលចំនួនពីរឆ្នាំ (SCW, 2006)។ កង្វះកន្លែងស្នាក់នៅខ្វះការឧបត្ថម្ភ និងគ្មានប្រាក់ចំណូលគ្រប់គ្រាន់ ធ្វើឱ្យជីវភាពគ្រូបង្រៀនភាគច្រើនមានការលំបាក។ កង្វះខាតសាលារៀន និង មជ្ឈមណ្ឌលបណ្តុះបណ្តាល បន្ទប់រៀនមានសិស្សច្រើនហួសកម្រិត ការបង្រៀនមិនបានទៀងទាត់ធ្វើឱ្យគ្រូ បង្រៀនមិនអាចអនុវត្តតាមកម្មវិធីសិក្សាឱ្យបានពេញលេញ កង្វះខាតសម្ភារៈសិក្សា ខ្វះការលើកទឹកចិត្ត ដល់គ្រូ បង្រៀន រួមទាំងប្រាក់ ខែតិចតួច និងលក្ខខណ្ឌការងារមិនអំណោយផល។ ស្ថានភាពសង្គម-សេដ្ឋកិច្ច និង វិជ្ជាជីវៈ

របស់គ្រូបង្រៀនមិនល្អ។ មានការលើកទឹកចិត្តតិចតួចណាស់ដូចជា ការផ្តល់អាហាររូបករណ៍ ការបណ្តុះបណ្តាល និងការទទួលស្គាល់តម្លៃគ្រូបង្រៀនជាសាធារណៈ។

ជាច្រើនឆ្នាំកន្លងមកនេះ រដ្ឋាភិបាលបានជំរុញវិស័យអប់រំ តាមរយៈការបង្កើនចំនួនកម្រិតប្រាក់ខែរបស់គ្រូបង្រៀន និងលើកទឹកចិត្តការអប់រំក្នុងតំបន់សម្រាប់កូនចៅនៃគ្រួសារកងទ័ពដែលបានមកតាំងលំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ដោយផ្តល់សាលាបឋមសិក្សា និងមធ្យោបាយនៅគ្រប់ភូមិថ្មីៗទាំងអស់។ ជាលទ្ធផល គឺមាន សាលាអនុវិទ្យាល័យចំនួន១ និង សាលាបឋមសិក្សាចំនួន ៨ នៅគ្រប់ភូមិ។

ជាច្រើនជំនាន់មកហើយ ប្រជាពលរដ្ឋរស់នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ ទទួលបាន ការបណ្តុះ បណ្តាលវិជ្ជាជីវៈតិចតួចណាស់។ មានការបណ្តុះបណ្តាលវិជ្ជាជីវៈខ្លះៗផ្តល់ដោយអង្គការមិនមែន រដ្ឋាភិបាលទាក់ទងនឹង ការធ្វើកសិកម្ម ទេសចរណ៍ធម្មជាតិ ការចិញ្ចឹមសត្វ និងផ្នែកផ្សេងៗទៀតក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ បើទោះជាគ្មានមជ្ឈមណ្ឌលបណ្តុះបណ្តាលក្នុងស្រុកទាំងពីរក៏ដោយក៏ប្រជាពលរដ្ឋ នៅក្នុង និងជុំវិញតំបន់ព្រៃការពារ ព្រះវិហារ ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងទីរួមខេត្តព្រះវិហារ។

ក្នុងកំឡុងពេលនៃការអនុវត្តគម្រោង "គ្រប់គ្រងព្រៃការពារតំបន់ត្រីកោណមរកត ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការអភិរក្សជីវចម្រុះតាមបណ្តោយព្រំដែនរវាងប្រទេសថៃឡង់ដ៏-កម្ពុជា-ឡាវ ជំហានទី៣" គឺបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២៥វគ្គ ដែលមានសិក្ខាកាមអញ្ជើញចូលរួមចំនួន ១៧៩០នាក់ ពីបណ្តា ភូមិចំនួន ៨។ ចំណុចសំខាន់នៃវគ្គបណ្តុះបណ្តាល គឺផ្តោតទៅលើជំនាញកសិកម្ម និងឱកាសអភិវឌ្ឍជីវភាព របស់សហគមន៍មូលដ្ឋាន ដែលរួមមានបច្ចេកទេសដាំបន្លែ ការចិញ្ចឹមមាន់ ការលើក កំពស់ផលិតភាពកសិកម្ម ការជម្រុញកសិ-រុក្ខកម្ម និងកសិកម្មចម្រុះ ព្រមទាំងការរៀបចំបន្លែគ្រួសារ។

តារាង ២.២ ៖ ស្ថិតិចំនួនបន្ទប់រៀននៅតាមស្រុកនៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ

| លរ | ឈ្មោះស្រុក | បឋម | អនុវិទ្យាល័យ | វិទ្យាល័យ |
|---|---|---|---|---|
| 1 | **ស្រុកជាំក្សាន្ត** | ២២៨ | ៣៩ | ៧ |
| 2 | ស្រុកឆែប | ៨៩ | ២១ | ៦ |
| | សរុប | **៣១៧** | **៦០** | **១៣** |

ប្រភព ៖ ទិន្នន័យស្រុក ឆ្នាំ២០១៥

## ២.១.៣-ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លី

### -ការគ្រប់គ្រង

រដ្ឋបាលព្រៃឈើតាមរយៈនាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ និងរដ្ឋបាលព្រៃឈើមូលដ្ឋានដែលពាក់ព័ន្ធ (អធិការ ដ្ឋានខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលព្រៃឈើ) មានភារកិច្ចគ្រប់គ្រងលើព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងតំបន់ព្រៃការ ពារព្រះវិហារ។

បច្ចុប្បន្នរដ្ឋបាលព្រៃឈើបានសហការជាមួយអង្គការ ITTO និង WCS ដើម្បីគាំទ្រដល់កម្មវិធីគ្រប់គ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារ។ កម្មវិធីអភិរក្សតំបន់ព្រៃការពារព្រះវិហារ រួមមានផ្នែកពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ក្រុមល្បាតកំពុងធ្វើការសហការ ជាមួយកងរាជ អាវុធហត្ថ ដើម្បីល្បាតក្នុងតំបន់ព្រៃការពារព្រះវិហារ។ ផ្នែកសហគមន៍ បាននឹងកំពុងជួយបង្កើនជីវភាព សហគមន៍រស់នៅក្នុងតំបន់ព្រៃការពារព្រះវិហារ និងផ្តល់ការលើកទឹកចិត្តក្នុងការចូលរួមសកម្មភាពអភិរក្ស។ កម្មវិធីនេះ

កំពុងធ្វើការសហការជាមួយ សហគមន៍មូលដ្ឋាននៅជុំវិញតំបន់ព្រៃការពារ ព្រះវិហារផងដែរ ដើម្បី ធានាប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់នៅជាប់ព្រំប្រទល់ព្រៃការពារនេះ។ ផ្នែកស្រាវជ្រាវ និងអង្កេតសត្វព្រៃ កំពុងបន្តអនុវត្ត ដើម្បីធានាការស្វែងយល់ និងទទួលបានព័ត៌មានប្រសើរជាងមុនស្តីពី ស្ថានភាពសត្វព្រៃ សំខាន់ៗសេវាកម្មប្រព័ន្ធមជ្ឈដ្ឋាន ព្រមទាំងការប្រែប្រួលអាកាស ធាតុទាក់ទង នឹងតំបន់ព្រៃការពារព្រះវិហារ។ ក្រៅពីនេះ នៅមានកម្មវិធីជាច្រើនទៀតដូចជា ការរៀបចំផែនការប្រើប្រាស់ ដីធ្លីដោយមានការចូលរួម (រួមមាន ការរៀបចំផែនទីតំបន់កសិកម្ម និងភូមិដ្ឋាន) ការកំណត់ព្រំប្រទល់ព្រៃបម្រុងទុក អចិន្ត្រៃយ៍ ទេសចរណ៍ធម្មជាតិ ការអប់រំផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការដែលកំពុងអនុវត្ត។

ដើម្បីគ្រប់គ្រងតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារឱ្យមានប្រសិទ្ធភាព រដ្ឋបាលព្រៃឈើ និងគម្រោងអភិរក្សជីវចម្រុះតំបន់ត្រីកោណមរកត់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ-ឡាវ (ជំហានទី ២ និងទី ៣) បានរៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ ឆ្នាំ ២០១៦-២០២០។ ការរៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងនេះគឺជាដំណើរការដំបូងសម្រាប់ធ្វើជាផែនទីនាំផ្លូវស្តីពី យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីបង្កើនប្រសិទ្ធភាពការគ្រប់គ្រង និងការអភិវឌ្ឍធនធានធម្មជាតិ ដោយចីរភាពក្នុងតំបន់ព្រៃការពារព្រះវិហារ។

### - ការប្រើប្រាស់ដីធ្លី

មួយផ្នែកធំនៃតំបន់ព្រៃការពារព្រះវិហារគ្របដណ្តប់ដោយព្រៃល្បោះ ហើយផ្នែកខ្លះទៀតលិចទឹក នៅរដូវវស្សា។ ការធ្វើកសិកម្មនៅក្នុងស្រុកជាំក្សាន្ត មានលក្ខណៈអំណោយផល ដោយសារតំបន់នេះជា តំបន់ទំនាប និងមានភ្លៀងគ្រប់គ្រាន់ ចំណែកនៅតំបន់ខ្ពង់រាបមានលក្ខណៈពិបាកក្នុងការធ្វើកសិកម្មនៅក្នុង ស្រុកឆែប (ផរពឆែប ២០០៧)។ សហគមន៍មូលដ្ឋានភាគច្រើនពឹងផ្អែកលើកសិកម្ម។ ស្ថានភាពរបស់ សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធាន ធម្មជាតិ និងសិទ្ធិកាន់កាប់ដីធ្លីជាកត្តាសំខាន់មួយទាក់ទងនឹង ទំនាស់ដីធ្លីនៅក្នុងតំបន់ព្រៃការពារព្រះវិហារ នៅពេលបច្ចុប្បន្ននេះ។ ផែនការប្រើប្រាស់ដីដោយមានការ ចូលរួមទើបតែអនុវត្តសាកល្បងនៅក្នុងភូមិដងផ្លិត ឃុំសង្កែមួយ ស្រុកឆែបប៉ុណ្ណោះ។

ព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារត្រូវបានកាប់រានជារៀងរាល់ឆ្នាំសម្រាប់ធ្វើចំការ ហើយជាធម្មតា សម្រាប់ធ្វើស្រូវ។ ផលប៉ះពាល់នៅតាមមូលដ្ឋាន ដោយសារសកម្មភាពបែបនេះមាន ស្ថានភាពគួរឱ្យបារម្ភ ពីព្រោះប្រជា ពលរដ្ឋតែងតែលាក់បាំងសកម្មភាពរបស់ពួកគេ ហើយធ្វើការកាប់រាន តំបន់ព្រៃល្បោះ ឬព្រៃស្រោង។ ផលប៉ះពាល់ ដោយសារសកម្មភាពបែបនេះរួមមាន ការបាត់បង់ដើមឈើ សំខាន់ៗសម្រាប់បក្សីធ្វើសំបុក និងការរំខានដល់តំបន់ព្រៃឈើដែលជាជម្រកសំខាន់ៗសម្រាប់ពពួកតិណាសី (Wharton, 1961)។

ការពង្រីកដីកសិកម្មនៅជាប់តំបន់ព្រៃការពារព្រះវិហារ (ភូមិមួយចំនួននៅក្នុង និងជុំវិញតំបន់ ព្រៃការពារព្រះវិហារ) សម្រាប់ដំណាំស្រូវ គឺជាបញ្ហាកំពុងកើនឡើង ហើយក្រុមការងារសហគមន៍កំពុង ចូលរួមទប់ស្កាត់តាម រយៈការរៀបចំផែនការប្រើប្រាស់ដីដោយមានការចូលរួម ព្រមទាំងកំពុងធ្វើការពិភាក្សា ជាមួយគណៈកម្មការភូមិ។ ការចាប់យកដីនៅតាមតំបន់លិចទឹក ក្នុងរដូវវស្សាក្នុងតំបន់ព្រៃការពារព្រះវិហារ មានផលប៉ះពាល់ទៅលើការរកចំណី និងតំបន់ពងកូនរបស់ពពួកសត្វត្រយ៉ងយក្ស សត្វក្រៀល និងត្រដក់។

## ២.១.៤-មុខរបរ និងប្រាក់ចំណូល

### - មុខរបរ

ប្រជាពលរដ្ឋក្នុងតំបន់ព្រៃការពារព្រះវិហារ មានមុខរបរផ្សេងៗគ្នាតាមស្ថានភាពជាក់ស្តែង និងតាម ទីកន្លែងរបស់ពួកគេ។ ការធ្វើកសិកម្មជាមុខរបរសំខាន់ ការធ្វើស្រូវនៅរដូវវស្សា គឺជាប្រភពសំខាន់សម្រាប់ ធានាបានសន្តិសុខស្បៀង។ ក្រៅពីធ្វើស្រូវ ប្រជាពលរដ្ឋក្នុងតំបន់នេះដាំដំណាំរួមផ្សំសម្រាប់ផ្គត់ផ្គង់ជីវភាព ប្រចាំថ្ងៃ និងដាំដំណាំ ហូបផ្លែនៅតាមបរិវេណផ្ទះរបស់គេផងដែរ។ គ្រួសារខ្លះធ្វើការនេសាទនៅរដូវប្រាំង និងរដូវវស្សា។ បឹងធំៗមួយ ចំនួនជាប្រភពត្រីដ៏សំខាន់នៅរដូវប្រាំង ហើយអូរ និងបឹងមួយចំនួនទៀតរីងស្ងួត នៅរដូវប្រាំង។ ប្រជាពលរដ្ឋប្រើប្រាស់ ឧបករណ៍នេសាទតាមប្រពៃណី ដើម្បីនេសាទត្រី។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋខ្លះ ប្រើប្រាស់ឧបករណ៍ឆក់ត្រី ដែលគេចាត់ទុកថា មានផលប៉ះពាល់ដល់ការបន្តពូជរបស់ត្រី។ មានការចិញ្ចឹមសត្វ (គោ-ក្របី ជ្រូក មាន់ និងទា) សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ និងសម្រាប់លក់។ តាមការអង្កេតបង្ហាញថា ការចិញ្ចឹមគោ និងក្របី គឺជាប្រភព ចំណូលសំខាន់របស់ប្រជាពលរដ្ឋមូលដ្ឋានសម្រាប់ទិញឧបករណ៍ កសិកម្ម និងសាងសង់ផ្ទះ។ ម្យ៉ាងទៀត គោ និងក្របី គឺជាកំលាំងអូសទាញសំខាន់សម្រាប់ភ្ជួររាស់ដី។

មុខរបរប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកលើធនធានធម្មជាតិ ជាពិសេសសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។ ផល-អនុផលព្រៃឈើដែលប្រជាពលរដ្ឋមូលដ្ឋានប្រមូលរួមមាន ជ័រទឹក ជ័រចុង សត្វព្រៃ ឃ្មុំ ដើមផ្កាអ័រគីដេ បន្លែព្រៃ ផ្លែឈើព្រៃ អុស ស្បូវសម្រាប់ប្រក់ផ្ទះ ឫស្សី និងឈើសម្រាប់សាងសង់ផ្ទះ។ គ្រួសារមួយ ចំនួនតូចលក់ដូរ និងធ្វើការងារ។ ការបរបាញ់ជាប្រភពសម្រាប់ ផ្គត់ផ្គង់ជីវភាព និងសម្រាប់ លក់ក្នុងចំណោមអ្នកភូមិមួយចំនួន។ អ្នកប្រមាញ់ច្រើនប្រើឆ្កែ ដើម្បីប្រមាញ់ ហើយប្រភេទសត្វព្រៃដែលគេនិយម បរបាញ់រួមមាន ត្រកួត និងអណ្តើក។ ការបរបាញ់ប្រព្រឹត្តទៅពេញមួយឆ្នាំ ប៉ុន្តែការប្រមាញ់កើនឡើងនៅដើមរដូវវស្សា។

អ្នកភូមិខ្លះមានដើមជ័រ និងចោះយកជ័រសម្រាប់លក់។ ភូមិទាំងនេះនៅជិតតំបន់ដែលសម្បូរដើមឈើទាល។ ដើមឈើផ្តល់ជ័រទាំងនេះកាន់កាប់ដោយអ្នកភូមិតាមទំនៀមទំលាប់របស់គេ។ ជ័រចុងមានតម្លៃ ថោកជាងជ័រទឹក។ ជ័រទឹក និងជ័រចុងជាប្រភពចំណូលសំខាន់ក្នុងចំណោមអនុផលព្រៃឈើផ្សេងៗទៀត។

### - ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមូលដ្ឋាន

ផ្អែកតាមការសិក្សារបស់សមាគមន៍ឧស្សាហកម្មព្រៃឈើកម្ពុជា ឆ្នាំ២០០២ បានបង្ហាញអំពីប្រាក់ចំណូលបានមកពីការរកផល-អនុផលព្រៃឈើ។ គ្រួសារចំនួន ៤៩% រកចំណូលបានពី ០,៤-១,៣លាន/ឆ្នាំ ពីការលក់ផលិតផលកសិកម្ម។ ពួកគេមិនពឹងផ្អែកទៅលើធនធានព្រៃឈើទាំងស្រុងទេ។ តែទោះជាយ៉ាងណា សម្រាប់ជីវភាពប្រចាំថ្ងៃរបស់ពួកគេ ប្រជាពលរដ្ឋប្រើប្រាស់ធនធានធម្មជាតិខ្លះៗ ដើម្បីកាត់បន្ថយការចំណាយក្នុងគ្រួសារ។

ការវាយតម្លៃនិរន្តភាពនៃជីវភាពសហគមន៍នៅក្នុងឆ្នាំ២០១៥ នៅក្នុងការអនុវត្តគម្រោង "គ្រប់គ្រងព្រៃការពារតំបន់ត្រីកោណមរកត ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការអភិរក្សជីវចម្រុះតាមបណ្តោយ ព្រំដែនរវាងប្រទេសថៃឡង់ដ៏-កម្ពុជា-ឡាវ ជំហានទី៣" បង្ហាញថា ចំណូលគ្រួសារជាមធ្យមប្រចាំឆ្នាំរបស់ សហគមន៍ គឺ៤៦០ដុល្លា/ឆ្នាំ ដែលទទួលបានពីវិស័យព្រៃឈើ ស្មើនឹង៣០%នៃចំណូលសរុប សម្រាប់ សហគមន៍ជនជាតិដើម និងត្រឹមតែ ១២%នៃចំណូលសរុបរបស់គ្រួសារកងទ័ព។ ទោះបីជាយ៉ាងណា ចំនួនប្រជាជននៅក្នុងតំបន់ព្រៃការពារព្រះវិហារ គឺមានចន្លោះ ៣៦%-៤៤% ដែលស្ថិតនៅក្នុងបន្ទាត់នៃ ភាពក្រីក្រ ក្នុងឆ្នាំ២០១៤ ដែលប្រែប្រួលពីភូមិមួយទៅមួយទៀតដូចបង្ហាញនៅក្នុងផែនទី ២.១ (NPRS, 2002)។

ប្រាក់ចំណូលដែលរកបានពីការលក់ផល-អនុផលព្រៃឈើ ផលិតផលកសិកម្ម ផលនេសាទ និងសត្វពាហនៈមានចំនួនតិចតួច ប៉ុន្តែអាចរួមចំណែកក្នុងប្រាក់ចំណូលរបស់គ្រួសារ។ ពួកគេក៏មានទ្រព្យ សម្បត្តិផ្សេងៗទៀត រួមមាន ម៉ូតូ កង់ ទូក ត្រាក់ទ័រ ឡាន ទូរទស្សន៍ និងផ្ទះជាដើម (មើលឧបសម្ព័ន្ធ ២.១)។

ផែនទី ២.១ ៖ ស្ថានភាពប្រជាពលរដ្ឋស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រនៃតំបន់ព្រៃការពារព្រះវិហារ




ដ្យាក្រាម ២.១ ៖ ប្រភពប្រាក់ចំណូល




## ២.១.៥-សុខុមាលភាព

ទោះជាមានភាពជឿនលឿនសម្រេចបានដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងវិស័យសុខាភិបាលក៏ដោយក៏ស្ថានភាពសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាទាបជាងគេនៅក្នុងតំបន់ (SCW, 2006)។ អត្រាស្លាប់ របស់ស្ត្រី នៅពេលសម្រាលកូនមានកម្រិតខ្ពស់ ហើយកុមារជាច្រើនស្លាប់ដោយសារជម្ងឺឆ្លង។ រហូតមក

ទល់ ពេលនេះ ថវិកា ចំណាយសាធារណៈលើវិស័យសុខាភិបាល ជាពិសេសនៅតាមតំបន់ជនបទ នៅខ្វះខាត ហើយការប្រើប្រាស់សេវា សុខាភិបាលនៅមានកម្រិតទាប។ ប្រជាពលរដ្ឋភាគច្រើនដែលខ្វះខាតថវិកាសម្រាប់ចំណាយលើការថែទាំសុខភាព ដោយសារមានបញ្ហាចម្បងទាក់ទងនឹងបំណុល។ នៅក្នុង និងជុំវិញតំបន់ ព្រៃការពារព្រះវិហារមានមណ្ឌលសុខភាព ចំនួន ០៧កន្លែង តែមិនមានមន្ទីរពេទ្យ និងគ្លីនិកនៅក្នុងតំបន់ នេះទេ។

ប្រជាពលរដ្ឋភាគច្រើននៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ ទទួលបានសេវាថែទាំសុខភាព តិចតួច។ ម្យ៉ាងទៀត ប្រជាពលរដ្ឋខ្វះខាតថវិកាសម្រាប់ចំណាយលើសេវានេះ។ ជាងនេះទៅទៀត ធនធានចំណាយលើសេវាកម្មសាធារណៈដូចជា អគារមណ្ឌលសុខភាពដែលមានភាពទ្រុឌទ្រោមនៅតំបន់ជនបទ មិនអាចឆ្លើយតបនឹងតម្រូវការ សេវាសុខភាពរបស់ប្រជាពលរដ្ឋបានទេ ជាពិសេសគ្រួសារស្ថិតនៅតំបន់ ដាច់ស្រយាល។ ដោយសារខ្វះខាតអគារ ថែទាំសុខភាព និងធនធានមិនគ្រប់គ្រាន់ ប្រជាពលរដ្ឋត្រូវពឹង ផ្អែកលើគ្រូពេទ្យដែលគ្មានវិជ្ជាជីវៈច្បាស់លាស់ និងឱសថស្ថានជាលក្ខណៈគ្រួសារ ដើម្បីព្យាបាលជម្ងឺ របស់គេដោយចំណាយតិច។ នេះជាផលប៉ះពាល់អវិជ្ជមានទៅលើសុខភាព និងសុខុមាលភាពសង្គមសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋខ្លះអនុវត្តតាមប្រពៃណីដូនតា ដោយធ្វើការបន់ស្រន់ ដើម្បីព្យាបាលសមាជិកគ្រួសាររបស់ពួកគេ។

ប្រាក់ខែមិនគ្រប់គ្រាន់សម្រាប់បុគ្គលិកសុខាភិបាល ខ្វះខាតសម្ភារៈ និងបរិក្ខារពេទ្យ និងគ្មានថ្នាំ សង្កូវគ្រប់គ្រាន់ និងខ្វះការលើកទឹកចិត្តដល់បុគ្គលិកពេទ្យ។ នៅមានការព្រួយបារម្ភណ៍ស្ដីពី ការគ្រប់គ្រងសេវាសុខភាព ដោយសារសមត្ថភាពគ្រូពេទ្យនៅមានកម្រិត។ បញ្ហាសេវាសុខភាព ការទទួលស្គាល់នៅតាមមូលដ្ឋាន គុណភាពថែទាំសុខភាព ខ្វះខាតហិរញ្ញវត្ថុ ការព្យាបាលតាមប្រពៃណី និងជំនឿ បានធ្វើឱ្យមានអ្នកព្យាបាលជម្ងឺ និងសម្រាលទារកតាមបែប ប្រពៃណីនៅឡើយ។

ទាក់ទងនឹងសុខភាពអនាម័យ និងទឹកស្អាត ប្រជាពលរដ្ឋគ្មានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់តាមតម្រូវការ និងគ្មានអនាម័យ។ ទោះជាមានការផ្សព្វផ្សាយទូលំទូលាយក៏ដោយមានប្រជាពលរដ្ឋ តិចតួចណាស់ប្រើប្រាស់បង្គន់ ពាងទឹកស្អាត បរិភោគទឹកពុះ និងលាងសំអាតដៃ។ កត្តាទាំងនេះមានផល ប៉ះពាល់អវិជ្ជមានទៅលើសុខភាពរបស់ ប្រជាពលរដ្ឋនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ ផលវិបាកចម្បងដែលបណ្ដាលមកពីកង្វះប្រភពទឹកស្អាត និងបង្គន់ អនាម័យនាំឱ្យប្រជាពលរដ្ឋកើត ជម្ងឺឆ្លងដូចជាជម្ងឺអាសន្នរោគ គ្រុនក្ដៅ និងជម្ងឺរាគរូស។

បន្ថែមលើជម្ងឺដែលបានរៀបរាប់ខាងលើ ជម្ងឺគ្រុនចាញ់ របេង និងអេដស៏ គឺជាជម្ងឺមានគ្រោះថ្នាក់បំផុត ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋនៅជុំវិញតំបន់ព្រៃការពារព្រះវិហារ។ អ្នកភូមិតាមមូលដ្ឋាននៅជុំវិញតំបន់ព្រៃការពារព្រះវិហារ តែងតែឆ្លងជម្ងឺគ្រុនចាញ់ ជាពិសេសអ្នករស់នៅជាប់ និងក្នុងតំបន់ព្រៃឈើដោយគ្មានវិធានការការពារ និង សម្ភារៈជាមូលដ្ឋានដូចជាមុងជាដើម។ ការឆ្លងជម្ងឺរបេងគឺជាបញ្ហាចោទមួយទៀតនៅក្នុងតំបន់នោះ។ កត្តាសំខាន់ គឺដោយសារស្ថានភាពសង្គម-សេដ្ឋកិច្ចនៅមានកម្រិតទាប កង្វះអាហារឧបត្ថម្ភ និងធ្វើការហួសកំលាំង។ ការឆ្លងជម្ងឺ អេដស៏យ៉ាងឆាប់រហ័សនាំដល់ការឆ្លងជម្ងឺរបេងបន្ថែមទៀត។

## ២.១.៦-ជំនឿសាសនា

មានវត្តអារាមសរុបចំនួន ១៣កន្លែង សម្រាប់ពុទ្ធបរិស័ទស្ថិតនៅជុំវិញ និងក្នុងតំបន់ព្រៃការពារ ព្រះវិហារ។ វត្តអារាមភាគច្រើនមានសភាពទ្រុឌទ្រោម ដោយសារលទ្ធភាពរបស់ពុទ្ធបរិស័ទចំណុះជើងវត្តនៅ មានកម្រិត ហើយប្រជាពលរដ្ឋក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ ពុំទាន់មានលទ្ធភាពអាចសាងសង់ ទីអារាមនេះឱ្យមានសោភ័ណ ភាពសម្រាប់ជាទីគោរពសក្ការៈបូជានៅឡើយទេ។ ជាមួយគ្នានេះដែរនៅជុំវិញ និងក្នុង

តំបន់ព្រៃការពារព្រះវិហារ គ្មានវិហារគ្រឹស្តសាសនា និងវិហារឥស្លាមទេ។ យើងពុំមានរបាយការណ៍ ឬព័ត៌មាននានាអំពីជម្លោះនៃការរើសអើង នឹងជំនឿសាសនាក្នុងតំបន់នេះនៅឡើយ ហើយមានវត្តមួយ ចំនួនមិនទាន់មានការទទួលស្គាល់ដោយមន្ទីរធម្មការ និងសាសនា ខេត្តនៅឡើយ។

តារាង ២.៣ ៖ វត្តអារាមនៅតាមបណ្តាស្រុកទាំង២ ស្ថិតក្នុងតំបន់ព្រៃការពារព្រះវិហារ

| លរ | ឈ្មោះស្រុក | វត្តពុទ្ធសាសនា | វិហារឥស្លាម | វិហារគ្រឹះសាសនា |
|---|---|---|---|---|
| ១ | ស្រុកជាំក្សាន្ត | ៤ | - | - |
| ២ | ស្រុកឆែប | ៩ | - | - |
| | សរុប | **១៣** | - | - |

ប្រភព ៖ សាលាស្រុកជាំក្សាន្ត និងឆែប ឆ្នាំ២០១៥

## ២.២-ស្ថានភាពទូទៅនៃបរិស្ថានក្នុងតំបន់

### ២.២.១-ធនធានទឹក

នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ មានអូរ និងស្ទឹងជាច្រើន មានប្រភពពីតំបន់ជួរភ្នំហូរ ចាក់តំបន់ ទំនាបនៅរដូវវស្សា ចាប់ពីខែមិថុនា ដល់ខែកញ្ញា។ អូរភាគច្រើនរីងស្ងួតនៅរដូវប្រាំង ចាប់ពីខែតុលា ដល់ខែឧសភា។ ទន្លេសំខាន់ពីរ (ទន្លេមេគង្គ និងទន្លេល្ពៅ) ស្ថិតនៅភាគឥសាន្ត តំបន់ព្រៃការពារព្រះវិហារ និងស្ទឹងសែន ស្ថិតនៅភាគ ខាងលិចនៃតំបន់ព្រៃការពារព្រះវិហារ មានទឹកជាអចិន្ត្រៃយ៍។ នៅរដូវវស្សា ចាប់ផ្តើមនៅចុងខែ ឧសភា ស្ទឹង និងអូរ ចាប់ផ្តើមហូរ ហើយកម្រិតទឹកឡើងអតិបរមា នៅក្នុងខែ កញ្ញា ឬ តុលា។ ទន្លេទាំងពីរនេះដើរតួនាទីសំខាន់នៅក្នុង តំបន់មិនត្រឹមតែក្នុងការដឹកជញ្ជូនប៉ុណ្ណោះទេ ថែមទាំងនៅ ក្នុងវិស័យសង្គម-សេដ្ឋកិច្ចផងដែរ។

### ២.២.២ ការប្រើប្រាស់ដី

នៅក្នុងតំបន់ព្រៃការពារព្រះវិហាររួមមាន ដីកសិកម្ម ដីព្រៃឈើ ដីវាលស្មៅ ដីព្រៃគុម្ពោត ដីល្បាយថ្ម ដីភូមិ ទីប្រជុំជន និងផ្ទៃទឹក។

ផែនទី ២.២ ៖ ការប្រើប្រាស់ដីនៃតំបន់ព្រៃការពារព្រះវិហារ




ប្រភព ៖ រដ្ឋបាលព្រៃឈើឆ្នាំ ២០១៤

តារាង ២.៤ ៖ ការប្រើប្រាស់ដីនៅក្នុងតំបន់ព្រៃការពារព្រះវិហារ

| ល.រ | ចំណាត់ថ្នាក់ នៃការប្រើប្រាស់ដី | លំអិត | ការប្រើប្រាស់ដី ឆ្នាំ ២០០៩ | | ការប្រើប្រាស់ដី ឆ្នាំ ២០១៤ | | ការប្រែប្រួល | |
|---|---|---|---|---|---|---|---|---|
| | | | ផ្ទៃដី (ហត) | % | ផ្ទៃដី (ហត) | % | ផ្ទៃដី (ហត) | % |
| 1 | **ដីលំនៅដ្ឋាន** | ដីលំនៅដ្ឋាន | ១០០ | ០,០៥ | ៦.២៥៨ | ៣,២៩ | ៦.១៥៨ | ៣,២៤ |
| 2 | **ដីកសិកម្ម** | កសិកម្មពនេចរ | ៣០១ | ០,១៦ | ២៦០ | ០,១៤ | -៤១ | -០,០២ |
| | | ស្រូវរដូវវស្សា | ១.១២៩ | ០,៥៩ | ៧.៥៤២ | ៣,៩៧ | ៦.៤១៣ | ៣,៣៧ |
| 3 | **គម្របព្រៃ** | ព្រៃចម្រុះ (ស្រោងនិង ល្បោះ) | ២៩.៣៨៦ | ១៥,៤៦ | ២៨.៥៨២ | ១៥,០៤ | -៨០៤ | -០,៤២ |
| | | ព្រៃល្បោះ | ៩៣.៩៩២ | ៤៩,៤៦ | ៨៧.៤៣៩ | ៤៦,០១ | -៦.៥៥៤ | -៣,៤៥ |
| | | ព្រៃល្បោះវាលៗ | ១៧.៧៥៩ | ៩,៣៥ | ១៥.៤៣៣ | ៨,១២ | -២.៣២៧ | -១,២២ |
| | | ព្រៃស្រោងនិងពាក់កណ្ដាលស្រោង | ២០.៤២៩ | ១០,៧៥ | ២០.១០០១ | ១០,៥៨ | -៣២៨ | -០,១៧ |
| | | ព្រៃមាត់អូរ | ៩.៤៣៩ | ៤,៩៧ | ៨.៨៩០ | ៤,៦៨ | -៥៥០ | -០,២៩ |
| | | ព្រៃដុះឡើងវិញ | ២.៥៩៨ | ១,៣៧ | ២.៤៦១ | ១,៣០ | -១៣៧ | -០,០៧ |
| 4 | **វាលភក់/វាលស្មៅ** | វាលស្មោះ | ២១០ | ០,១១ | ១៩០ | ០,១០ | -២០,៣៥ | -០,០១ |
| | | វាលស្រែដុះស្មៅ | ៥.៤៤៤ | ២,៨៧ | ៤.៦៣២ | ២,៤៤ | -៨១១ | -០,៤៣ |
| 5 | **ព្រៃគុម្ពោត** | ដីចំការដុះព្រៃគុម្ពោត | ១.០៣៧ | ០,៥៥ | ៩៣៧ | ០,៤៩ | -១០០ | -០,០៥ |
| | | ព្រៃគុម្ពោត | ២០៩ | ០,១១ | ២០៩ | ០,១១ | ០ | ០,០០ |
| | | ព្រៃគុម្ពោតដុះ ដើមឈើមួយៗ | ២.៧៧៧ | ១,៤៦ | ១.៩៣៩ | ១,០២ | -៨៣៩ | -០,៤៤ |
| 6 | **ផ្លូវទឹក** | វាលល្បាប់ | ៥.២១១ | ២,៧៤ | ៥.១៥៣ | ២,៧១ | -៥៧,៦៤ | -០,០៣ |
| | | ទន្លេ | ៣ | ០,០០២ | ០ | 0.000 | -៣ | ០,០០ |
| | | បឹង | ៣ | ០,០០២ | ៣ | ០,០០២ | ០ | ០,០០ |
| | | **សរុប** | **១៩០.០២៧** | **១០០** | **១៩០.០២៧** | **១០០** | | |

## ២.២.៣ កសិកម្ម

វិស័យកសិកម្មដើរតួនាទីស្នូលក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា ហើយមានសារសំខាន់សម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ។ ប្រជាពលរដ្ឋប្រកបរបរកសិកម្ម និងដំណាំស្រូវនៅតែជាដំណាំចម្បងសម្រាប់ធានាបាន នូវសន្តិសុខ ស្បៀងរបស់ប្រជាពលរដ្ឋ ហេតុនេះ ស្រូវនៅតែមានអាទិភាពខ្ពស់។

ប៉ុន្តែការធ្វើកសិកម្មរបស់សហគមន៍នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ មានទិន្នផលទាប ដោយសារ ខ្វះខាតធនធានចាំបាច់ និងកង្វះបច្ចេកទេស។ ដីខ្សោះជីជាតិ និងខ្វះខាតទឹកស្រោចស្រពនាំឱ្យផលិតផលស្រូវទទួលផល ទាបប្រហែល ១.៩តោន/ហត។ ផលិតកម្មស្រូវនៅជុំវិញតំបន់ព្រៃការពារព្រះវិហារពឹងផ្អែកលើទឹកភ្លៀង។ បើទោះ បីជាស្ថិតិវិស័យកសិកម្មឆ្នាំ ២០០៣-២០០៤ បង្ហាញថាខេត្តព្រះវិហារទទួលបានទិន្នផលស្រូវលើសផែនការក៏ដោយ ក៏គ្រួសារភាគច្រើនមានការលំបាក ដើម្បីបំពេញសេចក្ដីត្រូវការ ប្រចាំថ្ងៃរបស់ខ្លួន ដោយសារពួកគេលក់ស្រូវស្ទើរអស់ ពីជង្រុក ជាពិសេសនៅដើម រដូវវស្សា។ សហគមន៍ខ្លះ ជាពិសេសនៅក្នុងស្រុកឆែប តែងតែខ្វះខាតស្បៀងជារៀងរាល់ឆ្នាំ។ ជួនកាលផលិតផលស្រូវ មានផល ប៉ះពាល់ដោយសារតែភាពរាំងស្ងួត និងគ្រោះទឹកជំនន់។

កសិករភាគច្រើនប្រើប្រាស់គោយន្តធុនតូចសម្រាប់ភ្ជួររាស់ជំនួសគោ-ក្របី ពីព្រោះគោយន្តមានភាពងាយស្រួល មានកំលាំងខ្លាំងជួយសន្សំពេលវេលា និងអាចប្រើប្រាស់សម្រាប់ដឹកទំនិញ និងក្នុងគោលបំណងផ្សេងៗទៀត។

ក្រៅពីធ្វើស្រែពឹងផ្អែកទឹកភ្លៀង កសិករធ្វើការនេសាទ ចិញ្ចឹមសត្វ ដាំដំណាំរួមផ្សំ និងសួនបន្លែសម្រាប់សម្រាលជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ សហគមន៍រស់នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារប្រមូលផល-អនុផល ព្រៃឈើសម្រាប់ប្រើប្រាស់ជាប្រពៃណី និងពឹងផ្អែកលើធនធានព្រៃឈើ ដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃផងដែរ។

កសិកម្មពនេចរ ក្រោយពីសង្គ្រាមស៊ីវិល សហគមន៍នៅក្នុងតំបន់ព្រៃការពារព្រះវិហារ បានពឹងផ្អែកកាន់តែខ្លាំងទៅលើកសិកម្មពនេចរជាងពេលមុនសង្គ្រាម។ រូបភាពនៃការធ្វើកសិកម្មពនេចរនៅភាគខាងត្បូងនៃតំបន់ព្រៃការពារព្រះវិហារ ពាក់ព័ន្ធនឹងការកាប់រាន និងដុតព្រៃឈើនៅជុំវិញភូមិរបស់គេ បើទោះបីជាសកម្មភាពនេះកម្រកើតមាន ក្នុងពេលបច្ចុប្បន្នក៏ដោយ។ ដំណាំដែលគេដាំនៅលើដីនោះរួមមាន ស្រូវ អំពៅ សណ្តែកដី ចេក ដំឡូងមី ដំឡូងជ្វា និងពោត។

សហគមន៍ខ្លះនៅតែអនុវត្តកសិកម្មពនេចរតាមប្រពៃណី។ តែទោះយ៉ាងណា ការធ្វើស្រូវបែបប្រពលវប្បកម្ម តាមគោលការណ៍ធម្មជាតិក៏ត្រូវបានណែនាំ ដោយមន្ទីរកសិកម្មខេត្តព្រះវិហារ។ ការធ្វើស្រូវបែប ប្រពលវប្បកម្មតាមគោលការណ៍ធម្មជាតិអាចជួយបង្កើនទិន្នផលស្រូវ។

វាលស្រែតំបន់ខ្លះនៅជាប់ និងក្នុងតំបន់ព្រៃការពារព្រះវិហារ ជាតំបន់ធ្វើស្រែដ៏សំខាន់។ មានកត្តាមួយចំនួនដែលបណ្តាលឱ្យវាលស្រែកាន់តែតូចជាងមុន សង្គ្រាមស៊ីវិលបណ្តាលឱ្យប្រជាពលរដ្ឋ បោះបង់ចោលដីស្រែ បាត់បង់កំលាំងអូសទាញ និងការប្រើប្រាស់ដីស្រែមុនសង្គ្រាមមានការពិបាក ដោយសារដីទាំងនោះត្រូវបានបោះបង់ចោលជាច្រើនទសវត្ស។

គម្រោងអភិរក្សជីវចម្រុះតំបន់ត្រីកោណមរកតកម្ពុជា-ថៃ-ឡាវ (FA-ITTO) និងគម្រោង (FA-CALM) កំពុងធ្វើការដើម្បីដោះស្រាយបញ្ហានេះ តាមរយៈការជួយលើកកំពស់ជីវភាពប្រជាពលរដ្ឋដូចជាធនាគារស្រូវ ធនាគារ គោ មាន់ កូនឈើហូបផ្លែ និងអណ្តូងស្នប់ ដោយមានការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមក្នុង ការការពារ និងអភិរក្សជីវចម្រុះនៅតំបន់ព្រៃការពារព្រះវិហារ។ ក្រៅពីនេះ ការរៀបចំផែនការប្រើប្រាស់ដីដោយមានការចូលរួម គឺជាជម្រើសមួយដែលកំណត់បាននូវតំបន់សម្រាប់ការប្រើប្រាស់របស់សហគមន៍ និងព្រៃការពារ។

ការដាំដំណាំ និងឈើហូបផ្លែ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ ប្រជាពលរដ្ឋដាំដំណាំហូបផ្លែតិចតួចដូចជា ចេក ខ្នុរ អំពៅ ដំឡូង និងពោតជាដើម ដែលមានសារសំខាន់សម្រាប់សុខុមាលភាពក្នុងភូមិរបស់គេ។ ស្របពេល ដែលដីនៅភាគខាងត្បូងតំបន់ព្រៃការពារព្រះវិហារមានផ្លូវអាចដឹកទំនិញទៅកាន់ទីផ្សារតាមស្រុក និងខេត្ត ព្រមទាំងតម្លៃ ស្បៀងកំពុងកើនឡើង ការដាំដំណាំ (ឧ. សណ្តែកដី និងពោត) និងដំណាំហូបផ្លែនៅជុំវិញតំបន់ព្រៃការពារព្រះវិហារ អាចឈានទៅរកការផលិតជាទ្រង់ទ្រាយធំ។ ការពង្រីកដីដាំដំណាំ អាចគំរាមកំហែងដល់ព្រៃឈើតំបន់ ព្រៃការពារព្រះវិហារ ដែលជុំរុញឱ្យមានការរានដីព្រៃឈើបន្ថែមទៀត។

ការចិញ្ចឹមសត្វ នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ មានទំនាក់ទំនងជាមួយ តម្រូវការសត្វ និងសំរាប់លក់ទៅឱ្យអ្នកភូមិផ្សេងទៀត។ សត្វដែលអ្នកភូមិចិញ្ចឹមរួមមាន មាន់ ទា ជ្រូក គោ និងក្របី។

ការប្រើប្រាស់ជី ជាធម្មតាកសិករដឹងពីរបៀបគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់ដំណាំរបស់ពួកគេតាមរយៈការប្រើជីធម្មជាតិ ប៉ុន្តែការយល់ដឹងតិចតួចអំពីការប្រើប្រាស់ជីគីមី។ សារធាតុចិញ្ចឹមរួមមាន លាមកសត្វ កាកសំណល់ ផ្ទះបាយ ផេះ ស្លឹកឈើ ចំបើង និងអំបិល។ ជាទូទៅ កសិករមានការយល់ដឹង មិនច្បាស់អំពី

របៀបប្រើប្រាស់ជីគីមី ទាក់ទងនឹងបរិមាណ ពេលវេលា និងប្រភេទជីសម្រាប់ដំណាំខុសៗគ្នា។ ដីស្រែភាគច្រើនជាដីគ្មានជីជាតិ ហេតុនេះ ការប្រើជីគីមីតាមលក្ខណៈបច្ចេកទេសសមស្របមានសារសំខាន់សម្រាប់បង្កើនទិន្នផលដំណាំ ដើម្បីធានាសន្តិសុខស្បៀង និងតុល្យភាពនៃកំណើនប្រជាពលរដ្ឋ។

ជីគីមីត្រូវបានប្រើប្រាស់សម្រាប់ដំណាំរយៈពេលវែង និងរយៈពេលខ្លី ដើម្បីឱ្យដំណាំលូតលាស់ល្អ និងការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត។ ក្នុងករណីខ្លះ ថ្នាំសំលាប់ស្មៅត្រូវបានប្រើប្រាស់ក្នុងចំការឈើហូបផ្លែ។ នៅពេលថ្មីៗ នេះមានការអប់រំផ្សព្វផ្សាយស្ដីពី គ្រោះថ្នាក់បណ្ដាលមកពីការប្រើជីគីមី ថ្នាំសំលាប់សត្វល្អិត និងសារសំខាន់នៃការ ប្រើប្រាស់ជីធម្មជាតិ (ជីកំប៉ុស្ត-ជី EM) ដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ សហគមន៍មូលដ្ឋានដឹងថាការប្រើប្រាស់ជីគីមីអាចធ្វើឱ្យប៉ះពាល់ គុណភាពដី និងគ្មានអំណោយផលល្អ សម្រាប់ដំណាំស្រូវក្នុងរយៈពេលវែង។

## ២.២.៤-សិប្បកម្ម និងឧស្សាហកម្ម

គ្មានការចុះបញ្ជីស្របច្បាប់នៃរោងសិប្បកម្មកែច្នៃឈើ និងរោងចក្រនៅក្នុង និងជុំវិញតំបន់ព្រៃការពារ ព្រះវិហារទេ។ តែនាពេល ថ្មីៗនេះមានសកម្មភាពសិក្សាជ្រាវរុករករ៉ែធម្មជាតិក្រោមដីចំនួន ៣កន្លែង ដែលស្ថិតនៅក្នុងឃុំ ចំនួន៤ រួមមាន ឃុំទឹកក្រហម ក្នុងស្រុកជាំក្សាន្ត និងឃុំកំពង់ស្រឡៅមួយ ឃុំឆែបពីរ ឃុំសង្កែមួយ ស្ថិតក្នុងស្រុកឆែប។

## ២.២.៥-បញ្ហាសង្គម និងបរិស្ថាន

ដ្យាក្រាម ២.២ ៖ បញ្ហាសង្គម និងបរិស្ថាន




បញ្ហាសង្គម និងបរិស្ថានមួយចំនួនមានផលប៉ះពាល់ដល់ការងារគ្រប់គ្រង និងអភិរក្សធនធាន ព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ បញ្ហាសំខាន់ៗដែលកំពុងជួបប្រទះរួមមាន ៖

**ភាពក្រីក្រ និងកង្វះការអនុវត្តកសិកម្មប្រកបដោយនិរន្តភាព៖** ភាពក្រីក្រអាចជាមូលហេតុដ៏សំខាន់មួយនៃ ការបំផ្លិចបំផ្លាញធនធានព្រៃឈើ និងសត្វព្រៃនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ សហគមន៍មូលដ្ឋានពុំមានលទ្ធភាពផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់តាមរយៈការធ្វើស្រែចំការបច្ចុប្បន្ន ហើយពួកគេត្រូវស្វែងរកប្រភពស្បៀងបន្ថែមតាមរយៈការ បរបាញ់សត្វព្រៃ និងប្រមូលផល-អនុផលព្រៃឈើសម្រាប់លក់ ។

**អស្ថេរភាពសង្គមក្នុងចន្លោះឆ្នាំ ១៩៧៩-១៩៩៨ បានជំរុញឱ្យប្រជាពលរដ្ឋប្រមូលផ្តុំគ្នា តាំងទីលំនៅក្នុងតំបន់ព្រៃឈើ៖** ការតាំងទីលំនៅថ្មីបានជំរុញឱ្យមានកសិកម្មពនេចរ។ ការសាងសង់ លំនៅដ្ឋាន ការកាប់ឆ្ការដីធ្វើស្រែចំការ ការបរបាញ់សត្វព្រៃ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការថយចុះ ធនធានព្រៃឈើ និងធ្វើឱ្យបាត់បង់សត្វព្រៃផងដែរ។

**កំណើនប្រជាពលរដ្ឋ និងការតាំងលំនៅថ្មី៖** សហគមន៍នៅជុំវិញតំបន់ព្រៃការពារព្រះវិហារកំពុង កើនឡើង យ៉ាងឆាប់រហ័ស ដោយសារតែអត្រាកំណើតខ្ពស់ និងការផ្លាស់ទីលំនៅមកពីខេត្តផ្សេងៗ។ បញ្ហា នេះកំពុងគំរាមកំហែងដល់ធនធានព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ដែលស្ថិតនៅជាប់សហគមន៍ ដោយសារតែតម្រូវការដីបាន ជំរុញឱ្យមានការពង្រីកព្រំប្រទល់របស់សហគមន៍ ចូលទៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ កង្វះខាតដីសម្រាប់ធ្វើកសិកម្ម និងដីបម្រុងទុកសម្រាប់សហគមន៍មានន័យថា អ្នកចំណូលថ្មីគ្មានដីសម្រាប់សង់នៅដ្ឋាន ហេតុនេះពួកគេត្រូវកាប់រានដីព្រៃឈើ និងដុតព្រៃឈើ ដើម្បីធ្វើស្រែចំការ។

**កង្វះការយល់ដឹងអំពីការអភិរក្ស៖** ការសិក្សាអំពីបញ្ហាសេដ្ឋកិច្ច-សង្គមដែលរៀបចំដោយក្រុមមន្ត្រីនៃគម្រោងអភិរក្សជីចំរុះតំបន់ត្រីកោណមរកត (FA-ITTO) និងគម្រោង FA-CALM នៅក្នុងតំបន់ព្រៃការពារព្រះវិហារបានបង្ហាញថា ការយល់ដឹងរបស់សហគមន៍មូលដ្ឋានអំពីសារសំខាន់នៃការការពារសត្វព្រៃ និងព្រៃឈើនៅមានកម្រិតនៅឡើយ ទោះជាមានព័ត៌មានស្តីពីយុទ្ធនាការអប់រំផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋាន ទាក់ទងនឹងច្បាប់ស្តីពីព្រៃឈើ និងច្បាប់ភូមិបាលទាំងនៅក្នុង និងជុំវិញតំបន់ព្រៃការពារ។ ជាទូទៅប្រជាពលរដ្ឋ ដែលយើងបានជួបសម្ភាសន៍ក្រៅផ្លូវការ (ពុំមែនជាព្រានព្រៃអាជីព) នៅក្នុងតំបន់ព្រៃការពារបានបញ្ជាក់ថា តាមរយៈបទសម្ភាសន៍ស្តីពីការ អភិរក្សបានជួយឱ្យពួកគេយល់ដឹងខ្លះៗអំពីសារសំខាន់នៃការការពារព្រៃឈើ និងថនិកសត្វខ្នាតធំដូចជា សត្វដំរី ខ្ទីង ខ្លាធំ ខ្លាឃ្មុំ ធំ និងទន្សោង។ ពួកគេទទួលស្គាល់ថា ការបរបាញ់ សត្វព្រៃកន្លងមកបានបណ្តាលឱ្យ បាត់បង់ប្រភេទសត្វ ទាំងនេះ និងដោយសារការបាត់បង់នេះ ហើយទើប ព្រានងាកមករកបរបាញ់សត្វតូចដូចជា ឈ្លូស ពង្រូល ត្រកួត រមាំង ទោច និងស្វាជំនួសវិញ។ ពួកគេគិតថា ក្នុងពេលអនាគតអាចមានការបាត់បង់ ប្រភេទថនិកសត្វខ្នាតធំដូចជា ដំរី ខ្លា ខ្ទីង ទន្សោង និងខ្លាឃ្មុំធំជាដើម (មិនមានកំណត់ត្រាស្តីពីវត្តមាន ខ្លាធំរយៈពេលប្រាំឆ្នាំកន្លងមកហើយ នៅ ក្នុងតំបន់ព្រៃការពារព្រះវិហារ)។

**ការបាត់បង់ និងបំផ្លាញទីជម្រក៖** សកម្មភាពទន្ទ្រានដីព្រៃ ការពង្រីកផ្ទៃដីកសិកម្មនៅក្នុងតំបន់ព្រៃ ឬកាប់ ឈើធ្វើធ្យូង មានសក្តានុពលក្នុងការគំរាមកំហែងដល់វិសាលភាពព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី និង ទីជម្រកសត្វព្រៃនៅក្នុង និងជុំវិញតំបន់ព្រៃការពារ។

**ការកាប់ឆ្ការព្រៃសម្រាប់ធ្វើកសិកម្ម៖** គឺជាសកម្មភាពជាប្រពៃណីរបស់សហគន៍មូលដ្ឋានដែលរស់ នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។ ពួកគេកាប់ព្រៃឈើ និងដុតយកដី ដើម្បីដាំដំណាំវិលជុំ រយៈពេល ២-៤ឆ្នាំនៅតាមតំបន់ខ្លះ។ រូបភាពនៃការធ្វើកសិកម្មពនេចរមានពាក់ព័ន្ធនឹងការកាប់រានដីព្រៃឈើ របស់សហគមន៍ដើម្បីធ្វើកសិកម្ម។ កម្មភាពទាំងនេះបានដាក់សំពាធទៅលើធនធានព្រៃឈើនៃសថតំបន់ ព្រៃការពារព្រះវិហារ ដែលស្ថិតនៅលើដីរបស់សហគមន៍ក្នុងព្រំប្រទល់តំបន់ព្រៃការពារ។ សហគមន៍មូលដ្ឋាន មានសិទ្ធិ

ធ្វើកសិកម្មពនេចរនៅលើដីរបស់គេ ប៉ុន្តែត្រូវបានហាមឃាត់នៅក្នុងតំបន់ព្រៃធម្មជាតិ (យោងតាម មាត្រា ៣៧ នៃច្បាប់ស្តីពីព្រៃឈើ)។

ការកាប់រានដីព្រៃឈើសម្រាប់ធ្វើកសិកម្មពនេចរ (កាប់រានព្រៃឈើ និងដុតដើម្បីដាំដំណាំ) នៅតំបន់ខ្លះក្នុងតំបន់ព្រៃការពារព្រះវិហារ គឺជាបញ្ហាគំរាមកំហែងធំមួយ។ សកម្មភាពនេះនឹងបំផ្លាញជម្រកសត្វព្រៃដោយផ្ទាល់បង្កើន សកម្មភាពរបស់មនុស្សនៅតាមតំបន់ក្បែរខាងដែលធ្វើឱ្យពពួកថនិកសត្វធំៗមួយចំនួនគេចចេញពីតំបន់នោះ។ ការហូរច្រោះដីអាចធ្វើឱ្យប៉ះពាល់តំបន់ដីសើមតូចៗ និងអូរផងដែរ។

ការបាត់បង់ទីជម្រកកំពុងប៉ះពាល់ដល់ការរស់នៅរបស់សត្វព្រៃ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ ជាពិសេស ថនិកសត្វធំៗដូចជា សត្វដំរីអាស៊ី ខ្ទីង ទន្សោង រមាំង និងខ្លាធំជាដើម។ ឧទាហរណ៍ការបំផ្លាញទីជម្រកបានធ្វើឱ្យសត្វដំរីអាស៊ីរស់នៅជាក្រុមតូច និងដាច់ចេញពីក្រុមដទៃទៀតដែលធ្វើឱ្យបាត់បង់ឱកាសបន្តពូជ។ ការបំផ្លាញទីជម្រក បានកាត់បន្ថយដែនបំលាស់ទីរបស់ខ្លាធំដែលត្រូវការរហូតដល់ ៣០គម/ថ្ងៃ ដើម្បីរកចំណី។

ប្រជាពលរដ្ឋមួយចំនួនធំដែលមានលំនៅដ្ឋាននៅក្នុង និងក្បែរតំបន់ព្រៃការពារព្រះវិហារ ប្រកបមុខរបរធ្វើកសិកម្មពនេចរដោយកាប់រានព្រៃឈើយកដីធ្វើចំការ។ ចំការពនេចរនេះមានរយៈពេលប្រមាណ ២-៣ ឆ្នាំប៉ុណ្ណោះ ហើយត្រូវបានអ្នកភូមិបោះបង់ចោលដោយសារដីខ្សោះជីជាតិ ហើយពួកគេចាប់ផ្តើមរុករានទន្ទ្រានដីព្រៃឈើកន្លែង ថ្មីទៀតមកធ្វើស្រែចំការបន្ត។ ផ្ទៃដីដែលសំបូរដោយរុក្ខជាតិ និងសត្វព្រៃត្រូវផ្លាស់ប្តូរស្ថានភាពដើមរបស់វា ដោយសារដំណុះពពួកដើមឫស្សី វល្លិ៍ ស្បូវ និងពពួករុក្ខជាតិ តូចៗដទៃទៀត។ ក្នុងមួយឆ្នាំៗកសិកម្មពនេចរបានបំផ្លាញផ្ទៃដីព្រៃឈើអស់ជាច្រើនហិកតា។

ការប្រើប្រាស់អនុផលព្រៃឈើ យោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីព្រៃឈើ ប្រជាពលរដ្ឋដែលរស់ នៅក្នុង ឬ ក្បែរដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ជាប្រពៃណី និងប្រមូលអនុផលព្រៃឈើដូចជា ឈើងាប់ ទឹកឃ្មុំ ជ័រ និងឈើសំណង់។ល។ តាមការវិភាគជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅជុំវិញ តំបន់ព្រៃការពារព្រះវិហារ បង្ហាញថា ធនធានព្រៃឈើគឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ជីវភាពរស់នៅរបស់ សហគមន៍មូលដ្ឋាន។ មានប្រភេទអនុផលព្រៃឈើជាង ២៥ប្រភេទផ្សេងគ្នាត្រូវបានសហគមន៍ប្រើប្រាស់ ជាអាហារ រកប្រាក់ចំណូល ធ្វើរបងផ្ទះ កន្ត្រក ធ្វើទូក ឧបករណ៍នេសាទ ខ្សែចំណង ថ្នាំបុរាណ និងអុស។ ការប្រើប្រាស់អនុផលទាំងនេះបានបង្ហាញពីចំណេះដឹងពីបុរាណរបស់សហគមន៍។ អនុផលដែលមានសារសំខាន់ ជាងគេ គឺការប្រមូលជ័រឈើដែលជាមុខរបរ លំដាប់ទី៣ បន្ទាប់ពីដាំដំណាំចំការ និងធ្វើស្រូវ របស់សហគមន៍មូលដ្ឋាននៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។

ការប្រមូលអនុផលព្រៃឈើដោយសហគមន៍មូលដ្ឋាន មានផលប៉ះពាល់តិចតួចទៅលើព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ដោយសារតែតំបន់នេះមានប្រជាពលរដ្ឋរស់នៅតិចនៅឡើយ និងការប្រមូលអនុផលមាននិរន្តភាព។ ការគំរាមកំហែងសំខាន់ នៅពេលអ្នកប្រមូលអនុផលព្រៃឈើខ្លះបានធ្វើការ បរបាញ់សត្វព្រៃ ដោយខុសច្បាប់នៅខណៈដែលពួកគេចូលក្នុងព្រៃ ឬក៏ពួកគេយកសត្វឆ្កែទៅជាមួយ។ សត្វឆ្កែអាចជាការគំរាមកំហែងដល់ សត្វព្រៃដូចជាការចាប់ និងការរំខានដល់សត្វព្រៃព្រមទាំងចម្លងជម្ងឺ ដល់សត្វឆ្កែព្រៃ ។

ការបរបាញ់សម្រាប់យកសាច់ លក់ និងធ្វើឱសថ ភស្តុតាងបានបង្ហាញថា ការបរបាញ់សត្វព្រៃ នៅតែកើត មាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ មានកត្តាបីយ៉ាងដែលនាំឱ្យមានការបបាញ់ និងជួញដូរសត្វព្រៃ ក) ការបរបាញ់សត្វព្រៃចូលស៊ីដំណាំស្រូវ និងចំការអ្នកភូមិ ខ) ការបរបាញ់ជាលក្ខណៈគ្រួសារ និង គ) ការបរបាញ់សម្រាប់លក់។

មានការបរបាញ់ និងចាប់សត្វព្រៃដោយប្រើអន្ទាក់ និងឧបករណ៍បុរាណដូចជាស្នា។ល។ សត្វព្រៃមានដោយ បង្គួរដូចជាជ្រូកព្រៃ និងសត្វស្វាជាគោលដៅនៃការប្រមាញ់។ នៅក្នុងករណីទាំងពីរនេះ ដោយសារ តែកង្វះប្រភព ប្រូតេអ៊ីនរបស់សហគមន៍នៅក្នុងតំបន់ព្រៃការពារព្រះវិហារមានន័យថា សកម្មភាពបរបាញ់សត្វទាំងនេះអាចជួយបំពេញបន្ថែមប្រភពប្រូតេអ៊ីនពីសាច់សត្វព្រៃ។

ថនិកសត្វខ្នាតធំត្រូវបានសំលាប់ដោយអាវុធទំនើបដូចជាកាំភ្លើង AK47។ ការបរបាញ់ថនិកសត្វធំៗកំពុងធ្លាក់ចុះគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដូចជាសត្វ ដំរីអាស៊ី កែះ ខ្ទីង ទន្សោង និងខ្លាធំ ដោយសារការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធភាព។

ពុំមានទិន្នន័យគ្រប់គ្រាន់ស្ដីពីការធ្វើអាជីវកម្មពពួកសត្វស្លាបនៅឡើយ ទោះបីជាការបរបាញ់ ដោយជំពាមកៅស៊ូ គឺជាបញ្ហាមួយក៏ដោយ។

មានសហគមន៍មួយចំនួនកំពុងតាំងលំនៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។ នៅក្នុងសហគមន៍ទាំងនេះមានអ្នកភូមិ រួមទាំងយោធាមួយចំនួនបានធ្វើការបរបាញ់ជាច្រើនដងក្នុងមួយសប្តាហ៍ ដោយប្រើកាំភ្លើង និងអន្ទាក់ ដើម្បីយកសាច់សត្វមកធ្វើម្ហូប។ អ្នកប្របាញ់មិនត្រឹមតែបរបាញ់សម្រាប់យកសាច់ប៉ុណ្ណោះទេ ប៉ុន្តែផ្គត់ផ្គង់ ទីផ្សារងងឹតផងដែរដូចជា សាច់ ស្បែក ស្នែង ភ្លុក ចង្កូម និងរោម។ល។

ជារួម ព្រៃឈើនៃតំបន់ព្រៃការពារព្រះវិហារ អាចចាត់ទុកថាជាតំបន់មួយសំបូរទៅដោយរុក្ខជាតិ សត្វព្រៃ គ្រប់ប្រភេទដែលសមស្របសម្រាប់ធ្វើការអភិរក្ស។

គ្រាប់មីន តំបន់មួយចំនួននៅក្នុងតំបន់ព្រៃការពារព្រះវិហារ សំបូរគ្រាប់មីនមិនទាន់ផ្ទុះ។ តំបន់សំបូរគ្រាប់មីន ភាគច្រើនស្ថិតនៅភាគខាងជើងនៃតំបន់ព្រៃការពារព្រះវិហារ ជាពិសេសតំបន់ក្បែរព្រំដែន កម្ពុជា-ថៃ-ឡាវ។ តំបន់មានគ្រាប់មីនតិចបំផុតស្ថិតនៅភាគកណ្តាលឈៀងខាងកើតតំបន់ព្រៃការពារព្រះវិហារ ដែលជាអតីតមូលដ្ឋានរឹងមាំរបស់ខ្មែរក្រហម។ ដំណើរការដោះមីនកំពុងបន្តដោយផ្តោតទៅលើការ ដោះមីននៅតាម បណ្តោយផ្លូវឆ្លោះ ទៅកាន់ភាគខាងជើងព្រំប្រទល់តំបន់ព្រៃការពារព្រះវិហារ។ គ្រាប់មីនកំពុងគំរាមកំហែងដល់សកម្មភាពស្រាវជ្រាវព្រៃឈើ អង្កេតសត្វព្រៃ និងការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ។

អាជីវកម្មឈើ មុនទសវត្សឆ្នាំ ១៩៨០ ការដកហូតឈើពាណិជ្ជកម្មមិនមែនជាកត្តាចម្បងនៅក្នុងការធ្វើអាជីវកម្មឈើក្នុងតំបន់ព្រៃការពារនេះឡើយ។ ការកាប់ឈើដើម្បីបំពេញតម្រូវការក្នុងសហគមន៍ ជាមុខព្រួញសំខាន់ គឺសាងសង់ផ្ទះ។ តំបន់ព្រៃការពារព្រះវិហារត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០២ ហើយ នៅអំឡុងដើមទស្សវត្ស ឆ្នាំ១៩៩០ តំបន់ព្រៃការពារនេះជាផ្នែកមួយនៃព្រៃសម្បទាន។ នៅអំឡុងទស្សវត្ស ឆ្នាំ ១៩៨០ កំលាំងខ្មែរក្រហម បានកាន់កាប់ និងគ្រប់គ្រងព្រៃឈើតំបន់ព្រៃការពារព្រះវិហារ។

នៅក្នុងទសវត្សឆ្នាំ១៩៩០ ព្រៃសម្បទានមួយផ្នែកធំដែលស្ថិតនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ត្រូវបានផ្តល់ឱ្យធ្វើអាជីវកម្ម។ រដ្ឋាភិបាលបានផ្តល់សិទ្ធិឱ្យក្រុមហ៊ុនព្រៃសម្បទានប្រមូលផលឈើ។ ក្រោយពី ការផ្អាកការធ្វើអាជីវកម្មព្រៃសម្បទាននៅក្នុងឆ្នាំ២០០២ ការធ្វើអាជីវកម្មឈើនៅក្នុងតំបន់ព្រៃការពារ ព្រះវិហារ ត្រូវបានបញ្ឈប់ទាំងស្រុង ហើយតំបន់ព្រៃការពារព្រះវិហារ ត្រូវបានបង្កើតឡើងនៅពាក់កណ្តាលឆ្នាំ២០០២។

អ្នកភូមិនៅតែពឹងផ្អែកទៅលើព្រៃឈើសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក។ ឧទាហរណ៍ គេកាប់ឈើសម្រាប់ជួសជុលស្ពាន សាងសង់ផ្ទះ អគារសហគមន៍ សាលារៀន និងវត្តអារាម។ល។

## សកម្មភាពគម្រោងអភិវឌ្ឍជីវភាពសហគមន៍
## គាំទ្រដោយគម្រោង ITTO PD577/10 Rev.1(F)






ការចុះពិនិត្យសកម្មភាពលើកកម្ពស់ជីវភាពសហគមន៍ ពាក់ព័ន្ធការបង្កើតជង្រុកស្រូវ និងការតំឡើងអំពូលប្រើថាមពលពន្លឺព្រះអាទិត្យ




ការបង្ហាញវិធីសាស្រ្តដាំឈើប្រណិត និងឈើហូបផ្លែដើម្បីបង្កើនគម្របដី កាត់បន្ថយការហូរច្រោះ និងបង្កើនការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ដោយដាំប្រភេទឈើទាំងនោះនៅជុំវិញស្រះទឹក ដែលគម្រោងបានឧបត្ថម្ភដល់សាលាបឋមសិក្សាជុញ






វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំសួនបន្លែគ្រួសារ ការចិញ្ចឹមសត្វ និងកសិ-រុក្ខកម្ម សម្រាប់គ្រួសារកងទ័ព និង សហគមន៍មូលដ្ឋាន






ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍សម្រាប់ក្រុមប្រឹក្សាឃុំទឹកក្រហម និងឃុំមរកត ប្រធានភូមិ និងសហគមន៍មូលដ្ឋាន ពាក់ព័ន្ធការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ ការចិញ្ចឹមត្រី ធនាគារគោ ស្រូវ ដែលអនុវត្តដោយសហគមន៍ព្រៃឈើតៀងលិច នៅក្នុងស្រុកបន្ទាយស្រី និងការកែច្នៃធ្វើវត្ថុអនុស្សាវរីយ៍ និងគ្រឿងសង្ហារឹម ចេញពីអនុផលព្រៃឈើ ដោយសហគមន៍មូលដ្ឋានស្ថិតក្នុងស្រុកសូត្រនិគម ខេត្តសៀមរាប




ការពិនិត្យ និងតាមដានការលើកកម្ពស់ជីវភាពសហគមន៍តាមរយៈធនាគារគោ




ការផ្តល់សម្ភារៈសិក្សា និងការចែកកូនឈើព្រៃ-កូនឈើហូបផ្លែ និងការរៀបចំវគ្គសំនួរចំលើយស្តីពីការអភិរក្ស ធនធានព្រៃឈើព្រមទាំងសកម្មភាពអបរំនៅសាលាបឋមសិក្សាអូរជុញ និងរបុញក្នុងព្រៃការពារព្រះវិហារ






សកម្មភាពសាងសង់អាគារសិក្សាចំនួន០១ ខ្នង មាន ០២បន្ទប់  ការលាបពណ៌ជញ្ជាំង ចាក់សាបបន្ទប់រៀន ការដាំកូនឈើ និងការដំឡើងផ្ទាំងកញ្ចក់សូឡាផ្តល់ជូនសាលាបឋមសិក្សាអូរជុញ ពីនិស្សិតសាស្ត្រាចារ្យនៃ សាកលវិទ្យាល័យសេអ៊ូល ក្នុងសាលាបឋមសិក្សាអូរជុញ



ការចែកកូនឈើប្រណីត-កូនឈើហូបផ្លែដល់គ្រួសារយោធិន និងសហគមន៍មូលដ្ឋាន នៅថ្នាលបណ្តុះកូនឈើមរកត ក្នុងព្រៃការពារព្រះវិហារ (អូរជុញ)



ការដាំកូនឈើព្រៃក្នុងពិធីរុក្ខទិវាថ្នាក់ខេត្ត និងការចែកកូនឈើគ្រួសារយោធិននៃកងពលតូចអន្តរាគមន៍ លេខ៩ ក្រុមប្រឹក្សាស្រុកជាំក្សាន្ត ក្រុមប្រឹក្សាឃុំទឹកក្រហម និងឃុំមរកត និងប្រជាសហគមន៍មូលដ្ឋាន

# ជំពូកទី ៣
# ការកំណត់តំបន់ និងការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍នៅក្នុង តំបន់ព្រៃការពារ សម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ ព្រះវិហារ

## ៣.១-ការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

ការចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២។ សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន។ ព្រៃបម្រុងទុកអចិន្ត្រៃយ៍ រួមមានព្រៃ ផ្តល់ផល ព្រៃការពារ និងផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍផ្សេងៗទៀត។

ការបែងចែកតំបន់គឺជាមធ្យោបាយមានប្រសិទ្ធភាព ដែលអាចសម្រេចបានគោលដៅការពារធនធាន ធម្មជាតិ ដ៏មានតម្លៃនៅក្នុងព្រៃការពារ និងការគ្រប់គ្រងសកម្មភាព ដែលមានផលប៉ះពាល់អវិជ្ជមានដល់តម្លៃ ធនធានទាំងនោះ។ ការបែងចែកតំបន់ក្នុងព្រៃការពារ មានលក្ខណៈខុសៗគ្នាដោយផ្អែកលើលក្ខណៈពិសេស នៃកត្តាជីវ-រូបសាស្ត្រ និងគោលបំណងនៃការគ្រប់គ្រង។ គោលបំណងនៃការបែងចែកតំបន់ និងគ្រប់គ្រង តំបន់ ព្រៃការពារព្រះវិហារ គឺឆ្លុះបញ្ចាំង និងឆ្លើយតបនឹងគោលបំណងជាមូលដ្ឋាននៃការបង្កើតព្រៃការពារ នេះ។ គោលបំណង ទាំងនេះមាន ពិពណ៌នានៅក្នុងសេចក្តីផ្តើមនៃផែនការគ្រប់គ្រងនេះ។

ការបែងចែកតំបន់ (Zonning) នៃតំបន់ព្រៃការពារព្រះវិហារ មិនគ្រាន់តែឆ្លើយតបនឹងគោលបំណងនៃ ការគ្រប់គ្រងប៉ុណ្ណោះទេ ប៉ុន្តែគាំទ្រដល់ការអភិរក្សជីវចម្រុះនៅតាមតំបន់ជិតខាងផងដែរ។ ការរស់រានរបស់ព្រៃ ឈើ និងសត្វព្រៃបានយូរអង្វែងក្នុងតំបន់ព្រៃការពារព្រះវិហារ អាស្រ័យលើកិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ ព័ន្ធ ដែលរស់នៅខាងក្រៅតំបន់ព្រៃការពារនេះ។ ជាការពិតណាស់យោងតាមលទ្ធផលនៃការសន្និដ្ឋានតាមរ យៈការ ប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្របង្ហាញថា ស្ថានភាពទីជម្រកសមស្របសម្រាប់ប្រភេទសត្វព្រៃសំ ខាន់ៗ មួយចំនួនមិនគ្រាន់តែ ស្ថិតនៅក្នុងតំបន់ព្រៃការពារព្រះវិហារទាំងមូលប៉ុណ្ណោះទេ ប៉ុន្តែគេក៏ទទួល ស្គាល់ផងដែរ ថាសត្វព្រៃតែងតែធ្វើបំលាស់ទីតាមរដូវកាលពីតំបន់មួយទៅតំបន់មួយទៀតដោយសេរី។ ជាការ សំខាន់ណាស់ ដែលគេត្រូវធ្វើការបែងចែកតំបន់គ្រប់ គ្រងឱ្យបានសមស្រប ដើម្បីអភិរក្សជីវចម្រុះនៅក្នុងតំបន់ ព្រៃការពារ ព្រះវិហារ។ គោលបំណងនៃការរៀបចំបែងចែកតំបន់គ្រប់គ្រង គឺដើម្បី ៖

- ការពារទីជម្រកសំខាន់ៗប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើនិងការវិវត្តន៍អេកូឡូស៊ីក្នុងតំបន់ព្រៃការពារព្រះវិហារ។
- ការពារតម្លៃធនធានធម្មជាតិ និងវប្បធម៌ នៅខណៈដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ធនធាននៃតំបន់ ព្រៃការពារព្រះវិហារប្រកបដោយនិរន្តភាព។
- សម្របសម្រួលការបំលាស់ទីរបស់សត្វព្រៃ និងធ្វើការស្តាររុក្ខជាតិនិងសត្វព្រៃ នៅក្នុងតំបន់ព្រៃរេចរឹល។

ដ្យាក្រាម ៣.១៖ ការបែងចែកតំបន់ព្រៃឈើ



## ៣.២-ព្រៃការពារ

យោងតាមមាត្រា ១០ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ បានចែងថា "ព្រៃការពារត្រូវបានថែរក្សាទុកជាចម្បងសម្រាប់ការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ"។ នៅក្នុងការរៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ បានធ្វើការបែងចែកតំបន់ព្រៃការពារនេះមានដូចនៅក្នុងតារាង ៣.១ និងផែនទី៣.១។

**តារាង ៣.១៖ ចំនួន ទំហំ និងប្រភេទតំបន់នៃព្រៃការពារព្រះវិហារ**

| លរ | ប្រភេទតំបន់ | ចំនួនតំបន់ | ផ្ទៃដីតំបន់ (ហិកតា) | ទីតាំងរដ្ឋបាល |
|---|---|---|---|---|
| ១ | តំបន់ប្រើប្រាស់របស់សហគមន៍ ព្រៃជំនឿសាសនា និងមរតក វប្បធម៌ (CUCR) | **CUCR-1** | ៤០.៨០០ | ឃុំទឹកក្រហម, មរកត និងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត |
| | | **CUCR-2** | ២២.២២២ | ឃុំឆែបពីរ និងកំពង់ស្រឡៅមួយ, ស្រុកជាំក្សាន្ត |
| ២ | តំបន់ទេសចរណ៍ធម្មជាតិ (NbT) | **NbT** | ៦.៨០៩ | ឃុំកំពង់ស្រឡៅមួយ, ស្រុកឆែប |
| ៣ | ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋាន ពិសេស (RFSE) | **RFSE-1** | ៣.៩៦៥ | ឃុំមរកត និងឃុំជាំក្សាន្ត |
| | | **RFSE-2** | ៦៧.៤៧៣ | ឃុំឆែបពីរ និងកំពង់ស្រឡៅមួយ, ស្រុកជាំក្សាន្ត |
| ៤ | ព្រៃការពារទីជម្រាល (WP) | **WP-1** | ៣០.៩៥៤ | ឃុំទឹកក្រហម, មរកត និងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត |
| | | **WP-2** | ៨.៩៣៧ | ឃុំទឹកក្រហម, មរកត និងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត |
| ៥ | ព្រៃលំហែកំសាន្ត (FR) | **FR** | ៩.២២៧ | ឃុំមរកត និងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត |
| | **សរុប** | | **១៩០.០២៧** | |

ផែនទី ៣.១៖ ផែនទីប្រភេទតំបន់នៃតំបន់ព្រៃការពារព្រះវិហារ



## ៣.២.១-តំបន់ប្រើប្រាស់របស់សហគមន៍ ព្រៃជំនឿសាសនា និងមរតកវប្បធម៌ (CUCR)

តំបន់ប្រើប្រាស់របស់សហគមន៍ ព្រៃជំនឿសាសនា និងវប្បធម៌ គឺត្រូវបានចែកចេញចេញជាពីរ អនុតំបន់។ វារួមបញ្ចូលនូវតំបន់លំនៅដ្ឋាន ភូមិករតូចៗជាច្រើន ក៏ដូចជាដីកសិកម្មដែលរួមមាន ដីស្រែ និងចំការរបស់សហគមន៍ប្រើប្រាស់ និងចំការកសិកម្មពនេចរឬចំការវិលជុំ។ តំបន់នេះមានផ្ទៃដី ៦៣.០២២ និងមានប្រាសាទបុរាណជាច្រើន ហើយជាតំបន់ដែលប្រជាជនចូលទៅប្រមូលអនុផលព្រៃឈើសម្រាប់ការ ប្រើប្រាស់បន្ទាប់បន្សំ ព្រមទាំងជាតំបន់ដែលត្រូវបានបែងចែកសម្រាប់សម្បទានដីសង្គមកិច្ច។ ដីភាគច្រើន នៃតំបន់នេះត្រូវបានផ្តល់ជូនគ្រួសារកងទ័ព និងប៉ូលីស៍ព្រំដែន។ សហគមន៍មូលដ្ឋានមានសិទ្ធិជាប្រពៃណី ក្នុងការប្រមូលអនុផលព្រៃឈើ សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ក្នុងលក្ខណៈតម្លាភាព និងនិរន្តភាព យោងទៅតាមច្បាប់ស្តីពីព្រៃឈើ។ ក្នុងការអនុវត្តជាក់ស្តែង ដើម្បីទទួលបានសិទ្ធិស្របច្បាប់ក្នុងការប្រើ ប្រាស់ដីរដ្ឋសហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងជុំវិញតំបន់ព្រៃបម្រុងទុកសម្រាប់សហគមន៍ត្រូវស្នើសុំ ដីប្រើប្រាស់ដីនោះ តាមរយៈអាជ្ញាធរមានសមត្ថកិច្ច (ក្រុមប្រឹក្សាឃុំ អាជ្ញាធរស្រុក និងខេត្ត) និងត្រូវមានការ ឯកភាពពីរដ្ឋបាលព្រៃឈើ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីស្នើសុំចុះបញ្ជីស្របតាមលិខិត បទដ្ឋានច្បាប់ (ភូមិបាលការប្រើប្រាស់ដីធ្លី ការចុះ បញ្ជីដីធ្លី។ល។)។

តំបន់មរតកវប្បធម៌ និងព្រៃជំនឿសាសនា ជាផ្នែកមួយនៃតំបន់ព្រៃការពារព្រះវិហារដែលសហគមន៍មូលដ្ឋានរក្សាជំនឿសាសនាតាមប្រពៃណី និងវប្បធម៌របស់ពួកគេ និងត្រូវបានរក្សាទុកជាព្រៃជំនឿសាសនា។ តំបន់ព្រៃការពារព្រះវិហារ មានតំបន់តូចៗមួយចំនួនដែលមានសារសំខាន់ផ្នែកវប្បធម៌ដូចជា ប្រាង្គប្រាសាទបុរាណ និងព្រៃអារក្ស។ នាពេលបច្ចុប្បន្ននេះ យើងបានរកឃើញប្រាសាទបុរាណចំនួន ១៧ ដែលស្ថិតនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ ប្រាសាទទាំងនោះខ្លះបាក់បែកស្ទើរតែទាំងស្រុង ខ្លះសល់តែស្លាក ស្នាមតួប្រាសាទ ខ្លះសល់តែជុំថ្មនៅរាយប៉ាយ និងខ្លះទៀតនៅរក្សាទំរង់ដើម។ ជាមួយគ្នានេះផងដែរ ប្រជាជនមូលដ្ឋានបានអោយដឹងថា នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ នៅមានប្រាសាទបុរាណ តូចៗមួយចំនួនទៀតតែពិបាកទៅដល់ និងអាចមានគ្រោះថ្នាក់ព្រោះមានគ្រាប់មីន និងគ្រឿងយុទ្ធភ័ណ្ឌ មិនទាន់ផ្ទុះច្រើនកប់នៅក្នុងដីជុំវិញតំបន់ទាំងនោះ។ ការខូចខាតប្រាសាទបុរាណទាំងនេះ គឺអាចបណ្តាល មកពីសង្គ្រាម ភ្លើងឆេះព្រៃ គ្មានការថែរក្សា ដើមឈើដុះឬសចាក់ និងការបំផ្លិចបំផ្លាញដោយជនអគតិ មួយចំនួន (វាយ ឬដាប់យករូបចម្លាក់ និងការជីកគាស់កកាយរកវត្ថុបុរាណមានតម្លៃនៅក្នុង និងជុំវិញ តំបន់ប្រាសាទទាំងនោះ)។ តំបន់ប្រាសាទបុរាណទាំងនេះ នឹងក្លាយទៅជាគោលដៅទេសចរណ៍វប្បធម៌ ធម្មជាតិនាពេលអនាគត។

## ៣.២.២ ព្រៃបម្រុងទុកសម្រាប់លំហែរកំសាន្ត (FR)

ព្រៃបម្រុងទុកសម្រាប់លំហែកំសាន្ត (FR) មានលក្ខណៈធម្មជាតិពិសេស និងបានបង្កើតឡើងសម្រាប់លំហែកំសាន្តបែបទេសចរណ៍ធម្មជាតិ។ ព្រៃលំហែកំសាន្តនៃតំបន់ព្រៃការពារព្រះវិហារអាចជាកន្លែងផ្តល់ដល់អ្នកទេសចរណ៍ទាំងឡាយ ដែលមានបំណងចង់ទស្សនាសម្ផស្សធម្មជាតិ រុក្ខជាតិព្រៃភ្នំដ៏ត្រកាលសត្វព្រៃ ជិះទូកកំសាន្តតាមដងស្ទឹងនានា (ដូចជាស្ទឹងសែន ទន្លេល្ពៅ) និងទស្សនាព្រៃព្រឹក្សា ពពួកសត្វព្រៃដែលរកស៊ីតាមវាលលិចទឹក វាលស្មៅ ដងស្ទឹង និងតាមតំបន់លំហែកំសាន្តនានា ព្រមទាំងស្រូបយកខ្យល់អាកាសបរិសុទ្ធផងដែរ។ លើសពីនេះទៀតតំបន់ព្រៃការពារព្រះវិហារនឹងក្លាយ ជាតំបន់លំហែកំសាន្តសម្រាប់អ្នកទេសចរណ៍ ដែលមានបំណងចង់ទស្សនាប្រាសាទបុរាណ ស្ទូចត្រី ហែលទឹក ជិះទូក កំសាន្ត ព្រមទាំងគយគន់ទេសភាពធម្មជាតិផងដែរ។ ការស្ថាបនាផ្ទះសំណាក់នៅក្នុងតំបន់ព្រៃការពារព្រះវិហារ នឹងត្រូវបានលើកទឹកចិត្ត និងអនុញ្ញាតដើម្បីផ្តល់ដល់អ្នកទេសចរណ៍ដែលមានបំណងទស្សនាព្រៃព្រឹក្សា ធម្មជាតិ និងការទស្សនាប្រាងប្រាសាទបុរាណនានា ដែលនៅរាយប៉ាយក្នុង និងជុំវិញតំបន់ព្រៃការពារ ព្រះវិហារ ការធ្វើដំណើរកំសាន្តតាមភូមិ ដើម្បីស្វែងយល់ពីទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច និងការ

រស់នៅរបស់ប្រជាជនសហគមន៍មូលដ្ឋានទាំងនោះផងដែរ។ តំបន់ព្រៃការពារព្រះវិហារ គឺជាផ្នែក មួយនៃផែនការជាតិ ដើម្បីពង្រីកសកម្មភាពទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិនៅក្នុងប្រទេស កម្ពុជា។ តំបន់ព្រៃការពារព្រះវិហារ ផ្តល់នូវទីតាំងមួយសមស្របបំផុតក្នុង ខេត្តព្រះវិហារ ដែលតភ្ជាប់ការធ្វើទេសចរណ៍នៅខាងជើងប្រទេសកម្ពុជាដូចជា តំបន់ប្រាសាទព្រះវិហារ ប្រាសាទកោះកេរ និងប្រាសាទបុរាណនានានៅក្នុងតំបន់ព្រៃការពារព្រះវិហារ និងការទស្សនាធម្មជាតិ ទេសភាពព្រៃភ្នំ សត្វព្រៃ ។ល។ តំបន់ព្រៃការពារព្រះវិហារ មានលក្ខណៈធម្មជាតិ ពិសេសជាច្រើនសម្រាប់វិស័យទេសចរណ៍ធម្មជាតិរួមមាន ទស្សនាសត្វព្រៃ និងសត្វស្លាប ដំណើរកំសាន្តក្នុងព្រៃ ជិះកង់ ឡើងភ្នំកំសាន្ត ស្នាក់នៅតាមផ្ទះសំណាក់ ក្នុងព្រៃ ជិះឧទ្ធម្ភាគចក្រកសាន្ត ជិះក្បូនកំសាន្ត ដំណើរកំសាន្តតាមទូក និងសកម្មភាពផ្សេងៗទៀត។

### ៣.២.៣ ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស (RFSE)

ព្រៃបម្រុងទុកនេះត្រូវបានការពារនៅទីណាដែលប្រព័ន្ធមជ្ឈដ្ឋាន ផ្តល់ទីជម្រកសំខាន់ដល់សារព័ន្ធ រុក្ខជាតិ និងសត្វព្រៃ ព្រមទាំងប្រព័ន្ធមជ្ឈដ្ឋានពិសេសដែលមានសារៈសំខាន់សម្រាប់ការអភិរក្សជីវចម្រុះ។ ព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស **(RFSE)** ត្រូវបានចែកជា ០២ អនុតំបន់ដែលមានពណ៌នា ក្នុង តារាង ៣.១ និង ផែនទី ៣.១ ដែលប្រើប្រាស់សម្រាប់ការងារសិក្សាស្រាវជ្រាវនៃចំនួនប្រភេទដ៏ច្រើននៃប្រភេទសត្វព្រៃ និងរុក្ខជាតិ ក៏ដូចជាសារៈសំខាន់នៅក្នុងការអភិរក្ស។ ប្រភេទមួយចំនួននៅក្នុងតំបន់នេះ អាចមានតម្លៃជាពិសេសសម្រាប់ឱសថ ការបន្តពូជ ទេសចរណ៍ធម្មជាតិ និងគោលបំណងផ្សេងៗ ហើយ ប្រព័ន្ធមជ្ឈដ្ឋាននៅក្នុងតំបន់នេះដើរតួនាទីជាធនាគារសេនេទិច ដែលអាចផ្តល់ជាប្រយោជន៍ខាងផ្នែក ហិរញ្ញវត្ថុដល់ប្រទេសជាតិវិញ។ បន្ថែមលើនេះ តំបន់ទាំងនេះ នឹងកាន់តែមានតម្លៃ នៅពេលដែលតំបន់ ផ្សេងទៀតនៅក្នុងតំបន់អាស៊ីត្រូវបានបាត់បង់ ហើយប្រទេសដទៃទៀតមានត្រឹមតែធនធានសេនេទិចទាំង នេះកាន់តែតិចតួចទៅ។

ព្រៃបម្រុងទុកទាំងនេះរួមមាន ដីសើម តំបន់មានរយៈកំពស់ខ្ពស់ ព្រៃស្រោង តំបន់ភ្នំ តំបន់ទីជម្រកពិសេស សម្រាប់ប្រភេទសត្វព្រៃសំខាន់ៗដូចជា ទន្សោង ខ្ទីង រមាំង ដំរី ខ្លារខិន ខ្លាឃ្មុំធំ ខ្លាឃ្មុំតូច ទោចម្ពុងកែះ ឈ្លូស រញ៉េផេះ ស្វាព្រាម ស្វាក្តាម ស្វាត្រោស ស្ពាធំ សំពោចភ្នំ សំពោចក្រអូប កេខ្លួនរលោង ឆ្កែព្រៃ ត្រយ៉ងយក្ស ទាព្រៃស្លាបស ក្រៀល ត្រដក់ធំ ក្ងោក មាន់ទោពណ៌ប្រាក់ សេកសោម ទីទុយធំព្រៃ ត្មាតផេះ ត្មាតភ្លើង អន្សង ត្រកួត ពស់ថ្លាន់ អណ្តើកព្រិច អណ្តើកសកល។ល។ នៅតំបន់នេះក៏មាន ដុះលូតលាស់ប្រភេទរុក្ខជាតិសំខាន់ៗជាច្រើន ប្រភេទដូចជា ប្រភេទឈើ ពាណិជ្ជកម្ម រុក្ខជាតិឱសថ និងប្រភេទអនុផលព្រៃឈើ។ ប្រភេទសត្វព្រៃ ដែលបានរកឃើញនៅក្នុងព្រៃបម្រុងទុកសម្រាប់ប្រព័ន្ធ មជ្ឈដ្ឋានពិសេសនៃតំបន់ព្រៃការពារព្រះវិហារ ត្រូវបានចាត់ថ្នាក់ជាប្រភេទក្រុមជិតផុតពូជ និងក្រុមប្រភេទ មានដោយកម្រ នៅក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងអនុតំបន់នេះ ផ្តោតជាសំខាន់ទៅ លើការអភិរក្សជីវចម្រុះ និងសកម្មភាពមួយចំនួននៅក្នុងអនុតំបន់ទាំងនេះ គួរតែត្រួត ពិនិត្យឱ្យបានតឹងរឹង ដើម្បីធានាថាសកម្មភាពទាំងនោះមិនរំលោភច្បាប់ស្តីពីព្រៃឈើ ហើយមានផលប៉ះពាល់ តិចតួចទៅលើជីវចម្រុះ។

### ៣.២.៤ ព្រៃបម្រុងទុកការពារទីជម្រាល (WP)

ព្រៃបម្រុងទុកសម្រាប់ការពារទីជម្រាល (WP) ជាផ្នែកមួយនៃតំបន់ព្រៃការពារព្រះវិហារ ដែលប្រើប្រាស់ជាអាទិភាព ដើម្បីបំពេញមុខនាទីការពារព្រៃឈើ និងតំបន់មានចំណោទខ្លាំងដែលងាយទទួលរង ការហូរច្រោះដី ឬហៅថាផ្ទៃរងទឹកភ្លៀង "Watershed Catchment"។ ព្រៃការពារទីជម្រាល ឬហៅថា តំបន់ផ្ទៃរងទឹកភ្លៀងនៃតំបន់ព្រៃការពារព្រះវិហារ គឺជាតំបន់ដែលមានសក្តានុពលសម្រាប់ការពារតំបន់ ព្រៃឈើ និង

ទីជម្រាលមានចំណោទខ្លាំងទប់ទល់នឹងការហូរច្រោះ។ មួយផ្នែកនៃតំបន់ព្រៃការពារព្រះវិហារ គឺជាតំបន់ភ្នំស្ថិតនៅតាមជួរភ្នំដងរែកព្រំប្រទល់ប្រទេសកម្ពុជា-ថៃ ដែលមានទីជម្រាលចំណាត់ថ្នាក់ទី២ និង៣ ហើយផ្តល់នូវប្រភពទឹកទៅកាន់តំបន់ទំនាបខាងជើងបឹងទន្លេសាប និងបណ្តាខេត្តជិតខាង។ នេះជា តឹកតាងអាចបញ្ជាក់ពីតួនាទីដ៏សំខាន់របស់តំបន់ព្រៃការពារព្រះវិហារ សម្រាប់គ្រប់គ្រងទីជម្រាលនៅភាគ ខាងជើងប្រទេសកម្ពុជា។ ការគ្រប់គ្រងតំបន់នេះ គួរផ្តោតទៅលើសកម្មភាពមានផលប៉ះពាល់តិចតួច ដល់ទីជម្រាល និងដល់តួនាទីរបស់តំបន់ព្រៃការពារព្រះវិហារ ក្នុងការធ្វើនិយតកម្មប្រភពទឹក។ ការគ្រប់គ្រង ទីជម្រាលនេះមានសារសំខាន់ជាពិសេសទៅលើវិស័យកសិកម្ម ព្រៃឈើ និងការនេសាទ។ តំបន់ព្រៃបម្រុង ទុកសម្រាប់ការពារទីជម្រាលទាំងនេះ គឺជាគោលដៅនៃការការពារ និងអភិរក្ស ដោយសារតំបន់ទីជម្រាល គឺជាកត្តាចង្កូល បង្ហាញយ៉ាងសំខាន់នៃសេវាកម្មប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើរបស់តំបន់ព្រៃការពារព្រះវិហារ។

តំបន់នេះ ក៏មានតួនាទីធ្វើនិយតកម្មប្រភពទឹក និងវដ្តរបស់ទឹក។ សេវាកម្មបរិស្ថានសំខាន់បំផុត នៃព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ គឺជាតំបន់ផ្ទៃរងទឹកភ្លៀង ការស្រូបឧស្ម័នកាបូនិច ($CO_2$) និងការបង្កើតខ្យល់បរិសុទ្ធ ការការពារការហូរច្រោះដីជាតិដី រក្សានិយតកម្មប្រភព ទឹក និងគុណភាពទឹក។ តំបន់ផ្ទៃរងទឹកភ្លៀងនេះ ផ្តល់ទឹកដល់សហគមន៍ដែលរស់នៅតាមតំបន់ទំនាបភាគខាងក្រោម ជួរភ្នំដងរែក ព្រមទាំងតំបន់វាលទំនាបនៅខាងជើងបឹងទន្លេសាប និងបឹងទន្លេសាប។ ព្រៃឈើនៅតំបន់ព្រៃការពារ ព្រះវិហារ មានមុខងារការពារកាបូនស្តុក (Carbon Stock) ដែលស្ថិតនៅក្នុងគ្រប់ប្រភេទរុក្ខជាតិ និងជួយ កាត់បន្ថយការសាយភាយនៃឧស្ម័នកាបូនិច ($CO_2$) ទៅក្នុងបរិយាកាស។ លក្ខណៈតំបន់ផ្ទៃរងទឹកភ្លៀង មានផលប៉ះពាល់ដោយសារការហូរច្រោះដែលអាស្រ័យលើកត្តាពីរសំខាន់ គឺរយៈកំពស់ និងកម្រិតជម្រាល។

តំបន់ព្រៃការពារព្រះវិហារ ជាប្រភពទឹកសម្រាប់ការប្រើប្រាស់របស់ប្រជាជន (ទឹកសម្រាប់ផឹក ធ្វើស្រែចំការវារីវប្បកម្ម និងនេសាទ) នៅក្នុងខេត្តព្រះវិហារ ក៏ដូចជាការហូរចាក់ទៅក្នុងបឹងទន្លេសាប និងទៅ ទន្លេមេគង្គ។ ម្យ៉ាងវិញទៀត នៅតំបន់ព្រៃការពារព្រះវិហារមានគម្របព្រៃឈើ និងទទួលទឹកភ្លៀងប្រចាំ ឆ្នាំប្រមាណពី ១៣៨៥,៥-២០៣៥,៥មម គឺជាតំបន់ទទួលទឹកភ្លៀងមធ្យមនៅក្នុងប្រទេសកម្ពុជា ដូចនេះ ការការពារគម្របព្រៃឈើនៅតំបន់នេះ គឺជាការចាំបាច់ជាពិសេសប្រភេទឈើដែលមានកំពស់ខ្ពស់។

### ៣.២.៥ តំបន់ស្តារព្រៃឈើ (FRS)

តំបន់ស្តារព្រៃឈើ **(FRS)** មានទំហំ ៨.០០០ហិកតា ដែលត្រូវបានទទួលរងភាពរេចរឹលយ៉ាងខ្លាំង និងទាមទារឲ្យមានកិច្ចអន្តរាគមន៍ ពាក់ព័ន្ធនឹងបច្ចេកទេសស្តារព្រៃឈើទៅតាមប្រភេទតំបន់ព្រៃឈើផ្សេងៗ រួមមានការស្តារដំណុះព្រៃឈើដោយធម្មជាតិ (Assisted Natural Regeneration) ការដាំបញ្ចូលបន្ថែម (Enrichment Planting) និងការបង្កើតចំការព្រៃឈើ។ ហេតុផលមួយសំខាន់នៃការបាត់បង់គម្រងព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ គឺតម្រូវការដីធ្វើកសិកម្ម កសិឧ-ស្សាហកម្ម ជាពិសេសការបំលែងដីព្រៃទៅជាដីសម្បទានសង្គមកិច្ច និងសម្បទានសេដ្ឋកិច្ច។ ប្រសិនបើនិន្នាការនោះនៅតែបន្ត អត្រានៃការស្តារព្រៃឈដោយដាំបញ្ចូលបន្ថែម នឹងមិនអាចជំនួសការបាត់បង់ ដោយរក្សាអត្រានៃគម្របព្រៃឈើបច្ចុប្បន្ន នៅក្នុងតំបន់ព្រៃការពារព្រះវិហារបានទេ។

# ជំពូកទី៤
# យុទ្ធសាស្ត្រគ្រប់គ្រង
# តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃព្រះវិហារ

យុទ្ធសាស្ត្រគ្រប់គ្រងដែលបានរៀបចំសម្រាប់ដំណាក់កាលទី២ នៃផែនការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ ឆ្លុះបញ្ចាំងពីការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព ដែលត្រូវបានរួមបញ្ចូលទៅក្នុងផែនការគ្រប់គ្រងលើកដំបូង ដែលបានរៀបចំអនុវត្តគម្រោងរួមគ្នារវាងរដ្ឋបាលព្រៃឈើ និងអង្គការITTO "គម្រោងគ្រប់គ្រងព្រៃការពារតំបន់ត្រីកោណ-មរកត ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការអភិរក្សជីវចម្រុះតាមបណ្តោយព្រំដែនរវាងប្រទេសថៃឡង់ដ៏-កម្ពុជា-ឡាវ (ជំហាន២)"។ ការរៀបចំផែនការគ្រប់គ្រងដំណាក់កាលទី២ ដែលមានរយៈពេលអនុវត្តគម្រោង ៥ឆ្នាំ ដោយផ្សាភ្ជាប់ ជាមួយនឹងផែនការគ្រប់គ្រងដំណាក់កាលទី១ គឺផ្អែកតាមការវាយតម្លៃបទពិសោធន៍នៃការអនុវត្តផែនការគ្រប់គ្រង ដំណាក់កាលដំបូង ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៤។ ការរៀបចំនេះរួមបញ្ចូលនូវការវាយតម្លៃនៃភាពសំខាន់ចាំបាច់ សម្រាប់សកម្មភាពគ្រប់គ្រងជាអាទិភាព ដែលបានមាននៅក្នុងផែនការគ្រប់គ្រងដំណាក់កាលដំបូង ក៏ដូចជាការ ពិចារណាទៅលើវិសាលគមនៃលទ្ធផលពីការអនុវត្តសកម្មភាពសិក្សាស្រាវជ្រាវ និងមេរៀនជាបទពិសោធន៍ ដែលទទួល បាននៅជំហានទី៣ ពីការអនុវត្តគម្រោង "អភិរក្សជីវចម្រុះតាមបណ្តោយព្រំដែនតំបន់ត្រីកោណមរកត"។

## ទស្សនវិស័យ

ទស្សនវិស័យដែលបង្កប់អត្ថន័យពីក្រោយផែនការគ្រប់គ្រងព្រៃការពារព្រះវិហារ គឺដើម្បីអភិរក្សព្រៃការពារ ព្រះវិហារ តាមរយៈការបង្កើតសមភាពដែលមាននិរន្តភាពរវាងតម្រូវការសេដ្ឋកិច្ច សង្គម និងបរិស្ថានដែលមានសង្គតិភាព ជាមួយនិងសេចក្តីថ្លែងការណ៍គោលនយោបាយព្រៃឈើជាតិ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងរបៀបវារៈជាសាកលនៃគោលដៅអភិវឌ្ឍន៍ដោយមាននិរន្តភាព។

## ៤.១ យុទ្ធសាស្ត្រគ្រប់គ្រង

ក្នុងគោលបំណងសម្រេចបានទស្សនវិស័យសម្រាប់ព្រៃការពារព្រះវិហារ ប្រកបដោយប្រសិទ្ធិភាព និង ប្រសិទ្ធ ផល ក្រុមការងារបានគូសបញ្ជាក់ពីសារសំខាន់នៃកម្មវិធីអាទិភាពចំនួន៦ ដើម្បីអនុវត្តសកម្មភាពគ្រប់គ្រង។ គម្រោង សំខាន់ៗនៃកម្មវិធីអាទិភាពទាំងនោះរួមមាន៖

- កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ
- កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ
- កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម
- ការគ្រប់គ្រងតំបន់ការពារ និងព្រៃការពារតាមបណ្តោយព្រំដែន ដោយមានកិច្ចសហការ
- កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន
- កម្មវិធីត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ

## ៤.២ កម្មវិធីគ្រប់គ្រង

### ៤.២.១ កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ

កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ មានអនុកម្មវិធីចំនួន ៣ រួមមាន៖

#### ៤.២.១.១ កាត់បន្ថយបទល្មើសព្រៃឈើ និងសត្វព្រៃ

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន ដើម្បីបញ្ឈប់សកម្មភាពកាប់ បំផ្លាញព្រៃឈើ ការជួញដូរសត្វព្រៃ និងបទល្មើកាប់រានដីព្រៃ
- ពង្រីកការប្រើប្រាស់ឧបករណ៍វិធីសាស្ត្ររាយការណ៍ និងត្រួតពិនិត្យដោយបង្ហាញចំណុចភូមិសាស្ត្រ (Spatial Monitoring and Reporting Tool: SMART) ដើម្បីពង្រឹងការរៀបចំផែនការល្បាត ទៅតាមចំណុច មានការគំរាមកំហែងដែលអង្កេតឃើញកើតមានឡើង និងការចាត់វិធានការឆ្លើយតបសមស្រប
- បង្កើនសកម្មភាពល្បាត រឹតបន្តឹងការអនុវត្តច្បាប់នៅតំបន់ជម្រកសត្វព្រៃសំខាន់ៗ និងតំបន់ដែលសកម្មភាពល្មើសច្បាប់ព្រៃឈើ ការជួញដូរសត្វព្រៃ និងបទល្មើសកាប់រានដីព្រៃឧស្សាហ៍កើតមានឡើង
- រឹតបន្តឹងការប្រើប្រាស់កាំភ្លើងដៃនៅក្នុងតំបន់ព្រៃការពារព្រះវិហារ
- ពង្រឹងយុទ្ធនាការប្រឆាំងការបរបាញ់ និងជួញដូរ សត្វព្រៃដោយខុសច្បាប់ រួមទាំងការប្រើប្រាស់សាច់សត្វ និងជម្រុញការអប់រំផ្សព្វផ្សាយបរិស្ថាន ដើម្បីលើកកំពស់ការយល់ដឹងជុំវិញសកម្មភាពទាំងអស់នេះ។

#### ៤.២.១.២ ពង្រឹងការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃអោយមាននិរន្តភាព

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- បង្កើនចំនួនកិច្ចប្រជុំទាំងផ្លូវការ និងក្រៅផ្លូវការ ជាមួយនិងមន្ត្រីរដ្ឋាភិបាល ដើម្បីពង្រឹងទំនាក់ទំនងនៃកិច្ចគាំទ្រខាងផ្នែកគោលនយោបាយ ដើម្បីពង្រឹងការអភិរក្សជីវចម្រុះក្នុងតំបន់ព្រៃការពារព្រះវិហារ
- ពង្រឹងសមត្ថភាពមន្ត្រីល្បាត តាមរយៈការបែងចែកសម្ភាររួមមានយានយន្ត ឧបករណ៍និងសម្ភារដែលប្រើក្នុង ការទំនាក់ទំនងនិងប្រតិបត្តិការបង្ក្រាបនៅទីវាល ក៏ដូចជាបង្កើនចំនួនមន្ត្រីល្បាតឲ្យដល់កម្រិតកំណត់ដោយ រដ្ឋាភិបាល គឺចំនួនមន្ត្រី ៨នាក់ សម្រាប់ស្នាក់ការមួយ។
- ផ្សព្វផ្សាយសហគមន៍មូលដ្ឋានអោយយល់ដឹងអំពីសារសំខាន់នៃតំបន់ជីវចម្រុះក្នុងព្រៃការពារព្រះវិហារ
- គាំទ្រកិច្ចខិតខំដើម្បីសង្គ្រោះ និងបង្កាត់ពូជប្រភេទសត្វមានដោយកម្រនិងរងការគំរាមកំហែង និងលែងសត្វ ដែលបានសង្គ្រោះនិងបង្កាត់ពូទាំងនោះទៅក្នុងព្រៃវិញ ព្រមទាំងជម្រុញការគ្រប់គ្រងប្រភេទរុក្ខជាតិ តាម រូបភាពដូចគ្នា ពិសេសការបង្កាត់ពូជពិសោធន៍ប្រភេទរុក្ខជាតអរគីដេរព្រៃ។

#### ៤.២.១.៣ ថែរក្សាបូរណភាពតំបន់ព្រៃឈើទាំងនៅក្នុង និងជុំវិញ តំបន់ព្រៃការពារព្រះវិហារ និងស្តារគុណភាពតំបន់ ជម្រកសត្វព្រៃ

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំបង្កើតច្រកចេញចូលតំបន់ព្រៃការពារព្រះវិហារ ដោយដាក់ព្រំប្រទល់ធ្វើពីស៊ីម៉ង់ត៍ ស្លាកសញ្ញា ចរាចរណ៍ នៅក្នុងតំបន់ព្រៃការពារ
- ថែរក្សាស្រះ ត្រពាំងទឹកដែលមានទឹកតាមរដូវកាល ដើម្បីរក្សាការពារស្ថានភាពតំបន់មជ្ឈដ្ឋាន និងកាត់បន្ថយ ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុទៅលើធនធានទឹក ដែលជួយគាំទ្រដល់ជីវភាពសហគមន៍ និងការផ្តល់ ជាជម្រកសម្រាប់សត្វស្លាបទឹក
- ជម្រុញការដាំស្តារព្រៃឈើនៅក្នុងតំបន់ព្រៃធម្មជាតិ សម្រាប់ប្រភេទឈើក្នុងតំបន់ដែលបានបណ្តុះនៅ ក្នុងថ្នាល នៅក្នុងព្រៃការពារព្រះវិហារ
- លើកទឹកចិត្តអោយមានការដាំស្តារព្រៃឈើ និងការវិនិយោគជាចំការព្រៃឈើសហគមន៍នៅក្នុងតំបន់ព្រៃ រេចរឹលនិងដីព្រៃដែលបានដកហូតពីការកាប់រាន ជាពិសេសតំបន់ដែលបង្ហាញថាពុំមានការវិវត្តស្ថានភាពព្រៃ ល្អប្រសើរឡើងវិញតាមវិធានការការពារបរិស្ថាន។

## ៤.២.២ កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ

មានអនុកម្មវិធីចំនួន៣ នៅក្នុងកម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ ដោយរួមមាន៖

### ៤.២.២.១ ជម្រុញប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានទេសចរណ៍ធម្មជាតិ និងសកម្មភាពទេសចរណ៍

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ជម្រុញរៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ ដើម្បីគាំទ្រជម្រើសនៃឱកាសអភិវឌ្ឍជីវភាព តាមរយៈការបង្កើត កម្មវិធីស្នាក់តាមផ្ទះ (homestays) ផ្ទះសំណាក់ ផ្ទះលំហែរធម្មជាតិ និងការបំពាក់ បំប៉នចំណេះដឹង ផ្នែកវប្បធម៌ និងសេវាមគ្គុទេសក៍ជាលក្ខណៈបុគ្គល ក្នុងកិច្ចសហការជាមួយសហគមន៍
- បណ្តុះបណ្តាលជំនាញស្តីពីសហគមន៍ទទួលបានអត្ថប្រយោជន៍ពីទេសចរណ៍ធម្មជាតិដល់សហគមន៍មូលដ្ឋាន
- រៀបចំកម្មវិធីបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើ បុគ្គលិកព្រៃការពារ សមាជិកគណកម្មការអភិរក្សព្រៃ សហគមន៍ ស្តីពីការគ្រប់គ្រងសកម្មភាព និងធនធានទេសចរណ៍ធម្មជាតិ
- ការពារទីតាំងប្រាសាទបុរាណ និងវប្បធម៌ ព្រមទាំងសហកាជាមួយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ដើម្បី ស្តារសំណង់ឬតំបន់មរតកវប្បធម៌ដែលរងការខូចខាត ដែលសំណង់បុរាណដែលនៅសេសសល់ក្នុងតំបន់ ព្រៃការពារព្រះវិហារ
- រៀបចំកិច្ចព្រមព្រៀងជាមួយសហគមន៍មូលដ្ឋាន ដើម្បីពង្រឹងការគ្រប់គ្រងតំបន់កំសាន្ត និងទេសចរណ៍ធម្មជាតិ ដើម្បីកាត់បន្ថយផលប៉ះពាល់លើសត្វព្រៃ ធនធានធម្មជាតិផ្សេងទៀត និងជីវចម្រុះ។

### ៤.២.២.២ ពង្រីកទីផ្សារទេសចរណ៍ធម្មជាតិ

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- អភិវឌ្ឍបណ្តាញទីផ្សារសម្រាប់សកម្មភាពលំហែរ កំសាន្តធម្មជាតិ និងទេសចរណ៍ដែលមិនមានការរំខាន ដើម្បីឆ្លើយតបតម្រូវការចង់បានរបស់ភ្ញៀវទេសចរ

- សហការជាមួយមន្ទីរទេសចរណ៍ខេត្ត និងអាជ្ញាធរមូលដ្ឋាន ដើម្បីលើកកំពស់ការយល់ដឹងសាធារណៈ អំពី ទីតាំងគោលដៅទេសចរណ៍ធម្មជាតិសំខាន់ៗក្នុងតំបន់ព្រៃការពារព្រះវិហារ។

### ៤.២.២.៣ ពង្រឹងសេវាកម្ម និងកម្មវិធីមគ្គុទេសក៍ទេសចរណ៍

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោមៈ

- ប្រមូលសម្ភារពាក់ព័ន្ធស្តីពីចំណេះដឹងវប្បធម៌ និង ប្រពៃពីក្នុងតំបន់សម្រាប់ប្រើក្នុងកម្មវិធីមគ្គុទេសក៍
- ពង្រឹងកម្មវិធីមគ្គុទេសក៍ទេសចរតាមរយៈការបង្កើត មជ្ឈមណ្ឌលភ្ញៀវទេសចរ តំបន់ទេសភាពសម្រាប់មើល សត្វព្រៃនិងផ្លូវដើរតាមចំរាក់ភ្នំ ផ្លូវទស្សនាមាន តាំងពិពណ៌សត្វ ក៏ដូចជាការដាក់ផ្លាំង ស្លាកសញ្ញា ក្រដាស់ និងសៀវភៅបង្ហាញព័ត៌មានសង្ខេបស្តីពី តំបន់ទេសចរណ៍ ព្រមទាំងសៀវភៅមគ្គុទេសក៍ ដើម្បីងាយស្រួល ផ្តល់ជាបទពិសោធន៍ការកំសាន្ត សម្រាប់ភ្ញៀវទេសចរ
- ជម្រុញបង្កើតសកម្មភាពទស្សនាសត្វព្រៃនៅតំបន់ទីតាំងទេសចរណ៍ក្នុងតំបន់ព្រៃការពារព្រះវិហារ ដែលមាន សក្តានុពលសម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ មានផលប៉ះពាល់ទាប ដែលអាចគ្រប់គ្រងធានានិរន្តភាព នៃសកម្មភាពទាំងនោះ
- ជម្រុញបង្កើតការដើរកំសាន្តក្នុងតំបន់ព្រៃ ដែលផ្តល់ជាមធ្យោបាយលើកកំពស់ជីវភាពសហគមន៍មូលដ្ឋាន ដោយអភិវឌ្ឍ និងកែលំអផ្លូវដើរក្នុងព្រៃ ព្រមទាំងសហការជាមួយសហគមន៍មូលដ្ឋាន ដើម្បីទប់ស្កាត់ការចិញ្ចឹម សត្វនៅក្នុងតំបន់ដែលកំណត់សម្រាប់ការដើរកំសាន្តពង្រីកបទពិសោធន៍ទេសចរធម្មជាតិ
- រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីផលប៉ះពាល់នៃទេសចរណ៍ទៅលើការអភិរក្សជីវចម្រុះដល់ អ្នកប្រតិបត្តិ ទេសចរណ៍ និងភ្ញៀវទេសចរ។

## ៤.២.៣ កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម

កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម មានអនុកម្មវិធីចំនួន៣ ដូចខាងក្រោមៈ

### ៤.២.៣.១ កាត់បន្ថយការពឹងអាស្រ័យលើធនធានធម្មជាតិ

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោមៈ

- ជម្រុញការអនុវត្តកសិ-រុក្ខកម្ម និងកសិកម្មដោយមាននិរន្តភាពនៅក្នុងព្រៃសហគមន៍ និងតំបន់កសិកម្មនៅក្នុង និងជុំវិញព្រៃការពារព្រះវិហារ
- សហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ដើម្បីបង្កើតសហគ្រាសសហគមន៍ បង្កើនប្រភពចំណូលសម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងផ្តល់វគ្គបណ្តុះបណ្តាលដើម្បីបង្កើនការចូលរួម ក៏ដូចជាកម្មវិធីអភិវឌ្ឍន៍ជីវភាពដោយមាននិរន្តភាព
- លើកទឹកចិត្តការដាំដើមឈើ និងប្រភេទរុក្ខជាតិផ្សេងទៀតដែលគាំទ្រជីវភាពសហគមន៍ ជាពិសេសឬស្សី និងការដាំប្រភេទរុក្ខជាតិដែលអាចហូបបាន ដូចជាផ្សិត ដើម្បីកាត់បន្ថយការប្រើប្រាស់រុក្ខជាតិព្រៃរបស់ សហគមន៍

- បង្កើត និងអនុវត្តបទបញ្ញត្តដើម្បីត្រួតពិនិត្យការប្រើប្រាស់អនុផលព្រៃឈើ ជួយគាំទ្រការអភិវឌ្ឍជីវភាព សហគមន៍ដោយចីរភាព និងបង្កើនចំណូលបន្ថែម ទន្ទឹមនិងការថែរក្សាធនធានធម្មជាតិក្នុងតំបន់ព្រៃការពារព្រះវិហារ។

#### ៤.២.៣.២ បង្កើនការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រង

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- គាំទ្រការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍នៅក្នុង និងជុំវិញព្រៃការពារព្រះវិហារ ដើម្បីកាត់បន្ថយ ការប្រើប្រាស់ធនធានព្រៃឈើ ដែលពុំមាននិរន្តភាព
- ដំណើរការប្រើប្រាស់យន្តការសង្គម ដើម្បីជម្រុញការចូលរួមការគ្រប់គ្រងព្រៃការព្រៃការពារព្រះវិហារពី សហគមន៍មូលដ្ឋាន ដូចជាការបង្កើតក្រុមប្រឹក្សាយោបល់ឬគណៈកម្មាធិការ ដើម្បីធានាការចូលរួមពីអ្នកនៅមូលដ្ឋាន សម្រាប់ការសម្រេចចិត្តក្នុងការងារគ្រប់គ្រងដែលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន។

#### ៤.២.៣.៣ លើកកំពស់ការយល់ដឹង

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំកម្មវិធីសិក្ខាសាលា កិច្ចប្រជុំ និងវគ្គបណ្ដុះបណ្ដាលសម្រាប់សហគមន៍ ដើម្បីបង្កើនការយល់ដឹង ពីការចូលរួមដល់ជីវភាពសហគមន៍ពាក់ព័ន្ធការអភិរក្សជីវចម្រុះ ការគ្រប់គ្រងព្រៃឈើដោយមាននិរន្តភាព និង កម្មវិធីសហគមន៍ព្រៃឈើ ស្របតាមផែនការ និងគោលនយោបាយអភិវឌ្ឍព្រៃឈើជាតិ
- រៀបចំកម្មវិធីអប់រំបរិស្ថានដែលពន្យល់អំពីគោលបំណងនៃការបង្កើតព្រៃការពារព្រះវិហារ និង បញ្ចូលព័ត៌មាន ស្ដីពីផលប៉ះពាល់បរិស្ថានទៅលើការប្រើប្រាស់ធនធានព្រៃឈើហួសកម្រិត ព្រមទាំងសិទ្ធិនិងការទទួល ខុសត្រូវរបស់ប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- ពង្រឹងទំនាក់ទំនងការងារដែលផ្ដល់ប្រយោជន៍ទៅវិញទៅមក ដោយពង្រីកការផ្សព្វផ្សាយ ការផ្លាស់ប្ដូរព័ត៌មាន ជាមួយសហគមន៍មូលដ្ឋាន។

### ៤.២.៤ កម្មវិធីពង្រឹងកិច្ចសហការគ្រប់គ្រងតំបន់ការពារតាមបណ្ដោយព្រំដែន

កម្មវិធីពង្រឹងកិច្ចសហការគ្រប់គ្រងតំបន់ការពារតាមបណ្ដោយព្រំដែនមានអនុកម្មវិធីចំនួន២៖

#### ៤.២.៤.១ ការពង្រឹងកិច្ចសហការគ្រប់គ្រងតាមបណ្ដោយព្រំដែន

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រធានតំបន់ព្រៃការពារ មន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងតំបន់ក្នុងប្រទេសកម្ពុជា ថៃ និងឡាវ ដើម្បីទប់ស្កាត់បទល្មើសព្រៃឈើឆ្លងកាត់ព្រំដែន និងការជួញដូរសត្វព្រៃ ដោយប្រើប្រាស់ក្របខណ្ឌច្បាប់ជាតិ អនុសញ្ញាអន្តរជាតិដូចជា CITES ដើម្បីរៀបចំកម្មវិធីសកម្មភាព

- បង្កើតកម្មវិធីប្រតិបត្តិការគ្រប់គ្រងមានប្រសិទ្ធិភាព ដោយផ្អែកលើការសិក្សាស្រាវជ្រាវតាមព្រំដែននៅក្នុង ប្រទេសកម្ពុជា ថៃ និងឡាវ ដើម្បីរក្សា និងធ្វើអោយប្រសើរឡើងនូវស្ថានភាពសហគមន៍រុក្ខជាតិ និងចំនួន ប្រភេទសត្វសំខាន់ៗ
- ថែរក្សាច្រករបៀងធម្មជាតិដែលតភ្ជាប់តំបន់ទេសភាពជាប់ព្រំដែន និងធានាការបំលាស់ទីដោយគ្មានការរំខាន នូវប្រភេទសត្វព្រៃសំខាន់ៗដែលឆ្លងកាត់តំបន់ព្រៃការពារត្រីកោណមរកត។

### ៤.២.៤.២ បង្កើនការផ្លាស់ប្តូរព័ត៌មានការឆ្លងកាត់ព្រំដែននៅក្នុងការគាំទ្រការអភិរក្សធនធានធម្មជាតិ និងបរិស្ថាន

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ពង្រឹងបណ្តាញសិក្សាស្រាវជ្រាវដែលរៀបចំដោយសាកលវិទ្យាល័យរវាងប្រទេសកម្ពុជា ថៃ និងឡាវ
- ជម្រុញកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការគ្រប់គ្រង សម្រាប់អ្នកគ្រប់គ្រងធនធានធម្មជាតិតាមព្រំដែនដែលស្ថិត នៅជាប់តំបន់ការពារនៃប្រទេសថៃ និងឡាវ។

## ៤.២.៥ កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន

កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន មានអនុកម្មវិធីចំនួន៣ ដូចខាងក្រោម៖

### ៤.២.៥.១ ការពង្រឹងសមត្ថភាពស្ថាប័ន

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ជម្រុញអភិបាលកិច្ចល្អក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងធនធានព្រៃឈើក្នុងតំបន់ព្រៃការពារព្រះវិហារ
- រៀបចំលក្ខខណ្ឌការងារដែលច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រងធនធានព្រៃឈើដោយមាននិរន្តរភាពនៅ ក្នុងតំបន់ព្រៃការពារព្រះវិហារ។

### ៤.២.៥.២ ការអភិវឌ្ឍធនធានមនុស្ស

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពីការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានព្រៃឈើដោយមាន និរន្តភាព ដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងមន្ត្រីគម្រោងព្រៃការពារដែលប្រតិបត្តិការងារ ដើម្បីពង្រឹងសមត្ថភាព គ្រប់គ្រងធនធាន
- រៀបចំយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកកំពស់ការយល់ដឹងសាធារណៈអំពី សារៈសំខាន់នៃការអភិរក្សជីវចម្រុះ
- បង្កើតប្រព័ន្ធផ្តល់រង្វាន់លើកទឹកចិត្តមន្ត្រីរដ្ឋបាលព្រៃឈើ និងមន្ត្រីគម្រោងព្រៃការពារដែលមានស្នាដៃល្អក្នុង ការបំពេញការងារ
- រៀបចំកម្មវិធីអប់រំការអភិរក្ស ដូចជាជុំរុំអភិរក្សធម្មជាតិ សម្រាប់យុវសិស្សសាលាអនុវិទ្យាល័យ និងសាលា បឋមសិក្សា

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីការពង្រឹងការអនុវត្តច្បាប់ និងអនុសញ្ញាអន្តរជាតិ គាំទ្រការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងព្រៃឈើដោយមាននិរន្តភាព។

### ៤.២.៥.៣ បង្កើនកិច្ចសហប្រតិបត្តិការការងារផ្ទៃក្នុង

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- បង្កើតយន្តការដ៏មានប្រសិទ្ធិភាព ដើម្បីធ្វើអោយប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការការងារផ្ទៃក្នុងរវាង ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធនិងការអភិវឌ្ឍ តាមរយៈការអភិរក្សជីវចម្រុះក្នុងតំបន់ព្រៃ ការពារព្រះវិហារ
- បង្កើតប្រព័ន្ធទិន្នន័យអន្តរកម្ម ងាយស្រួលដល់អ្នកប្រើប្រាស់ ដែលផ្សាភ្ជាប់ជាមួយស្ថាប័នរដ្ឋ និងអង្គការផ្សេងៗ ដើម្បីសម្របសម្រួលការផ្លាស់ប្តូរព័ត៌មាន ពាក់ព័ន្ធនិងការគ្រប់គ្រងព្រៃការពារព្រះវិហារ។

## ៤.២.៦ កម្មវិធីតាមដានត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ

កម្មវិធីតាមដានត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ មានអនុកម្មវិធីចំនួន៤ ដូចខាងក្រោម៖

### ៤.២.៦.១ វាយតម្លៃការអនុវត្តការងារគ្រប់គ្រងពីការសិក្សាស្រាវជ្រាវកន្លងមក

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ពិនិត្យសារឡើងវិញនូវការសិក្សាស្រាវជ្រាវកន្លងនៅក្នុងតំបន់ព្រៃការពារព្រះវិហារ និងប្រាស់លទ្ធផលនៃការ វាយតម្លៃទាំងនោះ ដើម្បីពង្រឹងការគ្រប់គ្រងធនធាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ។

### ៤.២.៦.២ ពង្រីកការសិក្សាស្រាវជ្រាវស្តីពីសហគមន៍រុក្ខជាតិ និងសត្វព្រៃដែលមាននៅតំបន់ភូមិសាស្ត្រសំខាន់ៗ

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំអនុវត្តការសិក្សាស្រាវជ្រាវស្តីពីប្រភេទសត្វព្រៃដែលមាននៅតំបន់ភូមិសាស្ត្រសំខាន់ៗ រួមមានប្រភេទ កម្រ ជិតផុតពូជ ប្រភេទដែលមាននៅតែតំបន់ជាក់លាក់ណាមួយ ដើម្បីគាំទ្រការរៀបចំតាមលំដាប់នៃផែន ការគ្រប់គ្រងប្រភេទសត្វព្រៃជាក់លាក់
- រៀបចំកម្មវិធីសិក្សាស្រាវជ្រាវ ដើម្បីពិនិត្យទៅលើទំនាក់ទំនងនៃប្រព័ន្ធមជ្ឈដ្ឋាននៅក្នុងសហគមន៍រុក្ខជាតិ ក៏ដូចជាប្រភេទរុក្ខជាតិនីមួយៗ រួមមានប្រភេទអរគីដេដែលដើមកំណើតនៅក្នុងតំបន់ រុក្ខជាតិស៊ីសត្វល្អិត រុក្ខជាតិឱសថ ប្រភេទរុក្ខជាតិមានដោយកម្រ ជិតផុតពូជ និងមានវត្តមានតែនៅតំបន់ជាក់លាក់ណាមួយ ដើម្បីពង្រឹងការអនុវត្តការគ្រប់គ្រងនៃទំនាក់ទំនងរបស់ប្រភេទទាំងនោះ
- សិក្សាផលប៉ះពាល់នៃការលំហែរកំសាន្ត និងទេសចរណ៍ធម្មជាតិទៅលើតំបន់ធម្មជាតិ ជាពិសេសនៅក្នុង តំបន់ព្រៃការពារព្រះវិហារ នៅកន្លែងដែលមានសក្តានុពលអភិវឌ្ឍការលំហែរកំសាន្តនិងទេសចរណ៍ធម្មជាតិ
- រៀបចំអនុវត្តសិក្សាស្រាវជ្រាវផលប៉ះពាល់នៃប្រភេទឈ្លានពានទៅលើតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ។

### ៤.២.៦.៣ បង្កើនការសិក្សាអំពីធនធានដី និងធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារព្រះវិហារ

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- រៀបចំអនុវត្តការសិក្សាស្រាវជ្រាវតាមកំឡុងពេលផ្សេងៗអំពីស្ថានភាព និងបម្រែបម្រួលនៃកត្តាជម្រុញការ បាត់បង់ព្រៃឈើ និងភាពសឹករេចរឹលធនធានព្រៃឈើ ដែលប៉ះពាល់ទៅលើការផ្លាស់ប្តូរការប្រើប្រាស់ដីនៅ ក្នុងតំបន់ព្រៃការពារព្រះវិហារ
- រៀបចំវាយតម្លៃកាបូនស្តុក និងគម្រូនៃកំណើនមាឌឈើ ព្រមទាំងការអភិរក្សតំបន់ស្តុកទុកសេនេទិចឈើ ពាណិជ្ជកម្ម និងមិនមែនពាណិជ្ជកម្ម នៅក្នុងតំបន់ព្រៃការពារព្រះវិហារ
- វាយតម្លៃសេដ្ឋកិច្ចនៃផលិតផល និងសេវាកម្មប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិនៅក្នុងតំបន់ព្រៃការពារព្រះវិហារ
- រៀបចំការសិក្សារយៈពេលវែង ដើម្បីត្រួតពិនិត្យការចម្លងជម្ងឺរវាងសត្វចិញ្ចឹមក្នុងស្រុក និងសត្វព្រៃនៅក្នុង តំបន់ព្រៃការពារព្រះវិហារ។

### ៤.២.៦.៤ បង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន

មធ្យោបាយជាយុទ្ធសាស្ត្រនេះ នឹងរួមបញ្ចូលនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- ស្តីពីការវាយតម្លៃជាដំណាក់កាល ដើម្បីត្រួតពិនិត្យការប្រែប្រួល ចារិតលក្ខណៈផ្នែកសេដ្ឋកិច្ចសង្គមរបស់ សហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ
- រៀបចំសិក្សាស្រាវជ្រាវ ស្តីពីឥរិយាបថរបស់សហគមន៍មូលដ្ឋានចំពោះព្រៃការពារនិងជីវចម្រុះដោយប្រើ ប្រាស់លទ្ធផលទាំងនោះនៅក្នុងកម្មវិធីអប់រំបរិស្ថាន និងទំនាក់ទំនងសាធារណៈ។

# ជំពូកទី៥
# ផែនការសកម្មភាព និងគម្រោងថវិកាចំណាយ

## ផែនការសកម្មភាពតាមកម្មវិធីនីមួយៗសម្រាប់ប្រតិបត្តិឆ្នាំ២០១៦-២០២០

## តារាង ៥.១៖ កម្មវិធីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| **កាត់បន្ថយបទល្មើសព្រៃឈើ និងសត្វព្រៃ** | | | | | | | | | | |
| ១. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ មូលដ្ឋាន និងលើកទឹកចិត្តការចូលរួមរបស់ សហគមន៍មូលដ្ឋាន ក្នុង សកម្មភាពល្បាត និងការត្រួតពិនិត្យធនធានធម្មជាតិ ដើម្បីបញ្ឈប់សកម្មភាពល្មើសច្បាប់ព្រៃឈើ។ | ៥ | ៤៤ | ៤៤ | ៤៤ | ៤៤ | ៤៤ | FA, PV-CFA, Chhep and CK-DFA | Local authorities, DPs | RGC, Donors, DPs | ២២០ |
| ២. ពង្រីកការប្រើប្រាស់កម្មវិធី SMART ដើម្បីពង្រឹ ងការត្រួតពិនិត្យ ការរាយការណ៍បទល្មើស ព្រៃឈើ និង ការចាត់វិធានការឆ្លើយតបឆាប់ រហ័ស។ | ៤-៥ | ៥៥ | ៥៥ | ៤៤ | ៤៤ | ៤៤ | FA, PV-CFA, Chhep and CK-DFA | Local authorities, DPs | RGC, Donors, DPs | ២៤២ |
| ៣. បង្កើនសកម្មភាព និងវិសាលភាពល្បាតនៅ តំបន់ជម្រកសត្វព្រៃសំខាន់ៗ និងរឹតបន្តឹងការ ប្រើប្រាស់កាំភ្លើងខ្លី ដើម្បីទប់ស្កាត់សកម្មភាព ជួញដូរសត្វព្រៃ និងកាប់ឈើដោយខុសច្បាប់។ | ៤-៥ | ៣៨៥ | ៣៨៥ | ៣៨៥ | ៣៨៥ | ៣៨៥ | FA, PV-CFA, Chhep and CK-DFA | DPs | RGC, Donors, DPs | ១៩២៥ |
| ៤. ពង្រឹងយុទ្ធនាការប្រឆាំងការបរបាញ់ និងជួញ ដូរសត្វព្រៃដោយខុសច្បាប់ រួមទាំងការប្រើប្រាស់ សាច់សត្វ | ៤ | ៣៥ | ៣៥ | ៣៥ | ៣០ | ៣០ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ១៦៥ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| និងជម្រុញការ អប់រំផ្សព្វផ្សាយ បរិស្ថាន ដើម្បីលើកកំពស់ការយល់ដឹងជុំវិញ សកម្មភាពទាំងអស់នេះ។ | | | | | | | | | | |
| ពង្រឹងការអភិរក្ស និងការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃអោយមាននិរន្តភាព | | | | | | | | | | |
| ៥. បង្កើនសកម្មភាពប្រជុំទាំងផ្លូវការ និងក្រៅ ផ្លូវការ ជាមួយមន្ត្រីរដ្ឋាភិបាល ដើម្បីពង្រឹង ចំណង មិត្តភាព គាំទ្រខាងផ្នែកនយោបាយ សម្រាប់ពង្រឹងការអភិរក្សជីវចម្រុះក្នុងព្រៃ ការពារព្រះវិហារ។ | ៤ | ៣០ | ៣៤ | ៣៤ | ៣០ | ៣០ | FA | PS, Donors, DPs | RGC, Donors, PS, DPs | ១៥៨ |
| ៦. ពង្រឹងសមត្ថភាពមន្ត្រីល្បាត ដោយផ្តល់ និងបំពាក់ឧបករណ៍ និងសម្ភារ នៅស្នាក់កា រល្បាត និង បង្កើនចំនួនមន្ត្រីល្បាត។ | ៣-៤ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ១៥០ |
| ៧. ពង្រីការចូលរួមរបស់សហគមន៍មូលដ្ឋាន ពាក់ព័ន្ធសារៈសំខាន់នៃតំបន់ការពារជីវចម្រុះ សំខាន់ៗ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ | ៣-៤ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ២២៥ |
| ៨. គាំទ្រកិច្ចខិតខំដើម្បីសង្គ្រោះ និងបង្កាត់ពូជ ប្រភេទសត្វមានដោយកម្រនិងរងការគំរាម កំហែង និងលែងសត្វដែលបានសង្គ្រោះ និង បង្កាត់ពូជទាំងនោះទៅក្នុងព្រៃវិញ ព្រមទាំង ជម្រុញការគ្រប់គ្រងប្រភេទរុក្ខជាតិ តាមរូបភាព ដូចគ្នា ពិសេសការបង្កាត់ពូជពិសោធន៍ ប្រភេទរុក្ខជាតអរគីដេរព្រៃ។ | ២ | ១២ | ១២ | ១២ | ១២ | ១២ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ៦០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| **ថែរក្សាដែនជម្រកតំបន់ព្រៃឈើទាំងនៅក្នុង និងជុំវិញ តំបន់ព្រៃការពារព្រះវិហារ និងស្តារគុណភាពតំបន់ជម្រកសត្វព្រៃ** | | | | | | | | | | |
| ៩. រៀបចំបង្កើតច្រកចេញចូលតំបន់ព្រៃការពារ ព្រះវិហារ ដោយដាក់ព្រំប្រទល់ធ្វើពីស៊ីម៉ង់ត៍ ស្លាកសញ្ញាចរាចរណ៍ នៅក្នុងតំបន់ព្រៃការពារ។ | ៤ | ៨០ | ៨០ | ៨០ | ៤៤ | ៤៤ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ៣២៨ |
| ១០. ថែរក្សា និង/ឬធ្វើអោយប្រសើរឡើងនូវត្រពាំង ស្រះទឹកដែលមានទឹកតាមរដូវកាលដើម្បីការពារ សំបុកធម្មជាតិ និងកាត់បន្ថយផលប៉ះពាល់ពី ការប្រែប្រួលអាកាសធាតុទៅលើរបបធនធានទឹក សម្រាប់ផ្គត់ផ្គង់ជីវភាពសហគមន៍ និងផ្តល់ ជាជម្រក តាមរដូវកាលសម្រាប់សត្វស្លាបតំបន់ ដីសើម។ | ៤ | ៥៥ | ៥៥ | ៥៥ | ៥៥ | ៥៥ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ២៧៥ |
| ១១. ជម្រុញការដាំស្តារព្រៃឈើឡើងវិញក្នុងតំបន់ ព្រៃរេចរឹលសម្រាប់ប្រភេទឈើក្នុងតំបន់ដែល ផ្គត់ផ្គង់ ដោយថ្នាលបណ្តុះកូនឈើក្នុងតបន់ព្រៃ ការពារព្រះវិហារ។ | ៣ | ៥៥ | ៥៥ | ៣៤ | ៣៤ | ៣៤ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ២១២ |
| ១២. លើកទឹកចិត្តអោយមានការវិនិយោគជា លក្ខណៈគ្រួសារ និងសហគមន៍ ដើម្បីគាំទ្រ ចំការព្រៃឈើ និងការខិតខំស្តារព្រៃឈើ នៅក្នុងតំបន់ព្រៃរេចរឹល និងដីព្រៃដែល បានដកហូតពីការកាប់រាន។ | ៣ | ២២ | ២២ | ២២ | ២២ | ២២ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ១១០ |
| សរុប | | ៨៤៨ | ៨៥២ | ៨២០ | ៧៧៥ | ៧៧៥ | | | | ៤០៧០ |

## តារាង ៥.២៖ កម្មវិធីរៀបចំ និងគ្រប់គ្រងតំបន់លំហែកំសាន្តធម្មជាតិ និងទេសចរណ៍ធម្មជាតិ

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| **ជម្រុញប្រសិទ្ធិភាពនៃការគ្រប់គ្រងធនធានទេសចរណ៍ធម្មជាតិ និងសកម្មភាពទេសចរណ៍** | | | | | | | | | | |
| ១. ជម្រុញរៀបចំសហគមន៍ទេសចរណ៍ ដើម្បីគាំទ្រ ជម្រើសឱកាសអភិវឌ្ឍជីវភាពតាមរយៈការបង្កើត កម្មវិធីស្នាក់តាមផ្ទះ (homestays) ផ្ទះសំណាក់ ផ្ទះលំហែរធម្មជាតិ និងការបំពាក់បំប៉នចំណេះដឹង ផ្នែកវប្បធម៌ និងសេវាមគ្គុទេសក៍ ជាលក្ខណៈបុគ្គល ក្នុងកិច្ចសហការជាមួយសហគមន៍។ | ៤ | ៥៥ | ៦៥ | ៦៥ | ៦៥ | ៦៥ | FA, PV-CFA, Chhep and CK-DFA | Local authorities & communities, Donors, DPs, PS | RGC, Donors, PS, DPs | ៣០៥ |
| ២. បណ្តុះបណ្តាលជំនាញស្តីពីសហគមន៍ ទេសចរណ៍ធម្មជាតិ ដល់សហគមន៍មូលដ្ឋាន។ | ៤ | ២០ | ២០ | ១២ | ១២ | ១២ | FA, PV-CFA, Chhep and CK-DFA, DPs, PS | Local authorities & communities, DPs | RGC, Donors, PS, DPs | ៧៦ |
| ៣. បណ្តុះបណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើ និងបុគ្គលិក ព្រៃការពារស្តីពីការគ្រប់គ្រងសកម្មភាព និងធនធានទេសចរណ៍ធម្មជាតិ។ | ៤ | ២០ | ២០ | ១២ | ១២ | ១២ | FA, MoC | Local authorities, DPs | RGC, Donors, PS, DPs | ៧៦ |
| ៤. ការពារទីតាំងប្រាសាទបុរាណ និងវប្បធម៌ ដែលនៅរាយប៉ាយក្នុងតំបន់ព្រៃការពារ ព្រះវិហារ។ | ៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | FA, MoC | Local authorities, DPs | RGC, Donors, PS, DPs | ៧០ |
| ៥. រៀបចំកិច្ចព្រមព្រៀងជាមួយសហគមន៍មូលដ្ឋាន ដើម្បីពង្រឹងការគ្រប់គ្រងតំបន់លំហែរកំសាន្ត និង ទេសចរណ៍ធម្មជាតិ ដើម្បីកាត់បន្ថយផលប៉ះ ពាល់ទៅលើសត្វព្រៃ ធនធានធម្មជាតិផ្សេងទៀត និងជីវចម្រុះ។ | ៤ | ៥ | ៥ | ៥ | ៥ | ៥ | FA, PV-CFA, Chhep and CK-DFA | Local authorities, DPS | RGC, Donors, DPs | ២៥ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| **ពង្រីកទីផ្សារទេសចរណ៍ធម្មជាតិ** | | | | | | | | | | |
| ៦. អភិវឌ្ឍបណ្តាញទីផ្សារសម្រាប់សកម្មភាពលំហែរ កំសាន្តធម្មជាតិ និងទេសចរណ៍ដែលមិនមាន ការរំខាន ដើម្បីឆ្លើយតបតម្រូវការចង់បានរបស់ ភ្ញៀវទេសចរ។ | ៣ | ២២ | ៣០ | ៣០ | ៣០ | ២២ | FA, MoC | Local authorities, DPs | RGC, Donors, PS, DPs | ១៣៤ |
| ៧. សហការជាមួយមន្ទីរទេសចរខេត្ត និងអាជ្ញាធរ មូលដ្ឋានដើម្បីលើកកំពស់ការយល់សាធារណៈ អំពី ទីតាំងគោលដៅទេសចរសំខាន់ៗក្នុងតំបន់ ព្រៃការពារព្រះវិហារ។ | ៣ | ១២ | ១២ | ១២ | ១២ | ១២ | FA, MoC | Local authorities, DPs | RGC, Donors, PS, DPs | ៦០ |
| **ពង្រឹងសេវាកម្ម និងកម្មវិធីមគ្គុទេសក៍ទេសចរណ៍** | | | | | | | | | | |
| ៨. ប្រមូលសម្ភារពាក់ព័ន្ធស្តីពីចំណេះដឹងវប្បធម៌ និង ប្រពៃពីក្នុងតំបន់សម្រាប់ប្រើក្នុងកម្មវិធីមគ្គុទេសក៍ | ៣ | ៥ | ១០ | ៥ | ៥ | ៥ | FA, MoC | Local authorities, DPs | RGC, Donors, PS, DPs | ៣០ |
| ៩. ពង្រឹងកម្មវិធីមគ្គុទេសក៍ទេសចរណ៍ ដើម្បីពង្រីក បទពិសោធន៍ធ្វើទេសចររបស់ភ្ញៀវ ក៏ដូចជាការ យល់ដឹង និង ការគុណតម្លៃនៃធនធានធម្មជាតិ និង វប្បធម៌ដោយការពន្យល់បកស្រាយនៅនឹង កន្លែង តាមរយៈការដាក់ផ្ទាំង និងស្លាកសញ្ញា បង្ហាញ ព័ត៌មានទេសចរណ៍ មជ្ឈមណ្ឌលភ្ញៀវ ទេសចរ តំបន់ទេសភាពសម្រាប់មើលសត្វព្រៃ និងផ្លូវដើរ តាមចំរាក់ភ្នំ ផ្លូវទស្សនាមានតាំងពិពណ៌សត្វ ក៏ដូចជាក្រដាស់និងសៀវភៅ ព័ត៌មានណែនាំសង្ខេប អំពីតំបន់ទេសចរណ៍។ | ៣ | ១០ | ១២ | ១២ | ១០ | ១០ | FA, MoC | Local authorities, DPs | RGC, Donors, PS, DPs | ៥៤ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| ១០. ជម្រុញបង្កើតសកម្មភាពទស្សនាសត្វព្រៃនៅតំបន់ ទីតាំងទេសចរណ៍ក្នុងតំបន់ព្រៃការពារព្រះវិហារ ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍ ទេសចរណ៍ធម្មជាតិ។ | ៣ | ១២ | ១៤ | ១៤ | ១២ | ១២ | FA, MoT | Local authorities, DPs | RGC, Donors, PS, DPs | ៦៤ |
| ១១. ជម្រុញបង្កើតការដើរកំសាន្តក្នុងតំបន់ព្រៃ ដែលផ្តល់ ជាមធ្យោបាយលើកកំពស់ជីវភាព សហគមន៍ មូលដ្ឋាន ដោយអភិវឌ្ឍ និងកែលំអ ផ្លូវដើរក្នុងព្រៃ ព្រមទាំងសហការជាមួយសហគមន៍ មូលដ្ឋាន ដើម្បីទប់ស្កាត់ការចិញ្ចឹមសត្វនៅក្នុង តំបន់ដែល កំណត់សម្រាប់ការដើរកំសាន្តពង្រីក បទពិសោធន៍ទេសចរធម្មជាតិ។ | ៣ | ១០ | ១២ | ១២ | ១២ | ១០ | FA, MoT | Local authorities, DPs | RGC, Donors, PS, DPs | ៥៦ |
| ១២. ផ្តល់ព័ត៌មានពាក់ព័ន្ធដល់ប្រតិបត្តិករទេសចរណ៍ និងងភ្ញៀវទេសចរស្តីពីផលប៉ះពាល់ពីសកម្មភាព ទេសចរទៅលើការអភិរក្សជីវចម្រុះ។ | ៣ | ៥ | ៥ | ៥ | ៥ | ៥ | FA, MoT | Local authorities, DPs | RGC, Donors, PS, DPs | ២៥ |
| សរុប | | ១៩៥ | ២១៩ | ១៩៨ | ១៩៤ | ១៧៤ | | | | ៩៧៥ |

*Agencies and Organizations: *CFA= Cantonment Forestry Administration; CK= Choam Ksan; DFA= Division Forestry Administration; FA=Forestry Administration; JICA=Japanese International Cooperation Agency; DPs=Development Partners; PS=Private Sector; PV= Preah Vihear; RIs=Research Institutes; RGC= Royal Government of Cambodia; RUA=Royal University of Agriculture.*

## តារាង ៥.៣៖ កម្មវិធីសមាហរណកម្មការអភិវឌ្ឍសហគមន៍ និងការចូលរួម

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| **កាត់បន្ថយការពឹងអាស្រ័យលើធនធានធម្មជាតិ** | | | | | | | | | | |
| ១. ជម្រុញការអនុវត្តកសិ-រុក្ខកម្ម និងកសិកម្មដោយ មាននិរន្តភាពនៅក្នុងតំបន់កសិកម្មថ្នាក់ឃុំដែល បានកំណត់តាមរយៈការបង្កើតឡូតិ៍បង្ហាញ និងផ្តល់អោយសហគមន៍នូវសម្ភារ និងការបណ្តុះ បណ្តាល ដើម្បីអនុវត្តលើកកំពស់ជីវភាព។ | ៥ | ៣៥ | ៤០ | ៤០ | ៤០ | ៤០ | FA, PV-CFA, Chhep and CK-DFA | DPs, local authorities & communities | RGC, Donors, DPs | ១៩៥ |
| ២. សហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការមិន មែន រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើត សហគ្រាសសហគមន៍ បង្កើនប្រភពចំណូល សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងផ្តល់វគ្គ បណ្តុះបណ្តាលដើម្បីបង្កើនការចូលរួម និងកម្ម វិធីអភិវឌ្ឍន៍ ដោយមាននិរន្តភាព។ | ៤ | ២០ | ២០ | ២០ | ២០ | ២០ | FA, PV-CFA, Chhep and CK-DFA, DPs, PS | DPs, local authorities & communities | RGC, Donor, PS, DPs | ១០០ |
| ៣. លើកទឹកចិត្តការដាំដើមឈើ និងប្រភេទរុក្ខជាតិ ផ្សេងទៀតដែលគាំទ្រជីវភាពសហគមន៍ ជាពិសេសឫស្សី និងការដាំប្រភេទរុក្ខជាតិដែល អាចហូបបាន ដូចជា ផ្សិត ដើម្បីកាត់បន្ថយការ ប្រើប្រាស់រុក្ខជាតិព្រៃ ដោយគ្មានកំណត់របស់ សហគមន៍។ | ៤ | ២២ | ៣៤ | ៣៤ | ៣៤ | ៣៤ | FA, PV-CFA, Chhep and CK-DFA, DPs, PDA | DPs, local authorities & communities, PS | RGC, Donors, PS, DPs | ១៥៨ |
| ៤. បង្កើត និងអនុវត្តបទបញ្ញត្តដើម្បីត្រួតពិនិត្យការប្រើប្រាស់អនុផលព្រៃឈើ ជួគាំទ្រការអភិវឌ្ឍជីវភាព សហគមន៍ដោយចីរភាព និងបង្កើនចំណូល ទន្ទឹមនិងការថែ | ៣ | ២០ | ២០ | ២០ | ២០ | ២០ | FA, PV-CFA, Chhep and CK-DFA, DPs | DPs, local authorities & communities, CP | RGC, Donors, DPs | ១០០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី៤ | ឆ្នាំទី ៥ | | | | |
| រក្សាធនធានធម្មជាតិក្នុងតំបន់ ព្រៃការពារព្រះវិហារ។ | | | | | | | | | | |
| **បង្កើនការចូលរួមរបស់សហគមន៍ក្នុងការងារគ្រប់គ្រង** | | | | | | | | | | |
| ៥. គាំទ្រការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើ សហគមន៍នៅក្នុង និងជុំវិញព្រៃការពារព្រះវិហារ ដើម្បីកាត់បន្ថយការប្រើប្រាស់ធនធានព្រៃឈើ ដែលពុំមាននិរន្តភាព។ | ៥ | ២៤ | ២៤ | ២៤ | ២៤ | ២៤ | FA, PV-CFA, Chhep and CK-DFA, DPs | CP, local authorities & communities, DPs, PS | RGC, Donors, DPs | ១២០ |
| ៦. បង្កើតក្រុមប្រឹក្សាយោបល់ ឬគណកម្មាធិការ ដើម្បីធានាការចូលរួមពីអ្នកនៅមូលដ្ឋាន សម្រាប់ ការសម្រេចចិត្តក្នុង ការងារគ្រប់គ្រងដែល ជះឥទ្ធិពលដល់សហគមន៍មូលដ្ឋាន។ | ៤ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA, DPs | CP, local authorities & communities DPs, PS | RGC, Donors, DPs | ៥០ |
| **លើកកំពស់ការយល់ដឹង** | | | | | | | | | | |
| ៧. រៀបចំសិក្ខាសាលា កិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនការយល់ដឹងក្នុងចំណោមសហគមន៍ ស្តីពីការរួមចំណែករបស់ការលើកកម្ពស់ជីវភាព សហគមន៍មូលដ្ឋានពាក់ព័ន្ធនឹង ការគ្រប់គ្រង ព្រៃឈើដោយមាននិរន្តភាព ការអភិរក្សជីវចម្រុះ និងកម្មវិធីសហគមន៍ព្រៃឈើ។ | ៥ | ១០ | ១៥ | ១៥ | ១០ | ១២ | FA, PV-CFA, Chhep and CK-DFA, DPs | CP, local authorities & communities, DPs, PS | RGC, Donors, DPs | ៦៧ |
| ៨. រៀបចំកម្មវិធីអប់រំបរិស្ថាន ដែលពន្យល់ពី គោលបំណងនៃការបង្កើតព្រៃការពារព្រះវិហារ និងរួមបញ្ចូលព័ត៌មានស្តីពីផលប៉ះពាល់បរិស្ថាន ពីការប្រើប្រាស់ធនធានព្រៃឈើហួសកម្រិត សិទ្ធិ និងការទទួលខុសត្រូវរបស់ ប្រជា | ៤ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA, DPs | CP, local authorities & communities, DPs, PS | RGC, Donors, DPs | ៥០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| ជនមូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ | | | | | | | | | | |
| ៩. ពង្រឹងទំនាក់ទំនងការងារដែលផ្តល់ប្រយោជន៍ ទៅវិញទៅមក តាមរយៈការពង្រីកកម្មវិធី ផ្សព្វផ្សាយ និងការផ្លាស់ប្តូរព័ត៌មានជាមួយ សហគមន៍មូលដ្ឋាន។ | ៤ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA, DPs | CP, local authorities & communities, DPs, PS | RGC, Donors, DPs | ៥០ |
| សរុប | | ១៦១ | ១៨៣ | ១៨៣ | ១៨៣ | ១៨០ | | | | ៨៩០ |

## តារាង ៥.៤៖ កម្មវិធីពង្រឹងកិច្ចសហការគ្រប់គ្រងតំបន់ការពារតាមបណ្តោយព្រំដែន

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| **ការពង្រឹងកិច្ចសហការគ្រប់គ្រងតាមបណ្តោយព្រំដែន** | | | | | | | | | | |
| ១. បង្កើនការរៀបចំកិច្ចប្រជុំសហប្រតិបត្តិការ ទ្វេរភាគីតាមព្រំដែន និងរៀបចំយន្តការផ្សេង ទៀត ដើម្បីពង្រឹងការអនុវត្តច្បាប់ ទប់ស្កាត់បទ ល្មើស ព្រៃឈើឆ្លងកាត់ព្រំដែន ជាពិសេសតំបន់ ដែលមានហនិភ័យខ្ពស់ នៅក្នុង និងជុំវិញព្រៃ ការពារព្រះវិហារ និងជាប់ជាមួយ តំបន់ព្រៃ ការពារខាងភាគីថៃ និងឡាវ។ | ៤-៥ | ២២ | ២៤ | ២៤ | ២៥ | ២៥ | FA, PV-CFA, Chhep and CK-DFA | Local authorities & communities, DPs | RGC, Donors, DPs | ១២០ |
| ២. បង្កើតកម្មវិធីប្រតិបត្តិការគ្រប់គ្រងមាន ប្រសិទ្ធិភាព ដោយផ្អែកលើលទ្ធផលសិក្សាស្រាវ ជ្រាវតាមព្រំដែន ដែលអនុវត្តនៅក្នុងប្រទេស កម្ពុជា ថៃ និងឡាវ ដើម្បីរក្សា និងធ្វើ អោយ ប្រសើរ | ៣-៤ | ១៥ | ២០ | ២០ | ២០ | ១៥ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ៩០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | | | | |
| ឡើងនូវស្ថានភាពសហគមន៍រុក្ខជាតិ និងចំនួនប្រភេទសត្វសំខាន់ៗ។ | | | | | | | | | | |
| ៣. សហការជាមួយអ្នកគ្រប់គ្រងតំបន់ព្រៃការពារ ភាគីថៃ និងឡាវ ថែរក្សាច្រកបំលាស់ទីដែលបាន បង្កើតឡើង និងធ្វើអោយប្រសើរឡើងនូវភាព តភ្ជាប់ច្រករបៀងធម្មជាតិធម្មជាតិ ដើម្បីសម្រួលដល់ការបំលាស់ទីដោយគ្មានការរំខានដល់ ប្រភេទសត្វព្រៃសំខាន់ៗ នៅពាសពេញតំបន់ ព្រៃការពារត្រីកោណមរកត។ | ៣-៤ | ១៥ | ២០ | ២៥ | ២៥ | ២០ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ១០៥ |
| **ការពង្រីកការផ្លាស់ប្តូរព័ត៌មានការឆ្លងកាត់ព្រំដែននៅក្នុងការគាំទ្រការអភិរក្សធនធានធម្មជាតិ និងបរិស្ថាន** | | | | | | | | | | |
| ៤. បង្កើនសកម្មភាពសិក្សាស្រាវជ្រាវរួមគ្នា និងកិច្ចព្រមព្រៀង សហប្រតិបត្តិការសិក្សា ស្រាវជ្រាវ ជាមួយនិងនាយកដ្ឋានគ្រប់គ្រងធនធាន និងព្រៃឈើ រួមទាំងសាកលវិទ្យាល័យ នៅប្រទេសថៃ កម្ពុជា និងឡាវ។ | ៥ | ២៥ | ២៥ | ៣៥ | ៣៥ | ៣៥ | FA | RUA, RIs, DPs | RGC, Donors, DPs | ១៥៥ |
| ៥. ជម្រុញកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ការគ្រប់គ្រង សម្រាប់អ្នកគ្រប់គ្រងធនធានធម្មជាតិតាមព្រំដែន ដែលស្ថិតនៅជាប់តំបន់ការពារនៃប្រទេសថៃ និងឡាវ។ | ៣ | ២០ | ២០ | ២៥ | ២៥ | ២៥ | MAFF, FA | PS, Donors, DPs | RGC, Donors, PS, DPs | ១៥៥ |
| សរុប | | ៩៧ | ១០៩ | ១២៩ | ១៣០ | ១២០ | | | | ៥៨៥ |

*Agencies and Organizations: *CFA= Cantonment Forestry Administration; CK= Choam Ksan; DFA= Division Forestry Administration; FA=Forestry Administration; JICA=Japanese International Cooperation Agency; DPs=Development Partners; PS=Private Sector; PV= Preah Vihear; RIs=Research Institutes; RGC= Royal Government of Cambodia; RUA=Royal University of Agriculture.*

## តារាង ៥.៥៖ កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | | | | |
| **ការពង្រឹងសមត្ថភាពស្ថាប័ន** | | | | | | | | | | |
| ១. ជម្រុញអភិបាលកិច្ចក្នុងការអនុវត្តកម្មវិធី គ្រប់គ្រងធនធានព្រៃឈើ ក្នុងតំបន់ព្រៃ ការពារព្រះវិហារ។ | ៥ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | CP, RUA, RIs, DPs, PS | RGC, Donors, PS, DPs | ៥០ |
| ២. រៀបចំសកម្មភាពការងារដែលប្រពលភាព ទាមទារដើម្បីធានាការ គ្រប់គ្រងធនធានព្រៃ ឈើ ដោយមាននិរន្តរភាព នៅក្នុងតំបន់ ព្រៃការពារព្រះវិហារ។ | ៤ | ៥ | ៥ | ៥ | ៥ | ៥ | FA, PV-CFA, Chhep and CK-DFA | MAFF, CP, RUA, RIs, DPs | RGC, Donors, PS | ២៥ |
| **ការអភិវឌ្ឍធនធានមនុស្ស** | | | | | | | | | | |
| ៣. ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពីការ អភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានព្រៃ ឈើដោយមាននិរន្តភាព ដល់មន្ត្រីរដ្ឋបាល ព្រៃឈើ និងមន្ត្រី គម្រោងព្រៃការពារ កម្រិតអ្នកប្រតិបត្តិការងារ ដើម្បីពង្រឹង សមត្ថភាពគ្រប់គ្រងធនធាន។ | ៣ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | FA, PV-CFA, Chhep and CK-DFA | RUA, RIs, DPs | RGC, Donors, DPs | ១២៥ |
| ៤. រៀបចំយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធ ផ្សព្វផ្សាយ ព័ត៌មានដើម្បីលើកកំពស់ ការយល់ដឹងសាធារណៈ អំពីសារៈសំខាន់នៃការអភិរក្សជីវចម្រុះ។ | ៣ | ២០ | ២០ | ២០ | ២០ | ២០ | FA, PV-CFA, Chhep and CK-DFA | JICA, PDA, RUA, RIs, DPs | DPs, Donors, DPs | ១០០ |
| ៥. បង្កើតប្រព័ន្ធផ្តល់រង្វាន់លើកទឹកចិត្តមន្ត្រី រដ្ឋបាល ព្រៃឈើ និងមន្ត្រីគម្រោងព្រៃ ការពារ ដែលមានស្នាដៃការងារ។ | ៣ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | MoT, MoE, PDA, RUA, JICA, RIs, DPs | DPs, Donors, DPs | ៥០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | | | | |
| ៦. រៀបចំកម្មវិធីអប់រំអភិរក្ស ដូចជាជុំរុំអភិរក្ស ធម្មជាតិ សម្រាប់យុវសិស្សសាលា អនុវិទ្យាល័យ និងសាលាបឋមសិក្សា។ | ២ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA, DPs | PS, local authorities & communities, DPs, PS, CP | RGC, Donors, PS, DPs | ៥០ |
| ៧. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយ អ្នកពាក់ព័ន្ធស្ដីពីការពង្រឹងការអនុវត្តច្បាប់ និងអនុសញ្ញាអន្តរជាតិគាំទ្រការអភិរក្សជីវ ចម្រុះ និងការគ្រប់គ្រង ព្រៃឈើដោយមាន និរន្តភាព។ | ២ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA, DPs | PS, local authorities & communities, DPs, PS, CP | RGC, Donors, PS, DPs | ៥០ |
| **បង្កើនកិច្ចសហប្រតិបត្តិការការងារផ្ទៃក្នុង** | | | | | | | | | | |
| ៨. បង្កើតយន្តការដ៏មានប្រសិទ្ធិភាពសម្រាប់ធ្វើ អោយ ប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការ ការងារផ្ទៃក្នុង រវាងស្ថាប័នរដ្ឋ និងមិនមែន រដ្ឋាភិបាលដែលពាក់ ព័ន្ធនិងការអភិរក្ស ជីវចម្រុះ។ | ៣ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep CK-DFA DPs | PS, local authorities & communities, DPs, CP | RGC, Donors, PS, DPs | ៥០ |
| ៩. បង្កើតប្រព័ន្ធទិន្នន័យអន្តរកម្ម ដែលតភ្ជាប់ ជាមួយស្ថាប័នរដ្ឋ និងអង្គការផ្សេងៗពាក់ព័ន្ធ និងការ គ្រប់គ្រងព្រៃការពារព្រះវិហារ ដើម្បីសម្រប សម្រួលការផ្លាស់ប្តូរព័ត៌មាន។ | ៣ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep CK-DFA DPs | PS, local authorities & communities, DPs, CP | RGC, Donors, PS, DPs | ៥០ |
| សរុប | | ១១០ | ១១០ | ១១០ | ១១០ | ១១០ | | | | 550 |

## តារាង ៥.៦៖ កម្មវិធីតាមដានត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវ

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | | | | |
| **វាយតម្លៃការអនុវត្តការងារគ្រប់គ្រងពីការសិក្សាស្រាវជ្រាវកន្លងមក** | | | | | | | | | | |
| ១. ពិនិត្យសារឡើងវិញនូវការសិក្សាស្រាវជ្រាវកន្លងមក នៅក្នុងតំបន់ព្រៃការពារព្រះវិហារ និងប្រើប្រាស់ លទ្ធផលនៃការវាយតម្លៃទាំងនោះ ដើម្បីពង្រឹង ការគ្រប់គ្រងធនធានធម្មជាតិ ដោយមាននិរន្តភាព។ | ៥ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | DPs, JICA, DAD, RUA, RIs, DTM | RGC, Donors, PS, DPs | ៥០ |
| **ពង្រីកការសិក្សាស្រាវជ្រាវស្តីពីសហគមន៍រុក្ខជាតិ និងសត្វព្រៃដែលមាននៅតំបន់ភូមិសាស្ត្រសំខាន់ៗ** | | | | | | | | | | |
| ២. រៀបចំអនុវត្តការសិក្សាស្រាវជ្រាវស្តីពីជម្រក ប្រព័ន្ធម្ជ្ឈដ្ឋាន និងរបាយនៃប្រភេទសត្វព្រៃដែល មាននៅតំបន់ភូមិសាស្ត្រសំខាន់ៗ រួមមានប្រភេទ កម្រ ជិតផុតពូជ និងប្រភេទដែល មាននៅតែតំបន់ ជាក់លាក់ណាមួយ ដើម្បីគាំទ្រការរៀបចំផែនការ គ្រប់គ្រងតាមប្រភេទសត្វព្រៃជាក់លាក់។ | ៥ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | FA | RUA, RIs, DPs | RGC, Donors, DPs | ១៥០ |
| ៣. រៀបចំកម្មវិធីសិក្សាស្រាវជ្រាវ ដើម្បីពិនិត្យទៅលើ ទំនាក់ទំនង នៃប្រព័ន្ធមជ្ឈដ្ឋាននៅក្នុងសហគមន៍ រុក្ខជាតិ ក៏ដូចជាប្រភេទរុក្ខជាតិនីមួយៗ រួមមាន ប្រភេទអរគីដេដែលមានដើមកំណើតនៅក្នុងតំបន់ រុក្ខជាតិស៊ីសត្វល្អិត រុក្ខជាតិឱសថ ប្រភេទរុក្ខជាតិ មានដោយកម្រ ជិតផុតពូជ និងមានវត្តមាន តែនៅ តំបន់ជាក់លាក់ណាមួយ ដើម្បីពង្រឹងការអនុវត្តការ គ្រប់គ្រងនៃទំនាក់ទំនងរបស់ប្រភេទ | ៤ | ១០ | ១០ | ១០ | ១០ | ១០ | FA | RUA, RIs, DPs | RGC, Donors, DPs | ៥០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | | | | |
| ទាំងនោះ។ | | | | | | | | | | |
| ៤. សិក្សាផលប៉ះពាល់នៃការលំហែរកំសាន្ត និងទេសចរណ៍ធម្មជាតិទៅលើតំបន់ធម្មជាតិ ជាពិសេសនៅក្នុងតំបន់ព្រៃការពារព្រះវិហារ នៅកន្លែងដែលមានសក្តានុពលអភិវឌ្ឍការលំហែរកំសាន្តនិងទេសចរណ៍ធម្មជាតិ។ | ៤ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៥០ |
| ៥. រៀបចំអនុវត្តសិក្សាស្រាវជ្រាវផលប៉ះពាល់នៃ ប្រភេទឈ្លានពានទៅលើតំបន់ព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ | ៣ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៥០ |
| **បង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន** | | | | | | | | | | |
| ៦. រៀបចំអនុវត្តការសិក្សាស្រាវជ្រាវតាមកំឡុងពេល ផ្សេងៗ អំពីស្ថានភាព និងបម្រែបម្រួលនៃកត្តា ជម្រុញការបាត់បង់ព្រៃឈើ និងភាពសឹករេចរឹល ធនធានព្រៃឈើដែលប៉ះពាល់ ទៅលើការផ្លាស់ ប្តូរការប្រើប្រាស់ដីនៅក្នុងតំបន់ព្រៃការពារព្រះវិហារ និងរួមបញ្ចូលលទ្ធផលនៃការវាយតម្លៃទាំងនោះ ទៅក្នុងគម្រូវដែលប្រើប្រាស់ដើម្បីព្យាករណ៍ការប្រែប្រួល ការប្រើប្រាស់ដី។ | ៤ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, DPs | ៥០ |
| ៧. រៀបចំវាយតម្លៃកាបូនស្តុក និងគម្រូនៃកំណើន មាឌឈើពាណិជ្ជកម្ម ព្រមទាំងការអភិរក្សតំបន់ ស្តុកទុកសេនេទិចឈើពាណិជ្ជកម្ម និងមិនមែន ពាណិជ្ជកម្ម នៅក្នុងតំបន់ | ៤ | ២៥ | ២៥ | ២៥ | ២៥ | ២៥ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ១២៥ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | | | | |
| ព្រៃការពារព្រះវិហារ។ | | | | | | | | | | |
| ៨. រៀបចំផែនការសិក្សាស្រាវជ្រាវស្តីពីការវាយតម្លៃ សេដ្ឋកិច្ច នៃផលិតផល និងសេវាកម្មប្រព័ន្ធ មជ្ឈដ្ឋានតំបន់ព្រៃនៅក្នុងតំបន់ព្រៃការពារ ព្រះវិហារ។ | ៤ | ១០ | ១៥ | ១៥ | ១៥ | ១០ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៦៥ |
| ៩. រៀបចំ និងត្រួតពិនិត្យផែនការសិក្សាស្រាវជ្រាវ រយៈពេលវែង ស្តីពីការចម្លងជម្ងឺសត្វ រវាងសត្វ ចិញ្ចឹម និងសត្វព្រៃនៅ ក្នុងតំបន់ព្រៃការពារ ព្រះវិហារ។ | ៣ | ១៥ | ១៥ | ២០ | ១៥ | ១៥ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៨០ |
| ១០. រៀបចំ និងត្រួតពិនិត្យផែនការសិក្សាស្រាវជ្រាវ រយៈពេលវែង ដើម្បីត្រួតពិនិត្យសារៈសំខាន់នៃ ត្រពាំងមានទឹកតាមរដូវកាល ចំពោះសត្វចិញ្ចឹម និងសត្វព្រៃក្នុងតំបន់ព្រៃការពារព្រះវិហារ។ | | ១៤ | ១៤ | ១៤ | ១៤ | ១៤ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៧០ |
| **ពង្រីកការសិក្សាធនធានដី និងធនធានធម្មជាតិនៅក្នុង តំបន់ព្រៃការពារព្រះវិហារ** | | | | | | | | | | |
| ១១. រៀបចំការសិក្សាស្រាវជ្រាវជាដំណាក់កាល ដើម្បី ពិនិត្យការប្រែប្រួល ចារឹតលក្ខណៈផ្នែកសេដ្ឋកិច្ច សង្គម របស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ។ | ៤ | ១២ | ១២ | ១២ | ១២ | ១២ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៦០ |
| ១២. រៀបចំសិក្សាស្រាវជ្រាវជាដំណាក់កាលស្តីពី ឥរិយាបថរបស់សហគមន៍ មូលដ្ឋានចំពោះ តំបន់ព្រៃការពារ ការអភិរក្សធនធានធម្មជាតិ ជីវចម្រុះនិងការប្រើប្រាស់ លទ្ធ | ៣ | ១០ | ១០ | ១០ | ១០ | ១០ | FA, PV-CFA, Chhep and CK-DFA | Donors, JICA, DPs, RUA, RIs | RGC, Donors, PS, DPs | ៥០ |

| គម្រោង ឬសកម្មភាពគ្រប់គ្រង | អាទិភាព | ឆ្នាំប្រតិបត្តិ | | | | | ភ្នាក់ងារប្រតិបត្តិ | ស្ថាប័នគាំទ្រ | ប្រភពថវិកា | ថវិកា (លានរៀល) |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ | | | | |
| ផលទាំងនោះនៅ ក្នុងកម្មវិធីអប់រំបរិស្ថាន និងផ្សព្វផ្សាយជា សាធារណៈ។ | | | | | | | | | | |
| សរុប | | ១៦៦ | ១៧១ | ១៧៦ | ១៧១ | ១៦៦ | | | | ៨៥០ |

*Agencies and Organizations: *CFA= Cantonment Forestry Administration; CK= Choam Ksan; DFA= Division Forestry Administration; FA=Forestry Administration; JICA=Japanese International Cooperation Agency; DPs=Development Partners; PS=Private Sector; PV= Preah Vihear; RIs=Research Institutes; RGC= Royal Government of Cambodia; RUA=Royal University of Agriculture.*

# ជំពូកទី ៦
# សន្និដ្ឋាន

តំបន់ព្រៃការពារព្រះវិហារ ស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា និងជាតំបន់សំបូរជីវចម្រុះសំខាន់នៃតំបន់ឥណ្ឌូចិន-ភូមា (Indo-Burma Hotspot)។ ព្រៃឈើ និងធនធានព្រៃឈើនៃតំបន់ព្រៃការពារ ព្រះវិហារ នៅតែមានសារសំខាន់ចំពោះសង្គម និងសេដ្ឋកិច្ចជាតិ ព្រមទាំងជួយកាត់បន្ថយផលប៉ះពាល់ការ ប្រែប្រួលអាកាសធាតុ មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងតំបន់ផងដែរ។

ធនធានព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ មានសមត្ថភាពផ្តល់អុសធ្យូង ឈើសំណង់ និងការប្រើប្រាស់ផ្សេងៗ ទៀតនៅក្នុងខេត្តព្រះវិហារ និងខេត្តជិតខាងផ្សេងទៀត ប្រសិនបើការប្រើប្រាស់ធនធានទាំងនេះមានលក្ខណៈនិរន្តភាព និងអនុលោមទៅតាមច្បាប់ស្តីពីព្រៃឈើ។

ផែនការគ្រប់គ្រងដែលបានធ្វើបច្ចុប្បន្នកម្មនេះ បានពិពណ៌នាពិស្តារអំពីគោលបំណង ការចាត់ថ្នាក់តំបន់ សកម្មភាពសំខាន់ៗ និង គម្រោងចំណាយថវិកាសំរាប់អភិរក្ស ថែរក្សាធនធានជីវចម្រុះ និងព្រៃឈើតំបន់ព្រៃការពារព្រះវិហារ។ អន្តរាគមន៍បន្ទាន់រួមមានតម្រូវចាំបាច់នូវវិធានការគ្រប់គ្រងសមស្រប ដើម្បីការពារ ថែរក្សាជីវចម្រុះ និងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ព្រមទាំងការអនុវត្តផែនការគ្រប់គ្រងនេះ។

តម្រូវការថវិកាជាមូលដ្ឋានសំរាប់ដំណើរការគ្រប់គ្រងតំបន់ព្រៃការពារព្រះវិហារ មានចំនួន **៧.៧៤៦ លានរៀល** ស្មើនឹង **១.៩៣៦.៥០០ ដុល្លាសហរដ្ឋអាមេរិក**សំរាប់រយៈពេល **០៥ឆ្នាំ**។ ការអនុវត្តសកម្មភាពផែនការគ្រប់គ្រងនេះ អាចផ្តល់អត្ថប្រយោជន៍ដូចខាងក្រោមៈ

- ផ្តល់ការងារដល់ប្រជាពលរដ្ឋក្នុងតំបន់ប្រហែលជា ២០០ នាក់ និងផលប្រយោជន៍ដូចជាការបណ្តុះបណ្តាលបច្ចេកទេសដល់ប្រជាសហគមន៍ដែលរស់ក្នុងព្រៃការពារព្រះវិហារ
- អាចរកចំណូលបានប្រមាណ ១,២៥លានដុល្លាសហរដ្ឋអាមេរិក សំរាប់ធ្វើឱ្យប្រសើរឡើងដល់ជីវភាពរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចក្នុងតំបន់
- មជ្ឈមណ្ឌលស្រាវជ្រាវព្រៃឈើ និងសត្វព្រៃដែលបំពាក់សម្ភារៈសំរាប់គាំទ្រដល់សកម្មភាពអង្កេត និងស្រាវជ្រាវ
- អាចជួយការពារព្រៃបម្រុងទុកអចិន្ត្រៃយ៍បានប្រមាណ ២០០.០០០ហិកតា
- បង្កើនប្រាក់ចំណូលរបស់រដ្ឋតាមរយៈការប្រមូលពន្ធសួយសារពីចំការឈើដាំ និងសេវាកម្មទេសចរណ៍ធម្មជាតិ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតស្របពេលកំពុងអនុវត្តផែនការនេះ។

ដើម្បីគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារព្រះវិហារដោយចីរភាពស្របតាមគោលយោបាយព្រៃឈើជាតិក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងគោលដៅអភិវឌ្ឍសហស្សវត្សរបស់កម្ពុជាតម្រូវឱ្យមាន៖

- ការចូលរួមជាកំលាំងពលកម្ម ថវិកា ការគាំទ្រផ្នែកនយោបាយពីស្ថាប័ន និងអ្នកពាក់ព័ន្ធ ដើម្បី អនុវត្តកម្មវិធីសកម្មភាពសំខាន់ៗចំនួន ០៦ ដូចមានចែងនៅក្នុងជំពូក ៤ និងជំពូក ៥ នៃផែនការគ្រប់គ្រងនេះ
- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន បុគ្គលិកតំបន់ព្រៃការពារ និងអ្នកពាក់ព័ន្ធអំពីការគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើ ការការពារទីជម្រាល និងការអភិរក្សជីវចម្រុះ ការរៀបចំដំណើរការសកម្មភាពទេសចរណ៍ធម្មជាតិដោយសហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍

- ផ្តល់ការផ្គត់ផ្គង់សម្ភារៈ ឧបករណ៍ មធ្យោបាយ អាគារ និងបុគ្គលិក ។

ការអនុវត្តកម្មវិធីការងារនៃផែនការគ្រប់គ្រងនេះអាចជួយរួមចំណែកក្នុងការៈ

- ❖ បង្កើនជីវភាពរស់នៅ និងការធានានូវសន្តិសុខស្បៀងរបស់ប្រជាជនដែលរស់ក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ
- ❖ បង្កើន និងពង្រឹងសមត្ថភាពដល់មន្ត្រីស្ថាប័នមានសមត្ថកិច្ច សហគមន៍មូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយតម្លាភាព និងរួមចំណែកក្នុងការអភិវឌ្ឍ និងការប្រើប្រាស់ ធនធានធម្មជាតិដោយចីរភាព និងសមធម៌
- ❖ ពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងធនធានព្រៃឈើ និងបង្កើនប្រសិទ្ធភាពក្នុងការពង្រឹងការអនុវត្តច្បាប់
- ❖ បង្កើនផលិតភាពព្រៃឈើ និងធនធានព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ
- ❖ ធានាបាននូវការការពារព្រៃឈើ សត្វព្រៃ និងជីវចម្រុះ។

# ឯកសារយោង


Asian Development Bank (May 2005 *Strategic Framework and Technical Assessment 2005-2014.* Greater Mekong Sub-region (GMS) Biodiversity Conservation Corridors Initiative.

Bryan L. Stuart, Peter Paul van Dijk and Douglas B. Hendrie (2001) *A Photographic Guide to the Turtles of Thailand, Laos, Vietnam and Cambodia*. Wildlife Conservation Society.

Cambodia Tree Seed Project (CTSP), 2001, Some Endangered Species of Cambodia, Unpublished

Charles D. Crocker, (1962) *The soils of Cambodia*. Ministrére de L'Agriculture, Royaume du Cambodge

Chheang Dany, (2002) *Species Monographs. The 21 Priority Tree Species for Forest Gene Conservation in Cambodia.* CTSP, DFW-DANIDA, Unpublished

Chheang C., Weiler H., Kuy T., Sam H. (2001). *Chow Rovess: A report on the status, distribution and issues surrounding the domesticated Asian elephant in Cambodia.*

Chheang Dany, Hunter W., Kuy Tong & Sam Han (2001). *The Status, Distribution and Management of the Domesticated Asian Elephant in Cambodia. In Giants On Our Hands, pp. 79-88*. RAP publication: 2002/30, Food and Agriculture Organization of the United Nations Regional Office for Asia and the Pacific. Bangkok, Thailand 2002.

Collar, N.J. Crosby, M.J & Stattersfield, A.J. (1994) *Birds to watch2: The World List of Threatened Birds.* BirdLife Conservation Series4, Cambridge, UK.

Community Wildlife Ranger Program of FA-CAT (2005) *Programme Report of Project Activities.*

Cox, M.J. (1991) *The Snakes of Thailand and their Husbandry*. Krieger, Malabar, Florida.

Craig Robson A Field Guide to the Birds of South-East Asia, Thailand, Peninsular Malaysia, Singapore, Myanmar, Laos, Vietnam, Cambodia.

Dy Phon, 2000, *Dictionary of Plants used in Cambodia.*

Dy Phon, P., (1982) *Végétation du Cambodge: endemisme et affinités de sa flore avec les région voisines, C.R. Séances Soc*. Biogéogr, 58 (3): 135-144.

Dy Phon, P., (1981) *Contribution a l'Etude de la Vegetation du Cambodge*. Ph.D Thesis, Universite de Paris –Sud, Centre d'Orsay, Paris.

FAO, (2015) *Global Forest Resource Assessment 2015.* Food and Agriculture Organization of the United Nations; Rome, 2015.

Forestry Administration, (2016). *Cambodia Forest Cover Assessment 2014 (*Draft).

Forestry Administration, (2012). *Cambodia Forestry Statistics 2010.*

Forestry Administration, (2011) *Cambodia's Forest Cover Assessment 2010.*

Forestry Administration, (2010). *The Management Plan of the Preah Vihear Protected Forest for Plant and Wildlife Genetic Resources Conservation 2010-2014*. Phnom Penh, Cambodia

Forestry Administration, (2005). *Explanation of Terminology Used in Forestry Law.*

Forestry Administration (2004) *List of Trade Names of Commercial Wood in Cambodia, Trade Names of Commercial Wood*, unpublished.

ITTO, (2005) *Achieving the ITTO Objective 2000 and Sustainable Forest Management in the Kingdom of Cambodia*

IUCN, (2016) Red List of threatened species. www. Redlist.org.

IUCN, (1995) *Centres of Plant Diversity, Volume 2 –Australia, Asia and the Pacific*. IUCN, Gland, Switzerland.

IUCN, (1994) *Categories, Objectives and Criteria for Protected Areas*. IUCN, Gland, Switzerland.

IUCN, (1984) *Guidelines for Protected Area Management Categories*. IUCN, Gland, Switzerland.

Joint Royal Government of Cambodia and Donor Committee (2004) *Independent Forest Sector Review.*

Khorn Saret (2002) *Distribution of Selected Tree Species for Gene Conservation in Cambodia.*

Men Soriyun, Joe Walston (2008) *A Guide to The Mammals of Cambodia FA/WCS/MoE.*

Merel J. Cox, Peter Paul van Dijk, Jarujin Nabhitabhata and Kumthorn Thirakhupt, (1988) *A Photographic Guide to Snakes and Other Reptiles of Peninsular Malaysia, Singapore and Thailand*. New Holland.

Miller, K.R and Hamilton, L.S., (1999) *Editorial: Bioregional approach to Protected areas. Parks 9:1-6.*

Ministry of Planning (2016). *Cambodia Agriculture Census 2014. Phnom Penh, Cambodia.*

National Institute of Statistic, (2014). *Commune Database, 2013.* Ministry of Planning.

Royal Forest Department, (2015). The management Plan of The Pha Taem protected Forest Complex (Revised). Bangkok, Thailand.

Royal Government of Cambodia (2015). *National Strategic Development Plan 2014-2018.*

Royal Government of Cambodia 2004: "*Rectangular Strategy*" for Growth, Employment, Equity and Efficiency".

Royal Government of Cambodia 2002: "*National Poverty Reduction Strategy 2003-2005".*

Soun Phalla (2002), *Wildlife Identification for Law Enforcement*, DFW, WCS and TRAFFIC Southeast Asia-Indochina.

Turner, M.G., Gardner, R.H and O'Neill, R.V., (2001) *Landscape Ecology in Theory and Practices: Pattern and Process.* Springer, New York, USA.

Sareun Sithika (2004). *A study of Wood Consumption in Thbeng Meanchey District of Cambodia*

Seila Programme 2008: http:\\www.seila.gov.kh

World Bank, (2004) *Cambodia Independent Forestry Sector Review – Comments and Proposals Going Forward', October 2004.*

Zich, F.A. and Compton J., (2001) *The Final Frontier: Towards Sustainable Management of Papua New Guinea's Agarwood Resource*. TRAFFIC Oceania, WWF South Pacific Programme

**FOREST MANAGEMENT REGULATIONS, LEGISLATIONS AND GUIDELINES**

Law on Forestry (2002)

Law on Environmental Protection and Natural Resource Management (Nov. 1996)

Royal Government of Cambodia, (2002) Statement of the Royal Government on National Forest Sector Policy.

Sub Decree No. 53 on Legal Procedure for Establishment, Classification and Registration of the Permanent Forest Estates (Apr. 2005)

Sub Decree No. 118 on the State land Management (2005)

Sub-decree No. 76 on Establishment of *Preah Vihear Protected Forest for Forest and Wildlife Genetic Resources Conservation* 30 July 2002

Declaration Number 089, dated 14 February 2005: The Forest-Non Timber Forest Product are prohibited. Ministry of Agriculture Forestry and Fisheries.

Declaration Number 020, dated 25 January 2007: The Classification and List of Wildlife Species. Ministry of Agriculture Forestry and Fisheries.

Guidelines for Sustainable Forest Management, (2000, Department of Forestry and Wildlife). Phnom Penh Cambodia

a) Guidelines for Forest Concession Management Planning System;

b) Construction Guidelines for Forest Engineering Works;

c) Guidelines for Special Management Area Management;

d) Bio-diversity Conservation Guidelines for the Managed Forests;

e) Guidelines for Socio-Economic Surveys of Communities Surrounding Forest Concession Areas.

f) Guidelines for Environmental Impact Assessment for Forest Concessions;

g) Guidelines for the Evaluation of Environmental Impact Assessment for Forest Concessions.

# វាក្យស័ព្ទសំខាន់ៗប្រើប្រាស់ក្នុងផែនការគ្រប់គ្រងតំបន់ព្រៃការពារសម្រាប់ អភិរក្ស ធនធានសេនេទិចរុក្ខជាតិ និង សត្វព្រៃ ព្រះវិហារ

## ក. ចំណាត់ថ្នាក់សត្វព្រៃនៅកម្ពុជា

គ្រប់ប្រភេទសត្វព្រៃទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកជាបីក្រុមគឺ៖

| | |
|---|---|
| *១- សត្វព្រៃក្រុម ប្រភេទជិតផុតពូជ* | ប្រភេទសត្វព្រៃទាំងឡាយនៅក្នុងធម្មជាតិ ដែលចំពោះមុខដង់ស៊ីតេនៃសារព័ន្ធ និងភូមិសាស្ត្រ នៃលំនៅដ្ឋានរបស់វាត្រូវបានថយចុះយ៉ាងឆាប់រហ័សក្នុងរយៈពេល១០ឆ្នាំចុងក្រោយ ឬក្នុង រយៈពេល៣ជំនាន់តំណពូជ ហើយកំពុងប្រឈមមុខចំពោះការគំរាមកំហែងជាអតិបរមាឆ្ពោះ ទៅរកការផុតពូជនៅក្នុងធម្មជាតិ និងជាប្រភេទដែលមានសារៈសំខាន់ផ្នែកវិទ្យាសាស្ត្រ និងមានតំលៃសេដ្ឋកិច្ចខ្ពស់។ |
| *២- សត្វព្រៃក្រុម ប្រភេទមានដោយកម្រ* | ប្រភេទសត្វព្រៃទាំងឡាយនៅក្នុងធម្មជាតិ ដែលចំពោះមុខដង់ស៊ីតេនៃសារព័ន្ធរបស់វាមាន កម្រិតទាបកម្រជួបប្រទះ ឬមានដោយកម្រដែលអាចជួបប្រទះតែនៅក្នុងលំនៅដ្ឋានណា មួយជាក់លាក់ (ស្ថាបនិកប្រភេទ) និងអាចប្រឈមមុខចំពោះការគំរាមកំហែងឈានទៅរក ការផុតពូជនៅក្នុងធម្មជាតិ។ |
| *៣- សត្វព្រៃក្រុម ប្រភេទមានដោយបង្គួរ* | ប្រភេទសត្វព្រៃទាំងឡាយនៅក្នុងធម្មជាតិដែលចំពោះមុខដង់ស៊ីតេ នៃសារព័ន្ធរបស់វាមាន កម្រិតច្រើនបង្គួរ មានរប៉ាយទូលំទូលាយ មានសក្កានុពលបន្តពូជឆាប់រហ័ស និងរងការគំរាម កំហែងតិច តួចក្នុងតម្រូវការសង្គមសេដ្ឋកិច្ច។ |
| *ថនិកសត្វ* | គឺពពួកសត្វមានឆ្អឹងកងដែលមានលក្ខណៈវិវត្តន៍ខ្ពស់បង្កកំណើតក្នុង និងចិញ្ចឹមកូនដោយ ទឹកដោះ។ តាមការរីកចំរើនក្នុងការបង្កកំណើតរបស់វា ថនិកសត្វចែកចេញជា ៣ក្រុមខាងក្រោម៖<br>ថនិកសត្វមានសុខ៖ កូនបង្កកំណើតក្នុងស្បូនរបស់សារពាង្គកាយសត្វញី។<br>ថវិកសត្វ៖ ជាថនិកសត្វដែលមានគត៌រយៈពេលខ្លី (១២ថ្ងៃ)ហើយកូនដែលទើបនឹងកើតមិនទាន់ មានលក្ខណៈ និងសកម្មភាពពេញលេញ។<br>មូណូគ្រែម៖ ជាថនិកសត្វអូរ៉ីប៉ា ដែលបង្កកំណើតក្នុងស៊ុត ហើយភ្ញាស់កូនដូចបក្សី។ |
| *បក្សីសត្វ* | គឺជាពពួកសត្វមានឆ្អឹងកងដែលខ្លួនគ្របដណ្តប់ដោយស្លាប និង បង្កកំណើតក្នុងស៊ុត។ |
| *ឧរង្គសត្វ* | គឺជាពពួកសត្វមានឆ្អឹងកងដែលអាចផ្សាំជីវិតនៅលើគោកទាំងស្រុង ស្បែកស្ងួតគ្រប់ដណ្តប់ ដោយស្រកា។ លើកលែងតែពស់ ឧរង្គសត្វភាគច្រើនមានក្រញាំនៅចុងម្រាម និងបង្កកំណើត ក្នុង ហើយលូតលាស់ប្រព្រឹត្តទៅនៅលើគោកមានលក្ខណៈជាក្រុមសត្វបង្កកំណើតក្នុង(អូវីប៉ា) ឬក្រុមសត្វ បង្កកំណើតក្រៅ(អូវ៉ូវីប៉ា)។ |
| *បាណកសត្វ* | គឺពពួកសត្វតូចៗដែលគ្មានឆ្អឹងកង និងមានអង់តែនពីរ ជើងបីគូរ មានស្លាបមួយ ឬពីរគូរ។ |
| *ថលជលិកសត្វ* | គឺពពួកសត្វបង្កកំណើតក្រៅខ្លួន ហើយអាចរស់នៅក្នុងទឹកផង និងលើគោកផង។ |
| *សត្វឥតឆ្អឹងកង* | គឺពពួកសត្វដែលគ្មានឆ្អឹងខ្នង សារពាង្គកាយមានសភាពទន់ (ឧទាហរណ៍ ៖ ខ្ចងខ្ចៅ គ្រំងាវ) លើកលែងតែសត្វល្អិត ឬ សិប្បីសត្វ ដែលគ្រោងឆ្អឹងគ្របដណ្តប់ក្រៅសារពាង្គកាយ។ |
| សត្វបង្កកំណើតក្នុងទឹក | គឺជាវារីសត្វ ឬ សត្វបង្កកំណើតក្រៅ គឺអូវុលទទួលការបង្កកំណើតនៅក្រៅសារពាង្គកាយ សត្វញី ហើយការបង្កកំណើតប្រព្រឹត្តទៅដោយផ្ទាល់នៅក្នុងទឹក ក្រោយពេលមេបាបញ្ចេញ កាម៉ែតរៀងខ្លួនទៅក្នុងទឹកតាមបំពង់នាំកាម៉ែតចេញពីក្រពេញភេទ។ |
| សត្វព្រៃ | គឺជាពពួកសត្វដែលមិនមែនជាសត្វស្រុក (all non-domesticated animal life) និងជា |

សមាសភាគនៃធនធានព្រៃឈើ (ធម្មជាតិ) ដែលរួមមានពពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកងផ្សេងទៀត ព្រមទាំងពង-កូនរបស់វា និងជាសត្វរស់ ឬសំណាក កំពុងរស់ចិញ្ចឹមជីវិតដោយខ្លួនឯងនៅក្នុងធម្មជាតិ ឬ ចិញ្ចឹម ឬ ថែរក្សានៅក្នុងស្រុក ដែលមានប្រវត្តិ បានមកពីការបរបាញ់ ទាក់ចាប់ពីក្នុងដែនព្រៃធម្មជាតិ និងបានមកពីការបង្កាត់ពូជ ឬមិនមានចុះ ក្នុងបញ្ជីឈ្មោះ (សៀវភៅបន្ទុក) នៃសកម្មភាពមិនអនុញ្ញាតណាមួយពីស្ថាប័នរដ្ឋ ឬអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងលើធនធានសត្វព្រៃ។

## ខ. ចំណាត់ថ្នាក់ប្រភេទព្រៃ

សំរាប់ប្រភេទព្រៃឈើ គេអោយនិយមន័យតាមការកំណត់ផ្សេងៗគ្នា ទៅតាមស្ថានភាពនៃតំបន់តាមការ ឯកភាពនៃប្រទេសសាមី៉ ដែលអាចទទួលយកនិយមន័យណាមួយនោះសំរាប់ការប្រើប្រាស់នៅក្នុងប្រទេសនោះ។ យោងតាមនិយមន័យព្រៃរបស់ FAO គំរបព្រៃត្រូវបានកំណត់ដូចខាងក្រោម៖ ផ្ទៃដីព្រៃត្រូវចាត់ថ្នាក់ជាដីព្រៃឈើ លុះត្រាតែមានកម្រិតគ្របដណ្តប់ កន្សោមស្លឹក ដើមឈើចាប់ពី ១០% និង មានផ្ទៃដីចាប់ពី ០,៥ ហិចតា ហើយដើមឈើមានកំពស់ចាប់ពី ៥ ម៉ែត្រឡើងទៅ។

ការបកស្រាយគំរបព្រៃឆ្នាំ១៩៩៦/៩៧ របស់អង្គការ MRC/GTZ មាន ១៨ប្រភេទ រួមទាំងធាតុរចនាសម្ព័ន្ធព្រៃ និងដង់ស៊ីតេ។ តាមការចាំបាច់ក្នុងការសិក្សាបានបញ្ចូលគ្នាជា ៥ ប្រភេទព្រៃធំ ឆ្នាំ២០០២ ដែលរួមមានព្រៃបៃតងជានិច្ច (មានប្រភេទព្រៃបៃតងជានិច្ចក្រាស់ មធ្យម និងស្តើង) ព្រៃពាក់កណ្តាលស្រោង (មានប្រភេទព្រៃពាក់កណ្តាលស្រោងក្រាស់ មធ្យម និងស្តើង) ព្រៃល្បោះ (មានប្រភេទព្រៃល្បោះ និងព្រៃល្បោះស្តើង) ប្រភេទព្រៃផ្សេងទៀត (មានប្រភេទដំណុះព្រៃឡើងវិញ ព្រៃនិងគុម្ពព្រឹក្ស ព្រៃគ្រីន ចំការឈើ កសិកម្មពនេចរ ព្រៃឬស្សី និងព្រៃកោងកាង) និងដីមិនមែនព្រៃ (មានវាលស្មៅ ដីសើម ដីកសិកម្ម ផ្ទៃទឹក និងទីប្រជុំជន)។

### ព្រៃបៃតងជានិច្ច

ប្រភេទព្រៃបៃតងជានិច្ច ជាទូទៅមានច្រើនស្រទាប់ ហើយដើមឈើមានស្លឹកបៃតងជានិច្ចពេញមួយឆ្នាំ។ តាមធម្មតាមាននៅលើភ្នំ ខ្ពង់រាប និងតាមបណ្តោយដងអូរ ស្ទឹង និងទន្លេ។ អត្តសញ្ញាណនៃប្រភេទព្រៃបៃតងជានិច្ច នៅលើរូបភាពផ្កាយរណបមានពណ៌ក្រហមជាំ និងមធ្យមលាយភាពគគ្រើមនេះជាលក្ខណៈសំគាល់នៃប្រភេទព្រៃនេះ។

### ព្រៃពាក់កណ្តាលស្រោង

ប្រភេទព្រៃពាក់កណ្តាលស្រោងមានការប្រែប្រួលអត្រាភាគរយនៃដើមឈើបៃតងជានិច្ច និងដើមឈើជ្រុះស្លឹកអត្រា ភាគរយនៃដើមឈើបៃតងជានិច្ចប្រែប្រួលពី ៣០ ទៅ ៧០%។ ប្រភេទព្រៃពាក់កណ្តាលស្រោងលេចចេញបៃតងជានិច្ចពេញមួយឆ្នាំ ទោះបីជាអត្រាភាគរយនៃដើមឈើជ្រុះស្លឹកខ្ពស់ក៏ដោយ។ នៅពេលដែលដើមឈើជ្រុះស្លឹករបស់វានៅរដូវប្រាំង សញ្ញាបាច់ពន្លឺនៅពេលនោះ ជាទូទៅលេចចេញនូវពណ៌ត្នោតចាស់ ឬប្រផេះចាស់។ ការប្រែប្រួលចំណាត់ថ្នាក់គំរបដីព្រៃប្រភេទនេះមានខ្ពស់ និងអាស្រ័យនឹងសមាមាត្រនៃដើមឈើជម្រុះស្លឹកទាំងមូល ផ្នែកខ្លះនៃប្រភេទព្រៃបៃតងជានិច្ចស្ងួត អាចត្រូវបានគេធ្វើផែនទីបញ្ចូលទៅក្នុងប្រភេទព្រៃនេះ។

### ព្រៃល្បោះ

ព្រៃប្រភេទនេះមានព្រៃល្បោះចំរុះស្ងួត និងប្រភេទព្រៃ Dipterocarp ស្ងួត។ ព្រៃល្បោះជ្រុះស្លឹកច្រើន ឬ តិចនៅរដូវប្រាំង។ សញ្ញាបាច់ពន្លឺរបស់វាប្រែប្រួលពីពណ៌ត្នោតចាស់-បៃតង ទៅពណ៌ខៀវចាស់-ប្រផេះ នៅរដូវប្រាំងជាមួយនឹងវាយនភាព ពីមធ្យមទៅរលោង។ ឥទ្ធិពលរបស់មនុស្សរួមមានភ្លើងឆេះព្រៃ ជាធម្មតាកើតមានជាញឹកញាប់នៅក្នុងប្រភេទព្រៃល្បោះ ជាងប្រភេទព្រៃផ្សេងទៀត។ ប្រភេទព្រៃ Dipterocarp ស្ងួតមានលក្ខណៈធម្មជាតិរហាលនៅពេលមិនមានការរំខាន វាអាចមានគំរបកន្សោមស្លឹកត្រឹមតែ ៤០%ប៉ុណ្ណោះ។ ស្រទាប់ដី និងស្មៅអាចមានឥទ្ធិពល

សំខាន់ទៅលើការជះត្រឡប់មក វិញនៃព្រៃនេះ។ ជាលទ្ធផលវាស្ទើរតែមិនអាចញែកពីព្រៃល្បោះ និងគុម្ពព្រឹក្សនៅ រដូវប្រាំង។

**ប្រភេទព្រៃផ្សេងទៀត**

ប្រភេទព្រៃផ្សេងទៀតនេះរួមមានដំណុះព្រៃឡើងវិញ និងគុម្ពព្រឹក្ស ព្រៃក្រិន ព្រៃឬស្សី ព្រៃកោងកាង ព្រៃលិចទឹក និងចំការឈើឧស្សាហកម្ម។ ដំណុះព្រៃឡើងវិញនៃព្រៃបន្ទាប់មានស្រទាប់ញឹក និងដើមឈើតូចៗ។ ព្រៃក្រិន មានការលូតលាស់យ៉ាងយឺតដោយសារលក្ខខណ្ឌនៃទីកន្លែងពុំសមស្របនៅលើដីប្រភេទ Hydromorphic និងនៅលើថ្ម។ ការរំខានដ៏ធ្ងន់ធ្ងរនៃព្រៃដូចជាព្រៃដុះដោយដុំ ដំណុះព្រៃឡើងវិញ និងកសិកម្មពនេចរដែលក្នុងនោះ អត្រាភាគរយ នៃព្រៃឈើលើសពី ៤០% និងផ្ទៃដីដែលមានដំណុះឈើចាស់ និងដំណុះព្រៃឈើថ្មី ដែលបានដុះឡើងវិញបន្ទាប់ពីការ កាប់រានក៏ស្ថិតនៅក្នុងប្រភេទព្រៃផ្សេងទៀតដែរ។

**ដីមិនមែនព្រៃ**

ដីប្រភេទនេះរួមបញ្ចូលដីកសិកម្ម តំបន់ទីប្រជុំជន ផ្ទៃទឹក គុម្ពព្រឹក្ស និងវាលស្មៅ។

ដោយឡែកយោងតាមច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ ២០០២) សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមានៈ ព្រៃបំរុងទុកអចិន្ត្រៃយ៍ និង ព្រៃឯកជន ។ ព្រៃបំរុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ៖

១-ព្រៃផ្តល់ផលត្រូវបានរក្សាទុកសម្រាប់ផលិតកម្ម អនុផលព្រៃឈើប្រកបដោយនិរន្តភាពដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់។ ព្រៃផ្តល់ផលមានជាអាទិ៍ៈ ព្រៃសម្បទាន ព្រៃផ្តល់ផលក្រៅពីសម្បទាន ព្រៃឈើត្រូវស្តារឡើងវិញ ផ្ទៃដីព្រៃបម្រុងទុក សំរាប់ដាំដើមឈើឡើងវិញ ឬ ចំការព្រៃឈើ ផ្ទៃដីព្រៃបម្រុងទុកសម្រាប់បន្តពូជ ព្រៃឈើ ផ្ទៃដីព្រៃរេចរឹល ព្រៃសហគមន៍ ក្រោមកិច្ចព្រមព្រៀង។

២-ព្រៃការពារត្រូវបានរក្សាទុកជាចម្បង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ។ តំបន់ព្រៃដែលមានមុខងារចំបងសំរាប់ការពារប្រព័ន្ធមជ្ឈដ្ឋានជាអាទិ៍ រក្សានិយតភាពប្រភពទឹក អភិរក្សជីវចម្រុះ អភិរក្សដី ទឹក ទីជំរាល តំបន់ផ្ទៃរងទឹកភ្លៀង ជំរកសត្វព្រៃ មច្ឆាជាតិ រាំងទឹកជំនន់ ការពារការហូរច្រោះ រាំងការទន្ទ្រាន នៃទឹក សមុទ្ររក្សាជីជាតិដី ឬ មានតំលៃសំរាប់សម្បត្តិវប្បធម៌ដែលបំរើប្រយោជន៍សាធារណៈ។ ព្រៃការពារមិនបញ្ចូលនូវតំបន់ការពារធម្មជាតិ ក្រោមយុត្តាធិការនៃក្រសួងបរិស្ថាន អនុលោមតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។ ព្រៃការពារមានជាអាទិ៍ៈ ព្រៃបម្រុងទុកសំរាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស ព្រៃសម្រាប់សិក្សាស្រាវ ជ្រាវ ព្រៃនិយតកម្មប្រភពទឹក ព្រៃការពារទីជំរាល ព្រៃលំហែកំសាន្ត សួនរុក្ខជាតិ ព្រៃជំនឿសាសនា។ ព្រៃការពារនេះអាចអនុញ្ញាតឱ្យប្រមូលផល-អនុផល ព្រៃឈើជាលក្ខណៈប្រពៃណីដែលមានផលប៉ះពាល់ទាបដោយសហគមន៍មូលដ្ឋាន។

៣-ផ្ទៃដីព្រៃសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិព្រៃបន្ទាប់បន្សំដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍ រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍន៍សម្រាប់គោលបំណងផ្សេងទៀតដោយរាជរដ្ឋាភិបាល។ ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់។

**ព្រៃបម្រុងទុកអចិន្ត្រៃយ៍៖** ព្រៃឈើរដ្ឋគ្របដណ្តប់លើដី ដែលមិនមែនជាកម្មសិទ្ធឯកជន និងត្រូវបានចាត់ថ្នាក់ ជាព្រៃ ផ្តល់ផល ព្រៃការពារ និងផ្ទៃដីសំរាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ។

**ព្រៃសម្បទាន៖** ផ្នែកមួយនៃព្រៃផ្តល់ផលរបស់រដ្ឋ និងមានសក្តានុពលផ្តល់ផលដែលរាជរដ្ឋាភិបាលប្រគល់ឱ្យជាបណ្តោះអាសន្ន ឬ អាចបញ្ឈប់បានឱ្យទៅនីតិបុគ្គលណាមួយដែលមានសមត្ថភាពផ្នែកវិជ្ជាជីវៈ និងធនធាន តាមរយៈការដេញថ្លៃ ជាសាធារណៈដើម្បីទទួលសិទ្ធិគ្រប់គ្រងអភិវឌ្ឍន៍ និងប្រមូលផលព្រៃឈើប្រកបដោយ និរន្តភាព ក្នុងរយៈពេលមួយកំណត់ដោយអនុវត្តតាមកិច្ចព្រមព្រៀង និងបទបញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ និងលិខិត បទដ្ឋានពាក់ព័ន្ធ។

**ព្រៃផ្តល់ផលក្រៅព្រៃសម្បទាន៖** ផ្នែកមួយនៃព្រៃផ្តល់ផលដែលស្ថិតនៅក្រៅដែនព្រៃសម្បទាន ឬ ជាព្រៃផ្តល់ផលដែលត្រូវបានរៀបចំជាព្រៃគុបប្រចាំឆ្នាំ ដោយរដ្ឋបាលព្រៃឈើក្នុងគោលបំណងផ្គត់ផ្គង់សេចក្តីត្រូវការផល-អនុផលព្រៃឈើក្នុងស្រុកជាចំបង។

**ព្រៃឈើត្រូវស្តារឡើងវិញ៖** ផ្នែកមួយនៃដែនព្រៃផ្តល់ផលដែលស្ថិតក្រោមកម្រិតរេចរឹលមួយទាប ហើយទាមទារនូវអន្តរាគមន៍រុក្ខវប្បកម្មតាមរយៈការដាំបញ្ចូលធ្វើឱ្យសំបូរប្រភេទឈើដើមកំណើត ឬថែទាំដំណុះព្រៃដើមដោយធ្វើឱ្យមាន ការបន្តពូជឡើងវិញដោយធម្មជាតិ។

**ព្រៃរេចរឹល៖** ផ្នែកមួយនៃព្រៃផ្តល់ផលដែលគំរបព្រៃ និងធនធានព្រៃឈើត្រូវបានវិវត្តន៍ថយចុះជាបន្តបន្ទាប់ក្នុង រយៈពេលវែងរួមទាំងការប្រែប្រួលរចនាសម្ព័ន្ធរូបរបស់ព្រៃឈើផង។

**ព្រៃបម្រុងទុកសំរាប់ដាំឈើឡើងវិញ៖** ផ្នែកមួយនៃដែនព្រៃផ្តល់ផល ដែលស្ថិតក្រោមស្ថានភាពរេចរឹលយូរអង្វែង ហើយដែលត្រូវបម្រុងទុក សំរាប់បង្កើតដំណុះព្រៃឡើងវិញ តាមរយៈការដាំ ឬ សាបគ្រាប់។

***ព្រៃបម្រុងទុកសំរាប់បន្តពូជឈើប្រភពគ្រាប់ពូជ*** " ជាផ្នែកមួយនៃដែនព្រៃផ្តល់ផល ឬ ប្រព័ន្ធមជ្ឈដ្ឋានក្នុងតំបន់ដែល សំបូរដោយដើមឈើមានតំលៃគុណភាពសេនេទិចខ្ពស់ និងមានសក្តានុពលផ្តល់គ្រាប់ពូជ ដែលត្រូវបម្រុងទុកសំរាប់រក្សាដើមឈើមេ និងសំរាប់អភិរក្សធនធានសេនេទិចរូបធាតុតំណពូជមានតំលៃ និងសក្តានុពលដើម្បីបំរើប្រភពផ្គត់ផ្គង់គ្រាប់ពូជក្នុងកិច្ចការរុក្ខវប្បកម្ម ឬ សំរាប់ការបន្តពូជព្រៃឈើដោយធម្មជាតិ។

**ព្រៃសហគមន៍៖** ព្រៃរបស់រដ្ឋដែលបានប្រគល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខណ្ឌរដ្ឋបាលព្រៃឈើជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដោយពឹងផ្អែកលើព្រៃឈើសំរាប់ការចិញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណីហើយបានព្រមព្រៀងធ្វើការគ្រប់គ្រង និងប្រើប្រាស់ព្រៃឈើនោះប្រកបដោយនិរន្តភាព។

**ព្រៃឯកជន៖** ព្រៃឯកជនត្រូវថែរក្សាទុកដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៍ក្នុងការអភិវឌ្ឍន៍ និងប្រមូលផលប្រើប្រាស់-លក់ចែកចាយផលិតផលរបស់ខ្លួនដោយផ្ទាល់។

**ព្រៃបម្រុងទុកសំរាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស៖** ជាដែនព្រៃការពារដែលប្រព័ន្ធមជ្ឈដ្ឋានរបស់ព្រៃឈើនោះ ផ្តល់នូវលំនៅដ្ឋានពិសេសសំរាប់ប្រភេទរុក្ខជាតិព្រៃឈើ ឬ សត្វព្រៃមួយចំនួន។

**ព្រៃសំរាប់សិក្សាស្រាវជ្រាវ៖** ជាផ្នែកមួយនៃដែនព្រៃការពារ ដែលត្រូវបានរៀបចំសំរាប់បំរើឱ្យការសិក្សាស្រាវជ្រាវពិសោធន៍ ឬ បង្ហាញនូវការងារបច្ចេកទេសរុក្ខវប្បកម្ម ឬ វិទ្យាសាស្ត្រព្រៃឈើ។

**ព្រៃនិយតកម្មប្រភពទឹក៖** ជាផ្នែកមួយនៃព្រៃការពារដែលមានមុខងារសំរួលដល់អត្ថិភាពនៃប្រភពទឹក និងដំណើរនៃវដ្តទឹក។

**ព្រៃការពារទីជំរាល៖** ជាផ្នែកមួយនៃដែនព្រៃការពារដែលមានមុខងារការពារផ្ទៃដីព្រៃឈើ ហើយមានចំណោតខ្ពស់ងាយរងការសឹករេចដោយសារការហូរច្រោះ ឬ ហៅថាតំបន់ទីជំរាល។

**ព្រៃលំហែកំសាន្ត៖** ជាផ្នែកមួយនៃដែនព្រៃការពារដែលមានទេសភាពធម្មជាតិពិសេស និងត្រូវបានរៀបចំសំរាប់ បំរើការ លំហែកំសាន្ត និងបរិស្ថានទេសចរណ៍។

**សួនអនុស្សាវរីយ៍៖** ជាផ្ទៃដី ឬស្ថានីយ៍សំរាប់ដាំកូនឈើក្នុងឱកាសបុណ្យជាតិ ឬអាពាហ៍ពិពាហ៍ .....

**សួនរុក្ខគាម៖** ជាផ្ទៃដី ឬស្ថានីយ៍ពិសោធន៍សំរាប់ដាំបណ្តារុក្ខជាតិដើមកំណើត ឬ រុក្ខជាតិតំណាងឱ្យមជ្ឈដ្ឋាន ផ្សេងៗគ្នា ក្នុងតំបន់ឬក្រៅតំបន់។ សួនរុក្ខគាមអាចជាផ្ទៃដីព្រៃតំណាងអោយមជ្ឈដ្ឋានព្រៃឈើមួយ ដែលគេរក្សា ទុកនូវសមាសភាពរុក្ខជាតិដើមជាសក្ខីគំរូ។ ជាមជ្ឈដ្ឋានព្រៃឈើក្នុងប្រទេស ដែលមានវត្តមានច្រើនជាងគេ ភាពសំបូរបែបនៃរុក្ខជាតិដែលបាន ប្រមូលជាប្រចាំសំរាប់គោលបំណងផ្សេងៗគ្នា។

**ព្រៃជំនឿសាសនា៖** ជាផ្នែកមួយនៃដែនព្រៃការពារដែលសហគមន៍មូលដ្ឋាន មានជំនឿគោរពបូជា ស្របតាមប្រពៃណី និង វប្បធម៌របស់ពួកគេ និងត្រូវបានរក្សាទុកជាព្រៃជំនឿសាសនា។

**តំបន់ផ្ទៃដីសំរាប់ផ្ទេរ៖** ជាផ្ទៃដីព្រៃសំរាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិ ព្រៃបន្ទាប់បន្សំ ដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវបានដាក់ឱ្យស្ថិតនៅក្នុងចំណាត់

ថ្នាក់នៃព្រៃបម្រុងទុកអចិន្ត្រៃយ៍រហូតដល់មានការសំរេចឱ្យប្រើប្រាស់ និងអភិវឌ្ឍន៍សំរាប់គោលបំណងផ្សេងទៀត ដោយរាជរដ្ឋាភិបាល។ ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍អាចត្រូវបានរំសាយសំរាប់អភិវឌ្ឍន៍វិស័យផ្សេងៗទៀត ដូចជា ដំណាំឧស្សាហកម្ម ដំណាំកសិឧស្សាហកម្ម ឬ វិស័យផ្សេងទៀត ដែលផ្តល់នូវប្រយោជន៍សេដ្ឋកិច្ច និងសង្គមខ្ពស់ជាងតំរូវការពីមុនៗ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលដើម្បីកំណត់ រកផ្ទៃដីព្រៃទំនេរផ្សេងទៀតដើម្បីជំនួស ផ្ទៃដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលបានរំសាយក្នុងគោលបំណងការពារ និងដាំព្រៃឡើងវិញដើម្បីរក្សាគំរបព្រៃជាអចិន្ត្រៃយ៍ ។

**ធនធានព្រៃឈើ៖** ធនធានជីវសាស្ត្រទាំងឡាយដែលកំណត់លើផ្ទៃដីព្រៃឈើមួយជាក់លាក់រួមមានធនធាន រុក្ខជាតិព្រៃឈើ និងធនធានសត្វព្រៃគ្រប់លំដាប់ថ្នាក់ និងគ្រប់ប្រភេទ រួមទាំងធនធានអជីវសាស្ត្រផ្សេងៗទៀត ដែលស្ថិតនៅក្នុងនោះក្រៅអំពីរ៉ែក្រោមដី។

**ព្រៃឈើ៖** ឯកតានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬសិប្បនិមិត្តក្រោមទំរង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិចំរុះ ទោះបីដុះដោយធម្មជាតិក្តី ឬ ដោយដាំក្តី រួមទាំងធនធានសត្វព្រៃ និងធនធានធម្មជាតិ ដ៏ទៃទៀតដែល ស្ថិតនៅក្នុងនោះដែលមានគោលបំណងប្រើប្រាស់សំខាន់គឺជាផល-អនុផលព្រៃឈើ ឬ សេវាកម្មផ្តល់ដោយព្រៃឈើ។ ពុំត្រូវចាត់ទុកជាព្រៃឈើតាមន័យរបស់ច្បាប់នេះទេ គឺដីដែលបានកំណត់ដោយរដ្ឋជាដីកសិកម្មស្ថេរ រួមមានចំការដីទំនេរ សំរាប់ផលិតកម្មកសិកម្មក្រៅពីផលឈើ ដីក្នុងតំបន់ឧស្សាហកម្ម និងដីសំរាប់ នគរូបនីយកម្ម និងសំណង់។

**ផល-អនុផលព្រៃឈើ៖** ផលិតផលដែលផ្តល់ដោយព្រៃឈើរួមមានផលឈើ និងផលមិនមែនឈើព្រមទាំងផលិតផល កែច្នៃបន្តរបស់វាក៏ដូចជាសេវាកម្មដែលផ្តល់ដោយព្រៃឈើ។

## គ.ប្រភេទតំបន់ពិសេសក្នុងព្រៃសម្បទាន

**រដ្ឋបាលព្រៃឈើ៖** អាជ្ញាធររដ្ឋាភិបាលគ្រប់ថ្នាក់ដែលមានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើស្របតាមគោលនយោបាយ វិស័យ ព្រៃឈើជាតិ និងអនុវត្តតាមច្បាប់នេះ។

**សម្បត្តិព្រៃឈើអចិន្ត្រៃយ៍៖** ព្រៃឈើទូទៅនៃព្រះរាជាណាចក្រកម្ពុជា ទោះជាកម្មសិទ្ធិរបស់រដ្ឋ ឬ ឯកជន ដុះដោយធម្មជាតិ ឬដោយដាំក្តីដែលត្រូវបានកំណត់ជាពីរក្រុម៖ ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន ហើយត្រូវរក្សា ជាគំរបព្រៃឈើអចិន្ត្រៃយ៍ ដើម្បីធានាការប្រើប្រាស់ប្រកបដោយនិរន្តភាព។

**សហគមន៍មូលដ្ឋាន៖** សហគមន៍ជនជាតិដើមភាគតិច ឬក្រុមអ្នកស្រុកដែលមានលំនៅដើមកំណើតក្នុងភូមិមួយ ឬច្រើន ស្ថិតនៅក្នុង ឬក្បែរតំបន់ព្រៃឈើរដ្ឋ ដែលមានប្រពៃណី ទំនៀមទំលាប់ ជំនឿសាសនា វប្បធម៌ និងរស់នៅចិញ្ចឹមជីវិត ដោយពឹងអាស្រ័យទៅលើការរុករកផល-អនុផលព្រៃឈើ និងប្រើប្រាស់ធនធានព្រៃឈើទាំងនោះជាមូលដ្ឋាន។

**សហគមន៍ព្រៃឈើ៖** សហគមន៍ដែលស្ម័គ្រចិត្តចងក្រងប្រមូលផ្តុំក្រោមកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តភាពនៅក្នុងព្រៃសហគមន៍ ដោយអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ។

**អនុផលព្រៃឈើ៖** ផលិតផលមិនមែនជាឈើហ៊ុបដែលទាញចេញពីព្រៃឈើ រួមមានផលិតផលនៃរុក្ខជាតិមិនមែនឈើ ផលប្រមាញ់នៃសត្វព្រៃ និងសេវាកម្មដែលផ្តល់ដោយព្រៃឈើ ហើយដែលកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**តំបន់ទីជំរាល ឬតំបន់អភិរក្សដី៖** ជាតំបន់ដែលមានការគ្រប់គ្រងសារព័ន្ធរុក្ខជាតិ សំរាប់ការអភិរក្ស និងការពារ ដីដែល មានសារៈសំខាន់ចាំបាច់ដើម្បីធានានូវស្ថេរភាពនៃតំបន់ទាំងនេះដែលរួមមាន ៖

- តំបន់ផ្ទៃរងទឹកភ្លៀងនៅជិតខាងក្រុង ឬ ទីប្រជុំជន
- តំបន់ដែលបានកំណត់ដោយគណៈកម្មាធិការទន្លេមេគង្គថា ជាតំបន់ងាយទទួលរងនូវការហូរច្រោះ ឬ

ដីងាយ ទទួលរងការខូចខាត។

**ជំរកសត្វព្រៃ ឬ ជីវចម្រុះ៖** ជាតំបន់ដែលមានសារៈសំខាន់សំរាប់ការអភិរក្ស ដែលត្រូវបានគេដឹងថាមានប្រភេទសារព័ន្ធរុក្ខជាតិ និងសត្វដ៏សំខាន់កំពុងរស់នៅ ហើយមានតំបន់ជាច្រើនទៀតដែលនឹងត្រូវកំណត់ជាតំបន់ដែលមានសារៈសំខាន់សំរាប់ការអភិរក្ស។

**ប្រភពផ្តល់គ្រាប់ពូជ៖** រក្សាដើមឈើសំរាប់ផ្តល់ពូជ ចុះបញ្ជី និងការចេញវិញ្ញាបនប័ត្រគ្រាប់ពូជ ប្រើប្រាស់គ្រាប់ពូជ។ តំបន់ដែលមានសារៈសំខាន់សំរាប់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជុំវិញតំបន់ព្រៃឈើ ៖ ការប្រាស្រ័យទាក់ទងរវាងសហគមន៍ ត្រួតពិនិត្យ ឬ ការហាមឃាត់ការកាប់ឈើ ដើម្បីធានាការចិញ្ចឹមជីវិតត្រូវបានរក្សា។

**តំបន់ដែលមានសក្តានុពលភាពសេដ្ឋកិច្ច៖** ជាផ្នែកមួយនៃទេសចរណ៍ធម្មជាតិមានឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្នែកសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន។ បានកំណត់ និងអនុវត្តការជ្រើសរើសសកម្មភាពពាណិជ្ជកម្មផ្សេងទៀតជំនួសអោយការកាប់ឈើ។

**កន្លែងដែលមានសារៈសំខាន់ប្រវត្តិសាស្ត្រ ឬវប្បធម៌៖** ថែរក្សាបរិស្ថានព្រៃឈើនៅកន្លែងដែលមានសារៈសំខាន់ប្រវត្តិសាស្ត្រ ឬ វប្បធម៌។

## ឃ. ចំណាត់ថ្នាក់ប្រភេទទទួលរងគ្រោះរបស់ IUCN

**ប្រភេទផុតពូជ** *(Ex)* ប្រភេទនោះបានចាត់ទុកថាផុតពូជនៅពេលប្រភេទសត្វចុងក្រោយបានងាប់។ ប្រភេទដែល សន្មត់ថាផុតពូជនៅពេលដែលការស្រាវជ្រាវល្អិតល្អន់នៅក្នុងទីជម្រកដែលគេបានដឹង ឬរំពឹងថាមានប្រភេទផុតពូជទាំងនោះ តាមពេលវេលា មួយសមស្រប (ជារៀងរាល់ថ្ងៃ តាមរដូវ តាមឆ្នាំ) ទូទាំងដែនជំរកជាប្រវត្តិសាស្ត្ររបស់វា ខកខាន មិនបានកត់ត្រានូវប្រភេទនោះ។ ការស្រាវជ្រាវគួរតែធ្វើឡើងតាមពេលវេលាសមស្របចំពោះវដ្តជីវិត និងលក្ខណៈ រស់នៅរបស់ប្រភេទផុតពូជ។

**ប្រភេទផុតពូជនៅក្នុងព្រៃ** *(EW)* ប្រភេទនោះបានផុតពូជនៅក្នុងព្រៃនៅពេលដែលគេគ្រាន់តែដឹងថារស់នៅដោយចិញ្ចឹមក្នុងទ្រុង ឬក៏លែងចូលទៅក្នុងធម្មជាតិ (ឬពពួកសត្វ)ស្ថិតនៅខាងក្រៅដែនជំរកមុនៗ។ ប្រភេទដែលសន្មត់ថា ផុតពូជនៅក្នុង ព្រៃនៅពេលដែលការស្រាវជ្រាវល្អិតល្អន់នៅក្នុងទីជំរកដែលគេដឹង ឬ រំពឹងថាមានប្រភេទសត្វទាំងនេះ តាមពេលវេលាមួយសមស្រប (ជារៀងរាល់ថ្ងៃ តាមរដូវ ឬតាមឆ្នាំ) ទូទាំងដែនជំរកជាប្រវត្តិសាស្ត្ររបស់វាខកខាន មិនបានរកឃើញ ឬកត់ត្រា ពពួកសត្វព្រៃដែលជិតផុតពូជនៅក្នុងព្រៃ។ ការស្រាវជ្រាវគួរតែធ្វើឡើងតាមពេលវេលាមួយ សមស្របចំពោះវដ្តជីវិត និង លក្ខណៈរស់នៅរបស់ប្រភេទជិតផុតពូជក្នុងព្រៃ។

**ប្រភេទជិតផុតពូជបំផុត** *(CR)* ប្រភេទដែលចាត់ទុកជិតផុតពូជបំផុតនៅពេលដែលភស្តុតាងជាក់ស្តែងបានបង្ហាញថាប្រភេទនោះ បានឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យណាមួយ ដែលបានបញ្ជាក់នៅក្នុងចំណាត់ថ្នាក់បញ្ជីក្រហម និងលក្ខណៈវិនិច្ឆ័យរបស់ *IUCN* សំរាប់ប្រភេទជិតផុតពូជបំផុត ហេតុនេះត្រូវបានចាត់ទុកថាប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរជិតផុតពូជនៅក្នុងព្រៃ។

**ប្រភេទជិតផុតពូជ** *(EN)* ប្រភេទដែលចាត់ទុកថាជិតផុតពូជនៅពេលដែលភស្តុតាងជាក់ស្តែង បានបង្ហាញថាប្រភេទនោះបាន ឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យណាមួយដែលបានបញ្ជាក់នៅក្នុងលក្ខណៈវិនិច្ឆ័យ និងចំណាត់ថ្នាក់បញ្ជីក្រហមរបស់ *IUCN* សំរាប់ប្រភេទជិតផុតពូជ ហេតុនេះត្រូវបានចាត់ទុកថាកំពុងប្រឈមមុខគ្រោះថ្នាក់ធ្ងន់ធ្ងរ ជិតផុតពូជនៅក្នុងព្រៃ។

**ប្រភេទងាយរងគ្រោះ:** *(VU)* ប្រភេទដែលចាត់ទុកថាងាយរងគ្រោះនៅពេលដែលមានភស្តុតាងជាក់ស្តែងបានបង្ហាញ ថាប្រភេទនោះបានឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យណាមួយដែលបានចុះក្នុងចំណាត់ថ្នាក់បញ្ជីក្រហម និងលក្ខណៈវិនិច្ឆ័យ

របស់ *IUCN* សំរាប់ប្រភេទងាយរងគ្រោះ ហេតុនេះត្រូវបានចាត់ទុកថាកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ជិតផុតពូជនៅក្នុងព្រៃ។

**ប្រភេទជិតរងគ្រោះ** *(NT)* ប្រភេទដែលចាត់ទុកថាជិតរងគ្រោះ នៅពេលដែលគេបានធ្វើការវាយតម្លៃទល់នឹងលក្ខណៈវិនិច្ឆ័យ ប៉ុន្តែមិនមានលក្ខណៈសម្បត្តិសំរាប់ប្រភេទជិតផុតពូជ ឬងាយរងគ្រោះនៅពេលបច្ចុប្បន្នប៉ុន្តែ ទំនងជាមាន លក្ខណៈសម្បត្តិ សំរាប់ចំណាត់ថ្នាក់ជិតរងគ្រោះក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

**ប្រភេទមានដោយបង្គួរ** *(LC)* ប្រភេទដែលចាត់ទុកថាមានដោយបង្គួរនៅពេលដែលប្រភេទនោះ ត្រូវបានវាយតំលៃទល់នឹងលក្ខណៈវិនិច្ឆ័យ ហើយមិនមានលក្ខណៈសម្បត្តិសំរាប់ប្រភេទជិតផុតពូជបំផុត ជិតផុតពូជ ប្រភេទងាយរងគ្រោះ ឬប្រភេទជិតរងគ្រោះ។ ប្រភេទដែលមានគ្រប់ទីកន្លែង និងសំបូរត្រូវបានបញ្ចូលនៅក្នុងចំណាត់ថ្នាក់នេះ។

**ប្រភេទកង្វះខាតទិន្នន័យ** *(DD)* ប្រភេទដែលចាត់ទុកថាកង្វះខាតទិន្នន័យនៅពេលដែលគ្មានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើការវាយតម្លៃដោយផ្ទាល់ ឬដោយប្រយោលពីការរងគ្រោះជិតផុតពូជដោយផ្អែកលើរបាយ និង/ឬ ស្ថានភាពសត្វ។ ប្រភេទ នៅក្នុងចំណាត់ថ្នាក់នេះត្រូវបានសិក្សាយ៉ាងល្អិតល្អន់ និងជីវសាស្ត្ររបស់វាត្រូវបានស្គាល់ច្បាស់ ប៉ុន្តែទិន្នន័យសមស្របស្តីពីភាព សំបូរបែប និង/ឬ របាយនៅខ្វះខាតនៅឡើយ។ ហេតុនេះកង្វះទិន្នន័យ មិនមែនជាចំណាត់ថ្នាក់គំរាមកំហែងទេ។ ការចុះបញ្ជី ប្រភេទនេះនៅក្នុងចំណាត់ថ្នាក់នេះបានបង្ហាញថា គេត្រូវការព័ត៌មានបន្ថែមទៀត និងទទួលស្គាល់នូវលទ្ធភាពដែលថា ការស្រាវជ្រាវពេលអនាគតនឹងបង្ហាញថា ការចាត់ថ្នាក់ ជិតរងគ្រោះគឺសមស្រប។ វាមានសារៈសំខាន់ដើម្បីធ្វើការប្រើប្រាស់ទិន្នន័យវិជ្ជ មានដែលអាចរកបាន។ នៅក្នុងករណីជាច្រើន ការថែទាំជិតដល់ គួរតែធ្វើឡើងក្នុងការជ្រើសរើសរវាងការខ្វះខាតទិន្នន័យ និង ស្ថានភាពគំរាមកំហែង ។

**ខ.អនុសញ្ញាសាយតេស** (CITES)

**ឧបសម្ព័ន្ធ *I*** រួមមានបណ្តាប្រភេទដែលបានទទួលការគំរាមកំហែងឈានទៅដល់ផុតពូជ។ ការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិត្រូវហាមឃាត់ដាច់ខាត លើកលែងតែក្នុងគោលបំណងនៃការនាំចេញពុំបំរើ ហេតុផលពាណិជ្ជកម្ម ហើយត្រូវមានលិខិតអនុញ្ញាតនាំចូល-នាំចេញ ឬលិខិតបញ្ជាក់ឱ្យនាំចេញបន្ត។

**ឧបសម្ព័ន្ធ *II*** រួមមានបណ្តាប្រភេទដែលមិនទាន់ទទួលការគំរាមកំហែងធ្ងន់ធ្ងរឈានទៅរកផុតពូជ។ ក្នុងនោះការធ្វើពាណិជ្ជកម្មត្រូវត្រួតពិនិត្យដោយហ្មត់ចត់ ដើម្បីចៀសវាងនូវការគំរាមកំហែងដល់ពួកវាឈានទៅរកផុតពូជ។ ការធ្វើជំនួញជាអន្តរជាតិត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវត្រួតពិនិត្យតាមប្រព័ន្ធមួយដែលមានលិខិតអនុញ្ញាតនាំចេញគ្រប់គ្រាន់។

**ឧបសម្ព័ន្ធ *III*** រួមមានបណ្តាប្រភេទដែលត្រូវបានការពារយ៉ាងហោចណាស់មាននៅក្នុងប្រភេទមួយ ហើយប្រភេទនោះបានស្នើសុំដល់ភាគី *CITES* ផ្សេងទៀតឱ្យជួយត្រួតពិនិត្យការធ្វើជំនួញ។ ការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិត្រូវបានអនុញ្ញាតតែត្រូវមានលិខិតអនុញ្ញាតនាំចេញ ឬលិខិតបញ្ជាក់ជាសំណៅដើម និងស្របតាម ច្បាប់នៃប្រទេសសាមីត្រូវនាំចេញ។

## ឧបសម្ព័ន្ធ ១.១ ៖ របបទឹកភ្លៀងប្រចាំខែពីឆ្នាំ ២០០២-២០១៥

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០០២ | **០** | **០** | **៥** | ១២៩ | ១៩១ | ២៥៦,៥ | ១១៤,៥ | ៣២៨,៥ | ៣៣៧,៥ | ៥៤ | ៧៨,៥ | ១៧ | **១.៥១១,៥** |
| ២០០៣ | ០ | ១៣ | ៤៨ | ៥៦,៥ | ៣០១ | ២២៧ | ១៩៤ | ២០៨ | ២៨៦ | ១០០ | ២៩ | ៧ | **១.៤៦៩,៥** |
| ២០០៤ | ០ | ១៦ | ២៧ | ៥១,៥ | ៨៤,៥ | ២១៩ | ១៧៨ | ២៣៤ | ៣១៧,៥ | ១៩៥ | ២៣ | ០ | **១.៣៤៥,៥** |
| ២០០៥ | ០ | ០ | ១១ | ៧៤ | ១៦៦ | ១៩០ | ២៣៣ | ១៩៥ | ៣២៧ | ១៤៦ | ៦៤ | ៤៦ | **១.៤៥២,០** |
| ២០០៦ | ០ | ៣៤ | ៧៩ | ៨៦ | ១២៧ | ១៥៤ | ២៨២,៥ | ២៥៨,៥ | ២០១ | ២៦៤,៥ | ០ | ៣៨ | **១.៥២៤,៥** |
| ២០០៧ | ០ | ០ | ១៤ | ៨៩,៥ | ៣១៩,៥ | ១៣៤ | ៤៥៧ | ៥៩០,៥ | ២៥៧,៥ | ១០៧ | ៦៦ | ០ | **២.០៣៥,០** |
| ២០០៨ | ២,២ | ៨,២ | ៤៩,៧ | ១៥០ | ៣៣៦,៩ | ២៧៩,៧ | ២០៩,១ | ១៤៥,៩ | ៣២០ | ២៥០,៩ | ៥៣ | ០ | **១.៨០៥,៦** |
| ២០០៩ | ០ | ៣,៧ | ១៣,៨ | ៩៤,៦ | ១៧៩,៩ | ១៧៧,៣ | ៣១០,៥ | ១៥២,៧ | ៥៣២,៤ | ១២៦,២ | ៤១,៨ | ០ | **១.៦៣២,៩** |
| ២០១០ | ១៥,៣ | ០ | ០,១ | ១២,៦ | ៨១,៣ | ១៥៧,៩ | ២៧០,៥ | ២៦៤,១ | ២៧២,៩ | ២២៦ | ០ | ០ | **១.៣០០,៧** |
| ២០១១ | ០ | ០ | ៨៦,១ | ១៧៥,៧ | ១១១,៧ | ១៩០,៥ | ១៩៤,៨ | ២២៥,១ | ៥៣៧,២ | ២៩៤,៦ | ២៩,៨ | ៤,៦ | **១.៨៥០,១** |
| ២០១២ | ០,៤ | ០ | ៣,២ | ៣៩,១ | ១៤៧,៦ | ១៥៣,៩ | ២១២,៧ | ១៦៤,១ | ៥០០ | ១៦០,៣ | ៦១,៩ | ១៥ | **១.៤៥៨,២** |
| ២០១៣ | | | ៦១,០ | ១៨៣,១ | | ១៨៨,២ | | ១៧៨,៨ | ៥០៣,៦ | ៣២៦,២ | - | - | **១.៤៤០,៩** |
| ២០១៤ | - | ៤៩,០ | | ១៥៩,០ | ១៣៥,៤ | ២៨៩,៥ | ៣៤៨,៦ | ២៤៨,៦ | ២៤៩,៥ | ៩៩,៧ | ១០,០ | | **១.៥៨៩,៣** |
| ២០១៥ | | - | ៤៤,៥ | ៥១,៦ | ៧៩,៦ | ១៥៤,៥ | ៤០៩,៦ | ២៨១,៨ | ១៨៤,៤ | ១៥៣,២ | | | **១.៣៥៩,២** |
| សរុប | **១៧,៩** | **៧៤,៩** | **៣៣៦,៩** | **៩៥៨,៥** | **២.០៤៦,៤** | **២.១៣៩,៨** | **២.៦៥៦,៦** | **២.៧៦៦,៤** | **៣.៨៨៩** | **១.៩២៤,៥** | **៤៤៧** | **១២៧,៦** | |
| មធ្យម | **១,៥** | **៩,៥** | **៣៤,០** | **៩៦,៦** | **១៧៣,៩** | **១៩៨,០** | **២៦២,៧** | **២៤៨,៣** | **៣៤៤,៧** | **១៧៨,៨** | **៣៥,២** | **១០,៦** | **១.៥៩៣,៩** |
| អតិបរមា | **១៥,៣** | **៤៩,០** | **៨៦,១** | **១៨៣,១** | **៣៣៦,៩** | **២៨៩,៥** | **៤៥៧,០** | **៥៩០,៥** | **៥៣៧,២** | **៣២៦,២** | **៧៨,៥** | **៤៦,០** | **២.០៣៥,០** |

ប្រភពៈ ស្ថានីយ៍ឧតុនិយមគូលែន ខេត្តសៀមរាប ឆ្នាំ២០១៥

## ឧបសម្ព័ន្ធ ១.២ ៖ សីតុណ្ហភាពសរុបប្រចាំខែ ពីឆ្នាំ ១៩៩៤-២០១២

ក-សីតុណ្ហភាពសរុបអតិបរមាប្រចាំខែ ពីឆ្នាំ ១៩៩៤-២០១២

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៩៩៤ | ៣១ | ៣២,៩ | ៣៤,៣ | ៣៧,៨ | ៣៥,២ | ៣២,៥ | ៣២,៥ | ៣២,៩ | ៣១,៥ | ៣២ | ២៩,៣ | ២៩ | **៣២,៥** |
| ១៩៩៥ | ៣១,២ | ៣២,៣ | ៣២,៦ | ៣៨,៩ | ៣៥ | ៣៤,៥ | ៣២ | ៣០,៦ | ៣១,៣ | ៣០,២ | ៣០ | ២៩ | **៣២,៣** |
| ១៩៩៦ | ៣១,៦ | ៣២,៥ | ៣៣,២ | ៣៧,៥ | ៣៦,៩ | ៣៣,៦ | ៣២,៦ | ៣១,៥ | ៣២ | ២៩,៨ | ៣០,២ | ២៩,១ | **៣២,៥** |
| ១៩៩៧ | ៣១,២ | ៣២ | ៣៣,៦ | ៣៦,៨ | ៣៦,៥ | ៣៣,៨ | ៣០,៣ | ៣១ | ៣១ | ២៩ | ៣០,១ | ៣០ | **៣២,១** |
| ១៩៩៨ | ៣១,៥ | ៣៣,២ | ៣៤,៥ | ៣៥,៩ | ៣៤,៦ | ៣៥,៦ | ៣២,២ | ៣១,៥ | ៣២ | ២៩,៦ | ២៩,៨ | ៣០,៦ | **៣២,៦** |
| ១៩៩៩ | ៣១,៤ | ៣២,៣ | ៣៥,២ | ៣៥,៦ | ៣៥,៦ | ៣៣,៤ | ៣២,៥ | ៣១,៦ | ៣១,៥ | ៣០ | ២៩ | ៣០,២ | **៣២,៤** |
| ២០០០ | ៣០,៣ | ៣៥,២ | ៣៥,៣ | ៣៥,៦ | ៣៥,៤ | ៣៣,១ | ៣២,៦ | ៣១,៣ | ៣០,៦ | ៣០,៥ | ២៩,៥ | ៣០,៥ | **៣២,៥** |
| ២០០១ | ៣១,៥ | ៣៤,៤ | ៣៦,២ | ៣៥,៧ | ៣៥,៦ | ៣៣ | ៣២ | ៣២ | ៣០,៤ | ៣០,៦ | ២៩,៦ | ៣០ | **៣២,៦** |
| ២០០២ | ៣៤,៧ | ៣៥,៥ | ៣៧,៩ | ៨,៦ | ៣៧,៧ | ៣៧ | ៣៤,៧ | ៣៤ | ៣២,៥ | ៣២,៥ | ៣២,៦ | ៣២,៧ | **៣៥** |
| ២០០៣ | ៣៣,២ | ៣៤,៥ | ៣៦,២ | ៣៧,៨ | ៣៨,៥ | ៣៦,៥ | ៣៥,៦ | ៣៤,៧ | ៣៣ | ០ | ០ | ០ | **៣៥,៦** |
| ២០០៤ | ៣២,០ | ៣២,៨ | ៣៥,៧ | ៣៦,៦ | ៣៥,៥ | ៣៣,២ | ៣៣,០ | ៣២,៦ | ៣១,៨ | ៣១,៧ | ៣២,៤ | ៣០,៩ | **៣៣,២** |
| ២០០៥ | ៣១,៣ | ៣៤,០ | ៣៥,០ | ៣៦,៥ | ៣៥,៦ | ៣២,៣ | ៣២,២ | ៣២,២ | ៣១,៥ | ៣១,៥ | ៣១,៤ | ២៩,៣ | **៣២,៧** |
| ២០០៦ | ៣១,៦ | ៣៣,២ | ៣៤,២ | ៣៤,៩ | ៣៥,០ | ៣៤,៦ | ៣២,៨ | ៣២,៤ | ៣១,៧ | ៣១,០ | ៣២,០ | ៣១,៥ | **៣២,៩** |
| ២០០៧ | ៣១,៦ | ៣២,៩ | ៣៤,៨ | ៣៥,៧ | ៣៣,៥ | ៣៣,៩ | ៣២,៩ | ៣២,១ | ៣២,៤ | ៣១,៣ | ៣០,៩ | ៣១,៦ | **៣២,៨** |
| ២០០៨ | ៣១,៨ | ៣១,៩ | ៣៣,៩ | ៣៥,៥ | ៣៣,១ | ៣២,៩ | ៣២,៩ | ៣២,៩ | ៣១,៤ | ៣២,២ | ៣០,១ | ២៩,៧ | **៣២,៤** |
| ២០០៩ | ៣១,៨ | ៣១,៩ | ៣៤,២ | ៣៤,៩ | ៣៣,២ | ៣៣,០ | ៣៣,២ | ៣២,៩ | ៣១,៤ | ៣១,៩ | ៣០,៣ | ២៩,៤ | **៣២,៣** |
| ២០១០ | ៣១,៩ | ៣៤,២ | ៣៧,០ | ៣៩,២ | ៣៧,៧ | ៣៥,៦ | ៣៣,៧ | ៣២,២ | ៣២,៦ | ៣១,៨ | ៣១,២ | ៣១,៦ | **៣៤,១** |
| ២០១១ | ៣០,៤ | ៣២,៧ | ៣២,៣ | ៣២,៤ | ៣៤,១ | ៣២,២ | ៣៣,០ | ៣១,៩ | ៣០,១ | ៣០,៥ | ៣២,៥ | ៣០,៣ | **៣១,៩** |
| ២០១២ | ៣១,៨ | ៣៤,០ | ៣៤,៧ | ៣៥,៩ | ៣៥,៨ | ៣៤,៤ | ៣៣,៨ | ៣៣,៤ | ៣០,៧ | ៣២,៣ | ៣២,៨ | ៣៣,៦ | **៣៣,៦** |
| សរុប | **៣១៧,៦** | **៣៣៣,៩** | **៣៤៩,០** | **៣៧០,២** | **៣៦១,០** | **៣៤៣,០** | **៣២៧,០** | **៣២១,១** | **៣១៥,៨** | **២៧៤,២** | **២៧០,១** | **២៧១,១** | |
| មធ្យម | **៣១,៧** | **៣៣,៣** | **៣៤,៨** | **៣៦,៤** | **៣៥,៥** | **៣៤,០** | **៣២,៩** | **៣២,៣** | **៣១,៥** | **២៩,៤** | **២៩,១** | **២៨,៩** | ៣២,៩ |
| អតិបរមា | **៣៤,៧** | **៣៥,៥** | **៣៧,៩** | **៣៩,២** | **៣៨,៥** | **៣៧** | **៣៥,៦** | **៣៤,៧** | **៣៣** | **៣២,៥** | **៣២,៨** | **៣៣,៦** | ៣៥,៦ |

ប្រភពៈ ស្ថានីយ៍ឧតុនិយមគូលែន ខេត្តសៀមរាប ឆ្នាំ២០១៥

ខ-សីតុណ្ហភាពសរុបអប្បបរមាប្រចាំខែ ពីឆ្នាំ ១៩៩៤-២០១២

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៩៩៤ | ២០,៩ | ២១,៩ | ២៥,៥ | ២៣,៨ | ២៤,៥ | ២៤,៤ | ២៤,៩ | ២៥ | ២៥,១ | ២៣,២ | ២៤,២ | ២៤ | **២៤** |
| ១៩៩៥ | ២២,២ | ២១,៤ | ២៣,៦ | ២៥,៣ | ២៥,១ | ២៤,៧ | ២៤,៧ | ២៤,៧ | ២៤,៦ | ២៤,៤ | ២៤ | ២៣,៥ | **២៤** |
| ១៩៩៦ | ២០,៣ | ២២,១ | ២៤,៤ | ២៥,៧ | ២៥,៥ | ២៤,៧ | ២៥ | ២៥ | ២៥,១ | ២៥,១ | ២៤,៧ | ២៣,៥ | **២៤,៣** |
| ១៩៩៧ | ១៩,៨ | ២២ | ២៧,៤ | ២៥ | ២៥,២ | ២៤,៦ | ២៤,៨ | ២៤,៨ | ២៤,៤ | ២៤ | ២២,៨ | ២១,៣ | **២៣,៨** |
| ១៩៩៨ | ១៩,៤ | ២២,១ | ២៩,៥ | ២៤,៨ | ២៥,៥ | ២៤,៧ | ២៤,៥ | ២៤,៥ | ២៣,៨ | ២៣,២ | ២១,៦ | ២០,៦ | **២៣,៧** |
| ១៩៩៩ | ១៩,៨ | ១៨,៨ | ២៣,៦ | ២៤,៧ | ២៤,៧ | ២៤,៨ | ២៤,៧ | ២៤,៧ | ២៤,៦ | ២៣,៥ | ២១,៤ | ១៩,៣ | **២២,៩** |
| ២០០០ | ១៩,៦ | ២០,៨ | ២៤,៧ | ២៥,៦ | ២៦,១ | ២៤,៩ | ២៤,៩ | ២៥,២ | ២៤,៧ | ២៤,៦ | ២២,៨ | ២០,១ | **២៣,៧** |
| ២០០១ | ១៩,៩ | ២០,៥ | ២៥,២ | ២៥,៣ | ២៥,៥ | ២៥ | ២៥,១ | ២៥,៤ | ២៤,៩ | ២៤,៣ | ២៣,២ | ១៩,៨ | **២៣,៧** |
| ២០០២ | ២៩,៥ | ៣១,៥ | ៣១,៧ | ៣២,៣ | ២៨,៥ | ៣០,៨ | ៣០ | ២៧,៦ | ២៨,៥ | ២៩ | ២៧,២ | ២៨,៩ | **២៩,៦** |
| ២០០៣ | ២៦,៨ | ២៩,៥ | ២៩,៨ | ៣១,៣ | ៣១,៥ | ៣១,៦ | ២៩,៩ | ២៨,៨ | ៣០ | - | - | - | **២៩,៩** |
| ២០០៤ | ២១,៦ | ២២,២ | ២៤,៥ | ២៥,២ | ២៥,៧ | ២៤,៧ | ២៥,១ | ២៥,៥ | ២៤,៩ | ២៣,៩ | ២៣,៤ | ១៩,៥ | **២៣,៩** |
| ២០០៥ | ២០,១ | ២៣,០ | ២៣,៩ | ២៥,៧ | ២៥,៧ | ២៤,៣ | ២៤,៨ | ២៤,៧ | ៣១,៧ | ២៤,២ | ២៣,៣ | ២០,៦ | **២៤,៣** |
| ២០០៦ | ២១,០ | ២៣,១ | ២៤,១ | ២៤,៦ | ២៤,៥ | ២៤,២ | ២៤,៥ | ២៤,៤ | ២៤,២ | ២៤,៣ | ២៣,៥ | ២០,៨ | **២៣,៦** |
| ២០០៧ | ១៩,៧ | ២១,៣ | ២៤,៧ | ២៥,១ | ២៤,៧ | ២៥,៨ | ២៤,៧ | ២៤,៩ | ២៤,៩ | ២៣,៧ | ២០,០ | ២១,០ | **២៣,៤** |
| ២០០៨ | ១៨,៥ | ១៩,៦ | ២១,៨ | ២៤,០ | ២៤,២ | ២៤,៤ | ២៤,៣ | ២៤,៥ | ២៤,០ | ២៤,៣ | ២២,២ | ២០,១ | **២២,៧** |
| ២០០៩ | ២១,០ | ២១,៤ | ២៣,៥ | ២៥,៥ | ២៥,២ | ២៥,៤ | ២៥,២ | ២៥,០ | ២៤,៧ | ២៥,២ | ២២,៦ | ២០,១ | **២៣,៧** |
| ២០១០ | ២១,៨ | ២៤,១ | ២៤,៨ | ២៦,៨ | ២៧,០ | ២៦,១ | ២៥,៣ | ២៥,២ | ២៥,៤ | ២៥,៩ | ២២,៩ | ២១,៦ | **២៤,៧** |
| ២០១១ | ១៨,៩ | ២២,៤ | ២២,៨ | ២៣,៩ | ២៥,៥ | ២៤,៨ | ២៤,៩ | ២៤,៩ | ២៥,១ | ២៤,៣ | ២៣,៦ | ២០,៣ | **២៣,៥** |
| ២០១២ | ២១,៨ | ២៣,៧ | ២៣,៩ | ២៥,៦ | ២៦,៣ | ២៥,៧ | ២៥,៣ | ២៥,៨ | ២៤,៩ | ២៥,៥ | ២៦,១ | ២៣,៦ | **២៤,៩** |
| សរុប | **៤០២,៥** | **៤៣១,៣** | **៤៧៩,៥** | **៤៩០,១** | **៤៩០,៨** | **៤៨៥,៥** | **៤៨២,៥** | **៤៨០,៦** | **៤៨៥,៦** | **៤៤២,៧** | **៤១៩,៥** | **៣៨៨,៧** | |
| មធ្យម | **២១,២** | **២២,៧** | **២៥,២** | **២៥,៨** | **២៥,៨** | **២៥,៦** | **២៥,៤** | **២៥,៣** | **២៥,៦** | **២៤,៦** | **២៣,៣** | **២១,៦** | ២៤,៤ |
| អតិបរមា | **១៨,៥** | **១៨,៨** | **២១,៨** | **២៣,៨** | **២៤,២** | **២៤,២** | **២៤,៣** | **២៤,៤** | **២៣,៨** | **២៣,២** | **២០,០** | **១៩,៣** | **២២,៧** |

ប្រភព: ស្ថានីយ៍ឧតុនិយមគូលែន ខេត្តសៀមរាប ឆ្នាំ២០១៥

## ឧបសម្ព័ន្ធ ១.៣.គៈ ប្រភេទឈើសំខាន់ៗក្នុងតំបន់ព្រៃការពារព្រះវិហារ

យោងតាមសៀវភៅប្រភេទឈើអាទិភាពចំនួន២១ប្រភេទ សំរាប់អភិរក្សហ្សែនព្រៃឈើក្នុងប្រទេសកម្ពុជា (Chheang Dany, 2002) នៅក្នុង និងជុំវិញតំបន់ព្រៃការពារព្រះវិហារ មានប្រភេទឈើអាទិភាព និងមានតំលៃជាច្រើនរួមមាន៖

**នាងនួន** (ជាប្រភេទឈើរងគ្រោះជិតផុតពូជនៅក្នុងបញ្ជីក្រហម IUCN)

អត្តសញ្ញាណ

| | | |
|---|---|---|
| ឈ្មោះវិទ្យាសាស្ត្រ | : | *Dalbergia oliveri* |
| ឈ្មោះផ្សេងៗ | : | *Dalbergia dongnaiense* Pierre |
| អំបូរ | : | Leguminosae |
| អនុអំបូរ | : | Papilionoideae |
| ចំណាត់ថ្នាក់នៅកម្ពុជា | : | ឈើប្រណិត |

**របាយ និងជំណុះ៖** មាននៅពាសពេញប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម (Dy Phon, 2000)។ ដើមនាង នួន ដុះតែឯង ឬជាក្រុម ៥-១០ ដើម។ ជាទូទៅ នាងនួនច្រើនដុះនៅក្នុងព្រៃស្រោងតំបន់ត្រូពិក ឬព្រៃពាក់កណ្តាលស្រោងដែលលប់ដោយពពួកស្រឡៅ និងពពួកឈើជម្រុះស្លឹក (Dipterocarps)។ នាងនួនដុះនៅរយៈកម្ពស់ទាប (<៩០០ ម៉ែត្រ) ហើយជាទូទៅច្រើនដុះនៅតំបន់មានសំណើមតាមបណ្តោយដងអូរ និងនៅតាមតំបន់ ទីទួលខ្ពស់ៗ។ កូននាងនួនអាចរស់នៅក្រោមម្លប់នៅពេលវានៅតូច ប៉ុន្តែជាទូទៅវាត្រូវការ ពន្លឺ។ ដើមនាងនួនអាចផលិតគ្រាប់ពូជបានច្រើន ប៉ុន្តែជាធម្មតារបាយរបស់វាក្នុងធម្មជាតិមិនសូវសំបូរទេ ដោយសារអត្រាដំណុះទាប ឬលក្ខខណ្ឌតាមតំបន់ និងអាកាសធាតុមិនអំណោយផល។ ជាទូទៅ ដើមនាងនួន លូតលាស់យឺតទាំងនៅក្នុងធម្មជាតិ និងតំបន់ព្រៃ ដាំដោយមនុស្ស (CTSP, 2001)។

នៅកម្ពុជា ឈើនាងនួនឃើញមានដុះនៅក្នុងខេត្តក្រចេះ ព្រះវិហារ កំពង់ធំ រតនគីរី ស្ទឹងត្រែង ពោធិសាត់ សៀមរាប (Khorn, 2002) កំពង់ស្ពឺ និងខេត្តកោះកុង។

**ការប្រើប្រាស់៖** ដោយងាយស្រួលខាត់ឱ្យរលោង ឈើនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសំរាប់ផលិតគ្រឿងសង្ហារឹមដែលមានគុណភាពខ្ពស់ ដូចជា តុ ទូ វត្ថុអនុស្សាវរីយ៍ និងប្រើប្រាស់សំរាប់ការតុបតែងលម្អរផ្សេងៗ។ល។

**ស្ថានភាពបច្ចុប្បន្ន៖** ដោយសារមានតម្លៃសេដ្ឋកិច្ច ឈើនាងនួនកំពុងប្រឈមនឹងការថយចុះយ៉ាងធ្ងន់ធ្ងរដោយសារកាប់ដោយខុសច្បាប់។ ឈើនាងនួងដែលនៅសេសសល់មានតិចតួចណាស់ ហើយប្រហែលជាកំពុងបាត់បង់នៅតាមតំបន់មួយចំនួន។ នៅតាមតំបន់ជាច្រើន គេកម្រឃើញដើមនាងនួនធំៗ និងពេញវ័យណាស់។ កិច្ចខិតខំប្រឹងប្រែងដើម្បីបណ្តុះ និងដាំឈើប្រភេទនេះជាទ្រង់ទ្រាយធំនៅមានកំរិត។ ប្រភេទនាងនួនកំពុងប្រឈមនឹងការឈាន ទៅរកភាពហិនហោច ប្រសិនបើគ្មានវិធានការការពារឱ្យមានប្រសិទ្ធភាពទេនោះ (CTSP, 2001)។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជាស្តីពីយុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃ ឈើបានកំណត់ឈើនាងនួនជាប្រភេទអាទិភាពមួយ និងជាប្រភេទមួយដែលត្រូវមានកិច្ចអន្តរាគមន៍អភិរក្សជាបន្ទាន់ និងការពារឱ្យបានសមស្រប។ ឈើប្រភេទនេះត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើរបស់កម្ពុជា។

**ក្រញូង** (ជាប្រភេទឈើងាយរងគ្រោះនៅក្នុងបញ្ជីក្រហម IUCN)
អត្តសញ្ញាណ
ឈ្មោះវិទ្យាសាស្ត្រ : *Dalbergia cochinchinensis* Pierre
ឈ្មោះផ្សេងៗ : *Dalbergia cambodiana* Pierre
អំបូរ : *Leguminosaea*
អនុអំបូរ : *Papilionoideae*
ចំណាត់ថ្នាក់នៅកម្ពុជា : ឈើប្រណិត

**របាយ និងដំណុះ៖** មានប្រភពនៅតំបន់ឥណ្ឌូចិន និងបណ្តាប្រទេសជិតខាង ក្រញូងធន់នឹងម្លប់ពេលវានៅតូច។ ជាធម្មតា វាដុះរាយប៉ាយនៅតំបន់ព្រៃចំរុះ ចាប់ពីរយៈកម្ពស់ ៤០០-៥០០ម និងចូលចិត្តដុះនៅលើដីខ្សាច់ ដីឥដ្ឋ ឬ ប្រភេទដីមានជាតិកំបោរ (Khorn, 2002)។ ក្រញូងច្រើនដុះតាមតំបន់ដែលមានកំពស់ទឹកភ្លៀងចន្លោះពី ១២០០-១៦៥០មម/ឆ្នាំ។ ក្រញូងជាប្រភេទឈើត្រូវការពន្លឺថ្ងៃដើម្បីដុះលូតលាស់ និងជាប្រភេទធន់នឹងភាពរាំងស្ងួត ហើយអាចដុះលូតលាស់នៅលើដីសើម (DFSC, 2000)។ ក្នុងប្រទេសកម្ពុជា ក្រញូងមានដុះនៅខេត្តកំពង់ធំ ព្រះវិហារ រតនគីរី ពោធិសាត់ សៀមរាប ក្រចេះ កោះកុង ស្ទឹងត្រែង និងខេត្តមណ្ឌលគីរី (Khorn, 2002)។

**ការប្រើប្រាស់៖** ឈើក្រញូងមានតម្លៃខ្ពស់ និងត្រូវបានប្រើប្រាស់សំរាប់ផលិតគ្រឿងសង្ហារឹមមានគុណភាពខ្ពស់ វត្ថុអនុស្សាវរីយ៍ និងឧបករណ៍ភ្លេង។ ឬសកែវ និងឬសរយោងអាចប្រើប្រាស់ផងដែរសំរាប់ជាវត្ថុ អនុស្សាវរីយ៍មានគុណភាពល្អ (CTSP, 2001) និងមានតម្លៃខ្ពស់សំរាប់ធ្វើការនាំចេញ។

**ស្ថានភាពបច្ចុប្បន្ន៖** ក្រញូងមានដុះនៅក្នុងតំបន់ព្រៃសម្បទាន (ព្រៃពាណិជ្ជកម្ម) តំបន់ព្រៃការពារ តំបន់ការពារ និងតំបន់ផ្សេងៗទៀត ជាពិសេសនៅតំបន់ខ្ពស់ៗភាគខាងជើងនៃប្រទេសកម្ពុជា។ ការកាប់រំលំដោយខុសច្បាប់នៅ ក្នុងតំបន់ជាច្រើនបណ្តាលឱ្យឈើប្រភេទនេះនៅសេសសល់តិចតួចក្នុងធម្មជាតិ។ បញ្ហានេះបង្ហាញថាគេពិបាកក្នុងការស្វែងរកប្រភពដំណុះរបស់វាទាំងនៅក្នុង និងក្រៅតំបន់ព្រៃការពារ តំបន់ការពារ ឬឧទ្យាន ជាតិ។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជាស្តីពីយុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃឈើបានកំណត់ដើមក្រញូងជាប្រភេទអាទិភាពមួយ ដែលត្រូវមានកិច្ចអន្តរាគមន៍ និងអភិរក្សបន្ទាន់ ព្រមទាំងការពារឱ្យបានសមស្រប។ ក្រញូងជាប្រភេទរុក្ខជាតិឈើដែលត្រូវបានការពារដោយច្បាប់ស្តីពី ព្រៃឈើ។

**បេង** (ជាប្រភេទឈើរងគ្រោះជិតផុតពូជនៅក្នុងបញ្ជីក្រហម IUCN)
អត្តសញ្ញាណ
ឈ្មោះវិទ្យាសាស្ត្រ : *Afzelia xylocarpa* (Kurz) Craib
ឈ្មោះផ្សេងៗ : Pahudia cochinchinensis Pierre
អំបូរ : Leguminosae
ចំណាត់ថ្នាក់នៅកម្ពុជា : ឈើប្រណិត

**របាយ និងដំណុះ៖** គេឃើញឈើបេងដុះនៅក្នុងប្រទេសឡាវ ថៃ កម្ពុជា និងវៀតណាម។ ឈើបេងគឺជាប្រភេទត្រូវការពន្លឺ និងដុះលូតលាស់តាមដងអូរ ឬតំបន់ចន្លោះព្រៃស្រោង និងព្រៃល្បោះ នៅចន្លោះរយៈ

កម្ពស់ពី ៥០០-៧០០ម។ ឈើបេងមានដុះផងដែរនៅតំបន់មានរយៈកម្ពស់លើសពី ៩០០ម (Dy Phon, 2000) នៅក្នុងព្រៃចម្រុះ។ ជាញឹកញយ ដើមបេងដុះលាយឡំជាមួយដើមនាងនួន ធ្នង់ ស្រឡៅ ខ្លុង និងសំពង់។ ដើមបេងដុះរាយប៉ាយ ក្នុងតំបន់ព្រៃចម្រុះ។ នៅក្នុងប្រទេសកម្ពុជា ឈើបេងមានដុះក្នុងខេត្ត កំពង់ធំ ក្រចេះ ស្ទឹងត្រែង ព្រះវិហារ កំពត សៀមរាប បាត់ដំបង រតនគីរី មណ្ឌលគីរី និងខេត្តពោធិ៍សាត់ (Khorn, 2002)។

**ការប្រើប្រាស់៖** ឈើបេងជាប្រភេទឈើមានតម្លៃដែលមានពណ៌ក្រម៉ៅ ឬពណ៌ក្រហមស្រាល មានសសៃសាច់ឈើរឹងល្អ និងជាប់បានយូរ។ ឈើបេងត្រូវបានប្រើប្រាស់សំរាប់សំណង់ផ្ទះ តុ ទូ និងវត្ថុអនុស្សាវរីយ៍មានគុណភាពខ្ពស់ (CTSP, 2001)។ សំបកបេងប្រើសំរាប់ជាថ្នាំសម្លាប់ស្បែកសត្វ ជាឱសថក្នុងស្រុក ព្រមទាំងជាឱសថ សំរាប់ព្យាបាលសត្វពាហនៈផងដែរ (Dy Phon, 2000)។ គ្រាប់នៅតូចមានកូទីឡេដុង ពីរ ដែលអាចបរិភោគបាន (DFSC, 2000) ។

**ស្ថានភាពបច្ចុប្បន្ន៖** ដោយសារឈើបេងមានតម្លៃ ទើបឈើប្រភេទនេះត្រូវបានធ្វើអាជីវកម្មហួសកំរិត និងឈានទៅរកផុតពូជ ប្រសិនបើគ្មានវិធានការការពារឱ្យបានគ្រាប់គ្រាន់។ ភាគច្រើន ឈើបេងកំពុងធ្លាក់ចុះយ៉ាងខ្លាំងនៅតាមតំបន់ជាច្រើន និងមានការលំបាកក្នុងការស្វែងរកដើមបេងដែលអាចផ្តល់គ្រាប់ពូជណាស់។ ចំនួនដើមបេងផ្តល់ផ្លែត្រូវបានថយចុះគួរឱ្យកត់សម្គាល់ ហើយបច្ចុប្បន្ន គេពិបាកស្វែងរកប្រភពដើមមេផ្តល់គ្រាប់ពូជ។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជាស្តីពី យុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃឈើបានកំណត់ដើមបេងជាប្រភេទរុក្ខជាតិឈើអាទិភាពមួយ ដែលត្រូវមានកិច្ចអន្តរាគមន៍អភិរក្សជា បន្ទាន់។ រុក្ខជាតិឈើបេងត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើ។

**ធ្នង់** (ជាប្រភេទឈើងាយរងគ្រោះនៅក្នុងបញ្ជីក្រហម IUCN)
អត្តសញ្ញាណ
ឈ្មោះវិទ្យាសាស្ត្រ : *Pterocarpus macrocarpus Kurz*
អំបូរ : Fabacea
ចំណាត់ថ្នាក់នៅកម្ពុជា : ឈើប្រណិត

**របាយ និងដំណុះ៖** ឈើធ្នង់ជាប្រភេទឈើ ដែលមានច្រើនបង្គួរក្នុងព្រៃល្បោះនៅប្រទេសកម្ពុជា ឡាវ និង វៀតណាម (FIPI, 1996)។ នៅក្នុងប្រទេសកម្ពុជា ធ្នង់មានដុះនៅក្នុងព្រៃល្បោះ ឬព្រៃរេចរឹលដែលមានរយៈកម្ពស់រហូតដល់ ៧០០ម (Dy Phon, 2000)។ជាទូទៅ ដើមធ្នង់ដុះលាយឡំ ជាមួយប្រភេទឈើផ្សេងទៀត ប៉ុន្តែដុះជាប្រភេទលប់។ ឈើធ្នង់ត្រូវការពន្លឺ ហើយធន់នឹងភាពរាំងស្ងួតដែល អាចដុះនៅតាមដីមានស្រទាប់លើរាក់ និងមានសំណើមតិច (Khorn, 2002)។ ឈើធ្នង់មានដុះនៅក្នុងខេត្តកំពង់ធំ ស្ទឹងត្រែង ព្រះវិហារ រតនគីរី ក្រចេះ សៀមរាប កំពត ពោធិសាត់ និងមណ្ឌលគីរី (Khorn, 2002) កំពង់ស្ពឺ និង ខេត្តកោះកុង។

**ការប្រើប្រាស់៖** ឈើប្រភេទនេះត្រូវបានប្រើប្រាស់ដើម្បីផលិតគ្រឿងសង្ហារឹមប្រណិត តុ ទូ និងវត្ថុអនុស្សាវរីយ៍ ឧបករណ៍តន្ត្រី និងធ្វើកម្រាល (FIPI, 1996)។

**ស្ថានភាពបច្ចុប្បន្ន៖** នៅក្នុងប្រទេសកម្ពុជា ភាគច្រើនឈើធ្នង់ដុះនៅភាគខាងជើង។ មួយភាគធំ ឈើធ្នង់ត្រូវបានប្រមូលពីព្រៃធម្មជាតិ ហើយឈើប្រភេទនេះកំពុងទទួលរងការធ្វើអាជីវកម្មហួសកំរិត និងការពង្រីកដីធ្វើ

កសិកម្ម (CTSP, 2001)។ ដំណុះនៅក្នុងធម្មជាតិរបស់វាកំពុងត្រូវបានបំផ្លាញ ហើយឈើប្រភេទនេះកំពុងប្រឈមនឹងការផុតផុតពូជ ប្រសិនបើគ្មានវិធានការការពារ។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជា ស្ដីពីយុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃឈើបានកំណត់ដើមធ្នង់ជាប្រភេទរុក្ខជាតិឈើអាទិភាពមួយ ដែលត្រូវការសំរាប់អន្តរាគមន៍អភិរក្សជាបន្ទាន់ និង ការពារឱ្យបានសមស្រប។ ដើមធ្នង់ក៏ត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើផងដែរ។

## ឈើខ្មៅ

អត្តសញ្ញាណ

ឈ្មោះវិទ្យាសាស្ត្រ : *Diospyros creunata Thwaites*

អំបូរ : Ebanaceae

ចំណាត់ថ្នាក់នៅកម្ពុជា : ឈើប្រណិត

**របាយ និងដំណុះ៖** មានដុះនៅក្នុងព្រៃស្រោង និងព្រៃចំរុះនៃតំបន់អាស៊ីខាងកើត។

**ការប្រើប្រាស់៖** ឈើខ្មៅមានតម្លៃសំរាប់ច្នៃជាគ្រឿងលំអ និងធ្វើអុសឆេះល្អ (Dy Phon,2000) ។

ស្ថានភាពបច្ចុប្បន្ន៖ ដោយសារឈើខ្មៅមានតម្លៃ និងតម្រូវការខ្ពស់ ទើបឈើប្រភេទនេះរងការធ្វើអាជីវកម្មហួសកំរិត និងអាចឈានទៅរកផុតពូជ ប្រសិនបើគ្មានវិធានការការពារសមស្រប។ ឈើខ្មៅដុះរាយប៉ាយ និងនៅតាម តំបន់ខ្លះដំណុះរបស់វាត្រូវទទួលរងការបំផ្លាញដោយសារការបង្វែរដីព្រៃឈើ និងការកាប់ឱ្យ រហាល។ លើសពីនេះ ឈើប្រភេទនេះត្រូវបានកាប់ដោយជ្រើសរើសចេញពីព្រៃធម្មជាតិ។ ចំនួនដើមឈើខ្មៅ ដែលអាចផ្តល់គ្រាប់ពូជត្រូវ បានកំពុងថយចុះគួរឱ្យកត់សម្គាល់ ហើយបច្ចុប្បន្ននៅកម្ពុជាគេពិបាកស្វែងរក ប្រភពដើមមេផ្តល់គ្រាប់ពូជណាស់។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជា ស្ដីពីយុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃឈើបានកំណត់ដើមឈើខ្មៅជាប្រភេទរុក្ខជាតិអាទិភាពមួយ ដែលត្រូវមានកិច្ចអន្តរាគមន៍អភិរក្សជាបន្ទាន់ និង ការពារឱ្យបានសមស្រប។ ដើមឈើខ្មៅត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើ។

## អង្កត់ខ្មៅ

អត្តសញ្ញាណ

ឈ្មោះវិទ្យាសាស្ត្រ : *Diospyros bejaudii Lecomts*

អំបូរ : Ebenaceae

ចំណាត់ថ្នាក់នៅកម្ពុជា : ឈើប្រណិត

**របាយ និងដំណុះ៖** មានដុះនៅក្នុងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងនៃប្រទេសកម្ពុជាដែលជាប្រភេទឈើ មានដុះតែនៅតាមតំបន់ខ្លះប៉ុណ្ណោះ (Dy Phon, 2000)។

**ការប្រើប្រាស់៖** ឈើប្រភេទនេះប្រើប្រាស់សំរាប់ធ្វើគ្រឿងសង្ហារឹម ដងកាំបិត និងជួនកាលសំរាប់ធ្វើឧបករណ៍ភ្លេង (Dy Phon, 2000)។

**ស្ថានភាពបច្ចុប្បន្ន៖** ដោយសារអង្គត់ខ្មៅមានតម្លៃ និងតម្រូវការខ្ពស់ ទើបឈើប្រភេទនេះរងការធ្វើអាជីវកម្ម ហួសកំរិត និងអាចឈានទៅរកផុតពូជ ប្រសិនបើគ្មានវិធានការការពារសមស្រប។ ឈើអង្គត់ខ្មៅដុះរាយប៉ាយ និងនៅតាមតំបន់ខ្លះដំណុះរបស់វាត្រូវទទួលរងការបំផ្លាញដោយសារការបង្វែរដីព្រៃឈើ និងការកាប់ដោយខុសច្បាប់។ ចំនួនដើមអង្គត់ខ្មៅ ដែលអាចផ្តល់គ្រាប់ពូជបានកំពុងថយចុះគួរឱ្យកត់សម្គាល់ ហើយបច្ចុប្បន្ននៅកម្ពុជា គេពិបាកស្វែងរកប្រភពដើមមេផ្តល់គ្រាប់ពូជណាស់។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជា ស្តីពីយុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃឈើបានកំណត់ដើមអង្គត់ខ្មៅជាប្រភេទអាទិភាពមួយ ដែលត្រូវមានកិច្ចអន្តរាគមន៍អភិរក្សជាបន្ទាន់ និងការពារឱ្យបានសមស្រប។ ដើមអង្គត់ខ្មៅត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើ។

**តាត្រាវ**

អត្តសញ្ញាណ

ឈ្មោះវិទ្យាសាស្ត្រ : *Fagraea fragrans Pit*

អំបូរ : Loganiaceae

ចំណាត់ថ្នាក់នៅកម្ពុជា : ឈើប្រណិត

**របាយ និងដំណុះ៖** ឈើប្រភេទនេះសំបូរក្នុងប្រទេសកម្ពុជា វៀតណាម ឡាវ ថៃ ភូមា ស៊ូម៉ាត្រា ឧបទ្វីប ម៉ាឡេស៊ី និងឥណ្ឌា។ នៅក្នុងប្រទេសកម្ពុជា ជាទូទៅគេប្រទះឃើញដើមតាត្រាវដុះនៅក្នុងព្រៃចម្រុះ និងកម្រ ដុះក្នុងព្រៃស្រោង និងព្រៃល្បោះ (FA,1997) ។ ឈើប្រភេទនេះច្រើនដុះលើដីល្បាយខ្សាច់ដែលជន់លិចតាម រដូវនៅតាមបណ្តោយអូរ និងស្ទឹងដែលមានរយៈកំពស់ទាបជាង ៨០០ម ធៀបនឹងនីវ៉ូទឹកសមុទ្រ។ តាត្រាវជាប្រភេទឈើដុះមុនគេនៅលើដីដែលត្រូវភ្លើងឆេះ។ ដើមតាត្រាវមានដុះនៅក្នុងខេត្តកោះកុង ពោធិសាត់ ស្ទឹងត្រែង ក្រចេះ កំពង់ធំ មណ្ឌលគីរី និង ខេត្តព្រះវិហារ (Khorn, 2002)។

**ការប្រើប្រាស់៖** គេប្រើប្រាស់ឈើតាត្រាវសំរាប់ធ្វើសរសរផ្ទះ និងក្តារមឈូស (FIPI, 1996) ។ ក្នុងវប្បធម៌ខ្មែរ តាត្រាវប្រើប្រាស់សំរាប់ធ្វើទ្វារ និងស៊ុមទ្វារ ជាពិសេសនៅតាមប្រាសាទបុរាណនានា (FA, 1997)។ សំបកតាត្រាវប្រើប្រាស់សំរាប់ធ្វើឱសថបុរាណ។ ដើមរបស់វាអាចដាំធ្វើជាម្លប់ (FIPI, 1996) ។

**ស្ថានភាពបច្ចុប្បន្ន៖** ដោយសារតាត្រាវមានតម្លៃ និងតម្រូវការខ្ពស់ ទើបឈើប្រភេទនេះរងការធ្វើអាជីវកម្មហួសកំរិត និងអាចឈានទៅរកផុតពូជ ប្រសិនបើគ្មានវិធានការការពារសមស្រប។ ឈើតាត្រាវដុះរាយប៉ាយ និងនៅតាមតំបន់ដំណុះរបស់វាត្រូវទទួលរងការបំផ្លាញដោយសារការបង្វែរដីព្រៃឈើ និងការកាប់ព្រៃឈើដោយខុសច្បាប់។ ចំនួនដើមតាត្រាវដែលអាចផ្តល់គ្រាប់ពូជបានកំពុងថយចុះគួរឱ្យកត់សម្គាល់ ហើយបច្ចុប្បន្ននៅកម្ពុជា គេពិបាកស្វែងរកប្រភពដើមមេផ្តល់គ្រាប់ពូជណាស់។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជា ស្តីពីយុទ្ធសាស្ត្រអភិរក្ស សេនេទិចព្រៃឈើបានកំណត់ដើមតាត្រាវជាប្រភេទរុក្ខជាតិអាទិភាពមួយ ដែលត្រូវមានកិច្ចអន្តរាគមន៍ អភិរក្សជាបន្ទាន់ និងការពារឱ្យបានសមស្រប។ ដើមតាត្រាវត្រូវបានការពារដោយច្បាប់ស្តីពីព្រៃឈើ។

**ទេពិរូ**

អត្តសញ្ញាណ

ឈ្មោះវិទ្យាសាស្ត្រ : *Cinnamomum cambodianum Lecomte*

អំបូរ : *Lauraceae*
ចំណាត់ថ្នាក់នៅកម្ពុជា : គ្មានចំណាត់ថ្នាក់

**របាយ និងដំណុះ៖** ឈើប្រភេទនេះដុះនៅតំបន់ព្រៃក្រាស់ ហើយសើមនៅរយៈកម្ពស់ពី ៦០០- ៧០០ ម (Dy Phon, 2000)។ ទេពិរូសម្បូរនៅជម្រាលភ្នំបូកគោ និងជួរភ្នំក្រវាញ។ ឈើទេពិរូក៏មានដុះនៅក្នុងខេត្តរតនគីរី កំពង់ធំ និងជួរភ្នំដងរែក ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ប្រភេទនេះជាប្រភេទឈើស្ថានិកកម្ពុជា (FA, 2000)។ ឈើទេពិរូត្រូវការម្លប់នៅពេលនៅជាកូនឈើ ហើយអាចដុះលូតលាស់ល្អនៅដីជួរ។ ជាទូទៅ វាដុះពី ៥-១០ដើម នៅក្នុងព្រៃព្រហ្មចារីយ៍ និងព្រៃបន្ទាប់នៅរយៈកម្ពស់ក្រោម ១៥០០ម ធៀបនឹងនីវ៉ូទឹកសមុទ្រ (Khorn, 2002)។

**ការប្រើប្រាស់៖** ឈើទេពិរូត្រូវបានប្រើប្រាស់ជាគ្រឿងសាងសង់លំនៅដ្ឋាន និងជាអុសដុត (FA, 2000)។ សំបកវាអាចត្រូវបានគេទំពារជាមួយស្លឹកម្លូរ ឬត្រូវបានប្រើសំរាប់ជាអាហារ។ គេប្រើទេពិរូជាឱសថបុរាណសំរាប់ព្យាបាល ជម្ងឺជាច្រើនមុខដូចជាជំងឺទល់ពោះ ជំងឺរបេង និងធ្វើឱ្យរដូវមកទៀងទាត់ (Dy Phon, 2000)។

**ស្ថានភាពបច្ចុប្បន្ន៖** ដោយសារតែវាមានតម្លៃ និងតម្រូវការខ្ពស់ ប្រភេទនេះបានស្ថិតក្រោមសំពាធនៃ ការធ្វើអាជីវកម្មហួសកម្រិត និងស្ថិតក្នុងការគំរាមកំហែងជិតផុតពូជ លុះត្រាតែមានវិធានការអនុវត្តដើម្បី ការពារពីការ ធ្វើអាជីវកម្មខុសច្បាប់។ ចំនួនដើមមេត្រូវបានថយចុះគួរឱ្យកត់សម្គាល់ ហើយបច្ចុប្បន្ននៅកម្ពុជា គេពិបាកស្វែងរក ប្រភពដើមមេដើម្បីផ្តល់គ្រាប់ទុកធ្វើពូជណាស់។

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំលើកទីពីររបស់គម្រោងគ្រាប់ពូជឈើកម្ពុជា ស្តីពីយុទ្ធសាស្ត្រអភិរក្សសេនេទិចព្រៃឈើបានកំណត់ដើមទេពិរូជាប្រភេទអាទិភាពមួយ ដែលត្រូវមានកិច្ចអន្តរាគមន៍អភិរក្សជាបន្ទាន់ និងការពារឱ្យបានសមស្រប។

## រុក្ខជាតិកេសរកូល រឺ អ័រគីដេ

តំបន់ព្រៃការពារព្រះវិហារ សម្បូររុក្ខជាតិកេសរកូល ឬអ័រគីដេជាច្រើនប្រភេទ ដែលជាគោលដៅរបស់អ្នកភូមិប្រមូលសំរាប់លក់ នៅក្នុងស្រុក និងក្រៅប្រទេស។ រុក្ខជាតិកេសរកូល ឬអ័រគីដេមិនទាន់ត្រូវបាន ជ្រើសរើសជាគោលដៅសំរាប់ធ្វើការអភិរក្សនៅឡើយទេ ដោយសារគេបានដឹងតិចតួចស្តីពីរបាយ និងស្ថានភាព អភិរក្សរបស់វា ហើយរុក្ខជាតិប្រភេទនេះបាននឹងកំពុងទទួលរងការគំរាមកំហែងនៅពេលបច្ចុប្បន្ននេះ ដោយបរិមាណនៃការប្រមូលពីធម្មជាតិដោយគ្មានកំណត់។

# ឧបសម្ព័ន្ធ ១.៣.ខ៖ បញ្ជីឈ្មោះផល-អនុផលព្រៃឈើនៅក្នុងតំបន់ព្រៃការពារព្រះវិហារ

| No | Khmer Name | Scientific Name | Family | Timber Classification | Other uses | |
|---|---|---|---|---|---|---|
| | | | | | Medicinal Plant | Edible Plant |
| **Forest Tree Species** | | | | | | |
| 1 | គ្រើល | *Melanorrhera laccifera* | Anacarliaceae | L | √ | |
| 2 | ជើងចាប | *Dasymaschalon lomentaceum* | Annoceae | L | | √ |
| 3 | នាងនួន | *Disoxylon oliveri* | Caesalpinioideae | L | √ | |
| 4 | អង្កាញ់ | *Cassia Siamea* | Caesalpinioideae | L | √ | √ |
| 5 | ត្រយឹង | *Diospyros pilosanthera* | Ebenaceae | L | √ | |
| 6 | អង្កត់ខ្មៅ | *Diospyros bejaudii* Lecomte | Ebenaceae | L | | |
| 7 | ឈើខ្មៅ | *Diospyros spp* | Ebenaceae | L | | |
| 8 | បេង | *Afzelia xylocarpa* (Kruz.) Craib | Caesalpinioideae | L | √ | |
| 9 | ប្រេស | *Albizia lebbeck* (L.) Benth | Fabaceae | L | √ | |
| 10 | ក្រញូង | *Dalbergia cochinchinensis* | Leguminosae | L | | |
| 11 | តាត្រាវ | *Fagraea fragrans* | Loganiaceae | L | √ | |
| 12 | ធ្នង់ | *Pterocarpus macrocarpus,* Kurz. | Papilionaceae | L | √ | |
| 13 | កកោះ | *Sindora cochinchinensis,* Baill | Caesalpiniaceae | 1 | | √ |
| 14 | ត្រសេក ឬ ត្រាំកង់ | *Peltophorum ferruginium* | Caesalpinioideae | 1 | √ | |
| 15 | ពពេល | *Hopea recopei* | Caesalpinioideae | 1 | √ | |
| 16 | ឈ្លីក | *Terminalia tomentosa* | Combretaceae | 1 | √ | |
| 17 | ធ្នឹក | *Shorea obtuse* | Diperocarpaceae | 1 | √ | |
| 18 | គគីរដែក | *Hopea ahelferi* | Dipterocarpaceae | 1 | | |
| 19 | គគីរម្សៅ | *Hopea odorata* | Dipterocarpaceae | 1 | √ | |
| 20 | គគីរថ្ម | *Hopea ferrea* | Dipterocarpaceae | 1 | | |
| 21 | រាំងភ្នំ | *Shorea siamensis* | Dipterocarpaceae | 1 | | |
| 22 | ក្រឡាញ់ | *Dialium cochinchinensis* | Fabaceae | 1 | | √ |
| 23 | ស្រឡៅ ឬ ឥន្ទនេល | *Lagerstroemia sp.* | Lythraceae | 1 | | |
| 24 | យោង | *Chukrasia tabularis* | Meliaceae | 1 | | |
| 25 | សុក្រម | *Xylia dolabriformis* | Minosoideae | 1 | √ | |
| 26 | ដូនចែម ឬ បីសន្លឹក | *Heritiera javanica* | Sterculiaceae | 1 | | |
| 27 | ពពូល ឬ ភ្នែល | *Vitex sp* | Verbenaceae | 1 | √ | √ |

| No | Khmer Name | Scientific Name | Family | Timber Classification | Other uses | |
|---|---|---|---|---|---|---|
| | | | | | Medicinal Plant | Edible Plant |
| 28 | ម៉ៃសាក់ | *Tectona grandis* | Verbenaceae | 1 | √ | |
| 29 | ពពូលថ្ម | *Vitex pinnata* | Verbenaceae | 1 | √ | |
| 30 | សង្កូតត្នោត | *Stereospermum chelonoides* | Bignoniaceae | 1 | | |
| 31 | ដើមសំព័រ | *Artocarpus nitidus* | Moraceae | 1 | | |
| 32 | ផ្ដៀក | *Anisoptera costata* | Diperocarpaceae | 2 | √ | |
| 33 | ត្បែង | *Dipterocarpus obtusifoliius* | Diperocarpaceae | 2 | | |
| 34 | ខ្លុង | *Dipterocarpus turberculatus* | Diperocarpaceae | 2 | | |
| 35 | ច្រម៉ាស់ | *Vatica astrotricha* | Diperocarpaceae | 2 | | |
| 36 | ឈើទាលទឹក | *Dipterocarpus altatus* | Diperocarpaceae | 2 | √ | |
| 37 | ឈើទាលធូរ | *Dipterocarpus dyeri* | Diperocarpaceae | 2 | | |
| 38 | ជ័រចុង | *Shorea vulgaris* | Diperocarpaceae | 2 | | |
| 39 | ឈើទាលបង្គួយ ឬ នាងដែង | *Dipterocarpus costatus* | Diperocarpaceae | 2 | | |
| 40 | ត្រឡាត់ | *Vatica philastreana,* Pierre | Dipterocarpaceae | 2 | | |
| 41 | ត្រាច | *Dipterocarpus intricatus* | Dipterocarpaceae | 2 | √ | |
| 42 | គគីរខ្សាច់ | *Hopea pierrei,* Pierre | Dipterocarpaceae | 2 | √ | |
| 43 | លំបោរ | *Shorea sp.* | Dipterocarpaceae | 2 | | |
| 44 | ឆាំឆា | *Toona febrifuga.*M.Roem | Meliaceae | 2 | | |
| 45 | ខ្វាវ | *Haldinia cordifolia* | Rubiaceae | 2 | √ | |
| 46 | ស្រគុំ | *Madhuca major* | Sapotaceae | 2 | √ | |
| 47 | ទទឹម | *Punica granatum* | Punicaxeae | 2 | √ | √ |
| 48 | ធ្នឹកឧត្តម | *Shorca thorelli,* Pirre | Dipterocarpaceae | 2 | √ | |
| 49 | ស្វាយចំរៀង | *Swintonia pierrei,* Hance | Anacardiaceae | 3 | √ | √ |
| 50 | ស្វាយព្រៃ | *Mangifera indica* | Anacardiacees | 3 | √ | √ |
| 51 | ក្រាយ | *Polyalthia cerasoides,* Benth & Hook | Annonaceae | 3 | | |
| 52 | ប្រាំដំឡឹង | *Terminalia mucronata, Graib ct Huth* | Combretaceae | 3 | | |
| 53 | ក្របៅ | *Hydnocarpus annamensis* | Flacourtiaceae | 3 | | |
| 54 | ផ្អុង | *Callophyllum sp* | Guttiferae | 3 | √ | |
| 55 | ទ្រមូង | *Garcinia oliveri,* Pierre | Guttiferae | 3 | √ | √ |
| 56 | ល្មៀង | *Cratoxylon prunifolium,* Dyer | Hypericaceae | 3 | √ | √ |
| 57 | កណ្ដោល | *Careya sphaerica,* Pierre | Moraceae | 3 | √ | √ |

| No | Khmer Name | Scientific Name | Family | Timber Classification | Other uses | |
|---|---|---|---|---|---|---|
| | | | | | Medicinal Plant | Edible Plant |
| 58 | ខ្នុរព្រៃ | *Artocarpus chaphash* Roxb | Moraceae | 3 | | |
| 59 | ស្មាក្របី | *Knema corticosa,*Lour. | Myristicaceae | 3 | √ | |
| 60 | ព្រីង"គ្រប់បែក" | *Eugenia sp.* | Myrtaceaa | 3 | √ | |
| 61 | ស្មាច់ | *Melalcuca leucadendrom* | Mytaceae | 3 | √ | |
| 62 | ត្រមែង | *Carallia lucida,* Roxb. | Rhizophoraceae | 3 | √ | |
| 63 | ធ្លក | *Parinarium annamensis* | Rosacees | 3 | √ | √ |
| 64 | ចង្អូរត្នោត | *Vitex pinnata,*L. | Verbenaceae | 3 | √ | |
| 65 | ចេកទុំ | *Cinnamomum litsacfolium,* Thw | Lauraceae | 3 | √ | |
| 66 | បង្គោ | *Aglaia cambodiana,* Pierre | Meliaceae | 3 | | |
| 67 | បាយពូរាំង | *Aglaia spectabilis,* S.K.Jain & Benn | Meliaceae | 3 | | |
| 68 | ព្រូស | *Garcinia schefferi, Pierre* | Guttiferae | 3 | | |
| 69 | សំពង់ | *Tetrameles nudiflora* | Datiscaceae | 3 | √ | |
| 70 | ព្រីងដោះក្របី | *Syzygium cumini* | Myrtaceae | 3 | √ | √ |
| 71 | ព្រីងភ្នំ | *Syzygium lineatum* | Myrtaceae | NG | | √ |
| 72 | រំដួល | *Miliusa mesnyi* | Annonaceae | NG | √ | √ |
| 73 | ដក-ព | *Markhamia stipulacea pierrei* | Bignoniaceae | NG | √ | |
| 74 | រកា | *Bombax ceiba or Bombax malabaricum* | Bombacacea | NG | √ | |
| 75 | គ្រប់ទុំ | *Crypteronia paniculata* | Crypteroniaceae | NG | | √ |
| 76 | ភ្លូធំ | *Dillenia ovata* | Dilleniaceae | NG | √ | √ |
| 77 | ភ្លៅនាង | *Cleistanthus tomentosus* | Euphorbiaceae | NG | | |
| 78 | ខោស | *Lithocarpus elegans* | Fagaceae | NG | | √ |
| 79 | ព្រូស | *Garcinia schefferi* | Guttiferae | NG | | |
| 80 | ទេពីរូ | *Cinnamomum cambodianum* | Lauraceae | NG | √ | |
| 81 | ស្នួល | *Dalbergia nigrescens* | Leguminosae | NG | | √ |
| 82 | ចារ | *Butea monosperrna* | Leguminosae - Papilionoidae | NG | √ | √ |
| 83 | ចំរៀក | *Albizia corniculata* | Leguminosae- Mimosoideae | NG | √ | |
| 84 | ត្របែកព្រៃ | *Lagertroemia floribunda* | Lythraceae | NG | √ | |
| 85 | ស្តុកស្តោ | *Walsura villosa* | Meliaceae | NG | √ | |
| 86 | ល្វាព្រៃ | *Ficus hispida* | Moraceae | NG | √ | √ |
| 87 | ស្មាច់ដោម | *Syzygium zeylanicum* | Myrtaceae | NG | √ | |
| 88 | ពង្រ | *Scheicheria trijuga* | Sapindaceae | NG | √ | √ |

| No | Khmer Name | Scientific Name | Family | Timber Classification | Other uses | |
|---|---|---|---|---|---|---|
| | | | | | Medicinal Plant | Edible Plant |
| 89 | សិរមាន់ | *Nephelium hypoleucum* | Sapindaceae | NG | | √ |
| 90 | សាវម៉ាវព្រៃ | *Nephelium lappaceum* | Sapindaceae | NG | √ | √ |
| 91 | ចំបក់ | *Irvingia malayana* | Simaroubaceae | NG | | √ |
| 92 | សំរោង | *Sterculia lychnophora* Hance. | Sterculiaceae | NG | | |
| 93 | សំរ៉ង | *Scaphium macropodium* | Sterculiaceae | NG | √ | √ |
| 94 | ក្រពុលបាយ | *Litsca glutinosa* | Lauraceae | NG | √ | √ |
| 95 | គរ | *Ceiba pentandra* | Bombacacea | NG | √ | √ |
| 96 | ឆ្កែស្រែង | *Cananga latifolia* | Annonaceae | NG | √ | |
| 97 | ជ័រឆក់ | *Antiaris toxicaria* | Moraceae | NG | √ | |
| 98 | ជ័ររុង | *Garcinia hamburyi* Hook | Guftifera | NG | √ | |
| 99 | ជ្រៃក្រឹម | *Ficus benjamina* | Moraceae | NG | √ | |
| 100 | ឈើភ្លើង | *Diopyros hermaphroditica* | Ebenaceae | NG | √ | |
| 101 | ឈើរមាស់ | *Schima wallichii* | Theaceae | NG | √ | |
| 102 | ដង្កោ | *Diospyros malabarica* | Ebenaceae | NG | √ | √ |
| 103 | តាកោ | *Amomum sp* | Zingiberaeae | NG | √ | |
| 104 | ថ្កូវ | *Anthocephalus chinensis* | Rubiaceae | NG | √ | √ |
| 105 | ពពេលខែឈ្មោល | *Terminalia bialata* | Combretaceae | NG | √ | |
| 106 | ពោន | *Spondias pinnata* | Anacardiaceae | NG | √ | √ |
| 107 | ព្រះភ្នៅ | *Terminalia triptera* | Combretaceae | NG | √ | √ |
| 108 | ល្វាស្រុក | *Ficus racemosa* | Moraceae | NG | √ | √ |
| 109 | សណ្តាន់ | *Garcinia cochinchinensis* | Guttiferae | NG | √ | √ |
| 110 | ស្តៅ | *Azadirachta indica* | Meliaceae | NG | √ | √ |
| 111 | ស្លែង | *Strychnos nux-vomica* | Loganiaceae | NG | √ | |
| 112 | ស្វាយអាណោ | *Evodia lepta Merr* | Rutaceae | NG | √ | |
| 113 | កន្សែង | *Xanthophyllum glaucum* | Xanthophyllaceae | NG | √ | |
| 114 | ដង្កោខ្មោច | *Diospyros montana* | Ebennaceae | NG | | |
| 115 | ផ្ទៀវ | *Baccaurea ramifiora* | Euphorbiaceae | NG | √ | √ |
| 116 | ក្ងោកបារាំង | *Delonix regia* | Leguminosae-Caesalpinioideae | NG | √ | √ |
| 117 | គ្រាប់បែក | *Swietenia macrophylla* | Meliaceae | NG | | |
| 118 | ញញួយ | *Maclura cochinchinensis* | Moraceae | NG | √ | |
| 119 | ឈើដែខ្លា | *Wrightia annamensis* | Apocynaceae | NG | | √ |
| 120 | តាឡាត់ | *Canarium album* | Burseraceae | NG | √ | √ |

| No | Khmer Name | Scientific Name | Family | Timber Classification | Other uses | |
|---|---|---|---|---|---|---|
| | | | | | Medicinal Plant | Edible Plant |
| 121 | ត្របែកជួរ | *Terminalia pierrei* | Combretaceae | NG | | |
| 122 | ធ្នា | *Acacia intsia* | Leguminosae-Mimosoideae | NG | √ | |
| 123 | ភ្នៅ | *Aegle marmelos* | Rutaceae | NG | √ | |
| 124 | ព្រះធ្លក | *Ellipanthus tomentosus* | Connaraceae | NG | √ | |
| 125 | ភ្លូ ឬល្ងៀង | *Dillenia indica* | Dilleniaceae | NG | | √ |
| 126 | រាំងទឹក | *Barringtonia acutangula* | Lecythidaceae | NG | √ | |
| 127 | ល្វេ | *Dillenia pentagyna* | Dilleniaceae | NG | √ | √ |
| 128 | ស្រម៉ | *Terminalia chebula* | Combretaceae | NG | √ | √ |
| 129 | អាចម៍កណ្ដុរ | *Diospyros cambodiana* | Ebenaceae | NG | | |
| 130 | ពពលខែ | *Alstonia scholaris* | Apocynaceae | NG | √ | |
| 131 | ជើងគោ | *Tetracera scadens* | Dilleniaceae | NG | √ | √ |
| 132 | មៀនព្រៃ | *Aporusa planchoniana* | Euphorbiaceae | | √ | √ |
| 133 | កន្ទួតព្រៃ | *Phyllanthus emblica* | Euphorbiaceae | | √ | √ |
| 134 | គ្រង់ | *Aporusa filicifolia,* Baill. | Euphorbiaceae | | √ | |
| 135 | ភ្លូង | *Memecylon acuminatum* | Melastomaceae | | | |
| 136 | ភ្លូងជួរ | *Memecylon edule* | Melastomaceae | | √ | √ |
| 137 | ស្រងាំ | *Tristaniopsis burmannica* | Myrtaceae | | | |
| 138 | ល្វៀង | *Cathunaregam tomentosa* | Rubiaceae | | √ | √ |
| 139 | ក្រវាន់ | *Amomum krevanh* | Medical Plant | | √ | |
| 140 | គោមួយ | *Euonymus cochinchinensis* | Celastraceae | | √ | |
| 141 | គ្រាំពុក | *Randia uliginosa* | Rubiaceae | | √ | |
| 142 | ឃ្នាស | *Memecylon edule* | Melastomaceae | | √ | |
| 143 | រំ | *Anogeissus rivularis* | Combretaceae | | | |
| 144 | ស្មាវ | *Homalium brevidens* | Flacourtiaceae | | | |
| 145 | អង្កាសិល | *Ochna integerrima* | Ochnaceae | | √ | |
| 146 | ក្រខុបព្រៃ | *Scolopia spinosa* | Flacourtiaceae | | √ | √ |
| 147 | ក្រធំថេតព្រៃ | *Cassia timoriensis* | Leguminosae-Caesalpinioideae | | √ | √ |
| 148 | ខ្លែងគង់ | *Hoarrhena pubescens, Wrightia pubescens* | Apocynaceae | | √ | |
| 149 | ជន្លុះ | *Erioglossum edul, Lepisanthes rubiginosa* | Sapindaceae | | √ | √ |
| 150 | ជ្រៃទឹក | *Ficus subpyriformis* | Moraceae | | | √ |
| 151 | ជ្រៃលៀប | *Ficus racemosa* | Moraceae | | √ | √ |
| 152 | ឈើកែវ | *Murraya paniculata* | Rutaceae | | | |

| No | Khmer Name | Scientific Name | Family | Timber Classification | Other uses | |
|---|---|---|---|---|---|---|
| | | | | | Medicinal Plant | Edible Plant |
| 153 | បាក់ដង | *Gardenia philastrei* | Rubiaceae | | | |
| 154 | ប្រដាក់ | *Mitrephora maingayi* | Annonaceae | | | √ |
| 155 | ព្រិច | *Melienthes suavis* | Opiliaceae | | | √ |
| 156 | ព្រីងអួល | *Syzygium bracteatum* | Myrtaceae | | | √ |
| 157 | រលាយឈាម | *Lasianthus Kamputensis* | Rubiaceae | | √ | |
| 158 | រលាយធំ | *Neonauclea scssilitlora* | Rubiaceae | | √ | |
| 159 | សង្ឃឹរ | *Zizyphus oenoplia* | Rhamnaceae | | √ | √ |
| 160 | ភ្លាំង | *Glycosmis pentaphylla* | Rutaceae | | √ | √ |
| 161 | ដើមយុថ្កា | *Randia fasciculata Dc* | Rubiaceae | | √ | |
| 162 | ញព្រៃ | *Morinda tomentosa* | Rubiaceae | | √ | |
| 163 | ដៃខ្លា | *Gardenia angkoriensis* | Rubiaceae | | √ | |
| 164 | ទ្រមូងសេក | *Suregada multiflorum* | Euphorbiaceae | | √ | |
| 165 | ត្រមូច | *Antidesma acidum* | Euphorbiaceae | | √ | √ |
| 166 | ទំពូងភ្លើង | *Croton oblongifoius* | Euphorbiaceae | | √ | |
| 167 | ពញ្ញា | *Grewia asiatica.L* | Tiliaceae | | √ | √ |
| 168 | ពិកា (ដើម) ឬស្រោមដាវ | *Oroxylum indicum* | Bignoniaceae | | √ | √ |
| 169 | ស្រម៉ពិភេទក៍ | *Terminaha bellirica* | Combretaceae | | √ | |

## ឧបសម្ព័ន្ធ ១.៤.ក៖ ប្រភេទថនិកសត្វសំខាន់ៗនៅតំបន់ព្រៃការពារព្រះវិហារ

**ដំរីព្រៃអាស៊ី** *Elephas maximus* (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទ រងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

-**ទំហំ**៖ ប្រវែងដងខ្លួនពី ៤០០០-៦០០០មីលីម៉ែត្រ កំពស់ត្រឹមស្មាពី ២៥០០-៣០០០ មីលីម៉ែត្រ ទំងន់ ៣៥០០-៥០០០គីឡូក្រាម។

-**លក្ខណៈជីវសាស្ត្រ**៖ ដំរីច្រើនរស់នៅតាមព្រៃល្បោះ និងវាលស្មៅ ព្រៃឫស្សី វាស៊ីសំបកឈើ មើមឈើ ឬ ឫសឈើខ្ចី ស្លឹកឫស្សី អំពៅ ចេក។ល។ វាអាចផឹកទឹករហូតដល់ ២០០ លីត្រ ក្នុង១ថ្ងៃ (នៅកន្លែង សំបូរទឹក)។ ដំរីអាស៊ីឈ្មោលមានភ្លុក ឯដំរីញី និងដំរីឈ្មោលខ្លះមិនមានភ្លុកទេ។ ដំរី ចិញ្ចឹមកូនដោយទឹកដោះ បន្តពូជនៅខែ កក្កដា-សីហា។ ដំរីពរពោះរយៈពេល ២១ខែ (យូរបំផុត ២៥ខែ) កើតកូនម្តងបាន ១ក្បាល ដោយកំរកើតបានកូន ភ្លោះណាស់។ មេដំរីក្នុងមួយជីវិតវាអាចបង្កើតកូនបាន ៤ ឬ៥ដង ហើយដំរីមេអាច បន្តពូជរហូតបានដល់អាយុ៥០-៧០ឆ្នាំ។ គេអាចសំគាល់ដំរីចុះប្រេងនៅពេលដែលគេឃើញមានប្រេង ហូរចេញពីរន្ធមួយនៅចន្លោះរន្ធត្រចៀក និងភ្នែក។

-**ស្ថានភាព និងរបាយ**៖ ដំរីព្រៃមានតិចតួចនៅកម្ពុជា ដែលមានស្ថិតនៅក្នុងតំបន់មួយចំនួនដូចជា តំបន់ភូមិ ភាគឥសាន្ត និរតី និងភូមិភាគខាងជើង។

មានកំណត់ត្រាអំពីសត្វដំរីព្រៃអាស៊ីជាច្រើនទាំងនៅក្នុងរដូវប្រាំង និងរដូវវស្សាដែលបង្ហាញថា តំបន់ព្រៃការពារព្រះវិហារ គឺជាដែនជម្រកសំខាន់របស់វា ទោះជាមិនមានទិន្នន័យគ្រប់គ្រាន់ស្តីពីចំនួនពិត របស់ថនិកសត្វ ដែលមានមាឌធំជាងគេ នៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ ដោយសារដែនជម្រកនៅតាម តំបន់មួយចំនួននៅជុំវិញតំបន់ព្រៃការពារព្រះវិហារ មានលក្ខណៈស្រដៀងគ្នាសត្វដំរីព្រៃអាស៊ី ប្រហែល ជាឆ្លងកាត់ពីកម្ពុជាទៅកាន់ប្រទេសឡាវ និង ធ្វើបំលាស់ទីទៅកាន់ព្រៃសម្បទានចិន្តាប្លាយវូត។ ដែនជម្រក របស់វាប្រហែលជាមានការប្រែប្រួលក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយសារតែឥទ្ធិពលនៃការបរបាញ់ និងការរំខានផ្សេងៗ។ ដោយសារការស្រាវជ្រាវ និងការល្បាតមិនមាន លក្ខណៈដូចគ្នាជារៀងរាល់ឆ្នាំ និងកង្វះទិន្នន័យឧតុនិយមដែលអាចប្រើប្រាស់បានសំរាប់វាយតម្លៃឥទ្ធិពលរបបទឹកភ្លៀង ទៅលើបំលាស់ទី របស់ថនិកសត្វប្រភេទនេះ ហេតុនេះ យើងមិនអាចវាយតម្លៃបានថាតើ ការផ្លាស់ប្តូរដែនជម្រក របស់វា ជាការពិត ឬយ៉ាងណានោះទេ។ ទោះជាកាលពីមុន តំបន់ព្រៃការពារព្រះវិហារតភ្ជាប់ទៅនឹងដែនជម្រក សត្វព្រៃគូលេនព្រហ្មទេពតាមរយៈព្រៃសម្បទានចិន្តាប្លាយវូត តែក៏គ្មានភស្តុតាងណាមួយដែលអាចបង្ហាញថា សត្វដំរីព្រៃអាស៊ីធ្វើបំលាស់ទីទៅកាន់ដែនជម្រកសត្វព្រៃគូលេនព្រហ្មទេពដែរ។ ថ្មីៗនេះ ដោយសារមាន ការត្រួតពិនិត្យអំពីរបាយរបស់សត្វដំរី បង្ហាញថាមិនមានទិន្នន័យស្តីពីសត្វដំរីព្រៃអាស៊ី នៅក្នុងប្រទេសឡាវ ជាប់នឹងតំបន់ព្រៃការពារព្រះវិហារនោះទេ។ ហេតុនេះ យើងមិនដឹងថាតំបន់ព្រៃការពារព្រះវិហារ ជាផ្នែកមួយនៃដែនជម្រកសត្វដំរីព្រៃអាស៊ីនៅក្នុង តំបន់ដែលអាចបង្កើនសារសំខាន់នៅក្នុងតំបន់ព្រៃការពារ ព្រះវិហារនេះ។

ផែនទី ១.៤.១៖ រប៉ាយសត្វដំរីព្រៃអាស៊ីនៅតំបន់ព្រៃការពារព្រះវិហារ




**ខ្ទីង** ***Bos gaurus*** (ស្ថិតក្នុងឧបសម្ព័ន្ធ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះ ក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងដងខ្លួន ២៥០០-៣០០០មីលីម៉ែត្រ កំពស់ត្រឹមស្មាពី ១៧០០-១៨៧០មីលីម៉ែត្រ ទំងន់ ៦៥០ -៩០០ គីឡូក្រាម ។

**-លក្ខណៈជីវសាស្ត្រ**៖ គេអាចជួបប្រទះសត្វខ្ទីងនៅតាមទីជម្រកតំបន់ទំនាបរហូតដល់តំបន់ភ្នំដែលមានរយៈកំពស់ដល់ ២០០០ម៉ែត្រ។ ទីជម្រកសត្វខ្ទីងមានចាប់តាំងពីតំបន់ព្រៃស្រោង ពាក់កណ្ដាលស្រោង និងវាលស្មៅ និងអាចមាននៅតំបន់ភ្នំខ្លះ។ ពេលព្រឹកព្រលឹម និងពេលព្រលប់ គឺជាពេលវេលាសំរាប់ខ្ទីងដើរ រកស៊ីចំណី។ សត្វខ្ទីងស៊ីស្មៅ ត្រញ៉ំងខ្ចី និងស្លឹកឬស្សី។

**-រដូវបន្តពូជ**៖ ខ្ទីងញីពេញវ័យផ្តល់កំណើតបានកូនមួយ បន្ទាប់ពីពរពោះអស់រយៈពេល ៩-៩,៥ ខែ។

**-ស្ថានភាព និងរបាយ**៖ Heinen & Srikomamatara (1996) បានបង្ហាញពីស្ថានភាពសត្វខ្ទីងនៅតំបន់អាស៊ីអាគ្នេយ៍កំពុងទទួលរងគ្រោះយ៉ាងខ្លាំង។ នៅក្នុងប្រទេសកម្ពុជាសត្វខ្ទីងត្រូវបានគេឃើញនៅតំបន់ខ្ពង់រាបភាគខាងកើត ដូចជា ខេត្តមណ្ឌលគីរី រតនគីរី និងខេត្តស្ទឹងត្រែង និងតំបន់ខ្ពង់រាបភាគខាងជើង ដូចជា ខេត្តព្រះវិហារ ឧត្តរមានជ័យ ហើយអាចមានវត្តមាននៅតំបន់ភ្នំព្រៃស្រោងមួយចំនួនដូចជា ខេត្តកោះកុង កំពង់ស្ពឺ និងខេត្តពោធិសាត់។ ទោះជាយ៉ាងណាក៏ដោយក៏ចំនួនសត្វខ្ទីងមានតិចតួច និងនៅរាយប៉ាយគ្រប់ទីកន្លែង និងទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំង ជាពិសេសពីការបរបាញ់។

ខ្ទីងមានវត្តមានច្រើនបង្គួរនៅភាគកណ្តាលតំបន់ព្រៃការពារព្រះវិហារ និងព្រៃសម្បទានចិន្តាប្លាយវូត។ នេះប្រហែល ជាដោយសារតែខ្ទីងចូលចិត្តព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃនៅតាមមាត់អូរដែល សំបូរនៅក្នុងតំបន់នោះ។ គេកត់ត្រាសត្វខ្ទីងជាញឹកញាប់ក្នុងអំឡុងពេលសិក្សាថនិកសត្វខ្នាតធំប្រចាំឆ្នាំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ បើទោះបី ជាទិន្នន័យដែលមាន មិនទាន់អាចធ្វើការប៉ាន់ស្មានអំពីចំនួនពិតប្រាកដរបស់សត្វខ្ទីងក៏ដោយ។ ទោះជាសត្វខ្ទីងមានវត្តមាន ស្ទើរតែទូទាំងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែពពួកសត្វនេះ នៅតែទទួលរងការគំរាមកំហែងធ្ងន់ធ្ងរជាងទន្សោង ហើយបាននឹងកំពុងបាត់បង់ពីដែនជម្រករបស់វានៅក្នុង តំបន់អាស៊ីអាគ្នេយ៍។ ចំនួនសត្វខ្ទីងនៅក្នុងតំបន់ព្រៃការពារ ព្រះវិហារមានទំនាក់ទំនងទៅនឹង តំបន់ផ្សេង ទៀតនៅតាមខ្ពង់រាបភាគខាងជើង និងខាងកើតរបស់ប្រទេសកម្ពុជា ដែលមានសារសំខាន់ជាសាកល។

ផែនទី ១.៤.២៖ របាយសតខ្ទីងនៅតំបន់ព្រៃការពារព្រះវិហារ




**ទន្សោង** ***Bos javanicus*** (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងដងខ្លួនពី ១៩០០-២២៥០ មីលីម៉ែត្រ កំពស់ត្រឹមស្មាពី ១៥៥០-១៦៥០ មីលីម៉ែត្រ និងទំងន់ ៦០០-៨០០ គីឡូក្រាម។

**-លក្ខណៈជីវសាស្ត្រ**៖ ទន្សោងជាសត្វរស់នៅតំបន់ព្រៃល្បោះ និងវាលស្មៅដែលមានទឹកច្រប់ និងដីប្រាប។ ជាទូទៅ ទន្សោងចូលចិត្តរស់នៅតំបន់វាលនៃព្រៃល្បោះដែលផ្ទុយពីសត្វខ្ទីង ដែលចូលចិត្តរស់ នៅតំបន់ព្រៃពាក់កណ្ដាលស្រោង។ ទន្សោងច្រើនរស់នៅជាហ្វូង។ នៅពេលព្រឹកព្រលឹម និងពេលព្រលប់ជា ពេលវេលាដ៏ល្អសំរាប់ទន្សោង ចេញរកស៊ីចំណី។

**-រដូវបន្តពូជ**៖ ទន្សោងបង្កាត់ពូជនៅអំឡុងខែឧសភា និង មិថុនា។ ទន្សោងញីផ្តល់កំណើតឱ្យកូនចំនួន ១ ឬ២ បន្ទាប់ពីពរពោះរយៈពេល ៩ ខែ។ ទន្សោងញីមានលទ្ធភាពបង្កាត់ពូជនៅពេលមានអាយុ ២ឆ្នាំឡើង។

**-ស្ថានភាព និងរបាយ**៖ ទន្សោងជាសត្វដែលទទួលរងការគំរាមកំហែងយ៉ាងខ្លាំងពីការបរបាញ់ ដើម្បីធ្វើការលក់ ដូរសាច់ និងស្នែង។ នៅប៉ុន្មានទសវត្សចុងក្រោយនេះចំនួនសត្វទន្សោងមានការថយចុះជាខ្លាំងនៅក្នុងតំបន់។ ទន្សោងត្រូវបានគេប្រទះឃើញមាននៅតំបន់ព្រៃល្បោះនៅតំបន់ខ្ពង់រាបខាងជើង និងខាងកើតនៃប្រទេសកម្ពុជា និងមានចំនួនតិចតួចនៅក្នុងទីជម្រកព្រៃល្បោះភាគនិរតី។

ទន្សោងមានវត្តមាននៅទូទាំងតំបន់ព្រៃការពារព្រះវិហារ និងព្រៃសម្បទានចិន្តាប្លាយវូត។ គេធ្វើការអង្កេត ប្រភេទថនិកសត្វនេះជាញឹកញាប់ដោយប្រើម៉ាស៊ីនថតស្វ័យប្រវត្តិ និងការអង្កេតដោយផ្ទាល់។ ជាទូទៅ ទន្សោងចូលចិត្តតំបន់ព្រៃល្បោះជាងសត្វខ្ទីង ហើយនេះប្រហែលជាហេតុផលមួយនៅតំបន់ ព្រៃការពារព្រះវិហារ។ តាមទិន្នន័យនៃការសិក្សាស្រាវជ្រាវសត្វទន្សោង បានបង្ហាញថាតំបន់ព្រៃការពារ ព្រះវិហារ ពិតជាមានសារសំខាន់ជា សាកលសំរាប់ថនិកសត្វប្រភេទនេះ។ ទន្សោងកំពុងបាត់បង់ពីដែន ជម្រករបស់វានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ការពង្រឹងការអនុវត្តច្បាប់ ដើម្បីគ្រប់គ្រងការបរបាញ់ និងការ កាប់រានទីជម្រករបស់វា គឺជាវិធានការការពារដ៏សំខាន់សំរាប់ថនិកសត្វប្រភេទនេះ នៅក្នុងតំបន់ព្រៃការ ពារព្រះវិហារ។

ផែនទី ១.៤.៣ ៖ របាយសត្វទន្សោងនៅតំបន់ព្រៃការពារព្រះវិហារ




**រមាំង** ***Cervus eldi*** (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

**-ទំហំ៖** ប្រវែងដងខ្លួនពី ១០០០-១១៤០មីលីម៉ែត្រ ទំងន់ ១០០គីឡូក្រាម។

**-លក្ខណៈជីវសាស្ត្រ៖** រមាំងរស់នៅជាហ្វូងដែលក្នុងមួយហ្វូងមានពី ៥-១៥ក្បាល នៅតំបន់ទំនាបព្រៃល្បោះដែលមានវាលស្មៅជាមួយនឹងទឹកច្រប់ និងថ្លុកទឹក។ ស្មៅ ស្បូវ ឬស្សីខ្ចី និងត្រួយស្លឹកខ្ចីដែលទើបនឹងលាស់ជាអាហាររបស់រមាំង។ ជារៀងរាល់ឆ្នាំ នៅអំឡុងខែមិថុនា រមាំងធ្វើការជំរុះស្នែង ហើយក៏ជាពេលវេលា ដែលសំបូរទៅដោយចំណីសំរាប់ពួកវាផងដែរដែលអាចធ្វើឱ្យស្នែងរបស់វាអាចលូតលាស់សារជាថ្មី។ រមាំងជាសត្វ មិនសូវភ្ញាក់ផ្អើលនឹងមនុស្សទេ ហេតុដូច្នេះហើយបានជាពួកវាជាប្រភេទសត្វដែលងាយស្រួលបរបាញ់ជាទីបំផុត។ បច្ចុប្បន្ននេះ ចំនួនរបស់វានៅក្នុងប្រទេសកម្ពុជាមានការថយចុះជាខ្លាំងបើប្រៀបធៀបទៅនឹងឆ្នាំមុនៗ បើទោះបីជាមានតំបន់ជាច្រើន ជាទីជម្រកដ៏ល្អពួកវាក៏ដោយ។

**-រដូវបន្តពូជ៖** ជាធម្មតារដូវបង្កាត់ពូជសំរាប់សត្វរមាំងគឺចាប់ពីខែ មីនា-ឧសភា និងបន្ទាប់ពីការពរពោះរយៈពេល ៦-៨ខែ រួចមក រមាំងញីបានផ្តល់កំណើតបានកូនចំនួន ០១។

**-ស្ថានភាព និងរបាយ៖** របាយហ្វូងរមាំងតូចៗ មាននៅពាសពេញតំបន់ព្រៃល្បោះភាគខាងជើង ភាគខាងកើត និងភាគត្បូងឆៀងខាងលិចនៃប្រទេសកម្ពុជា ក្នុងខេត្តបន្ទាយមានជ័យ សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី ក្រចេះ និងខេត្តកំពង់ស្ពឺ។

រមាំងត្រូវបានកត់ត្រាជាញឹកញាប់នៅក្នុងព្រៃល្បោះ ជាពិសេសនៅក្នុងតំបន់ចំនួនបី៖ នៅភាគខាងត្បូង ភូមិរបុញ វាំងអូរគគីរ និងភូមិដងផ្លិត និងនៅភាគអាគ្នេយ៍ តំបន់ព្រៃការពារព្រះវិហារ។ តំបន់ព្រៃការពារព្រះវិហារ ប្រហែលជាតំបន់មួយដែលមានសារសំខាន់ សំរាប់សត្វរមាំងនៅក្នុងពិភពលោក នៅស្របពេលដែលតំបន់ព្រៃល្បោះនានា ដែលជាជម្រករបស់ប្រភេទថនិកសត្វប្រភេទនេះកំពុងបាត់បង់នៅតំបន់អាស៊ីអាគ្នេយ៍។

ផែនទី ១.៤.៤៖ រប៉ាយសត្វរមាំងនៅតំបន់ព្រៃការពារព្រះវិហារ




**កែះ** ***Naemorhedus sumatraensis*** (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងដងខ្លួនពី ១៤០០-១៥០០មីលីម៉ែត្រ កំពស់ត្រឹមស្មាពី ៨៥០-៩៤០មីលីម៉ែត្រ ទំងន់ពី ៨៥-១៤០គីឡូក្រាម។

***-លក្ខណៈជីវសាស្ត្រ***៖ កែះចូលចិត្តរស់នៅតំបន់ជ្រលងផ្ទាំងថ្ម ដែលមានគម្របព្រៃ និង ស្រទាប់ រុក្ខជាតិស្រទាប់ក្រោមក្រាស់។ កែះមានជើងយ៉ាងចំណាប់ក្នុងការឡើងតាមផ្ទាំងថ្មចោទៗ។ នៅពេលថ្ងៃវា ចូលចិត្តសំរាក តាមព្រៃគម្ពោតក្រាស់ ហើយចេញរកស៊ីនៅពេលព្រឹក ឬព្រលប់។ ពពួកសត្វកែះ វាស៊ីរុក្ខជាតិ ស្ទើរគ្រប់ប្រភេទ។ ជាធម្មតាវារស់នៅឯកកា។ វាបន្តពូជនៅខែ តុលា-ធ្នូ និងកើតបានកូន ១-២ បន្ទាប់ពីមាន គភ៌ ៧ខែ។ កូនរស់នៅជាមួយមេវាស្ទើរ ពេញមួយឆ្នាំទើបចាកចេញ។

***-ស្ថានភាព និងរប៉ាយ***៖ សត្វកែះអាចជួបប្រទះនៅតំបន់ភាគនិរតី និងតំបន់ខ្ពង់រាបភាគខាងជើងនៃប្រទេសកម្ពុជា ហើយចំនួនរបស់វាមានតិចតួចណាស់។

មានកំណត់ត្រាតិចតួចអំពីវត្តមានសត្វកែះ ចាប់តាំងពីភ្នំដងរែករហូតដល់ ភាគខាងកើតនៃ តំបន់ ព្រៃការពារព្រះវិហារ។ ជាទូទៅ សត្វកែះមានរស់នៅតំបន់ភ្នំ និងតំបន់ដែលមានចំណោទខ្លាំង។

**ឈ្លូស** ***Muntiacus muntjak*** (ជាប្រភេទសត្វមានដោយបង្គួរនៅក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយបង្គួរក្នុងប្រទេសកម្ពុជា )។

**-ទំហំ**៖ ប្រវែងដងខ្លួនពី ៩០០-១០៥០ មីលីម៉ែត្រ កំពស់ត្រឹមស្មាពី២០-២៨០គីឡូក្រាម ។

***-លក្ខណៈជីវសាស្ត្រ***៖ សត្វឈ្លូសរស់នៅតាមទីជម្រកខុសៗគ្នា ដូចជាព្រៃស្រោង តំបន់ខ្ពង់រាប និងតំបន់វាលទំនាប និងព្រៃល្បោះដែលមានវាលស្មៅ ទឹកច្រប់ និងថ្លុកទឹក។ ស្មៅ ស្បូវ ឬស្សីខ្ចី និងត្រួយ ស្លឹកខ្ចីដែលទើបនឹងលាស់ជាចំណីរបស់ឈ្លូស។ ពេលវេលាដែលវាចេញមកស៊ីចំណីគឺ ពីពេលព្រលប់ៗរហូតដល់ពេលថ្ងៃរះ។ ជារៀងរាល់ឆ្នាំ អំឡុងខែ កក្កដា-សីហា ជាពេលវេលាសត្វឈ្លូសធ្វើការជំរុះស្នែង។ ហើយក្នុងអំឡុងពេលនោះជាពេលវេលាមួយ ដែលវាលាក់ខ្លួន និងពិបាកជួបប្រទះពួកវាណាស់។

**-រដូវបន្តពូជ៖** ជាធម្មតា រដូវបង្កាត់ពូជរបស់ឈ្លូសគឺនៅអំឡុងខែ ធ្នូ-មករា ហើយបង្កើតកូនបាន ០១ បន្ទាប់ពីពរពោះរយៈពេល ៨ខែ។ ឈ្លូសជំទង់ឈ្មោលភាគច្រើនរស់នៅតែម្នាក់ឯង ហើយដល់រដូវបង្កាត់ ពូជទើប ពួកវាប្រមូលផ្តុំជាមួយនឹងឈ្លូសញី ដើម្បីធ្វើការបង្កាត់ពូជ។

**-ស្ថានភាព និងរបាយ៖** ឈ្លូសជាប្រភេទដែលគេអាចជួបប្រទះនៅតំបន់ព្រៃឈើនានាជាច្រើនក្នុងប្រទេសកម្ពុជា ប៉ុន្តែថ្មីៗនេះចំនួនសត្វឈ្លូសមានការធ្លាក់ចុះបើប្រៀបធៀបកាលពីមុននៅក្នុងប្រទេសកម្ពុជា បើទោះជា មានតំបន់ជាច្រើនជាទីជម្រកដ៏ល្អសំរាប់ពួកវាក៏ដោយ ។

សត្វឈ្លូសមាននៅគ្រប់ទីកន្លែង នៃតំបន់ព្រៃការពារព្រះវិហារ ហើយជាប្រភពចំណីដ៏សំខាន់សំរាប់ពពួកមំសាសីមាឌធំ (ខ្លាធំ ខ្លារខិន ខ្លាភ្លីថ្មកែវ ខ្លាលឿងមាស)។

ផែនទី ១.៤.៥ ៖ របាយសត្វឈ្លូសនៅតំបន់ព្រៃការពារព្រះវិហារ




## អំបូរខ្លា

មិនមានកំណត់ត្រាស្តីពីខ្លាពពកត្រូវបានរកឃើញនៅក្នុង តំបន់ព្រៃការពារព្រះវិហារទេ។ ក្រៅពីនេះមានការកត់ត្រាតិចតួចបំផុតអំពី វត្តមានខ្លាភ្លីថ្មកែវ និងខ្លាលឿងមាស។ ប្រភេទនៃអំបូរខ្លានេះមានពិពណ៌នាលម្អិតដូចខាងក្រោម៖

**ខ្លាធំ** Panthera tigris (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទរងគ្រោះ ជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

**-ទំហំ៖** ប្រវែងដងខ្លួនពី ១៧០០-២២៩០ មីលីម៉ែត្រ ទំងន់ ១៨០-២៤៥គីឡូក្រាម

**-លក្ខណៈជីវសាស្ត្រ៖** ខ្លាធំអាចរស់នៅក្នុងជម្រកគ្រប់ប្រភេទ ដែលមានទឹក ចំណី និងម្លប់គ្រប់គ្រាន់ព្រោះវាជាសត្វចាញ់កំដៅថ្ងៃ។ នៅពេលថ្ងៃក្តៅខ្លាំង ខ្លាធំចំណាយពេលច្រើនម៉ោងដើម្បីដេកត្រាំទឹក វាមានភាពស្ទាត់ជំនាញក្នុងការហែលទឹក ហើយវាមិនឡើងដើមឈើទេបើពុំចាំបាច់។ ខ្លាធំអាចចាប់ចំណីបានចាប់ពីសត្វតូចរហូតដល់សត្វធំ (ទន្សោង ខ្ទីង)។ ខ្លាធំអាចបន្តពូជបានគ្រប់រដូវ។ វាអាចបង្កើតកូនបានពី ១-៧ក្បាល បន្ទាប់ពីពរពោះ អស់រយៈពេលប្រហែល ១០០ថ្ងៃ។ វាអាចមានអាយុរហូតដល់ ២៥ឆ្នាំក្នុងធម្មជាតិ។

**-ស្ថានភាព និងរបាយ៖** ខ្លាធំជាប្រភេទសត្វដែលទទួលរងគ្រោះបំផុត ដោយការបរបាញ់ដើម្បីធ្វើពាណិជ្ជកម្មស្បែក ឆ្អឹងនៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដូចជាភូមិភាគឥសាន្ត ភូមិភាគខាងជើង ភូមិ

ភាគនិរតី។ គេមិនបានប្រទះឃើញវត្តមានខ្លាធំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ជាងប្រាំឆ្នាំមកហើយ (WCS 2008)។ ការស្រាវជ្រាវដោយ ប្រើម៉ាស៊ីនថតស្វ័យប្រវត្តិ និងការវាស់វែងដានជើងកំពុងធ្វើឡើង ដើម្បីវាយតម្លៃអំពីការពិត ស្តីពីវត្តមានសត្វខ្លា ធំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។

**ខ្លារខិន** ***Panthera pardus*** (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទជិតទទួលរងការគំរាមកំហែងក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

-**ទំហំ៖** ប្រវែងដងខ្លួនពី ១០៨០-១៣០០មីលីម៉ែត្រ ទំងន់ ៤៥-៦៥គីឡូក្រាម

-**លក្ខណៈជីវសាស្ត្រ៖** ខ្លារខិនអាចរស់នៅក្នុងតំបន់ព្រៃឈើស្ទើរគ្រប់ប្រភេទ ចាប់ពីព្រៃស្រោង រហូតដល់ព្រៃគម្ពោតមានថ្មាំងថ្ម។ វាជាសត្វរហ័សរហួន និងចូលចិត្តឡើងដើមឈើដែលជាជំនាញពិសេសរបស់វា។ វាពុំសូវចាញ់កំដៅថ្ងៃដូចខ្លាធំទេ ហើយអាចរស់នៅឆ្ងាយពីប្រភពទឹក។ បើទោះជាវាអាចហែលទឹកបាន ក៏វាព្យាយាមគេច ចេញពីតំបន់មានទឹកដែរ។ ខ្លារខិនស៊ីសាច់គ្រប់ប្រភេទដែលវាចាប់បានដូចជា ជ្រូក ប្រើស ស្វា សត្វល្អិតជាដើម។ ជារឿយៗ វាចាប់ចំណីដោយលោតសង្គ្រប់ពីលើដើមឈើ រួចទាញសត្វនោះឡើងលើដើមឈើដើម្បីស៊ី។ វាចូលចិត្តរក ចំណីតែឯកឯង និងជាសត្វរាត្រីចរ។ វាដើរជាគូរតែក្នុងរដូវបន្តពូជ។ ខ្លារខិនអាចបង្កើតកូនម្តងបានពី ១-៤ក្បាល បន្ទាប់ពីពរពោះអស់រយៈពេលប្រហែល ៩០-៩៥ថ្ងៃ។ កូនរស់នៅជាមួយមេរហូតដល់អាយុ ១-២ឆ្នាំ។

-**ស្ថានភាព និងរបាយ៖** វាមានតិចតួចនៅតាមតំបន់នានាដូចជា ភូមិភាគឥសាន្ត និរតី និងភាគខាង ជើង។

របាយខ្លារខិនមាននៅគ្រប់ទីកន្លែងទូទាំងតំបន់ព្រៃការពារព្រះវិហារ ជាពិសេសនៅភាគអាគ្នេយ៍តំបន់ព្រៃល្បោះ និងតំបន់ព្រៃស្រោង។ បើទោះបីថនិកសត្វប្រភេទនេះមានគ្រប់ទីកន្លែងចាប់តាំងពីទ្វីបអាហ្វ្រិករហូតដល់ទ្វីបអាស៊ីខាងកើត សត្វខ្លា រខិនកំពុងតែបាត់បង់ដោយសារការបាត់បង់ទីជម្រក ការបរបាញ់ និងគ្មានចំណីគ្រប់គ្រាន់។ តំបន់ដ៏ធំល្វឹងល្វើយ ដែលគ្រប់គ្រងបានល្អ និងសំបូរចំណី ដូចជា តំបន់ព្រៃការពារព្រះវិហារ នេះពិតមានសារសំខាន់សំរាប់ការរស់រាន រយៈពេលវែងរបស់ពពួកសត្វ ខ្លារខិន នៅតំបន់ អាស៊ីអាគ្នេយ៍។

ផែនទី ១.៤.៦៖ របាយសត្វខ្លារខិន Leopard នៅតំបន់ព្រៃការពារព្រះវិហារ



**ខ្លាត្រី** ***Prionailurus viverrinus*** (ស្ថិតក្នុងឧបសម្ព័ន្ធ១នៃអនុសញ្ញាសាយតេស្ត (CITES)ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយបង្គួរក្នុងប្រទេសកម្ពុជា )។

**-ទំហំ៖** ប្រវែងដងខ្លួនពី ៧២៥-៧៨០មីលីម៉ែត្រ ទំងន់ ៧-១១គីឡូក្រាម។

**-*លក្ខណៈជីវសាស្ត្រ*៖** ខ្លា ត្រីចូលចិត្តរស់នៅក្នុងព្រៃគម្ពោត ព្រៃល្បោះក្បែរទឹក ដែលនៅទីនោះវាអាចចាប់ត្រី ក្តាម បក្សី គ្រុំ និងសត្វដទៃទៀតបាន។ វាចាប់ត្រីដោយក្រាបលើថ្នាំងថ្មដែលលយចូលទៅក្នុងទឹក ហើយយកក្រញ៉ាំរបស់វាចូកបាចត្រីឡើងមកលើគោក គឺវាមិនចុះទៅក្នុងទឹកចាប់ត្រីដូចសត្វភេទេ។ វាអាចបង្កើតកូនម្តងបានពី ២-៣ក្បាល បន្ទាប់ពីមានគភ៌អស់រយៈពេលប្រហែល ៩០-៩៥ថ្ងៃ ហើយខ្លារខិនអាច ធ្វើការបន្តពូជបាននៅពេលវាមានអាយុចាប់ពី ៨ខែ កន្លះ។

**-ស្ថានភាព និងរបាយ៖** ខ្លាត្រីជាប្រភេទមួយមានជាបង្គួរ។ វារស់នៅស្ទើរគ្រប់ទីកន្លែងពិសេស តំបន់ភូមិភាគឥសាន្ត ខាងជើង និងនិរតីនៃប្រទេសកម្ពុជា។

មានកំណត់ត្រាអំពីវត្តមានខ្លាត្រីនៅទូទាំងតំបន់ព្រៃការពារព្រះវិហារ នៅតាមដែនជម្រកខុសៗគ្នា។ នេះជា ប្រភេទថនិកសត្វអំបូរឆ្មាខ្លួនតូចៗដែលគេបានកត់ត្រាញឹកញាប់រួមជាមួយឆ្មាព្រៃ។ បើពិចារណាអំពីស្ថានភាពគំរាមកំហែងជិតផុតពូជរបស់វានៅលើពិភពលោក ខ្លាត្រីដែលសំបូរបង្គួរនៅក្នុង តំបន់ព្រៃ ការពារព្រះវិហារ បង្ហាញថាតំបន់ព្រៃការពារនេះមានសារសំខាន់សំរាប់ការអភិរក្សប្រភេទ ថនិកសត្វនេះ ជាសាកល។

**ខ្លាឃ្មុំតូច** ***Helarctos malayanus*** (ស្ថិតក្នុងឧបសម្ព័ន្ធ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទ ពុំមានព័ត៌មាន ទិន្នន័យគ្រប់គ្រាន់ក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេស កម្ពុជា)។

**- ទំហំ៖** ប្រវែងដងខ្លួនពី ១០០០-១១៤០ មីលីម៉ែត្រ ទំងន់ ១០០គីឡូក្រាម។

**-*លក្ខណៈជីវសាស្ត្រ*៖** ខ្លាឃ្មុំតូចចូលចិត្តរស់នៅតំបន់ព្រៃស្តុក ភាគច្រើនពួកវាចេញរកចំណីនៅ ពេលយប់។ វាស៊ីចំណីដូចជា ឃ្មុំ ពង្រូត ម្រោម សត្វល្អិតផ្សេងៗ ពពួកបក្សី ត្រី និងគមដូងជាអាហារ។ ខ្លាឃ្មុំតូចវាអាចវាយ ប្រហារសត្រូវ និងចាប់ចំណីដោយប្រើជើងមុខទាំងគូររបស់វាដែលមានក្រចកដ៏រឹងមាំ។ ជាទូទៅសត្វខ្លាឃ្មុំតូចញី បង្កើតកូនម្តងបាន ១-២ក្បាល បន្ទាប់ពីមានគភ៌រយៈពេល ៨ខែ។ ខ្លាឃ្មុំតូចជា សត្វពូកែឡើងដើមឈើ ដើម្បីរកអាហារ ជាងគេក្នុងចំណោមសត្វខ្លាឃ្មុំគ្រប់ប្រភេទ វាដេកមិនរើសកន្លែង និងស្រមុកឮខ្លាំងៗផងដែរ។ វាជាសត្វដែលមានការប្រុងប្រយ័ត្ន ហើយឆ្លាតវាងវៃ តែវាចូលចិត្តរស់នៅដោយ ស្ងៀមស្ងាត់។

**-ស្ថានភាព និងរបាយ៖** ជាសត្វមានជាមធ្យមហើយមាននៅតំបន់ភាគឥសាន្ត ភាគនិរតី និងភាគ ខាងជើង នៃប្រទេសកម្ពុជា។

មានកំណត់ត្រាតិចតួចបំផុតអំពីវត្តមានខ្លាឃ្មុំតូចនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ដោយសារតែមានការពិបាកក្នុងការកំណត់អត្តសញ្ញាណខ្លាឃ្មុំទាំងពីរប្រភេទ។ មានកំណត់ត្រាដានខ្លាឃ្មុំជាច្រើន ប៉ុន្តែមិនអាចបញ្ជាក់បានថា តើដានទាំងនោះ ជាប្រភេទខ្លាឃ្មុំណាមួយ។ មានកំណត់ត្រាខ្លាឃ្មុំប្រភេទនេះ និងដានផ្សេងៗទៀតនៅពាសពេញ តំបន់ព្រៃឈើដែលភាគច្រើននៅក្នុងព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃនៅតាមមាត់អូរ (WCS 2008)។ ការបាត់បង់ទីជម្រក និងការបរបាញ់ប្រហែលជាការគំរាមកំហែងធ្ងន់ធ្ងរសម្រាប់ពពួកសត្វខ្លាឃ្មុំ។ ដោយសារខ្លាឃ្មុំ មិនមែនជាសត្វស៊ីពពួកសត្វតិណាសីធំៗ ដូច្នេះការបាត់បង់ប្រភេទសត្វ តិណាសីប្រហែលជាមិនមែនជាការគំរាមកំហែងសំខាន់ចំពោះខ្លាឃ្មុំឡើយ។

**ខ្លាឃ្មុំធំ** *Selenarctos thibetamus* (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

-**ទំហំ**៖ ប្រវែងដងខ្លួនពី ១០០០-១១៩០មីលីម៉ែត្រ ទំងន់ ១០០គីឡូក្រាម

-**លក្ខណៈជីវសាស្ត្រ**៖ ខ្លាឃ្មុំធំច្រើនចេញរកចំណីនៅពេលយប់ ចូលចិត្តរស់នៅតំបន់ព្រៃភ្នំ និងតាមវាលស្មៅ នៃតំបន់ខ្ពង់រាប។ វាចូលចិត្តឡើងដើមឈើធំៗដើម្បីរកអាហារ ហើយវាក៏ចូលចិត្តដេកននៀលភក់នៅតាមត្លុកនានា កាលណាវាលេងភក់អស់ចិត្ត វាក៏ឡើងមកសំដិលខ្លួនអោយស្ងួត។ វាក៏ចូលចិត្តកាច់មែកឈើយកមកធ្វើជម្រក ឬ ដកកូនឈើតូចៗ ដើម្បីស៊ីឬសផងដែរ។ វាចូលចិត្តដេកនៅជង្ហៀបឈើក្រោមចន្លោះឈើធំៗ ឬក្នុងរូងថ្ម ហើយវាដេកលក់ស្កប់ស្កល់ និងស្រមុកឮខ្លាំងៗ វាមិនងាយភ្ញាក់ពីដេកដោយ សំលេងក្តុងក្តាំងឡើយ។ ខ្លាឃ្មុំធំចូលចិត្តស៊ីផ្លែ ឈើ សត្វល្អិត ពពួកបក្សី គមដូង (ដូងប្រេង) ពោត និងត្រីជាអាហារ។ សត្វខ្លាឃ្មុំធំមេបង្កើតកូនម្តងបាន ១-៣ក្បាល ដោយកម្រអាចបង្កើតកូនបាន ៤-៦ ក្បាល វាមានគភ៌រយៈពេល ៨ខែ។ សត្វខ្លាឃ្មុំធំវាមានអាយុរហូតដល់ ៣៧ឆ្នាំ។

-**ស្ថានភាព និងរបាយ**៖ បច្ចុប្បន្ននេះនៅប្រទេសកម្ពុជា គេប្រទះឃើញសត្វខ្លាឃ្មុំធំដោយកម្រ។

ដូចជាប្រភេទខ្លាឃ្មុំតូចដែរ មានកំណត់ត្រាតិចតួចបំផុតអំពីវត្តមានខ្លាឃ្មុំធំ នៅតំបន់ព្រៃការពារ ព្រះវិហារ។ មានកំណាត់ត្រាខ្លា ឃ្មុំប្រភេទនេះ និងដានផ្សេងៗ ទៀតនៅពាសពេញតំបន់ព្រៃឈើដែល ភាគច្រើននៅក្នុងព្រៃស្រោង ព្រៃពាក់កណ្តាល ស្រោង និងព្រៃនៅតាមមាត់អូរ (WCS, 2008)។

**ឆ្កែព្រៃ** *Cuon alpinus* (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

-**ទំហំ**៖ ប្រវែងដងខ្លួនពី ៨០០-៩០០មីលីម៉ែត្រ ទំងន់ពី ១០-២០គីឡូក្រាម។

-**លក្ខណៈជីវសាស្ត្រ**៖ ឆ្កែព្រៃចូលចិត្តរស់នៅជាហ្វូង។ វាចូលចិត្តរស់នៅតំបនព្រៃភ្នំក្រាស់ៗ តាមក្រហែងថ្ម ម្លប់ឈើស៊ុបទ្រុប។ ឆ្កែព្រៃមានលទ្ធភាពចាប់ចំណីដែលមានមាឌធំជាងខ្លួនរបស់វាដូចជាសត្វឈ្លូស ប្រើស ជាដើម។ នៅពេលលោមព័ទ្ធចាប់សត្វជាចំណី ពួកឆ្កែព្រៃតែងតែដេញបណ្តាក់គ្នាដើម្បីអោយសត្វនោះអស់កំលាំង។ ឆ្កែព្រៃចូលចិត្តចេញទៅរកចំណីនៅពេលព្រលប់ និងពេលព្រឹកព្រលឹមស្រាងៗ។ វារត់លឿនអាចលោតបានចំងាយ ៦ម និង អាចហក់បានកំពស់ដល់ ៣,៥ម។ ឆ្កែព្រៃអាចមានជីវិតរស់ នៅបានរហូតដល់ ១៥ឆ្នាំ។ ឆ្កែព្រៃច្រើនផ្តល់កំណើត អោយកូននៅខែ វិច្ឆិកា-កុម្ភៈ ហើយវាអាចបង្កើតកូន មួយលើកបានពី ១-៤ក្បាល។

-**ស្ថានភាព និងរបាយ**៖ ឆ្កែព្រៃមានជាមធ្យម និងមានស្ទើរគ្រប់ទីកន្លែងដូចជាតំបន់ភាគឥសាន្ត ភាគនិរតី និងភាគខាងជើងនៃប្រទេស។

ឆ្កែព្រៃជាប្រភេទដែលគេបានកត់ត្រាញឹកញាប់បំផុតនៅក្នុងចំណោមប្រភេទមំសារសត្វនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ដែលមានកំណាត់ត្រាស្ទើរតែគ្រប់ទីកន្លែងក្នុងតំបន់ព្រៃការពារ (WCS, 2008)។ ឆ្កែព្រៃបានផុតពូជពីវិសាលភាពដែនជម្រករបស់វា នៅភាគខាងជើងតំបន់អាស៊ី ហើយគេបានប៉ាន់ស្មានថា មានឆ្កែព្រៃតែចំនួន ២៥០០ក្បាលប៉ុណ្ណោះ ដែលនៅសេសសល់ទូទាំងពិភពលោក (Durbin et al. 2008)។ ព្រៃល្បោះសើម និងស្ងួតនៅក្នុង តំបន់ត្រូពិកត្រូវបានចាត់ទុកថា ជាតំបន់សមស្របបំផុត នឹងអំបូរឈ្លូស ដែលជាចំណីសំខាន់របស់ពពួកឆ្កែព្រៃ។ ដូច្នេះ តំបន់ព្រៃការពារព្រះវិហារ ជាតំបន់មួយមានសារសំខាន់បំផុតសំរាប់ពពួកឆ្កែព្រៃ ស្របពេលដែលតំបន់ព្រៃ ការពារព្រះវិហារ ជាតំបន់មានវិសាលភាពធំទូលាយ និងសំបូរចំណី។

ផែនទី ១.៤.៧៖ របាយសត្វឆ្កែព្រៃ Dhole នៅតំបន់ព្រៃការពារព្រះវិហារ




**ពង្រូល** *Manus javanika* (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងក្បាល-ដងខ្លួន ៤២៥-៥០០ មីលីម៉ែត្រ កន្ទុយ ៣៤០-៤៧០ មីលីម៉ែត្រ ទំងន់ ៥-៧ គីឡូក្រាម។

**-លក្ខណៈជីវសាស្ត្រ**៖ វាមានជម្រកនៅក្នុងប្រភេទព្រៃដែលមានដើមឈើខ្ពស់ៗ ព្រៃក្រោយអាជីវកម្ម និងដីកសិកម្ម។ ពង្រូលជាសត្វរកស៊ីនៅលើផ្ទៃដី ឬក្នុងរន្ធឈើ ហើយពេលថ្ងៃវាដេកក្នុងរន្ធដី។ ចំណីអាហាររបស់វាមានស្រមោច សង្កា អង្រ្កង ដុកឌឿ និងកណ្តៀរច្រើនសន្ធឹកសន្ធាប់។ សត្វពង្រូលញីកើតកូនម្តង បានមួយ (ដោយកំរកើត កូនម្តងបានពីរ) ហើយកូនរបស់កើតក្រោយពីមេរបស់វាមានគភ៌រយៈពេល ២-៣ខែ។ វារមូខ្លួននៅពេលដែលវា ជួបនឹងឧបសគ្គ វាមានអណ្តាតស្អិតងាយនឹងចាប់ចំណី។ វាជាប្រភេទ សត្វស្លូតមិនបង្កគ្រោះថ្នាក់អ្វីឡើយ។

**-ស្ថានភាព និងរបាយ**៖ វាជាប្រភេទសត្វមានជាមធ្យម ស្ទើរតែគ្រប់ទីកន្លែង និងកំពុងរងនូវការបំផ្លិចបំផ្លាញយ៉ាងខ្លាំងក្លាពីមនុស្ស។

គេកម្រឃើញពង្រូលនៅក្នុង តំបន់ព្រៃការពារព្រះវិហារ និងកត់ត្រាវត្តមានរបស់វាតាមរយៈម៉ាស៊ីនថតស្វ័យប្រវត្តិ (WCS 2008)។ ពង្រូលជាប្រភេទថនិកសត្វកំពុងទទួលរងគ្រោះជិតផុតពូជដោយសារតែការបរបាញ់សំរាប់ពាណិជ្ជកម្ម នៅក្នុងវិស័យឱសថបុរាណ។

## អំបូរប្រចៀវ/ជ្រឹង

អំបូរប្រចៀវត្រូវបានធ្វើការសិក្សានៅក្នុង តំបន់ព្រៃការពារព្រះវិហារ ដោយ Walston & Bates (2000) ដែលបានកត់ត្រាវត្តមានសត្វ ប្រចៀវចំនួន ១០ប្រភេទ នៅអំឡុងពេលសិក្សារយៈពេលខ្លីមួយ នៅក្នុងឆ្នាំ ២០០០។ លទ្ធផលដែល គួរឱ្យកត់សម្គាល់ បំផុតគឺការចាប់ប្រភេទប្រចៀវម្យ៉ាង *Otomops wroughtoni* នៅភាគខាងត្បូងស្នាក់ការកាខឹក នៅក្នុងស្រុកឆែប ជិតព្រៃសម្បទានចិន្តាប្លាយវូត។ ប្រចៀវប្រភេទនេះ ត្រូវបានគេស្គាល់តែនៅភាគឥសាន្ត ប្រទេសឥណ្ឌា (Walston & Bates 2000)។ តាមរយៈកំណត់ ត្រានេះ បង្ហាញថាយើងស្គាល់អំបូរប្រចៀវតិចតួចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ជាងនេះទៅទៀត ប្រភេទជ្រឹងម្យ៉ាង *Pteropus sp.*

ត្រូវបានគេដឹងថាមានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ ប៉ុន្តែមិនទាន់កំណត់អត្ត សញ្ញាណថាជាប្រភេទណាមួយនៅឡើយដែរ។

**អំបូរពានរ**

ទោចម្កុដ *Hylobates pileatus* (ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

-**ទំហំ**៖ ប្រវែងក្បាល-ដងខ្លួន ៤៧០-៤៩៥មីលីម៉ែត្រ ទំងន់ ៤-៧គីឡូក្រាម។

-**លក្ខណៈជីវសាស្ត្រ**៖ ទោចម្កុដត្រូវបានគេប្រទះឃើញរស់នៅតាមតំបន់ព្រៃស្រោង។ ជាធម្មតាវា រស់នៅជាក្រុមតូចៗពី ២-៦ក្បាល។ ពួកវាចំណាយពេលជាច្រើននៅលើដើមឈើខ្ពស់ៗ ជារឿយៗវាតែង តែហក់លោតលើមែកឈើមួយទៅមួយនៅពេលព្រឹក។ អាហាររបស់វាមាន ផ្លែឈើ ស្លឹកឈើ ផ្កា សត្វល្អិត និងពងសត្វស្លាប។ ទោចញីមានកូនតែមួយគត់ បន្ទាប់ពីពរពោះរយៈពេល ២១០ថ្ងៃ។ រយៈពេលមានកូន ពីមួយទៅមួយ (ចន្លោះមានកូន) ២-៣ ឆ្នាំ។ នៅពេល កូនទោចអាយុប្រហែល១ឆ្នាំ វាចាប់ផ្តើមរៀនលោត តោងដើមឈើជិតៗមេវា។

-**ស្ថានភាព និងរបាយ**៖ មានជាមធ្យមមាននៅតំបន់ភាគខាងជើង និងនិរតី។

ទោចម្កុដមានវត្តមានគ្រប់ទីកន្លែងទូទាំងតំបន់ព្រៃការពារព្រះវិហារ ទាំងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង (WCS, 2008)។ ទោចប្រភេទនេះមានវត្តមានតែនៅភាគអាគ្នេយ៍ប្រទេសថៃ និងប្រទេសកម្ពុជារហូតដល់ទន្លេមេគង្គ (Brockelman 1975; Brockelman & Gittins 1984; Marshall & Sugardjito 1987)។ ហេតុនេះ ដែនជម្រករបស់វាមិនមានវិសាលភាពធំទូលាយ និងរបាយនៅតាមដែនជម្រករបស់វាកំពុងធ្លាក់ចុះយ៉ាងឆាប់ រហ័សនៅពេលមានការកាប់រានព្រៃឈើ។ ប្រសិនបើនិន្នាការនេះនៅតែបន្ត ដូចជានៅប្រទេសថៃ គេទំនងជារកឃើញទោចម្កុដតែនៅក្នុងតំបន់ព្រៃការពារនៃប្រទេសកម្ពុជា។ ការគ្រប់គ្រងដោយប្រសិទ្ធភាព និងស្ថានភាពព្រៃនៅតំបន់ព្រៃការពារព្រះវិហារ នៅល្អធ្វើឱ្យតំបន់នេះមានសារសំខាន់ ជាពិសេសសំរាប់សត្វទោចម្កុដ។ ក្រៅពីនេះ ដោយសារតំបន់ព្រៃការពារព្រះវិហារ ស្ថិតនៅជិតដែនជម្រក សត្វព្រៃយ៉ុតដុម (Yot Dom Wildlife Sanctuary) និងឧទ្យានជាតិភូចុង ណាយ៉យ (Phu Jong Na Yoi National Park) ក្នុងប្រទេសថៃ ដែលជាកន្លែងដែល Rungnapa & Brockelman បានរក ឃើញសត្វទោចម្កុដមានចំនួនតិចតួច។ ដោយសារមានការតភ្ជាប់គ្នានៃតំបន់ការពារនៅក្នុងតំបន់ដែលធ្វើឱ្យ តំបន់ព្រៃការពារព្រះវិហារក្លាយជា តំបន់កាន់តែមានសារសំខាន់សំរាប់ការរស់រានរបស់ពពួកសត្វទោចម្កុដ នៅក្នុងតំបន់។

ផែនទី ១.៤.៨៖ របាយសត្វទោចម្កុដ Pileated Gibbon នៅតំបន់ព្រៃការពារព្រះវិហារ




**រញ្ជឺផេះ** ***Nycticebus bengalenis*** (ស្ថិតក្នុងឧបសម្ព័ន្ធ ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

មានកំណត់ត្រាសត្វរញ្ជឺផេះតិចតួចនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ហើយត្រូវបានគេបរបាញ់ ទាក់ចាប់យ៉ាងធ្ងន់ធ្ងរ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍សំរាប់ធ្វើឱសថបុរាណ (Walston, 2008)។ ហើយ រញ្ជឺផេះកំពុងថយចុះតាមដែនជម្រករបស់វា។ ការការពារដែនជម្រករបស់វាដូចជា តំបន់ព្រៃការពារព្រះវិហារ នឹងធានាបាននូវការរស់រានរបស់ រញ្ជឺផេះនៅក្នុងប្រទេសកម្ពុជា។

**ស្វាព្រាម** ***Trachypithecus germaini*** (ស្ថិតក្នុងឧបសម្ព័ន្ធ ១នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទរងគ្រោះជិតផុតពូជនៅក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយបង្គួរក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងក្បាល-ដងខ្លួន ៤៩៣-៥៧០មីលីម៉ែត្រ កន្ទុយ ២២៥-៨៤០មីលីម៉ែត្រ ប្រវែងជើងមុខ ១៣៨-១៥៦ មីលីម៉ែត្រ ទំងន់ ៦-៨ គីឡូក្រាម ។

**-លក្ខណៈជីវសាស្ត្រ**៖ ស្វាព្រាមត្រូវបានគេប្រទះឃើញនៅព្រៃស្រោង និងតំបន់ឆ្នេរវាលភក់ព្រៃ កោងកាង។ ពួកវារស់នៅលើដីច្រើនជាងលើដើមឈើ។ វាស៊ីស្លឹកឈើ ផ្កាឈើ និងសត្វល្អិត។ វារស់នៅជា ក្រុមមានពី ១០-៤០ក្បាល ឬច្រើនជាងនេះ។ វាជាសត្វដែលស្ងៀមស្ងាត់បំផុត។ វាមានពណ៌ប្លែកគ្នាជាច្រើន អាស្រ័យលើតំបន់ ដូចជាតំបន់ឆ្នេរ តំបន់ទន្លេ ឬស្ទឹង តំបន់វាលភក់ តំបន់ព្រៃកោងកាង តំបន់ព្រៃពាក់កណ្ដាល ស្រោង។ ស្វាព្រាមកើតកូនក្នុងអំឡុង ខែ ធ្នូ រហូតដល់ខែ ឧសភា។

**-ស្ថានភាព និងរបាយ**៖ វាជាប្រភេទសត្វមិនសូវសំបូរ។ ទីតាំងដែលសំខាន់ជាងគេមាននៅភ្នំក្រវាញ (ខេត្ត កោះកុង-ពោធិសាត់) ភូមិភាគខាងជើងបឹងទន្លេសាប និងព្រំប្រទល់កម្ពុជា-វៀតណាម។

សត្វស្វាព្រាម មានវត្តមាននៅតាមព្រៃមាត់អូរគគីរ និងតំបន់មួយស្ថិតនៅក្នុងព្រៃសម្បទានចិន្តា ប្លាយវូត (Walston, 2008)។ គេប្រទះឃើញស្វាព្រាមនៅតាមព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងព្រៃ នៅតាមមាត់អូរដែលត្រូវបានកាប់រានយ៉ាងឆាប់រហ័សនៅខាងក្រៅ តំបន់ព្រៃការពារព្រះវិហារ។ ដូចប្រភេទថនិកសត្វធំៗផ្សេងៗទៀត ដែរស្វាព្រាមងាយរងគ្រោះដោយសារការបរបាញ់ ជាពិសេសនៅតំបន់ដែលមាន

ការកាប់រាន ព្រៃឈើដោយដុំៗ។ ស្វាព្រាមមានវប៉ាយតិចតួចនៅក្នុងពិភពលោក ហេតុនេះ តំបន់ព្រៃការពារព្រះវិហារ មានសារសំខាន់ជាសាកលសំរាប់ការអភិរក្ស ស្វាព្រាម។

**ស្វាគ្រោស** *Macaca leonina* (ស្ថិតក្នុងឧបសម្ព័ន្ធ១ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះនៅក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយបង្ខូរក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងក្បាល-ដងខ្លួន ៤៧០-៥៨៥មីលីម៉ែត្រ កន្ទុយ ១៤០-២៣០មីលីម៉ែត្រ ទំងន់ ៣,៥-៩ គីឡូក្រាម។

**-លក្ខណៈជីវសាស្រ្ត**៖ ស្វាគ្រោសរស់នៅព្រៃស្រោង ព្រៃជ្រុះស្លឹក ហើយពួកវារស់នៅជាហ្វូងពី ៦-៧ ឬអាចរហូតដល់ ៤០ក្បាល។ ហ្វូងរបស់វាមិនរស់នៅជាប្រចាំនៅកន្លែងណាមួយពិតប្រាកដទេ វាតែងតែដើរគ្រប់ទីកន្លែងក្នុងព្រៃ។ ចំណីរបស់វាមាន ផ្លែឈើ ផ្កា គ្រាប់ធញ្ញជាតិ សត្វល្អិត។

**-ស្ថានភាព និងវប៉ាយ**៖ ស្វាគ្រោសជាប្រភេទសត្វមានជាមធ្យម។ វារស់ស្ទើរតែគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។

សត្វស្វាគ្រោស មានវត្តមាននៅតាមព្រៃមាត់អូរគគីរ នៃតំបន់ព្រៃការពារព្រះវិហារ និងមានចំនួនច្រើននៅក្នុងព្រៃសម្បទាន ចិន្តាប្លាយវូត (Walston, 2008)។ ស្វាគ្រោសពឹងផ្អែកលើតំបន់ព្រៃឈើខ្ពស់ៗដែលមានវិសាលភាពធំទូលាយ សំរាប់ការរស់រានរបស់វា។ ការកាប់រានព្រៃឈើទំនងជាការគំរាមកំហែងដ៏ធំ បំផុតចំពោះស្វាគ្រោស នៅក្នុងប្រទេសកម្ពុជា។ បើទោះបីជាស្វាគ្រោសមិនមែនជាគោលដៅនៃការបរបាញ់ ប៉ុន្តែការប្រមាញ់នៅតែជា ការគំរាមកំហែង នៅទីណាដែលដែនជម្រករបស់វាមានការកាប់រានព្រៃឈើដោយដុំៗ។

**ស្វាក្តាម** *Macaca fascicularis* (ស្ថិតក្នុងឧបសម្ព័ន្ធ ៣ នៃអនុសញ្ញាសាយតេស្ត (CITES) និងស្ថិតក្នុងក្រុមប្រភេទមានដោយបង្ខូរក្នុងប្រទេសកម្ពុជា)។

**-ទំហំ**៖ ប្រវែងក្បាល-ដងខ្លួន ៤៨៥-៥៥០មីលីម៉ែត្រ ទំងន់ ៣,៥-៦,៥គីឡូក្រាម ។

**-លក្ខណៈជីវសាស្រ្ត**៖ ថ្វីបើទីជម្រកពិតប្រាកដរបស់ស្វាក្តាម គឺវាលភក់ ព្រៃលិចទឹក ព្រៃកោងកាង ក៏ដោយ ក៏គេប្រទះឃើញវារស់នៅព្រៃស្រោង និងតំបន់ធ្វើកសិកម្ម។ កន្លែងណាដែលមានពួកវារស់នៅ គឺមានអន្តរាយយ៉ាង ខ្លាំងដល់ដំណាំកសិកម្ម។ ជាទូទៅស្វាក្តាមរស់នៅតាមបណ្តោយឆ្នេរខ្សាច់ និងមាត់ឆ្នេរ កោះ ជាពិសេសវាលភក់ព្រៃកោងកាង។ វាចិញ្ចឹមជីវិតដោយចាប់ក្តាម សត្វទឹកដែលមានសំបករឹង ដូចជាក្តាម បង្កង និងខ្យង ខ្ចៅ គ្រុំ លៀស ងាវ ហើយនិងសត្វល្អិតដែលនាំមកដោយទឹកលំនាច។ ពួកវាមិនខ្លាចទឹក ហើយពួកវាអាចហែលទឹកបានយ៉ាងស្ទាត់ជំនាញ ស្វាក្តាមឈ្មោលអាចមុជទឹកបានជំរៅ ៥០ម។ ស្វាក្តាមចូល ចិត្តលោតលើដើមឈើចូលក្នុងទឹកម្តងហើយ ម្តងទៀត។ វារស់នៅជាហ្វូង ហើយហ្វូងធំអាចមានចំនួនច្រើន ជាង ១០០ក្បាល។ ស្វាក្តាមមានទំលាប់លូកដៃចូលទៅ ក្នុងរន្ធតូច ឬប្រហោង ដើម្បីរកក្តាម ឬសត្វដទៃ។

**-ស្ថានភាព និងវប៉ាយ**៖ ស្វាក្តាមសំបូរនៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ឆ្នេរ វាលភក់ ព្រៃកោងកាង។ វារស់ស្ទើរតែគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។

ស្វាក្តាមមានវត្តមានគ្រប់ទីកន្លែងទូទាំងតំបន់ព្រៃការពារព្រះវិហារ បើទោះបីជាស្វាក្តាមចូលចិត្ត ព្រៃស្រោងក្រាស់ៗ (WCS, 2008)។ ទោះជាស្វាក្តាមមិនបានចាត់ទុកជាប្រភេទមានការគំរាមកំហែងជា សាកលដោយសារការចាប់ស្វាប្រភេទនេះសំរាប់ ធ្វើការបង្កាត់ពូជ គេគិតថាថនិកសត្វប្រភេទនេះកំពុង ទទួលរងការគំរាមកំហែងខ្លាំង នៅខាងក្រៅតំបន់ព្រៃការពារក្នុងប្រទេសកម្ពុជា។ ប្រសិនបើមិនមានការ កាត់បន្ថយការ

ចាប់ស្វាប្រភេទនេះ តំបន់ផ្សេងៗនោះទេ តំបន់ព្រៃការពារព្រះវិហារ អាចជាតំបន់ដែលមាន វត្តមានប្រភេទថនិកសត្វប្រភេទនេះរស់នៅច្រើន។

**ជ្រូកពោន** *Arctonyx collaris* (ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

**-ទំហំ៖** ប្រវែងក្បាល-ដងខ្លួន ៦៥០-១០៤០មីលីម៉ែត្រ កន្ទុយ ១២០-១៧០មីលីម៉ែត្រ ទំងន់ ៧-១៤គីឡូក្រាម។

**-លក្ខណៈជីវសាស្ត្រ៖** រស់តែលើដី តាមរូង ឬក្រហែង និងរកស៊ីនៅពេលយប់។ វាមិនសូវពូកែភ្នែក និងត្រចៀកទេ វាប្រើច្រមុះហិតក្លិនច្រើនជាង ការរកចំណីចាប់ផ្តើមចេញនៅពេលព្រលប់នៅតាមតំបន់ព្រៃ ចំណីរបស់វា គឺមើមរុក្ខជាតិ ឬសឈើ សត្វល្អិត និងសត្វតូចៗ។ វាអាចមានកូនពី ២-៣ក្បាល និងមានអាយុកាលទៅដល់ ១៤ឆ្នាំ (ការចិញ្ចឹមដោយមនុស្ស)។

**-ស្ថានភាព និងរបាយ៖** សត្វជ្រូកពោនមានរស់នៅតាមតំបន់ស្ទើរទូទាំងផ្ទៃប្រទេស ពិសេសនៅភាគឥសាន្ត ប្រទេសកម្ពុជា។

មានកំណត់ត្រាតិចតួចបំផុតអំពីវត្តមានជ្រូកពោន នៅក្នុងព្រៃការពារព្រះវិហារ ហើយភាគច្រើនប្រទះឃើញនៅក្នុងព្រៃស្រោង (WCS, 2008)។ កំណត់ត្រាតិចតួចអំពីថនិកសត្វប្រភេទនេះប្រហែលជាបណ្តាលមកពីទំលាប់រកស៊ីនៅពេលយប់របស់វា។ ជ្រូកពោនដូចជា ប្រភេទថនិកសត្វខ្នាតតូចជាច្រើនទៀតដែរកំពុងទទួលរងការគំរាមកំហែង ដោយសារការបាត់បង់ទីជម្រកព្រៃ ទាំងការបរបាញ់ដោយប្រើអន្ទាក់។

**ភេខ្លួនរលោង** *Lutrogale perspicallata* (ស្ថិតក្នុងឧបសម្ព័ន្ធទី ២ នៃអនុសញ្ញាសាយតេស (CITES) និងជា ប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម (IUCN))។

**-ទំហំ៖** ប្រវែងក្បាល-ដងខ្លួន ៦៥៥-៧៥០មីលីម៉ែត្រ កន្ទុយ ៤០៦-៥០៥មីលីម៉ែត្រ ទំងន់ ៧-១១គីឡូក្រាម។

**-លក្ខណៈជីវសាស្ត្រ៖** វារសនៅតាមតំបន់ដែលរយៈកំពស់ទាប តាមដងអូរ បឹងត្រពាំង ព្រៃក។ ចំណីអាហាររបស់វាមាន កង្កែប កណ្តុរ ត្រី បក្សី។

**-ស្ថានភាព និងរបាយ៖** ជាប្រភេទសត្វមានជាមធ្យម មានស្ទើរគ្រប់ទីកន្លែង តាមបណ្តោយឆ្នេរសមុទ្រ ព្រៃកោងកាង និងតំបន់ឋបនីយជីវៈមណ្ឌលបឹងទន្លេសាប។

ភេខ្លួនរលោងមានវត្តមានតិចតួចនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ហេតុនេះការកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ នឹងត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀត (WCS, 2008)។ ការគំរាមកំហែងចំពោះភេខ្លួនរលោង គឺដោយសារការបាត់បង់ចំណី ការនេសាទហួសកំរិត ជាប់មងនេសាទ និងការបរបាញ់ដោយ ខុសច្បាប់។

# ឧបសម្ព័ន្ធ ១.៤ខ៖ បញ្ជីឈ្មោះថនិកសត្វដែលមានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| **PHOLIDOTA** | | | | | | |
| **Manidae** | | | | | | |
| 1 | ពង្រូល | Sunda Pangolin | *Manis javanica* | CR | II | Rare |
| **CHIROPTERA** | | | | | | |
| **Pteropodidae** | | | | | | |
| 2 | ជ្រឹង | Flying Fox sp. | *Pteropus sp.* | ? | II | |
| **Rhinolophidae** | | | | | | |
| 3 | ប្រចៀវ | Shamel's Horseshoe Bat | *Rhinolophus shameli* | LC | | |
| 4 | ប្រចៀវ | Acuminate Horseshoe Bat | *Rhinolophus acuminatus* | LC | | |
| 5 | ប្រចៀវ | Intermediate Horseshoe Bat | *Rhinolophus affinis* | LC | | |
| 6 | ប្រចៀវ | Indochinese Horseshoe Bat | *Rhinolophus chaseni* | LC | | |
| **Hipposideridae** | | | | | | |
| 7 | ប្រចៀវ | Diadem Roundleaf Bat | *Hipposideros diadema* | LC | | |
| **Verspertilionidae** | | | | | | |
| 8 | ប្រចៀវ | Peter's/Asian Whiskered Myotis | *Myotis ater/muricola* | LC | | |
| 9 | ប្រចៀវ | Greater Asian House Bat | *Scotophilus heathii* | LC | | |
| 10 | ប្រចៀវ | Least False-Serotine | *Hesperoptenus blanfordii* | LC | | |
| 11 | ប្រចៀវ | Hardwicke's Woolly Bat | *Kerivoula hardwickii* | LC | | |
| **Molossidae** | | | | | | |
| 12 | ប្រចៀវភ្នំត្បែង | Wroughton's Free-tailed Bat | *Otomops wroughtoni* | DD | | |
| **PRIMATES** | | | | | | |
| **Lorisidae** | | | | | | |
| 13 | រញ្ជើប្រផេះ | Bengal Slow Loris | *Nycticebus coucang* | VU | I | Rare |
| **Cercopithecidae** | | | | | | |
| 14 | ស្វាព្រាម | Indochinese Silvered Langur | *Trachypithecus germaini* | EN | II | Rare |
| 15 | ស្វាគ្រោស | Pig-tailed Macaque | *Macaca nemestrina* | VU | II | Common |
| 16 | ស្វាក្តាម | Long-tailed Macaque | *Macaca fascicularis* | LC | II | Common |
| **Hylobatidae** | | | | | | |
| 17 | ទោចម្កុដ | Pileated Gibbon | *Hylobates pileatus* | EN | I | Rare |
| **CARNIVORA** | | | | | | |
| **Canidae** | | | | | | |
| 18 | ឆ្កែចចក | Golden Jackal | *Canis aureus* | LC | III | Common |
| 19 | ឆ្កែព្រៃ | Dhole | *Cuon alpinus* | EN | II | Common |
| **Ursidae** | | | | | | |
| 20 | ខ្លាឃ្មុំតូច | Sun Bear | *Ursus malayanus* | VU | I | Rare |
| 21 | ខ្លាឃ្មុំធំ | Asian Black Bear | *Ursus thibetanus* | VU | I | Endangered |
| **Mustelidae** | | | | | | |
| 22 | សំពោចកលឿង | Yellow-throated Marten | *Martes flavigula* | LC | III | Common |

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| 23 | ផ្លុក | Ferret-Badger sp | *Melogale sp* | DD | | Common |
| 24 | ជ្រូកពោន | Hog Badger | *Arctonyx collaris* | NT | | Rare |
| 25 | ភេខ្លួនរលោង | Smooth coated Otter | *Lutrogale perspicillata* | VU | II | |
| **Viverridae** | | | | | | |
| 26 | ខ្ទីន | Large Indian Civet | *Viverra zibetha* | NT | III | Common |
| 27 | សំពោចធំ | Large-spotted Civet | *Viverra megaspila* | VU | III | Common |
| 28 | សំពោចវល្លិ៍ | Small Indian Civet | *Viverricula indica* | LC | III | Common |
| 29 | សំពោចក្រអូប | Common Palm Civet | *Paradoxurus hermaphroditus* | LC | III | Common |
| 30 | សំពោចភ្នំ | Binturong | *Arctictis binturong* | VU | III | Common |
| **Herpestidae** | | | | | | |
| 31 | ស្កាតូច | Small Asian Mongoose | *Herpestes javanicus* | LC | III | Common |
| 32 | ស្កាធំ | Crab-eating Mongoose | *Herpestes urva* | LC | III | Common |
| **Felidae** | | | | | | |
| 33 | ខ្លាធំ | Tiger | *Panthera tigris* | EN | I | Endangered |
| 34 | ខ្លារខិន | Leopard | *Panthera pardus* | NT | I | Rare |
| 35 | ខ្លាភ្លីថ្មកែវ | Marbled Cat | *Pardofelis marmorata* | NT | I | Rare |
| 36 | ខ្លាលឿងមាស | Asiatic Golden Cat | *Pardofelis temminckii* | NT | I | Rare |
| 37 | ឆ្មាដាវ | Leopard Cat | *Prionailurus bengalensis* | LC | II | Common |
| 38 | ខ្លាត្រី | Fishing Cat | *Prionailurus viverrinus* | EN | II | Common |
| 39 | ឆ្មាព្រៃ | Jungle Cat | *Felis chaus* | LC | II | Common |
| **PROBOSCIDEA** | | | | | | |
| **Elephantidae** | | | | | | |
| 40 | ដំរី | Asian Elephant | *Elephas maximus* | EN | I | Endangered |
| **ARTIODACTYLA** | | | | | | |
| **Suidae** | | | | | | |
| 41 | ជ្រូកព្រៃ | Eurasian Wild Pig | *Sus scrofa* | LC | | Common |
| **Tragulidae** | | | | | | |
| 42 | ក្តាន់ញ្ញៀងតូច | Lesser Mousedeer | *Tragulus kanchil* | LC | | Common |
| **Cervidae** | | | | | | |
| 43 | ប្រើស | Sambar | *Rusa unicolor* | VU | | Common |
| 44 | រមាំង | Eld's Deer | *Rucervus eldii* | EN | I | Endangered |
| 45 | ឈ្លូស | Red Muntjac | *Muntiacus muntjak* | LC | | Common |
| **Bovidae** | | | | | | |
| 46 | ទន្សោង | Banteng | *Bos javanicus* | EN | | Rare |
| 47 | ខ្ទីង | Gaur | *Bos gaurus* | VU | I | Rare |
| 48 | កែះ | Southern Serow | *Naemorhedus sumatraensis* | VU | I | Rare |
| **RODENTIA** | | | | | | |
| **Sciuridae** | | | | | | |
| 49 | កំប្រុកធំ | Black Giant Squirrel | *Ratufa bicolor* | NT | II | Rare |

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| 50 | កំប្រុកពណ៌ | Variable Squirrel | *Callosciurus finlaysonii* | LC | | Common |
| 51 | កង្ហិចកម្ពុជា | Cambodian Striped Squirrel | *Tamiops rodolphi* | | | Common |
| 52 | កង្ហែន | Indochinese Striped Squirrel | *Menetes berdmorei* | LC | | Common |
| 53 | ឆ្មាបាកន្ទុយខ្មៅ | Indian Giant Flying Squirrel | *Petaurista philippensis* | LC | | Rare |
| 54 | កំប្រុក | Small Flying Squirrel sp | *Hylopetes sp* | | | |
| **Hystricidae** | | | | | | |
| 55 | ប្រម៉ា | East Asian Porcupine | *Hystrix brachyura* | VU | | Common |
| 56 | ប្រមោញ | Asian Brush-tailed Porcupine | *Atherurus macrourus* | LC | | Common |
| **LAGOMORPHA** | | | | | | |
| **Leporidae** | | | | | | |
| 57 | ទន្សាយគល់ | Burmese Hare | *Lepus peguensis* | LC | | Common |

| | |
|---|---|
| Critically Endangered | CR |
| Endangered | EN |
| Vulnerable | VU |
| Near-threatened | NT |
| Data Deficient | DD |
| Least Concern | LC |

## ឧបសម្ព័ន្ធ ១.៥.ក៖ ប្រភេទសត្វស្លាបសំខាន់ៗនៅតំបន់ព្រៃការពារព្រះវិហារ

**ក្រៀល** ***Grus antigone*** (ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

ព្រៃការពារព្រះវិហារជាជំរកពងកូនដ៏សំខាន់របស់ពពួកសត្វក្រៀល។ ចំនួនសត្វក្រៀលកំពុងកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងតំបន់ព្រៃការពារព្រះវិហារ ចាប់តាំងពីគម្រោងការ ការពារសំបុករបស់វា ចាប់ផ្តើមក្នុងឆ្នាំ២០០៤។ សំបុកសត្វក្រៀលចំនួន ១៦ ត្រូវបានរកឃើញនៅក្នុងឆ្នាំ ២០០៤ និង ៣៣សំបុករកឃើញនៅក្នុងឆ្នាំ២០០៨។ មុនពេលមានគម្រោងការពារសំបុកក្រៀល ពង និងកូនក្រៀល ត្រូវខានប្រមូលដោយអ្នកភូមិ និងទាហាន ដើម្បីលក់ ទៅប្រទេសថៃ។ ការគំរាមកំហែងបែបនេះត្រូវបានកាត់បន្ថយ មួយផ្នែកធំ។ ការគំរាមកំហែងផ្សេង ទៀតរួមមាន ការរំខាន និងការបាត់បង់ទីជម្រកដែលបច្ចុប្បន្ននេះបាននឹងកំពុង ថយចុះ ជាពិសេសនៅក្រៅ តំបន់ព្រៃការពារ ព្រះវិហារ។ ហ្វូងរបស់សត្វក្រៀលនៅក្នុងតំបន់ព្រៃ ការពារព្រះវិហារ ជាផ្នែកមួយនៃចំនួនសត្វក្រៀលដ៏ច្រើនបំផុត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ សត្វក្រៀលត្រូវបាន គេដឹងថាធ្វើបំលាស់ទីពីតំបន់ព្រៃការពារព្រះវិហារ ទៅកាន់អាងត្រញឹងថ្ម នៅក្នុងខេត្តបន្ទាយមានជ័យ នៅរដូវប្រាំងដែលមិនមែនជារដូវបន្តពូជ។

ផែនទីទី ១.៥.១ ៖ ទីតាំងសត្វក្រៀលនៅតំបន់ព្រៃការពារព្រះវិហារ




**ត្រដក់តូច** ***Leptoptilos javanius*** (ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

ត្រដក់តូចជាច្រើនកំពុងបន្តពូជជាក្រុមទូទាំងតំបន់ព្រៃការពារព្រះវិហារ។ សំបុកសត្វត្រដក់តូចចំនួន ១១៥ ត្រូវបានរកឃើញ នៅពេលគេធ្វើការរាប់ត្រដក់តូចនៅក្នុងឆ្នាំ ២០០៧។ ជាធម្មតា គេឃើញត្រដក់តូចនៅតាមត្រពាំង និងតំបន់ដីសើម ហើយអាចជួបជាញឹកញាប់នៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ គេឃើញបក្សីប្រភេទនេះ នៅតាមតំបន់ដីសើមទាំង នៅក្នុងព្រៃល្បោះ និងព្រៃស្រោង។ តំបន់ភាគខាងជើងមានចំនួនត្រដក់តូចច្រើន ហើយសំបូរជាងនៅតំបន់បឹងទន្លេសាប។ ក្រៅពីនេះ ពពួកត្រដក់តូច នៅក្នុងតំបន់ព្រៃការពារព្រះវិហារ ទំនងជាកើនឡើង ដែលបង្ហាញពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីការពារសំបុកបក្សី។ ពពួកត្រដក់តូច នៅក្នុងតំបន់ព្រៃការពារព្រះវិហារ អាចចាត់ទុកថាមានសារសំខាន់ជាអន្តរជាតិ នៅពេលដែលចំនួនបក្សីនេះនៅក្នុងពិភពលោកកំពុងថយចុះ។

ផែនទី ១.៥.២៖ របាយសត្វត្រដក់តូចនៅតំបន់ព្រៃការពារព្រះវិហារ




**ត្រដក់ធំ** *Lepoptilos dubius* (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

គេកម្រប្រទះឃើញត្រដក់ធំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ ត្រដក់ធំមិនបន្តពូជនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ហេតុនេះ តំបន់ព្រៃការពារព្រះវិហារ មិនមែនជាដែនជម្រកដ៏សំខាន់របស់ពួកវាទេ។

ផែនទី ១.៥.៣៖ របាយសត្វត្រដក់ធំនៅតំបន់ព្រៃការពារព្រះវិហារ




**ទាព្រៃស្លាស** *Cairina scutulata* (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

មានចំនួនទាព្រៃស្លាបសតិចតួចប៉ុណ្ណោះដែលគេបានប្រទះឃើញនៅតាមព្រៃជិតមាត់អូរ ជិតភូមិរបុញ និងជិត ស្នាក់ការកាខឹក អូរគគីរ អូរការប៉ុក និងនៅក្នុងតំបន់ព្រៃសម្បទានចិន្តាប្លាយវូត។ គេប្រទះឃើញទាព្រៃស្លាបស នៅទីណាដែលមានព្រៃក្រាស់ៗជាមួយថ្លុកទឹក ឬអូរ និងមានការរំខានតិចតួច។ បក្សីប្រភេទនេះមានការទាក់ទាញភ្ញៀវទេសចរណ៍។ បច្ចុប្បន្ននេះ ចំនួនបក្សីប្រភេទនេះនៅលើពិភពលោកនៅរាយប៉ាយតិចតួច ហើយភាគច្រើន ចំនួនទាព្រៃស្លាបសមានសេសសល់តែនៅក្នុងប្រទេសកម្ពុជា និងប្រទេសភូមាប៉ុណ្ណោះ។ ហេតុនេះ តំបន់ព្រៃការពារព្រះវិហារ គឺជាតំបន់ដែលមានសារសំខាន់ជាសាកលសំរាប់ការរស់រានរបស់ពួកវាបក្សីប្រភេទនេះ។

ផែនទី ១.៥.៤៖ រប៉ាយសត្វទាព្រៃស្លាបសនៅតំបន់ព្រៃការពារព្រះវិហារ




**ត្មាតផេះ** ***Gyps bengalensis*** (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

ត្មាតផេះមានការបន្តពូជតិចតួចនៅតំបន់ព្រៃការពារព្រះវិហារ (ក្នុងរដូវបន្តពូជឆ្នាំ ២០០៧-២០០៨ មានតែសំបុកចំនួន ៤ ប៉ុណ្ណោះ ត្រូវបានរកឃើញ ដែលក្នុងនោះមានតែសំបុកពីរដែលបានញាស់កូន) ហើយសត្វត្មាត ប្រភេទនេះ មានចំនួនជាង ៤០ក្បាល ត្រូវគេប្រទះឃើញនៅពេលរាប់សត្វត្មាតក្នុងខែ មិថុនា ឆ្នាំ២០០៨។ គេតែងតែ ធ្វើការកត់ត្រាសត្វត្មាតជាប្រចាំនៅពេលធ្វើអាហារដ្ឋានសត្វត្មាតប្រចាំខែ ស្របពេលដែលមានសត្វត្មាតចំនួនជាង ៦០ក្បាល ត្រូវបានកត់ត្រា។ សត្វត្មាតនៅក្នុងតំបន់ព្រៃការពារព្រះវិហារ និងនៅកន្លែងផ្សេងទៀតកំពុងបន្តពូជនៅ តាមដើមឈើ ជារឿយៗសត្វត្មាតជ្រើស រើសតំបន់ជិតប្រភពចំណី។ សត្វត្មាតប្រភេទនេះត្រូវបានគំរាមកំហែងជាសាកល ដោយសារការប្រើប្រាស់ថ្នាំ diclo- fenac (ថ្នាំសំលាប់សត្វល្អិតដែលកសិករប្រើប្រាស់) ដែលមានជាតិពុលខ្ពស់ ព្រមទាំងមិនមានចំណីគ្រប់គ្រាន់ ការបាត់បង់ទីជម្រក ការបំផ្លាញសំបុក និងការសំលាប់សត្វត្មាតដោយចៃដន្យ ដោយសារការប្រើប្រាស់ថ្នាំបំពុលសំលាប់ប្រភេទសត្វផ្សេងៗទៀត។ តំបន់ព្រៃការពារព្រះវិហារ ប្រហែលជាតំបន់មានសារសំខាន់បំផុត សំរាប់ប្រភេទបក្សីនេះនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស្របពេលដែលសត្វត្មាតផេះកំពុងធ្លាក់ចុះយ៉ាងឆាប់រហ័ស នៅតាមដែនជម្រកសំខាន់ៗរបស់វានៅអាស៊ីខាងត្បូង ដោយសារតែឥទ្ធិពលថ្នាំ diclo-fenac។ ប្រភេទត្មាតផេះ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជាប្រភេទដែលនៅ សេសសល់មិនប៉ះពាល់ដោយសារថ្នាំ diclo-fenac។ ហេតុនេះ តំបន់ព្រៃការពារព្រះវិហារ មានសារសំខាន់សំរាប់ ការរស់រានរបស់បក្សីប្រភេទនេះ។

**ត្មាតត្នោត** ***Gyps Tenuirostris*** (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

គេតែងតែកត់ត្រាត្មាតប្រភេទនេះជាប្រចាំនៅក្នុងតំបន់ព្រៃការពារព្រះវិហារ នៅពេលធ្វើអាហារដ្ឋានសត្វត្មាត និងនៅពេលរាប់ចំនួនសត្វត្មាត។ ក្នុងខែមិថុនា ឆ្នាំ២០០៨ ត្មាតប្រភេទត្នោតចំនួន ១១ ក្បាលត្រូវបានកត់ត្រាដែលជា ចំនួនច្រើនបំផុត ដែលគេបានដឹងតិចតួចបំផុតនៅក្នុងប្រទេសកម្ពុជា។ ការគំរាមកំហែងចំពោះត្មាតនេះស្រដៀងនឹង ការគំរាមកំហែង ចំពោះត្មាតផេះ ប៉ុន្តែចំនួនសត្វត្មាតត្នោតមានតិចតួចជាងចំនួន

ត្មាតផេះ ហេតុនេះប្រហែលជាមានការ គំរាមកំហែងធ្ងន់ធ្ងរចំពោះត្មាតត្នោតជាងត្មាតផេះ។ តំបន់ព្រៃការពារព្រះវិហារ កំពុងដើរតួនាទីសំខាន់ក្នុងការអភិរក្សសត្វត្មាតនេះ។

**ត្មាតភ្លើង** ***Sarcogyps calvus*** (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

ត្មាតភ្លើងត្រូវបានគេរកឃើញថា មានចំនួនច្រើនជាងគេនៅក្នុងតំបន់ព្រៃការពារព្រះវិហារ ហើយត្មាតភ្លើង ចំនួន ១៦ ក្បាលត្រូវបានគេឃើញនៅអំឡុងពេលរាប់សត្វត្មាតឆ្នាំ២០០៨។ ត្មាតប្រភេទនេះ កំពុងបន្តពូជនៅក្នុងតំបន់ព្រៃការពារព្រះវិហារ។ ត្មាតភ្លើង មិនរស់នៅជាហ្វូងដូចប្រភេទសត្វត្មាតប្រភេទផ្សេងទៀតទេ ហើយប្រហែល ជាស៊ីចំណីឆ្ងាយពីសាកសពធំៗ ដូចជាគោដែល គេប្រើប្រាស់ជាចំណីនៅពេលធ្វើអាហារដ្ឋានសត្វត្មាត។ ហេតុនេះ សត្វត្មាតភ្លើងប្រហែលជាកត់ត្រាបានតិចតួច ដោយប្រើប្រាស់វិធីសាស្ត្រនេះ។ ត្មាតភ្លើងទទួលរងការគំរាមកំហែង ដូចពពួកសត្វត្មាតផ្សេងទៀតដែរ ហើយតំបន់ព្រៃការពារព្រះវិហារមានសារសំខាន់សំរាប់ការរស់រានរបស់វាជាសាកល។

**ក្ងោក** ***Pavo muticus*** (ស្ថិតក្នុងឧបសម្ព័ន្ធ ២ នៃអនុសញ្ញាសាយតេស្ត (CITES) ជាប្រភេទងាយរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

ក្ងោកត្រូវបានគេរកឃើញនៅភាគខាងត្បូង និងភាគខាងលិចស្នាក់ការកាខឹក និងនៅតាមបណ្តោយអូរកាប៉ុក។ ដោយសារក្ងោកចូលចិត្តព្រៃល្បោះមិនទាន់មានការកាប់រាននៅជិតអូរ និងតំបន់ដីសើម តំបន់ព្រៃការពារព្រះវិហារ អាចជាជម្រកសមស្របបំផុតសំរាប់បក្សីប្រភេទនេះ។ នៅតាមដែនជម្រករបស់វា ចំនួនក្ងោកកំពុងថយចុះយ៉ាងឆាប់រហ័ស ហើយចំនួនក្ងោកភាគច្រើនដែលនៅសេសសល់ក្នុងពិភពលោកត្រូវបានគេជឿថានៅភាគខាងជើង និងខាងកើតប្រទេសកម្ពុជា និងភាគកណ្តាលខាងលិចប្រទេសវៀតណាម។ រហូតមកដល់ពេលនេះ ការការពារព្រៃឈើនៅតំបន់ព្រៃការពារព្រះវិហារ ទំនងជាមានសារសំខាន់ជាសាកលសំរាប់សត្វក្ងោក។ ការបាត់បង់ព្រៃឈើ និងការបរបាញ់ទំនងជាការគំរាមកំហែងធ្ងន់ធ្ងរបំផុតចំពោះបក្សីប្រភេទនេះនៅក្នុងតំបន់ ហើយកំណើននៃការបាត់បង់ព្រៃឈើប្រហែលជាធ្វើឱ្យសត្វក្ងោកងាយរងគ្រោះដោយសារការបរបាញ់ និងការរំខាន។ នាពេលបច្ចុប្បន្ននេះ គេកំពុងពិនិត្យមើលស្ថានភាព ការគំរាមកំហែងរបស់ក្ងោកឡើងវិញ ហើយគេទំនងជាចាត់ថ្នាក់សត្វក្ងោកជាប្រភេទកំពុងរងគ្រោះជិតផុតពូជ។

ផែនទី ១.៥.៥៖ វត្តមានសត្វក្ងោកនៅតំបន់ព្រៃការពារព្រះវិហារ



**កេងកងធំ** ***Buceros bicornis*** (ស្ថិតក្នុងឧបសម្ព័ន្ធ១ នៃអនុសញ្ញាសាយតេស្ត(CITES) ជាប្រភេទជិតទទួលរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទមានដោយកម្រក្នុងប្រទេសកម្ពុជា)។

មានចំនួនកេងកងធំតិចតួចត្រូវបានកត់ត្រាជាពិសេស វត្តមានរបស់វាស្ថិតនៅជិតស្នាក់ការល្បាតកាខឹក នៃ តំបន់ព្រៃការពារព្រះវិហារ។

**អង្កត់ខ្មៅ** ***Ephippiorhynchos asiaticus*** (ជាប្រភេទជិតទទួលរងគ្រោះក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

អង្កត់ខ្មៅមានចំនួនតិចតួច កំពុងបន្តពូជនៅក្នុងតំបន់ព្រៃការពារព្រះវិហារហើយរបាយរបស់វាមានតិចតួច។ អង្កត់ខ្មៅចូលចិត្តវាលស្មៅធំៗដែលលិចទឹកដោយកន្លែង។

**ត្រយ៉ងយក្ស** ***Pseudibis gigantea*** (ជាប្រភេទរងគ្រោះជិតផុតពូជក្នុងបញ្ជីក្រហម IUCN និងស្ថិតក្នុងក្រុមប្រភេទជិតផុតពូជក្នុងប្រទេសកម្ពុជា)។

តំបន់ព្រៃការពារព្រះវិហារ គឺជាតំបន់សំខាន់បំផុតនៅក្នុងពិភពលោកសំរាប់សត្វបក្សីដែលជិតផុតពូជបំផុតប្រភេទនេះ។ សំបុករបស់វាចំនួន ៣៦ ត្រូវបានរកឃើញក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ហើយចំនួនត្រយ៉ងយក្សសរុបមានប្រហែលជា ជាង១០០ ក្បាល។ នៅពេលថ្មីៗនេះ គេបានប៉ាន់ស្មានថាចំនួនត្រយ៉ងយក្ស នៅក្នុងពិភពលោកមានចំនួនជិត ២០០ក្បាល ប៉ុណ្ណោះ។ ប្រសិនបើសំបុករបស់វាមិនងាយរងគ្រោះ ដោយសារមនុស្ស គម្រោងការពារសំបុកបក្សីក៏ត្រូវ បានប្រើប្រាស់ដើម្បីការពារបក្សីប្រភេទនេះទេ បើទោះបីជាគេប្រើប្រាស់សំរាប់ធ្វើការអង្កេតចំនួនបក្សីនេះក៏ដោយ។

ផែនទី ១.៥.៦៖ របាយសត្វត្រយ៉ងយក្សនៅតំបន់ព្រៃការពារព្រះវិហារ



## ឧបសម្ព័ន្ធ ១.៥ខ៖ បញ្ជីឈ្មោះសត្វស្លាបដែលមានវត្តមាននៅក្នុងតំបន់ព្រៃការពារព្រះវិហារ

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| | **Francolins, Partridges and Pheasants (Phasianidae)** | | | | | |
| 1 | ទទា | Chinese Francolin | *Francolinus pintadeanus* | LC | | Common |
| 2 | មាន់ព្រៃ | Red Junglefowl | *Gallus gallus* | LC | | Common |
| 3 | មាន់ទោពណ៌ប្រាក់ | Silver Pheasant | *Lophura nycthemera* | LC | | Common |
| 4 | ស្ដេចកូលីត | Siamese Fireback | *Lophura diardi* | **LC** | | |
| 5 | ក្ងោក | Green Peafowl | *Pavo muticus* | **EN** | II | Rare |
| | **Whistling-ducks (Dendrocygnidae)** | | | | | |
| 6 | ប្រវឹក | Lesser Whistling-duck | *Dendrocygna javanica* | LC | | Common |
| | **Ducks and Pygmy-geese (Anatidae)** | | | | | |
| 7 | ទាព្រៃសាបស | White-winged Duck | *Cairina scutulata* | **EN** | I | Endangered |
| | **Buttonquails (Turnicidae)** | | | | | |
| 8 | ក្រួចអ៊ីតជើងលឿង | Yellow-legged Buttonquail | *Turnix tanki* | LC | | Common |
| 9 | ក្រួចអ៊ីត | Barred Buttonquail | *Turnix suscitator* | LC | | Common |
| | **Piculets and Woodpeckers (Picidae)** | | | | | |
| 10 | ត្រសេះតូចខ្នោស | Grey-capped Woodpecker | *Dendrocopos canicapillus* | LC | | Common |
| 11 | ត្រសេះមធ្យមខ្នោស | Fulvous-breasted Woodpecker | *Dendrocopos macei* | LC | | Common |
| 12 | ត្រសេះតូចក្បាលលឿង | Yellow-crowned Woodpecker | *Dendrocopus mahrattensis* | | | Common |
| 13 | ត្រសេះពោះត្នោត | Rufous-bellied Woodpecker | *Dendrocopos hyperythrus* | LC | | Common |
| 14 | ត្រសេះត្នោតចំពុះខ្មៅ | Rufous Woodpecker | *Celeus brachyurus* | LC | | Common |
| 15 | ត្រសេះធំពោះស | White-bellied Woodpecker | *Dryocopus javensis* | LC | I | Common |
| 16 | ត្រសេះតូចកំប៉ោយលឿង | Lesser Yellownape | *Picus chlorolophus* | LC | | |
| 17 | ត្រសេះធំកំប៉ោយលឿង | Greater Yellownape | *Picus flavinucha* | LC | | Common |
| 18 | ត្រសេះតូចក្បាលក្រហម | Laced Woodpecker | *Picus vittatus* | LC | | Common |
| 19 | ត្រសេះបៃតងទ្រូងពញ្លាក់ | Streak-throated Woodpecker | *Picus xanthopygaeus* | LC | | Common |
| 20 | ត្រសេះបៃតងក្បាលខ្មៅ | Black-headed Woodpecker | *Picus erythropygius* | LC | | Common |
| 21 | ត្រសេះបៃតងក្បាលប្រផេះ | Grey-headed Woodpecker | *Picus canus* | LC | | Common |
| 22 | ត្រសេះតូចខ្នងភ្លើង | Common Flameback | *Dinopium javanense* | LC | | Common |
| 23 | ត្រសេះធំខ្នងភ្លើង | Greater Flameback | *Chrysocolaptes lucidus* | LC | | Common |
| 24 | ត្រសេះពពាលបំពង់ក-ស | Heart-spotted Woodpecker | *Hemicircus canente* | LC | | Common |
| 25 | ត្រសេះដំរី | Great Slaty Woodpecker | *Mulleripicus pulverulentus* | VU | | Common |
| | **Asian Barbets (Megalaimidae)** | | | | | |
| 26 | ប៉ោលតោកក្បាលព្រលែត | Lineated Barbet | *Megalaima lineata* | LC | | Common |
| 27 | ប៉ោលតោកត្រចៀកបៃតង | Green-eared Barbet | *Megalaima faiostricta* | LC | | Common |
| 28 | ប៉ោលតោកថ្ងាសខ្មៅ | Blue-eared Barbet | *Megalaima australis* | | | Common |
| 29 | ប៉ោលតោកអំបុក | Coppersmith Barbet | *Megalaima haemacephala* | LC | | Common |

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| **Hornbills (Bucerotidae)** | | | | | | |
| 30 | កេងកងតូច | Oriental Pied Hornbill | *Anthracoceros albirostris* | LC | II | Common |
| 31 | កេងកងធំ | Great Hornbill | *Buceros bicornis* | **NT** | I | Rare |
| **Hoopoes (Upupidae)** | | | | | | |
| 32 | បាគូ | Common Hoopoe | *Upupa epops* | LC | | Common |
| **Trogons (Trogonidae)** | | | | | | |
| 33 | ចាបចៀបពោះលឿង | Orange-breasted Trogon | *Harpactes oreskios* | LC | | Common |
| **Rollers (Coraciidae)** | | | | | | |
| 34 | ទៀវខៀវ | Indian Roller | *Coracias benghalensis* | LC | | Common |
| 35 | ទៀវព្រៃ | Dollarbird | *Eurystomus orientalis* | LC | | Common |
| **Smaller Kingfishers (Alcedinidae)** | | | | | | |
| 36 | ចចាតក្រឹម | Common Kingfisher | *Alcedo atthis* | LC | | Common |
| **Larger Kingfishers (Halcyonidae)** | | | | | | |
| 37 | កដបព្រៃ | Banded Kingfisher | *Lacedo pulchella* | | | Common |
| 38 | ងាវកក | Stork-billed Kingfisher | *Halcyon capensis* | | | Common |
| 39 | កដបទ្រូងស | White-throated Kingfisher | *Halcyon smyrnensis* | LC | | Common |
| 40 | កដបក្បាលខ្មៅ | Black-capped Kingfisher | *Halcyon pileata* | LC | | Common |
| **Pied Kingfishers (Cerylidae)** | | | | | | |
| 41 | កដបខ្មៅស | Pied Kingfisher | *Ceryle rudis* | LC | | Common |
| **Bee-eaters (Meropidae)** | | | | | | |
| 42 | ត្រដេវព្រៃ | Blue-bearded Bee-eater | *Nyctyornis athertoni* | LC | | Common |
| 43 | ត្រដេវតូច | Green Bee-eater | *Merops orientalis* | LC | | Common |
| 44 | ត្រដេវក្បាលបៃតង | Blue-tailed Bee-eater | *Merops philippinus* | LC | | Common |
| 45 | ត្រដេវក្បាលត្នោតខ្ចី | Chestnut-headed Bee-eater | *Merops leschenaulti* | LC | | Common |
| **Cuckoos (Cuculidae)** | | | | | | |
| 46 | តាវៅកំប៉ោយ | Chestnut-winged Cuckoo | *Clamator coromandus* | LC | | Common |
| 47 | តាវៅធំ | Large Hawk Cuckoo | *Hierococcyx sparverioides* | LC | | Common |
| 48 | តាវៅក្បាលប្រផេះស្រាល | Indian Cuckoo | *Cuculus micropterus* | LC | | Common |
| 49 | តាវៅពោះអង្កន់លឿង | Oriental Cuckoo | *Cuculus saturatus* | LC | | Common |
| 50 | តាវៅខ្លួនអង្កន់ត្នោត | Banded Bay Cuckoo | *Cacomantis sonneratii* | LC | | Common |
| 51 | តាវៅភូមិ | Plaintive Cuckoo | *Cacomantis merulinus* | LC | | Common |
| 52 | តាវៅបៃតង | Asian Emerald Cuckoo | *Chrysococcyx maculatus* | LC | | Common |
| 53 | តាវៅស្វាយ | Violet Cuckoo | *Chrysococcyx xanthorhynchus* | LC | | Common |
| 54 | តាវៅខ្មៅ | Drongo Cuckoo | *Surniculus lugubris* | LC | | Common |
| 55 | តាវៅ | Asian Koel | *Eudynamys scolopacea* | LC | | Common |
| 56 | តុកកាគូ | Green-billed Malkoha | *Phaenicophaeus tristis* | LC | | Common |
| **Coucals (Centropodidae)** | | | | | | |
| 57 | ល្អូតធំ | Greater Coucal | *Centropus sinensis* | LC | | Common |
| 58 | ល្អូតស្បូវ | Lesser Coucal | *Centropus bengalensis* | LC | | Common |
| **Parrots and Parakeets (Psittacidae)** | | | | | | |
| 59 | សេកក្រិច | Vernal Hanging Parrot | *Loriculus vernalis* | LC | II | Common |

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| 60 | សេកសោម | Alexandrine Parakeet | *Psittacula eupatria* | NT | II | Rare |
| 61 | សេកកន្ទុយខៀវលឿង | Grey-headed Parakeet | *Psittacul afinschii* | NT | II | Common |
| 62 | សេកអាត់ | Blossom-headed Parakeet | *Psittacula roseata* | NT | II | Common |
| 63 | សេកសក | Red-breasted Parakeet | *Psittacula alexandri* | NT | II | Common |
| **Swifts (Apodidae)** | | | | | | |
| 64 | ត្រចៀកកាំធំខ្នងត្នោត | Brown-backed Needletail | *Hirundapus giganteus* | LC | | Common |
| 65 | ត្រចៀកកាំដើមត្នោត | Asian Palm Swift | *Cypsiurus balasiensis* | LC | | Common |
| 66 | ត្រចៀកកាំកន្ទុយផ្នែក | Fork-tailed Swift | *Apus pacificus* | LC | | Common |
| **Treeswifts (Hemiprocnidae)** | | | | | | |
| 67 | ត្រចៀកកាំព្រៃ | Crested Treeswift | *Hemiprocne coronata* | LC | | Common |
| **Barn and Bay Owls (Tytonidae)** | | | | | | |
| 68 | ខ្លែងស្រាក | Barn Owl | *Tyto alba* | LC | II | Common |
| 69 | ឱឡុក្របី | Oriental Bay Owl | *Phodilus badius* | LC | II | Common |
| **Typical Owls (Strigidae)** | | | | | | |
| 70 | ឱឡុឡឹក | Collared Scops Owl | *Otus bakkamoena* | LC | II | Common |
| 71 | ទីទុយធំព្រៃ | Spot-bellied Eagle Owl | *Bubo nipalensis* | LC | II | Rare |
| 72 | ទីទុយត្រីថ្ងាសត្នោត | Brown Fish Owl | *Ketupa zeylonensis* | LC | II | |
| 73 | មៀមធំរូ | Spotted Wood Owl | *Strix seloputo* | LC | II | Common |
| 74 | មៀមធំគួក | Brown Wood Owl | *Strix leptogrammica* | LC | II | Common |
| 75 | មៀមតូចព្រៃ | Asian Barred Owlet | *Glaucidium cuculoides* | LC | II | Common |
| 76 | មៀមតូចភូមិ | Spotted Owlet | *Athene brama* | LC | II | Common |
| 77 | មៀមខ្លែង | Brown Hawk Owl | *Ninox scutulata* | LC | II | Common |
| **Frogmouths (Batrachostomidae)** | | | | | | |
| 78 | ចាបមាត់កង្កែប | Javan Frogmouth | *Batrachostomus javensis* | LC | | Common |
| **Eared Nightjars (Eurostopodidae)** | | | | | | |
| 79 | ពញ្លាក់ធំ | Great Eared Nightjar | *Eurostopodus macrotis* | LC | | Common |
| **Typical Nightjars (Caprimulgidae)** | | | | | | |
| 80 | ពញ្លាក់ចង់ | Large-tailed Nightjar | *Caprimulgus macrurus* | LC | | Common |
| 81 | ពញ្លាក់តូច | Indian Nightjar | *Caprimulgus asiaticus* | LC | | Common |
| 82 | ពញ្លាក់ជ្ញីច | Savanna Nightjar | *Caprimulgus affinis* | LC | | Common |
| **Pigeons and Doves (Columbidae)** | | | | | | |
| 83 | ពពូលក្បាលព្រលែត | Pale-capped Pigeon | *Columba punicea* | **VU** | | Rare |
| 84 | លលកបាយធំ | Oriental Turtle Dove | *Streptopelia orientalis* | LC | | Common |
| 85 | លលកបាយ | Spotted Dove | *Streptopelia chinensis* | | | Common |
| 86 | លលកទ្រាំង | Red Collared Dove | *Streptopelia tranquebarica* | LC | | Common |
| 87 | លលកស្លាបបៃតង | Emerald Dove | *Chalcophaps indica* | LC | | Common |
| 88 | លលកតូច | Peaceful Dove | *Geopelia striata* | LC | | Common |
| 89 | ពពូលក្បាលបៃតង | Orange-breasted Green Pigeon | *Treron bicincta* | LC | | Common |
| 90 | ពពូលចំពុះធំលឿង | Thick-billed Green Pigeon | *Treron curvirostra* | LC | | |
| 91 | ពពូលជើងលឿង | Yellow-footed Green Pigeon | *Treron phoenicoptera* | LC | | Common |
| 92 | ព្រាបព្រៃ | Green Imperial Pigeon | *Ducula aenea* | LC | | Common |
| **Cranes (Gruidae)** | | | | | | |
| 93 | ក្រៀល | Sarus Crane | *Grus antigone* | **VU** | II | Rare |

| No | Khmer Name | English name | Scientific name | IUCN | CITES | Cambodia Classification |
|---|---|---|---|---|---|---|
| **Rails, Crakes and Coots (Rallidae)** | | | | | | |
| 94 | មាន់ទឹក | White-breasted Waterhen | *Amaurornis phoenicurus* | LC | | |
